បូជានៅ (២៨) សាលក្រឡាហោម (ក្នុងរាជវាំង) ។ សឹងធ្វើជាមន្ត្រីព្រះរាជា ហើយដែលបានទទួលការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិទាំងឡាយរបស់ វង្សត្រកូល ។ វង្សត្រកូលរបស់អ្នកទាំងនោះ សឹងបានធ្វើជាអាចារ្យហោមសព្វរជ្ជកាលតរៀងមក ។ (២៩) នៅក្នុង រជ្ជកាលព្រះបាទ **រុទ្រវរលោក** និង ព្រះបាទ **បរមរុទ្រវរលោក** វង្សត្រកូលទាំងអស់បានចូលរួមធ្វើសក្ការៈបូជាដល់ ព្រះកម្រតេងជគតដ៏រាជាដូចពីពេលមុនមក ។ ព្រះស្ដែងអញ (៣០ ) **កុមារស្វាមី** ជាក្មួយរបស់ព្រះកម្រតែង **សិវាស្រម** ។ ជាអាចារ្យប្រធាន ជាប្រធាននៃវង្សត្រកូលបានបង្កើតស្រុក **បរាសរៈ** នៅក្នុងដីភូមិនៃ **ស្តុករន្សី** បានផ្ដល់គ្រឿងឧបភោគបរិភោគ (៣១) ដល់ព្រះវិហារស្របតាមព្រះរាជបញ្ជាដែលបានធ្វើឡើងដល់វង្សត្រកូល ។ នៅក្នុងរាជ្ជកាលព្រះបាទ **បរមសិវបទ** ព្រះអង្គបានយាងចេញអំពីរាជធានី **ស្រីយសោធរបុរៈ** ទៅសោយរាជសម្បត្តិនៅឯទីក្រុង **វរាគគិរ្ស** (កោះកេរសព្វថ្ងៃ) (៣២) ព្រះអង្គបាននាំរូបព្រះកម្រតេងជគតដ៏រាជា ទៅតំកល់នៅទីនោះ ។ វង្សត្រកូលផងទាំងឡាយបានទៅធ្វើពិធីសក្ការៈបូជាព្រះកម្រតែងជគតដ៏រាជាដូចពីពេល មុន ។ ព្រះស្ដែងអញ **ល្វសានមូត្តិ** ជាចៅរបស់ព្រះកម្រតេង (៣៣) **សិវាស្រម** ជាអាចារ្យប្រធានគឺជា ប្រធាននៃវង្សត្រកូលបានមករស់នៅរាជធានី **វរាគគិរ្ស** ។ បានសុំដីភូមិនៅ **វរាគគិរ្ស** (ពីព្រះមហាក្សត្រ) បានបង្កើតស្រុកឈ្មោះ **ខ្ទញ** បានទុក (៣៤) ខ្ញុំបំរើទាំងឡាយអោយរស់នៅទីនោះបានផ្ដល់គ្រឿងឧបភោគបរិភោគដល់ព្រះ(វិហារ)នៅ **វរាគគិរ្ស** ដែលជាភារកិច្ចនៃវង្សត្រកូលរបស់ព្រះស្ដែងអញ **ល្វសានមូត្តិ** បានស្ថាបនារូប ព្រះសិវលិង្គនោះ នៅឯ **ស្តុករន្សី** ។ ក្នុងរជ្ជកាល (៣៥) ព្រះបាទ **ព្រហ្មវរលោក** វង្សត្រកូលផងទាំងឡាយបានធ្វើ សក្ការៈបូជាដល់ព្រះកម្រតេងជគតដ៏រាជាដូចពីពេលមុន ព្រះស្ដែងអញ **អាត្មសិវៈ** ជាក្មួយរបស់ព្រះស្ដែងអញ **ល្វសានមូត្តិ** ជាបរោហិត (៣៦) នាព្រះកម្រតេងជគតដ៏រាជាជាអាចារ្យហោមបានធ្វើជាប្រធាននៃវង្សត្រកូល ។ មានព្រះបាទ **សិវវរលោក** ត្រឡប់មកសោយរាជ្យឯរាជធានី **ស្រីយសោធរបុរៈ**វិញ ព្រះអង្គបាននាំយករូបព្រះ កម្រតេងជគតដ៏រាជា (៣៧) មកវិញផងដែរ ។ វង្សត្រកូលផងទាំងឡាយធ្វើសក្ការៈបូជាព្រះកម្រតេងជគតដ៏ រាជាដូចពីពេលមុនមក ។ ព្រះស្ដែងអញ **អាត្មសិវៈ** ជាបរោហិតនាព្រះកម្រតេងជគតដ៏រាជា (៣៨) ជាអាចារ្យ ហោម ជាប្រធាននៃវង្សត្រកូលបានសាងប្រាសាទនានា មានប្រាសាទវលភី នៅឯស្តុករន្សីបានបង្កើតស្រុក **ព្រហ្មបុរៈ** បង្កើតភូមិ **ភតុកៈភូមិសាន្តិ** នៅក្នុងដីនៃស្តុករន្សីបានស្ថាបនាព្រះវិហារនៅទីនោះ (៣៩) ។ ព្រះស្ដែងអញ **អាត្មសិវៈ** បានទទួលមរណៈភាពនៅក្នុងរជ្ជកាលព្រះបាទ **បរមសិវវរលោក** វង្សត្រកូលផងទាំងឡាយមកនៅធ្វើសក្ការៈបូជាព្រះកម្រតេងជគតដ៏រាជាដូចពីពេលមុន (៤០) ។ ព្រះស្ដែងអញ **សិវាចារ្យ** ជាចៅព្រះស្ដែងអញ **អាត្មសិវៈ** ជាបរោហិតនាព្រះកម្រតែងជគតដ៏រាជាបានធ្វើជាប្រធាននៃវង្សត្រកូល ។ មានព្រះបាទ **និរ្វាណបទ**

លើកពលច្បាំងប្រឆាំងនឹងពួកអ្នកដើរដកបំផ្លាញទេវរូបនៅឯស្រុក **ភទ្របត្តនៈ** និង **ស្តុករន្សី** ។ កាលព្រះអង្គឡើងសោយរាជ្យបានពីរឆ្នាំគត់ ព្រះស្តែងអញ **សិខាចារ្យ** បានស្ថាបនាព្រះ (វិហារ) នោះនៃវង្សត្រកូលវិញ ។ បាន ស្ថាបនា **ព្រះសង្ករនារាយណៈ** (៤២) មួយ រូបព្រះនាងភគវតីមួយ នៅស្រុក **ភទ្របត្តនៈ** (ដ៏ទៃមួយទៀត)..... ជារបស់វង្សត្រកូល ហើយបានទុកខ្ញុំបំរើទាំងឡាយអោយនៅទីនោះ ។ ពុំទាន់កសាងហើយផង ស្រុកនិងភូមិក៏ទៅជាខូចបង់ ហើយព្រះស្តែងអញសិវាចារ្យ (៤៣) ក៏បានទទួលមរណៈភាព ។ នៅក្នុងរជ្ជកាលព្រះបាទ **និទ្វាណបទ** វង្សត្រកូលផងទាំងឡាយបានធ្វើសក្ការៈបូជាព្រះកម្រតេងជគតដ៏រាជាដូចពីពេលមុនមក ។ ព្រះស្តែងអញ**សទាសិវៈ** ជាក្មួយរបស់ព្រះស្តែងអញ**សិខាចារ្យ** (៤៤) ជាបុរោហិតនាព្រះកម្រតែងជគតដ៏រាជា បានធ្វើជាប្រធាននៃវង្សត្រកូល ។ (ព្រះស្តែងអញសទាសិវៈ) បានត្រូវផ្សឹកដោយព្រះបាទនិវ្វានបទ ដើម្បីរៀបការជាមួយប្អូនស្រីរបស់ ព្រះនាង **ស្រីវិរលក្សី** ដែលជាអគ្គមហេសី (៤៥) របស់ព្រះអង្គ ។ (ព្រះស្តែងអញ) ត្រូវបានទទួលឋានន្តរនាមជា កំស្តែង **ស្រីជយេន្ទ្របណ្ឌិត** ជារាជបុរោហិតជាអធិបតីយថ្នាក់ឯកនៃមន្ត្រីកាម្មាន្តរៈ ។ ពេលនោះស្រុកបទ្របត្តនៈ និង ស្រុកស្តុករន្សីព្រមទាំងភូមិផង (៤៦) សឹងអន្តរាយខូចបង់នៅពេលដែលព្រះបាទ **និទ្វាណបទ** លើកពលព្យុហ យាត្រា ។ ព្រះកម្រតេង**ស្រីជយេន្ទ្របណ្ឌិត** ក៏បានជួលជុលភូមិស្រុកទាំងនោះឡើងវិញ បានជួសជុលស្ថាបនាហើយ ធ្វើពិធីអភិសេករូបព្រះទាំងនោះឡើងវិញ ។ នៅស្រុក **ភទ្របត្តនៈ** (លោកបាន) ស្ថាបនា (៤៧) រូបព្រះសិវលិង្គមួយ រូបបដិមាព្រះដ៏ទៃទៀតពីរអង្គឡើងវិញ ដែលជារបស់វង្សត្រកូល លោកបានប្រទានទ្រព្យសម្បត្តិផងទាំងឡាយដល់ព្រះវិហារទាំងនោះបានអោយខ្ញុំបំរើទាំងឡាយ ។ បានសាងសង់ប្រាសាទវលភី សាងសង់កំផែងថ្មបាយក្រៀម រៀបចំស្រែចំការ សួនឧទ្យាន ជីកត្រពាំង (៤៨) ធ្វើទំនប់ទឹកទាំងឡាយ ។ នៅស្រុក **ភទ្រខាសៈ** បាន អភិសេកទេវរូប បានអោយទានទ្រព្យសម្បត្តិ ចាត់ចែងធ្វើស្រែចំការច្បារដំណាំ បានជីកត្រពាំងធ្វើទំនប់ទាំងឡាយ នៅស្រុក **ភទ្រគិរី** បានធ្វើបុណ្យអភិសេកព្រះ បានធ្វើទំនប់ទឹកទាំងឡាយ ។ នៅស្រុក**ភទ្រខាសៈ** បានធ្វើបុណ្យអភិសេកព្រះ ធ្វើទានទ្រព្យសម្បត្តិគ្រប់យ៉ាង ។ បានធ្វើចំការ សួនច្បារ និងជីកត្រពាំង បានធ្វើទំនប់ទឹក ។ នៅស្រុក **ភទ្រគិរី** (លោក) បានធ្វើបុណ្យអភិសេកព្រះ បានរៀបចំស្រុកឡើងវិញ (៤៩) ធ្វើទំនប់ទឹក ធ្វើរបង ក្រោលគោ សំរាប់ព្រះគោទាំងឡាយរបស់ព្រះអទិទេព ។ នៅស្រុកស្តុករន្សី (លោក) បានធ្វើបុណ្យអភិសេកព្រះ បានអោយទានទ្រព្យសម្បត្តិសព្វសារពើ បានជីកអញ្ចូនទឹក (ស្រះទឹកព័ទ្ធជុំវិញ) ធ្វើសួនច្បារ (៥០) បានជីកត្រពាំង ។ ធ្វើទំនប់ ទឹក ។ បានសុំព្រះរាជទានដីភូមិពីព្រះបាទ **និទ្វាណបទ** មួយកន្លែងនៅឯអមោឃបុរៈ ឈ្មោះចំការ មានទំហំ ១០០ ពង្រោះ ។ បានទិញដីភូមិមួយអន្លើសោតទៀត (៥១) នៅទិសបូព៌ានៃព្រះត្រពាំង**មហារថា** **ឯអរមោឃបុរៈ** (ហើយ

បានបង់ថ្លៃដោយ) ភាជនៈរ៉ូទិមួយ ភាជនៈបទិកៈមួយ និង សំលៀកបំពាក់ថ្នបមួយ។ (ទំហំដីភូមិ) មានពាង្រោះ ៣០ ។ (លោក) បានទិញដីភូមិមួយ អន្លើសោតនៅឯនាយស៊ឹងអមោឃបុរៈ ឈ្មោះ (៥២) **ប្រលាក់កូនខេ** (ទិញ នឹង) ភាជនៈរ៉ូទិ២ ភាជនៈបទិកៈ២ សំលៀកបំពាក់ថ្នប ទំហំដីមាន ៦០ពង្រោះ ។ ដីភូមិទាំងអស់នោះផងសឹងមាន អោយដល់ព្រះវិហារ ឯស្តុករឡឹ និង ដល់វង្សត្រកូល ។ (លោក) បានកសាងភូមិ (៥៣) ឯអមោឃបុរៈ នៅលើដី ភូមិឈ្មោះ **នាគសុន្ទរៈ** ជារបស់វង្សត្រកូលបានរក្សាទុកខ្ញុំបំរើ រក្សាទុកស្រូវនៅទីនោះ ដើម្បីផ្គត់ផ្គង់ព្រះវិហារ បទ្រឫត្តនៈ ។ រីឯស្រែគណេស្វរៈ ព្រះបាទនិវ៌្វានបទ បានប្រើអោយ (៥៤) ដូរដើម្បីប្រគល់ដល់ពួកអ្នកបំរើព្រះ ។ ព្រះអង្គបានប្រើអោយប្រគល់ស្រែ **ទ្រិច** ជាសំណងវិញ ។ ព្រះអង្គបានអោយសង់គោលសីមាបែងចែកស្រែនោះ នៅឯភទ្រឫត្តនៈ ។ អោយដល់ព្រះវិហារឯស្តុករឡឹ និង ស្រុក (៥៥) **ព្រហ្មបុរៈ** បានស្ថាបនារូបព្រះនាងភគវតីមួយ បានអោយខ្ញុំបំរើទាំងឡាយ បានធ្វើសួនច្បារជីកត្រពាំង ធ្វើទំនប់ទឹក ។ នៅឯខេត្តបូព៌ទិស នៅឯស្រុកដើមឯកុតិ (លោកបាន) រៀបចំស្រុកនោះពីសូន្យឡើងវិញ បានធ្វើរបង (៥៦) ទាំងឡាយនៅទីនោះឡើងវិញ ។ បានស្ថាបនាព្រះសិវលិង្គប្រវែងទ្វីហត្ថ បានកសាងប្រាសាទ បានប្រទានអោយខ្ញុំបំរើទាំងឡាយ បានអោយទ្រព្យសម្បត្តិសព្វសារពើ ។ រីឯដីភូមិ **ខាហុយុទ្ធ** ដែលគ្មានម្ចាស់ នៅឯ **ព្រះខើចឆ្លាច** លោកបានសុំពី (៥៧) ព្រះបាទ **បរមនិវ៌្វាណបទ** ដោយបានសង់គោលសិមា នៅទីនោះ ហើយបានថ្វាយដល់វត្តអារាមឯកុតិ និង ដល់វង្សត្រកូលផង ។ ស្រុក **គខាលយៈ** ដែលព្រះកម្រតេង **សិខរៃខាល្យៈ** បានបង្កើត (៥៨) សំរាប់វង្សត្រកូលនៅឯ **អមរេន្ទ្របុរៈ** ដោយមានទាំងកំណត់ព្រះរាជសាសន៍នៅ **គទ្រឫត្តនៈ**នោះ ហើយដែលអ្នកស្រុកធ្វើអោយខូតខាតអន្តរាយដល់ស្រុក និង ដល់ព្រះសិវលិង្គ គឺធ្វើអោយទេវស្ថាននោះនៅជាព្រៃរហោស្ថាន ។ ព្រះកម្រតែង (៥៩) អញ **ស្រីជ័រយេន្ទ្របណ្ឌិត** បានថ្វាយពតិមានដល់ព្រះបាទ **ស្រីឧយាទិត្យវម្ម័នទេវៈ** ថាស្រុកនោះជារបស់វង្សត្រកូល ។ ព្រះមហាក្សត្រអោយ (៦០) ស្រុក **គខាលយ** មកសន្តានវិញ បានឆ្ការព្រៃនោះវិញ ធ្វើបុណ្យអភិសេកព្រះ ហើយធ្វើពិធីបូជាព្រះនោះវិញ ។ ព្រះអង្គបានប្រើអោយស្វែងរកខ្ញុំបំរើទាំងឡាយរបស់ព្រះវិហារនោះ ដែលបែកខ្ញែក ហើយអោយនៅបំរើការ ។ ក្នុងស្រុក ហើយតែងតាំងច្បាប់ទំលាប់ (៦១) នៃ **គទ្រឫត្តនៈ** ដូចដើមវិញ ។ មានព្រះកម្រតេងអញ **ស្រីជ័រយេន្ទ្របណ្ឌិត** ជាត្រកូលខ្សែស្រឡាយខាងបិតាជាមួយនិងព្រះធូលីជើងព្រះកម្រតេង អញ **ស្រីខាតិន្ទ្របណ្ឌិត** (៦២) នៅស្រុក **សទ្វាយគនៈ** ឯខេត្តបូព៌ទិស គឺជាអ្នកបានបំពេញអំពើធម្មិកម្មិដល់ព្រះធូលីជើងនៃព្រះកម្រតេងអញ **ស្រីខាតិន្ទ្របណ្ឌិត** ។ គឺបានបង្កើតស្រុក ស្ថាបនាព្រះវិហារ ធ្វើបុណ្យឆ្លង (៦៣) ត្រពាំងទឹក ។ ព្រះកម្រតេងអញ **ស្រីជ័រយេន្ទ្របណ្ឌិត** បានកសាងអាស្រមអោយខ្ញុំបំរើនៅទីនោះ

ទុកដូចសំណងគុណគ្រូដល់ព្រះវិហារ (៦៤) ។ មានព្រះកម្រតេងអញ **ស្រីឧទយាទិត្យាវម៌្មទេវៈ** ឡើងសោយរាជ្យ វង្សត្រកូលទាំងឡាយ បានធ្វើពិធីបូជាដល់ព្រះកម្រតេងជគតជីវាជាដូចពីពេលមុន ។ ព្រះ (៦៥) កម្រតេង **ស្រីជយេន្ទ្របណ្ឌិត** បានទៅជា ព្រះរាជគ្រូ ។ បានទទួលឋានន្តរសក្តិជាធូលីជើង ព្រះកម្រតេងអញ **ស្រីជយេន្ទ្រវម៌្ម** ។ ព្រះមហាក្សត្រទ្រង់រៀន វិទ្យាសាស្ត្រផងទាំងឡាយ មានជាអាទិ៍ វិទ្យាសាស្ត្រសុទ្ធាន្ត វេយ្យាករណ៍ និតិសាស្ត្រ ធម្មសាស្ត្រ និង វិទ្យាសាស្ត្រ ដទៃទៀត ។ ព្រះករុណាព្រះមហាក្សត្រ បានប្រារព្ធធ្វើពិធីបុណ្យសំខាន់ៗមានជាអាទិ៍ គឺពិធី **ភទនាទ្ធៈ** ពិធី **ព្រាហ្មយជ្ញ** ។ ធ្វើពិធីបុណ្យសំខាន់ៗ (មហោក្សវបូជា) ស្របតាមទ្រឹស្តីដ៏សំងាត់នៃពិធី **គុហ្យៈ** ។ អោយទក្ខិណា នុប្បទាន និង ទ្រព្យសម្បត្តិគ្រប់បែបយ៉ាង មានជាអាទិ៍គឺ គ្រឿងលំអរកាយដូចជា មកុដ ក្រវិលត្រចៀក កងដៃ កងជើង មកុដវណើ អាសនៈ ធ្វើពីប្រាក់ ភាជនៈមាស ឆ្នុតបក់ គ្រែស្នែងលាបទឹកមាសមានក្បាល ៣ ។ គ្រឿងអលង្ការលំអរកាយទាំងនេះ ត្រូវបានប្រគល់អោយដោយមានព្រះរាជប្រទាននូវទ្រព្យសម្បត្តិទាំងឡាយដល់រាជគ្រូ គឺ ។ មានកែវរតនៈ (៦៩) មាសប្រាក់ ទ្រព្យសម្បត្តិផងទាំងឡាយ ព្រះគោ ចំនួន ១០០០ ។ ដំរី ចំនួន ២០០ ។ សេះចំនួន ១០០ ពពែនិងក្របីចំនួន ១០០ មានអោយទាសាទាសីចំនួន ១០០០នាក់ (៧០) អោយស្រុក៣ ។ នៅភ្នំ **សន្តរៈមពិត** ស្រុកពីរ ហើយស្រុកមួយឈ្មោះ **មរនោ** នៅដែនដី **រខៀគរាញ** ។ ព្រះករុណាព្រះបាទ **ស្រីឧទយាទិត្យវម៌្មទេវៈ** ថែរក្សាអំណោយទាំងអប្បាលមាណនេះ នៅរាជធានីដោយគោរពប្រណិបត្តិព្រះរាជគ្រូ ជានិច្ចកាល (៧១) ។ ព្រះអង្គប្រើអោយចុះឈ្មោះអ្នកបំរើបុរសជារៀងរាល់ថ្ងៃ ព្រមទាំងអ្នកបំរើក្រយាបូជា មានជាអាទិ៍ សំលៀកបំពាក់ ម្ហូបអាហារ ភេសជ្ជៈ គ្រឿងទេស ម្លូស្លា និង គ្រឿងឧបភោគគ្រប់បែបយ៉ាង សំរាប់ធានាពិធីសក្ការៈបូជា (៧២) នៅជាន់លើ (នៃប្រាសាទដែលនៅទីនេះព្រះធូលីជើង) ព្រះកម្រតេងអញ កំពុងបំពេញពិធីបូជានិងការងាររាល់ថ្ងៃ ។ ផងនោះ ស្រុក **ស្តុករមាំខ** បានទៅជាដីភូមិគ្មានម្ចាស់ ព្រះករុណាបានអោយ (៧៣) ស្រុកនោះជាអំណោយទានដល់ព្រះធូលីជើង ព្រះកម្រតេងអញរួមទាំងស្រុក **វន្សី** ។ ព្រះធូលីជើង ព្រះកម្រតេងអញបានខ្មីខ្មាតធ្វើការស្ថាបនាផ្សេងៗ ។ ព្រះករុណាព្រះមហាក្សត្រ (៧៤) បានអោយព្រះសិវលិង្គ ទ្វិហត្ថ ព្រមទាំងទ្រព្យសម្បត្តិផងនានាជាភោគផលសំរាប់ព្រះវិហារទាំងនោះ ព្រមទាំងទ្រព្យសម្បត្តិផងទាំងឡាយ ដែលជាទក្ខិណានុប្បទាន ព្រះអង្គបានប្រើពួកមន្ត្រីទៅបង្កើតស្រុក (៧៥) បានរៀបចំស្រុកមួយទៀតឈ្មោះ **ភទ្រនិកេតនៈ** នៅដីភូមិ **ភទ្របត្តនៈ** ជារបស់ព្រះធូលីជើងព្រះកម្រតេងអញ ។ ព្រះអង្គបានអោយស្ថាបនា រូបសិវលិង្គទ្វិហត្ថ អោយដល់ព្រះធូលីជើង (៧៦) ព្រះកម្រតេងអញ ។ ព្រះករុណាបានអោយទាសាទាសីចំនួន មួយស្លឹក (៤០០) ដល់ព្រះវិហារទាំងនោះ ព្រះអង្គបានស្ថាបនា សិលាប្រាសាទ ប្រាសាទវាលភី បានសាងសួនច្បារ ។

(៧៧) កាលនៅក្នុងរជ្ជកាលរបស់ព្រះបាទ **បរមទិវលោក** មានព្រាហ្មណ៍ **សន្តស៑ះ** ព្រមទាំងមន្ត្រីឆ្លោញ **មាធវ:** ជាកូន ហើយជាជនមកពីប្រទេសបរទេស បានទិញដីមួយកន្លែងដើម្បីបង្កើតភូមិនៅ **អរន្ទេមរលោង** (៧៨) បានទុក ខ្ញុំបំរើនៅទីនោះ បានស្ថាបនារូបព្រះសិវលិង្គដែលជារបស់លោញ **មាធវ:** មន្ត្រីម្រតាញឆ្លោញ **សន្តស៑ះ** បានទទួល មរៈណភាពនៅក្នុងរាជព្រះបាទ **បរមទីវលោក** ឆ្លោញ (៧៩) **មាធវ:** ជាកូនបានរស់នៅ ។ លុះដល់រជ្ជកាលព្រះបាទ **បរមនិវ្វានបទ** គឺឆ្នាំ ៩៦៥ មហាសករាជ្យ ឆ្លោញ **មាធវ:** បានថ្វាយសារមួយថ្វាយព្រះបាទ **បរមនិវ្វានបទ** (៨០) អោយស្រុកនោះព្រមទាំងខ្ញុំបំរើទាំងនោះផងជាកម្មសិទ្ធិរបស់ព្រះធូលីជើងព្រះកម្រតេងអញ **ស្រីជ:យេន្ទ្រវម៌្ម** ។ ដែលទទួលថែរក្សាខ្ញុំបំរើទាំងនោះ លុះដល់ឆ្នាំ ៩៦៧ (៨១) នៃមហាសករាជ ទើបឆ្លោញ **មាធវ:** ទទួល មរណៈភាព ។ ព្រះបាទកម្រតេងអញ **ស្រីឧយាទិត្យវម៌្មទេវ:** ឡើងសោយរាជ្យនៅឆ្នាំ ៩៧១ នៃមហាសករាជ ។ លុះដល់ឆ្នាំ (៨២) ៩៧៤ នៃមហាសករាជ ព្រះកម្រតេងអញធូលីជើងបានស្ថាបនារូបកម្រតេងជគតសិវ:លិង្គ នៅឯ **ភទ្រនិរគេតន:** ហើយបានថ្វាយពតិមានដល់ព្រះករុណាព្រះបាទ **ស្រីឧទយាទិត្យវម៌្មទេវ:** ហើយសូមអោយភូមិនោះ និង ខ្ញុំបំរើទាំងនោះឡើងជាព្រះរាជទានដល់ព្រះកម្រតេងជគតសិវ:លិង្គ នៅឯ **ភទ្រនិរគេតន:** (៨៤) ។ ព្រះករុណាបានប្រទានដីភូមិនោះជាកម្មសិទ្ធិនៅទីនោះ ។ ដងនោះព្រះបាទ **បរមនិវ្វាណបទ** បានធ្វើអំណោយដូចបំណងរបស់ឆ្លោញ **មាធវ:** អោយប្រើប្រាស់ជាមធ្យោបាយចិញ្ចឹមជីវិត ។ (រាជកូលមហាមន្ត្រី) ធូលីជើង (៨៥) កម្រតេងអញបានចាត់ចែងអោយខ្ញុំបំរើទាំងនោះព្រមទាំងស្រុកនោះ ឋិតនៅបំរើការនៅព្រះវិហារសិវ:លិង្គនៅឯស្រុក **ភទ្រនិរគេតន:** ។ នេះគឺរឿងទាក់ទងនិងស្រុក **អរន្ទេមរលោង** ។ នៅឆ្នាំ (៨៦) ៨៩៤ នៃមហាសករាជ្យ ៣ កើត ខែបុស្ស ថ្ងៃពុធ មានព្រាហ្មណ៍មួយរូបឈ្មោះម្រតាញឆ្លោញ **សំកស៑ះ** និង ឆ្លោញ **មាធវ:** ជាកូនប្រុសជា ជនបរទេស បានទិញដីភូមិមួយរបស់អ្នកស្រុកនៅ **អរន្ទេមរលោង** (៨៧) ។ ពួកមនុស្សក្នុងវណ្ណៈ **កម្រ្តេន:** ។ មាន ឈ្មោះលោញ **បរ:** ។ លោញ **ធម្មបាល** ។ លោញ **រគោ** ។ លោញ **សទ្ធិវ** ។ ព្រះស្តែង **សិវបទ** ខ្លោញពល និង ខ្លោញ វិស័យ (ខែត្រ) **ខ្ទុក** ។ ទ្រព្យសំរាប់ទិញគឺ មាសទម្ងន់ពីរលិង (៨៨) ។ សំលៀកបំពាក់ ៣២០ បន្ទាស់ ។ សំលៀកបំពាក់ថ្មប ។ មួយបន្ទាស់ ។ ពពែ ៤ ក្បាល ។ គោ ។ ក្របី ១២ ក្បាល ។ ទំហំសីមានៃដីភូមិចំណោតនោះ និង ស្រែមានប្រវែង ៣ ជើង ។ នៅទិសបូពិ (ដី) មានព្រំប្រទល់ជាប់និងដីភូមិ **ធនខាហ:** នៅទិសទក្សិណ (៨៩) ដីភូមិលាតសន្ធឹងដល់ **ធ្លខ** ។ នៅ ទិសបច្ចិម ដីភូមិលាតសន្ធឹងដល់ផ្លូវរទេះ ខាងលិច **ស្តួល** ។ នៅទិសខាងជើង ដីភូមិលាតសន្ធឹងដល់សំឡូតក្រឡាជុតស្រូវ បតតាំងតែដល់ថ្នល់ត្រពាំង ។ ទិសបូពិដីភូមិលាតសន្ធឹងដល់ ព្រះល្មៅ (៩០) ជាប់និងដីភូមិត្បូងរមាំង ។ // ដីភូមិនានាដែលចូលមកជា (កម្មសិទ្ធិ) នៃចំណោត **អរន្ទេមរលោង** (មានដូច តទៅ) ។ នៅឆ្នាំ ៩០១ នៃមហា សករាជ្យ ៣កើត ខែបុស្ស

មានព្រាហ្មណ៍ឈ្មោះកម្រតាញឆ្លោញ សំកសិៈ និង ឆ្លោញមាធខៈ បានទិញដីភូមិដល់អ្នកស្រុក ថ្ងួរ មានឈ្មោះវាប ឥស្វរទិន្ទ ៰ វាប អាឡ្យ វាប តិមៈ ។ ទ្រព្យសំរាប់ ទិញមាន មាសពីរលិង ភាជនៈរុទិ ៥ សំល្បៀកបំពាក់ទោប ៥ សំល្បៀកបំពាក់ថ្មប ២ សំល្បៀកបំពាក់ថ្មបថ្មី ១ សំល្បៀកបំពាក់យៅ ៥ (៩២) សំល្បៀកបំពាក់ ៣០០ បន្ទាស់ ៰ ព្រំសីមាដីភូមិនោះគឺ ៰ ទិសខាងកើតទល់នឹងដី ព្រះត្បូងរមាំង ខាងត្បូងទល់នឹងដី អវទ្រមលោខ ៰ ខាងលិចដរាបដល់គោលសីមា (៩៣) ខាងជើងដរាបដល់ វ្រៃសំរោខ ៰ ដីភូមិចំណែកភាគ ព្រះស្តែង មាត់ឃ្លុខ ត្រូវបានទិញពីព្រះ ស្រលេខខាយនុប (៩៤) នៅចុងស្ទឹង ពីជាសាច់ញាតិ ៰ ត្រូវបានទិញពីបុរសម្នាក់ឈ្មោះលោញ ឡ្យូរ ជាមួយគ្នានិងអ្នកនោះ (ព្រះស្រលេង) ៰៰៰ ទំហំទាំងអស់នៃដីភូមិនោះគឺ ៣ជ្រោះ ៤០ ៰ ដីនោះបានត្រូវបញ្ចូលរួមជាមួយ (៩៥) ចំណត អវទ្រមលោខ របស់ឆ្លោញ មាធខៈ ៰ ខ្ញុំបំរើទាំងឡាយដែលម្រតែងឆ្លោញ សំកសិៈ និង ឆ្លោញ មាធខៈ ទុកបំរើការនៅចំណត អវទ្រមលោខ ដើម្បីថ្វាយដល់ព្រះវិហារ ៰ (៩៦) ភាគខាងលិចគឺ មានអ្នកថែរក្សាបុរសស៊ីនាមថ្ងូខគេភ ជីតាកែង មកអំពី សីខបុរៈធន្វេន ៰ ភាគកណ្តាលស្រុកសោតគឺ មានអ្នកថែរក្សាបុរសនាម ព្រហ្មបឆ នារី កែថ្លម (៩៧) មកអំពីស្រុក វ្រៃគុប ភូមិភាគបូពិ ៰ ភាគ (៩៨) កណ្តាលស្រុកសោតគឺ មានអ្នកថែរក្សាបុរសនាមមាត់ត្លូខ ជីតាកែខា មកពី សម្តេចទ្រាយ ខេត្ត ករោម ៰ ភាគខាងកើតមានអ្នកថែរក្សា នារីនាម កំយាន (៩៩) មកអំពី លិង្គបុរៈ ៰ ភាភខាងកើតសោតមានអ្នកថែរក្សា បុរសនាម វដីមខ្វិត ជីតា កែស្រសៈ ។ អ្នកស្រុក អវទ្រមលោខ បានអោយខ្ញុំបំរើជាថ្នូរ ៰ ភាគខាងលិច (១០០) សោតមានអ្នកថែរក្សាជាសាច់ញាតិបុរសនាម ថ្ងូខគេភ ៰ មាននារី កែរុទ្រាណី មកអំពី វស្រស្ចបុរៈ ៰ ស្រុក ភទ្រនិកេតនៈ ៰ នៅក្នុងដីភូមិមួយទៀតនៃភទ្របត្តនៈ ទីបូពិនៃដីភូមិភទ្របត្តនៈមួយទៀត (១០១) នៅខាងកើតភូមិ ភទ្របត្តនៈ មួយទៀត ទីអគ្នេយ៍ (ដីភូមិ) លាតសន្ធឹងដល់គោល សីមា ស្តុកកធម្ពៈ ទៅជួបនិងដីភូមិស្រុក វលខគួរ មានចំងាយ (១០២) ៨០ស្លឹក ៰ ទីទក្សិណដីភូមិលាតសន្ធឹងដល់ វស្រាំស្រមោច ទៅទល់និងដីភូមិស្រុក វលខគួរ ចំងាយ ៣៣២ ៰ ទិសនារតី (ដីភូមិ) ទៅទល់និងគោលសីមា គួបៈ ទល់និងដីភូមិស្រុក វលខគួរ ចំងាយ១ស្លឹក១២ ៰ ទិសបស្ចិមដីភូមិទៅទល់និង ស្តុកវត្លាត ទៅជួបនិងដីភូមិស្រុកត្លូខ ៰ ចំងាយ (១០៤) មាន ៦ ស្លឹក ៤៥ ។ ទីពាយព្យដីភូមិ ទៅជួបនិងគោលសីមាស្រុក ត្លូខ ទៅជួបនិងដីភូមិស្រុក ចំណត វគខគួន និង ស្ទឹងគតីរ ចំងាយមាន ៦ ស្លឹក៣៤០ . ៨ ផ្លាស់ (១០៥) ៣ ហត្ថ ៰ ទិសឧត្តរដីភូមិទៅជួបនិង ស្តុករុខ ទៅជួបនិងដីភូមិស្រុក ថ្ងួរមោ ៰ ចំងាយមាន ៤ ស្លឹក ៤០ ៰ ទីឥសានគឺជាដីភូមិស្រុក ភទ្របត្តនៈ ៰ (១០៦) ព្រះករុណាព្រះបាទ ស្រីឧទយាទិត្យវម៌្មទេវៈ បានអោយស្រុកឈ្មោះ ត្លូខច្រនាញរខា ព្រមទាំងអ្នកស្រុកនិង

ពួកផ្សេកនៅទីនោះចំនួន ១៥១ ព្រមទាំងដីភូមិ (១០៧) ភាគនោះ អោយជាព្រះជំនូនដល់ព្រះវិហារ ព្រះលិង្គនោះឯ **ភទ្រនិភេគនៈ** ។ មានព្រំសីមាដីភូមិនោះឯស្រុក **ត្លុងច្រនាញខោ** (១០៨) ។ ទីបូព៌ដីភូមិទៅជួបនិង **ស្តុកត្លោត** ទៅទល់និងដីភូមិស្រុក **ភទ្រនិភេគនៈ** មានចំងាយ ៣ ស្លឹក ១៥២ ។ ទីអគ្នេយ៍ ដីភូមិទៅជួបនិងគោលសីមា (១០៩) ទៅជួបនិងដីភូមិស្រុក **លេខគូរ** មានចំងាយ ៤ ស្លឹក ៣៩២ ។ ទីទក្សិណ ដីភូមិទៅជួបនិងភូមិសីមាទៅជួប និងដីភូមិស្រុកព្រៃខ្ទង់ចន្ទ្រាយ (១១០) មានចំងាយ ២ស្លឹក២៥០ ។ ទីនារតី ដីភូមិទៅជួបនិងគោលសីមា ទៅជួបនិងដីភូមិស្រុក**សិខបត្តនៈស្រះមើរអេម** មានចំងាយ ៤ស្លឹក ទីបស្ចិម ដីភូមិទៅជួបនិងគោលសីមាទៅជួបនិងដី ភូមិស្រុក **អន្លោង** មានចំងាយ ៣ ស្លឹក ៣៩១ ។ ទីពាយព្យ ដីភូមិទៅជួបនិងគោលសីមាទៅទល់និងដីភូមិស្រុក **ខ្ទ្រខ្ម៉ែ** (១១២) មានចំងាយ ៦ ស្លឹក ២៥០ ។ ទិសឧត្តរ ដីភូមិទៅជួបនិងគោលសីមានៅខាងជើងភ្នំ **វេទ្រខ** ទៅទល់និងដីភូមិស្រុក **ឈើរលំ** ស្រុក **ជូងមួយដើម** មានចំងាយ (១១៣) ១ខ្នាញ់ (=៤០០០) ៥ ស្លឹក ១៨០ , ៦ ថ្លាស ។ ទីឥសាន ដីភូមិទៅជួបនិងគោលសីមាទៅជួបនិងដីភូមិ ស្រុក **ស្ទឹងគគីរ** មានចំងាយ ៥ ស្លឹក ១០០ ។ ខ្ញុំបំរើព្រះវិហារ (១១៤) ព្រះសិវលិង្គ ឯ **ភទ្រនិភេគនៈ** ជូនជា អំណោយ ។ ស្រុក **ត្លុង** ពួកបំពេញការងារខាងខ្នើត ។ តម្រួតប្រុសពីរនាក់ ពួកនោះ ។ មានបុរស ២៧ នាក់ ស្រី ២៨ នាក់ ។ ពួកបំពេញការងារខាងរនោច ។ តម្រួតប្រុស២នាក់ ។ ពួក (១១៤) នោះមានប្រុសពីរនាក់ ។ ស្រី ៤៥នាក់ បូកសរុបទាំងអស់ មានប្រុស និង ស្រី ១៥១ នាក់ ។ ខ្ញុំបំរើកម្រតេងជគត **សិខលិទ្ធ** ឯ **ភទ្រនិភេគនៈ** ពួកបំពេញការងារខាងខ្នើត ។ តម្រួតប្រុសមួយនាក់ ពួកនោះ មានប្រុស ២១ នាក់ (១១៥) ស្ត្រី ៥៤ នាក់ ។ មានខ្លោញតម្រួតប្រុសម្នាក់ តម្រួតប្រុសពីរនាក់ ពួកនោះមានប្រុស ១៥ ។ មានស្ត្រី ៥០ នាក់ ។ អាស្រមនៅ ទីទក្សិណ ថ្នល់ជិតត្រពាំងទឹក ។ តម្រួតប្រុសម្នាក់ពួកនោះ មានប្រុស ១ ស្ត្រី ១៤ នាក់ ។ អាស្រមជិត (១១៦) កំពែង តម្រួតប្រុសម្នាក់ ពួកនោះមាន ប្រុស ៧ នាក់ ស្ត្រី ១៣ នាក់ ។ អាស្រមនៅទក្សិណរូបបដិមាព្រះតម្រួតមួយ ពួកនោះមានប្រុស ៤ នាក់ ស្ត្រី ១៦ នាក់ ។ ចំណតអន្ទ្រេមលោង ។ តម្រួតប្រុសមួយនាក់ ពួកនោះមានប្រុស ៤៦ នាក់ ស្ត្រី ៥៤ (១១៧) ពួកបំពេញការងារខាងរនោច តម្រួតប្រុសមួយនាក់ ពួកនេះមានប្រុស ២០ នាក់ ស្ត្រី ៥៣ ខ្លោញតម្រួតប្រុស ១ នាក់ ពួកនោះមានប្រុស ២១ នាក់ ស្ត្រី ៤៣ នាក់ ។ អាស្រមនៅឧត្តរថ្នល់ តម្រួតប្រុសម្នាក់ ពួកនោះមានប្រុស ៤ នាក់ ស្ត្រី ១០ នាក់ (១១៨) អាស្រមនៅឧត្តរ រូបបដិមាព្រះ តម្រួតប្រុសមួយនាក់ ពួកនោះមានប្រុស ៨ នាក់ ស្រី ២០ នាក់ ។ អាស្រមនៅឧត្តររូបបដិមាព្រះនោះសោត តម្រួតប្រុសមួយនាក់ ពួកនោះមានប្រុសមួយនាក់ ស្រី ១៣ នាក់ (នៅ) ចំណត **ចឹងខ្លា** ។ តម្រួតប្រុសម្នាក់ពួកនោះមានប្រុស ៤ នាក់ ស្ត្រី ១៣ នាក់ ។

## សិលាចារឹកស្តុកកក់ធំជាភាសាសំស្ក្រឹត

បកប្រែសំរួលដោយ សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម

----------

i. សូមថ្វាយបង្គំវន្ទាដល់ព្រះសីវា ដ៏មានជីវិតខ្ពង់ខ្ពស់ថ្លៃថ្លា មិនមានវាចាជាសំដីតែតាម ដួងព្រលឹងនៃអង្គប្រាណព្រះ ចូលជ្រួតជ្រាបសព្វកាយិន្ទ្រិយនៃសត្វលោក ។

ii. សូមព្រះដ៏មានគុណថែរក្សាផែនភសធា តាមត្រៃនេត្រានៃព្រះអង្គ មានព្រះចន្ទ្រ ព្រះអាទិត្យ ព្រះអគ្គី ព្រះអង្គប្រមើលមើលគ្មានស្រពិចស្រពិល នូវសច្ចភាពនៃធម្មជាតិពិតរបស់អាត្ម័ន ។

iii. សូមព្រះស្ថាបនករផែនភសធាការពារអ្នកទាំងឡាយ ព្រះអង្គដែលកាន់នូវភាជនៈនៃទឹកអម្រឹត ភាជនៈកែវចរណៃភ្លឺផ្លេកដូចរស្មីព្រះចន្ទ្រា ប្រៀបដូចប្រភពដ៏អស្ចារ្យនៃមហាសាគរទឹកដម ដែលជាករុណាធមិដល់ពិភពលោកនានា ។

iv. សូមព្រះស្វាមីព្រះនាងលក្ស្មីថែរក្សាអ្នកទាំងឡាយ ព្រះអង្គដែលមានព្រះនាងលក្ស្មីស្ថិតនៅលើទ្រូង ហាក់មានព្រះឱង្ការថា: "ល្អិកណាអ្វីដែលជាធម្មជាតិហ្នឹងហ្ន់នៅតែត្រូវការនូវសេចក្តីគាំទ្រ( ដែលជាធម្មជាតិមិនហ្នឹងហ្ន់) ខ្ញុំសូមសំដែងភក្តីភាពដល់ព្រះកៅស្តុភៈ" ។

v. មានព្រះរាជានៃផែនភសធា ដែលព្រះមហាក្សត្រដ៏ទៃលើកហត្ថាថ្វាយបង្គំព្រះអង្គប្រកប ដោយឥរិយាបទប្រៀបដូចបទុមបុប្ផ ដែលបណ្តាលអោយរីករាយដល់ដួងហឫទ័យនៃមនុស្សលោកធ្វើអោយបាត់បង់នូវភាពអន្ធការ ហើយដោយព្រះចេស្តារុងរឿង ព្រះអង្គបានត្រូវទទួលនាមថា ព្រះបាទឧទយាទិត្យា( គឺព្រះអាទិត្យរះ) ។

vi. "សេចក្តីស្នេហា ដែលអញបានបង្កើតមកដើម្បីបំភ្លឺនូវអ្វីដែលជារស្មីខ្ពង់ខ្ពស់ បាននៅជា គ្រឿងដុតកំដៅអណ្តាតអគ្គីនៃនេត្រាព្រះហរៈ( ព្រះឥសូរ) " ។ នេះគឺជាសេចក្តីគិតរបស់ព្រះព្រហ្ម គឺថារស្មីនៃទឹកអម្រឹតព្រះឥស្វរៈបានកើតមក ហើយដែលព្រះអង្គបានទ្រទ្រង់អោយសោយរាជសម្បត្តិ ។

vii. "ប្រៀបដូចបុត្រីព្រៃហេមពាន្ត ខ្ញុំត្រូវតែអោបក្រសោបសាពាង្គកាយពាក់កណ្តាលព្រះស្វាមី នេះជាសេចក្តីគិតរបស់ព្រះនាងលក្ស្មីដែលហាក់អោបក្រសោបសាពាង្គកាយទាំងមូល( របស់ព្រះមហាក្សត្រ) ប្រៀបដូចព្រះកាមទេព ។

viii. ដើម្បីស្តាប់ព្រះព្រហ្មដែលប្រកបដោយព្រះឱស្ឋបួន ព្រះឱស្ឋមួយរបស់ព្រះអង្គគឺជាអាត្មន(គឺដួងព្រលឹង) បានត្រូវរចនាឡើងដើម្បីសុភមង្គលពិភពលោក ដើម្បីមេត្តាករុណា និងគុណធម៌ដ៏ទៃទៀតនៃព្រះមហាក្សត្រ ។ ព្រះនាងភារតីជានិច្ចជាកាលទទួលស្គាល់ព្រះអង្គថាជាស្ថាបនករដ៏មហិមា ហើយបានស្ថិតនៅទីនោះដ៏រាប ។

ix. ប្រាជ្ញាព្រះអង្គលេចឡើងដោយទេពកោសល្យច្រើនមុខ មានទាំងចំណេះខាងសិល្បៈនិងមុខវិជ្ជាដ៏ទៃទៀត ។ ដើម្បីរៀបរាប់នូវគុណភាពរបស់ព្រះអង្គ ទើបព្រះស្ថាបនករពេញហឫទ័យពាក់ខ្សែផ្កានៅសុរង្គ ហើយសំណួតធម៌គ្រាន់តែជាឱកាសនៃអន្តរកាលប៉ុណ្ណោះ ។

x. ព្រះអង្គទ្រង់ប្រសព្វសំគាល់ស្ត្រីភេទ ត្រូវហាមឃាត់ព្រះអង្គទតមើលភរិយាជនដទៃដោយក្តីព្រងើយកន្តើយប្រៀបដូចពិសពុល ។ ក៏ប៉ុន្តែដើម្បីសំរួលហឫទ័យអោយរីករាយព្រះអង្គក្រេបជញ្ជក់យកនូវកាមរតីនៃកិត្តិគុណ ភក្តីភាព មេត្តា ករុណា តេជានុភាពទាំងអស់នេះគឺជា ភរិយានៃករណីកិច្ចដ៏ឧត្តុង្គឧត្តម ។

xi. ផែនដីប្រកបទៅដោយទុក្ខវេទនា ចុះទន់ខ្សោយ ស្លន់ភាន់ភាំង វត់មកជ្រកក្រោមបារមីប្រកបដោយរស្មីស្រទន់នៃព្រះមហាក្សត្រ ហើយដោយសារបារមីនៃព្រះរាជាដឹកនាំដោយសកម្មភាពប្រៀបពុំបាន ព្រះអង្គបានរំដោះផែនដីពីទុក្ខវេទនា ហើយលើកស្ទួយជួយប្រជារាស្ត្រអោយបានបរមសុខនិងសុភមង្គល ។

xii. វុក្ខជាតិមន្ទារៈនៃកិត្តិគុណដ៏ធំធេង មានម្លប់គ្របដណ្តប់លើត្រៃភពប្រកបដោយចំម្រៀងស្តូតិប្រៀបដូចបុប្ផផងទាំងឡាយ មានមែកសាខាត្រសុំត្រសាយជ្រៀតចូលដួងហឫទ័យនៃមនុស្សលោក ហាក់ដូចភ័យខ្លាចគេបំបែកនូវហិរញ្ញគតិ ។

xiii. ប្រៀបដូចគ្រូបង្រៀនសិស្ស ឬ ដូចជីតាបង្ហាត់បុត្រ ចក្ខុតំរង់ឆ្ពោះទៅករណីយកិច្ចដោយប្រាជ្ញាញាណ ព្រះអង្គធានាកិច្ចការពារនិងសុខមាលភាពប្រជារាស្ត្ររបស់ព្រះអង្គ ។

xiv. នៅសមរភូមិព្រះអង្គគ្រីដាវដ៏មុត ប្រលាក់ដោយឈាមនៃបណ្តាមហាក្សត្រជាសត្រូវដែលត្រូវបានផ្តាច់ជីវិត ហើយដែលបញ្ចេញរស្មីភ្លឺផ្លេកដូចបុទុមបុប្ផក្រហមលេចចេញពីត្របក ហើយដោយកំលាំងហត្ថា អាចរំដកកេសាជោគវាសនានៃសង្គ្រាមបាន ។

xv. នៅក្នុងពលីកម្មនោះ គឺមានសង្គ្រាម មានភ្លើងដ៏ខ្លាំងក្លានៃព្រះករុណាព្រះមហាក្សត្រ

ឆេះឆួលដោយគ្រឿងដុតកំដៅ គឺកងទ័ពសត្រូវ ហើយបក់ដោយវាយោនៃហត្ថាដ៏រឹងមាំ បានឆាបឆេះព្រះធរណីដែលរត់ទៅជ្រកក្នុងដួងរស្មីចន្ទ្រា ក្រោមរូបភាពនៃសត្វរមាំង ។

xvi. ព្រះបាទារបស់ព្រះអង្គប្រៀបដូចបុទុមបុប្ផា បានផ្សព្វផ្សាយករុណាធមិដល់ពពួកសត្រូវ ដោយហេតុថាចំណាំងភ្លឺផ្លេកឆ្លុះ ដោយត្បូងចរណៃនៃក្រចករបស់ស្តេចទាំងឡាយដែលអោនសីរសា ករុណាធមិ បានជ្រួតជ្រាបហើយបានបំផុសនូវភក្តីភាព ។

xvii. មហិទ្ធិឫទ្ធនៃព្រះមហាក្សត្រសំបើមអស្ចារ្យ ឫទ្ធិអំណាចខាងមន្តអាគមគាថាដែលអ្នកដទៃគ្មាន ហេតុដូចនេះហើយបានជាពិធីបូជាយញ្ញតែមួយប្រារព្ធធ្វើឡើង ដោយព្រះអង្គអាចបណ្តោយអោយកក្រើកដល់ព្រះឥន្ទ្រាធិរាជនិងព្រះអទិទេពដទៃទៀត ។

xviii. ព្រះវិស្ណុបានមានសាពាង្គកាយរុំព័ទ្ធដោយផ្សែងផេះ ផុសចេញមកពីភ្លើងនៃពិធីបូជាយជ្ញ ដែលដេញតាមហើយហុយចូលទីសំណាក់ព្រះអង្គគ្មានឈប់ឈរ ហើយពីពេលនោះមកដល់ឥឡូវ ព្រះវិស្ណុក៏មានសាពាង្គកាយឡើងក្រម៉ៅ ។

xix. ព្រះអង្គទុកជីវិតអោយសត្រូវដ៏សាហាវរាប់រយរូបដែលមកពីទីឆ្ងាយ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ព្រះអង្គផ្តាច់ជីវិតឥតត្រាប្រណីដល់សត្រូវហែរហាមតូចតាច គឺសត្រូវទាំង៦ (ក្នុងខ្លួនរបស់ព្រះអង្គ) ។

xx. ប្រសិនបើព្រះវិស្ណុទ្រង់ប្រកាន់ពេលវេលាទៀងទាត់ក្នុងឋានៈជាទេវៈ អភិរក្សពិភពលោក ហេតុអ្វីក៏ព្រះអង្គនៅផ្ទំគ្មានគិតអ្វីនៅលើផ្ទៃនៃសមុទ្រ ? ព្រះករុណាព្រះមហាក្សត្រ ព្រះអង្គថែរក្សាយើងទាំងអស់គ្នាជាមនុស្សលោក បានផ្សះស្នាមដំបៅយើងដោយទឹកដមនៃនយោបាយរបស់ពួកមានវិសៈ ។

xxi. ព្រះអង្គធ្វើអោយប្រជារាស្ត្រនៃរាជាណាចក្រ បានសុខសប្បាយរីករាយដោយទេពកោសល្យ ព្រះអង្គ ព្រះអង្គបានបង្កើតពន្ធដារមិនធ្ងន់ធ្ងរ ព្រះអង្គបានធ្វើអោយដួងចិត្តទាំងឡាយរីកស្គុះស្គាយ ព្រះអង្គមានទ្រង់ទ្រាយស្រស់សោភ័ណ ហើយត្រូវបានវន្ទាគោរពក្នុងនាមជាព្រះមហាក្សត្រ ។

xxii. ភ្លើងព្រះកាល ដោយភ័យក្លាចភាពឆេះឆួលរបស់ខ្លួនត្រូវរលត់ចុះ ក៏ត្រូវលាក់ខ្លួនខាងក្រោមអណ្តូៈនៃព្រះស្ថាបនករ ។ ហាក់មានបំណងបញ្ឆេះពិភពលោកដោយភ្លើងអចិន្ត្រៃយនៃភ្លើងឆេះកាល ព្រះអង្គរំងាប់អណ្តាតភ្លើងនោះទៅក្នុងមហាសាគរនៃ

កិត្តិគុណរបស់ព្រះអង្គ ។

xxiii. ព្រះអង្គទ្រង់មានព្រះរាជគ្រូជាទីគោរពប្រកបដោយប្រាជ្ញាញាណ នាមទេវជយេន្ទ្រវម៌្មន ដែលបានចាប់កំណើតក្នុងមហាសន្តានដ៏ស្អាតស្អំខ្ពង់ខ្ពស់មួយ ។

xxiv. វង្សត្រកូលមាតុបក្សរបស់ព្រះរាជគ្រូ បានបន្សល់ទុកទេពកោសល្យដ៏ប្រសើរ ហើយដែលត្រូវបានក្រេបរសជាតិដោយមហាក្សត្រទាំងឡាយនៃសុរ្យវង្ស ( មានព្រះបាទសុរ្យវរ្ម័ន ព្រះបាទឧទ្ទយាទិត្យវរ្ម័នជាដើម) បានលេចឡើង ដើម្បីសំរេចរស្មីព្រះចន្ទ្រនៃសុភមង្គលរបស់មនុស្សលោក ។

xxv. ព្រះករុណាព្រះបាទជយវរ្ម័ន(ទី២) ទ្រង់ស្ថាបនារាជធានីលើភ្នំមហេន្ទ្របពិត( ភ្នំគូលេន) បានមានព្រះរាជគ្រូជាវិញ្ញូជនដែលអ្នកផងទាំងពួង ឱនសិរសាគោរពដល់បាទា គេហៅឈ្មោះលោកថាជា ព្រះរាជគ្រូសិវកៃវល្យ: ។

xxvi. ព្រះគ្រូហិរណ្យទាមៈ ជាមហាព្រាហ្មណ៍មានសព្វបញ្ញាញាណ បានអញ្ជើញមកដល់ប្រៀបដូចព្រះព្រហ្មាប្រកបដោយមេត្តាករុណា បានសំដែងដោយគោរពចំពោះព្រះមហាក្សត្រនូវមន្តអាគមគាថាដ៏សក្តិសិទ្ធ ដែលអ្នកដ៏ទៃពុំអាចសម្តែងបានឡើយ ។

xxvii. ព្រាហ្មណ៍នោះទទួលនូវក្តីអនុញ្ញាត ពីព្រះមហាក្សត្រដើម្បីបង្រៀនមន្តអាគមគាថាតាមពិធីនានា ដើម្បីបង្កើនឫទ្ធិអំណាចដល់អាចារ្យបរោហិតសិវកៃវល្យ: ដែលមានចិន្តាបាញ់ឆ្ពោះទៅកាន់កុសលធម៌ ។

xxviii. គម្ពីរសិល្បិ៍សាស្ត្រដូចជា សីរឆេទៈ វិនាសិខៈ សម្មោហៈ នយោត្តនៈ ដែលជាចតុមុខ (មុខបួន)នៃទុមពុរុ ព្រាហ្មណ៍នោះបានបង្រៀនដល់អាចារ្យសិវកៃវល្យ: អោយចេះចាំស្ទាត់ពីដើមដល់ចប់ ។

xxix. ព្រាហ្មណ៍នោះប្រកបដោយប្រាជ្ញា និងបទពិសោធន៍ខាងសិល្បិ៍សាស្ត្រ បានដកស្រង់យកអ្វីជាសារៈសំខាន់នៃសាស្ត្រា បានប្រារព្ធដើម្បីបង្កើនភាពសំបូររុងរឿងលើផែនដីនូវពិធីសក្ការៈបូជាសក្តិសិទ្ធ ដែលមានឈ្មោះថាពិធីសក្ការៈបូជាព្រះទេវរាជា ។

xxx. ព្រះករុណាព្រះមហាក្សត្រព្រមទាំងបរមព្រាហ្មាចារ្យ ដើម្បីផ្តល់ដល់ផែនដីនូវសុភមង្គលអចិន្ត្រៃយ៍ ទ្រង់បានបញ្ជាអោយប្រារព្ធពិធីសក្ការៈបូជាព្រះទេវរាជានេះឡើងដែលជាប្រភពនៃឃ្លាំងមហិទ្ធិឫទ្ធនៃព្រះមុនីនាថ ។

B

xxxi. "សូមអោយកូនប្រុសកើតចេញពីស្ត្រីនៃមាតុវង្សនេះត្រូវបានតែងតាំង....ជាព្រាហ្មណ៍បរោហិត ធ្វើពិធីសក្ការៈបូជានៅទីនេះហើយគ្មានអ្នកណាក្រៅអាចធ្វើបានឡើយ" នេះគឺជាច្បាប់ទំលាប់ដែលរៀបចំឡើងដោយពួកព្រាហ្មណ៍នៅបរមរាជវាំង ។

xxxii. កាលពីយូរលង់មកហើយ ព្រះមហាក្សត្រនៃភវបុរៈ បានប្រទានដីភូមិមួយ នៅវិស័យឥន្ទ្របុរៈដល់បុព្វបុរសរបស់ព្រាហ្មណាចារ្យ (សិវកៃវល្យៈ) ដែលនៅទីនោះ លោកបានធ្វើពិធីសក្ការៈបូជារូបសិវលិង្គ(ដ៏សក្តិសិទ្ធ) មួយ ស្ថាបនានៅក្នុងបុរីដ៏រុងរឿងមួយឈ្មោះភទ្រយោគី ។

xxxiii. បន្ទាប់ពីបានទទួលពីព្រះមហាក្សត្រ នូវដីភូមិមួយនៅស្រុកបូព៌ទិស លោកបានបង្កើតបុរីមួយឈ្មោះកុដិ ហើយបាននាំវង្សត្រកូលលោកមករស់នៅទីនោះ ។

xxxiv. បន្ទាប់ពីបានទទួលពីព្រះករុណាព្រះមហាក្សត្រ នូវដីភូមិមួយនៅជិតទីក្រុងអមរេន្ទ្របុរៈ លោកបានបង្កើតបុរីមួយឈ្មោះភវាល័យ ហើយបានស្ថាបនាព្រះវិហារសិវលិង្គមួយនៅទីនោះ ។

(ព្រាហ្មណ៍) សូកសមរិទ្ធ ជាបុត្ររបស់ប្អូនស្រីសិវកៃវល្យៈ ជាវិញ្ញូជនប្រកបដោយបញ្ញា ជ្រៅជ្រះ បានទៅជារាជបរោហិត របស់ព្រះបាទជយវរ្ម័ន(ទី៣) ជារាជបុត្ររបស់ព្រះបាទជយវរ្ម័ន(ទីពីរ) ។

xxxv. ប្អូនពៅរបស់សិវកៃវល្យៈ(នាម)រូទ្រាចារ្យ បានទទួលពីព្រះមហាក្សត្រនូវភ្នំមួយនៅក្នុងស្រុកជើងភ្នំ ។

xxxvi. បន្ទាប់ពីបានបង្កើតភូមិមួយ និងបានស្ថាបនាតាមប្រពៃណីនូវព្រះវិហារសិវលិង្គព្រះមុនីនោះបានដាក់ឈ្មោះភ្នំនោះថាភ្នំភទ្រគិរី ។

xxxvii. វាមសិវៈ ជាប្អូនពៅប្រកបដោយប្រាជ្ញាឈ្លាសវៃរបស់សូកសមរិទ្ធ ធ្វើជាព្រះរាជគ្រូរបស់ព្រះអម្ចាស់ស្រីយសោវធិនៈ បានធ្វើជារាជបរោហិតរបស់ព្រះបាទស្រីឥន្ទ្រវរ្ម័ន ។

xxxviii. (ព្រះស្តែងអញ) វាមសិវៈ ជាសិស្សរបស់សិវសោម ជាព្រះរាជគ្រូរបស់ព្រះមហាក្សត្រអាចប្រៀបបានទៅនឹងទន្លេនៃវិទ្យាសាស្ត្រខាងទស្សនៈអាត្ម័ន ដែលសំដែងឡើងជារូបរាងដ៏ប្រចក្ស ។

xxxix. (ព្រះស្ដេងអញ) សិវសោម មានមតិឯកភាពជាមួយសិស្សរបស់លោក បានស្ថាបនាអាស្រម សិវស្រម ហើយបានប្រតិស្ឋានរូបសិវលិង្គមួយនៅទីនោះ ។

xl. (ព្រះស្ដេងទាំងពីរ) បានត្រូវគេហៅថាព្រះសិវស្រម ហើយបន្ទាប់ពីមរណៈភាពនៃសិវសោម ព្រះស្ដេងសិវស្រមវាមសិវៈបានត្រូវគេហៅថាព្រះសិវស្រម ។

xli. នៅពេលដែលព្រះអម្ចាស់ស្រីយសោវធិនៈ បានទៅជាព្រះមហាក្សត្រនាមព្រះករុណាព្រះបាទស្រីយសោវម្មិទេវៈ ព្រះស្ដេងវាមសិវៈបានស្ថិតនៅជាព្រះរាជគ្រូដូចមុនដដែល ។

xlii. ស្របតាមព្រះរាជបញ្ជា លោកបានស្ថាបនារូបសិវលិង្គមួយនៅលើកំពូលភ្នំសយោធរគិរី ដែលមានសោភ័ណភាពស្មើនឹងរាជបពិត (ហេមល័យ) ។

xliii. ព្រះរាជគ្រូបានទទួលអំណោយពីព្រះមហាក្សត្រ ជាដីភូមិឈ្មោះជយបដ្ដនីនៅជិតភទ្រគិរី ។

xliv. នៅលើដីភូមិនោះ ព្រះមហាក្សត្របានស្ថាបនាបុរីមួយឈ្មោះ ភទ្របដ្ដនៈ ហើយបានប្រតិស្ឋានរូបសិវលិង្គ ឧទ្ទិសដល់គុណូបការៈរបស់ព្រះរាជគ្រូ ។
នៅទីនោះព្រះអង្គទ្រង់ធ្វើអំណោយទានជាចលនវត្ថុនានាមាន ជើងពាន ថូទឹក និងវត្ថុដ៏ទៃទៀត មានទ្រព្យសម្បត្តិបរិបូរគឺគោទាំងឡាយព្រមទាំងខ្ញុំប្រុសស្រីពីររយនាក់ ។

xlv. នៅក្នុងស្រុកអមោឃបុរៈ ព្រះមហាក្សត្រប្រកបដោយករុណាធម៌ ដែលជាទាយកបុគ្គលដ៏ធំបានធ្វើអំណោយដល់ព្រះសិវស្រម នូវដីភូមិមួយឈ្មោះគណេស្វរៈមានទាំងរបង (ព័ទ្ធជុំវិញ) ។

xlvi. (ព្រះមុនី) សិវស្រមមានប្រាជ្ញាភ្លឺស្វាង បានកសាងស្រុកមួយឈ្មោះភទ្រវាសៈ ហើយបានប្រតិស្ឋានបដិមាព្រះនាងសរស្វតី ។

xlvii. ប្អូនពៅទ្រង់ផ្នួសប្រកបដោយប្រាជ្ញាញាណ របស់ព្រះមុនី សិវស្រម នាមឈ្មោះហិរណ្យរុចិបានទទួលអំណោយពីព្រះមហាក្សត្រនូវដីភូមិមួយឈ្មោះវិសហរដៈ ។

xlviii. នៅក្នុងបុរីដែលលោកបានកសាង ព្រះមុនីមានប្រាជ្ញាឈ្លាសវៃ បានស្ថាបនាតាមពិធីបុណ្យសាសនានូវវិហារសិវលិង្គមួយលើដីភូមិវិសរដៈ ដើម្បីសុភមង្គលនៃវង្សត្រកូល ។

xlix. ព្រះមុនីទាំងពីររូប (គឺសិវស្រមនិងហិរណ្យរុចិ) បាននាំយកបុត្រី បីរូបរបស់ប្អូនស្រីពីភូមិ

កុដិ មកអោយរស់នៅលើដីភូមិវិសរដ:ពីរនាក់ និងនៅលើដីភូមិភទ្របដ្តនៈមួយនាក់ ។

l. កូនប្រុសរបស់ប្អូនស្រីនៃព្រះមុនីសិវស្រម នាមកុមារស្វាមិន បានធ្វើជារាជបរោហិត របស់ព្រះបាទហសិវរ្ម័ន(ទីមួយ) តមករបស់ព្រះបាទព្សសានវរ្ម័នទី២ ។

li. (កុមារស្វាមិនជា) កំពូលនៃវេញ្ញជន ជារាជគ្រូមានប្រាជ្ញាឈ្លាសវៃ ប្រៀបដូចបុត្ររបស់បរាសរ: បានបង្កើតទីក្រុងនាមបរាសរ:នៅលើដីភូមិវិសហរដ: ។

lii. បុត្រារបស់កូនស្រីនៃប្អូនស្រីរបស់ព្រះមុនីសីវស្រម ប្រកបដោយប្រាជ្ញាជ្រាលជ្រៅនាមឈ្មោះព្សសានមូរតិ បានធ្វើជារាជបរោហិតរបស់ព្រះបាទជយវរ្ម័ន(ទី៤) ។

liii. ដោយភក្តីភាពចំពោះព្រះត្រៃភវានេស្វរ: បន្ទាប់ពីបានទទួលដីភូមិមួយជាអំណោយរបស់ព្រះមហាក្សត្រ ព្រះមុនីនោះបានបង្កើតបូរីមួយឈ្មោះខ្ទញ ។

liv. បុត្រារបស់ប្អូនស្រីព្សសានមូរតិ ប្រកបដោយប្រាជ្ញាខ្ពង់ខ្ពស់ដូចព្រះអាង្គិរស:(ព្រហស្បតិ) នាមអាត្មសិវ: បានធ្វើជារាជបរោហិតព្រះបាទហសិវរ្ម័នទី២ ។

lv. ក្នុងឋានៈជារាជបរោហិតព្រះបាទរាជេន្ទ្រវរ្ម័ន លោកបានបង្កើតបូរីសាន្តបុរ: កដុកបុរ: និងព្រហ្មបុរ: នៅលើដីវិសហរដ: ។

lvi. នៅក្នុងបូរីនិមួយៗ លោកបានប្រិស្ថានបដិមា ព្រះហរិ ព្រះវិស្ណុ និងព្រះនាងសរស្វតីដើម្បីសុភមង្គល(នៃអ្នកស្រុក) ។

lvii. កូនប្រុសដ៏មានប្រាជ្ញារបស់ប្អូនស្រីព្រះមុនីអាត្មសិវ នាមសិវចារ្យដែលមានរាសីប្រសើរ បានធ្វើជារាជបរោហិតរបស់ព្រះបាទជយវរ្ម័នទី៥ ។

lviii. នៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១(ព្រះមុនីសិវចារ្យ) បានប្រតិស្ឋាន តាមប្រពៃណីសាសនា នូវបដិមាព្រះហរិហរ: និងព្រះនាងសរស្វតី ។

lix. មែនពិត ព្រះមុនីដ៏ឧត្តមទាំងអស់នេះ ប្រកបដោយប្រាជ្ញាញាណខ្ពស់សក្តិសមនិងគារវភក្តីរាប់អានពីបណ្តាព្រះមហាក្សត្រ ស្ថិតនៅរាជធានី ហើយធ្វើសក្ការ:បូជាព្រះទេវរាជារៀងរាល់ថ្ងៃដោយទៀងទាត់ ដោយប្រកាន់វិន័យតឹងរឹងនិងដោយភាពសាទរ រវៀសរវៃ ។

lx. ប្រសូត្រចេញពីវង្សត្រកូលមាតុបក្សដ៏ថ្លៃថ្នូរសម្បូរសប្បាយនេះ កូនប្រុសរបស់ប្អូនស្រី

នៃសិវចារ្យ ប្រកបដោយដួងចិន្តាជ្រះថ្លាជាអចិន្ត្រៃយចំពោះបល័ង្កព្រះសិវា បានទៅជាល្បីល្បាញ ក្រោមនាមឈ្មោះសទាសិវៈ ។

lxi. អប់រំតាមទំនៀមទំលាប់នៃពិធីសក្ការៈបូជាព្រះទេវរាជា មានប្រពៃណីពីញាតិសន្តានមួយល្បីល្បាញ( សទាសិវៈ) បានធ្វើជារាជបរោហិតរបស់ព្រះបាទសូរ្យវរ្ម័នទី១ ហើយត្រូវបានគេគោរពដោយមានលក្ខណៈចារឹកខុសពីបណ្តារាជបរោហិតនានា ។

lxii. ពេញហប្ញទ័យជានិរន្តរ៍ចំពោះទឹកអម្រឹត នៃក្តីអភិវឌ្ឍឥតឈប់ឈរ ព្រះឥសូរបានលាក់ទុកថាមពលរបស់ព្រះអង្គនៅមួយកន្លែង ក៏បានជ្រាបចូលឥតឧបស័គ្គទៅក្នុងដួងហឫទ័យរបស់( សទាសិវៈ) ។

lxiii. "តើអញអាចស្ថិតនៅដ៏ទៀងទាត់ នៅទីសំណាក់ណាដែលពុំមានភាពអន្ធការនៃទោសៈនិងតណ្ហាដទៃទៀត ? "។ បន្ទាប់ពីបានពោលដូច្នេះ ព្រះធម៌ ដោយក្តីសង្ឃឹមជៀសផុតពីអន្ធការ បានចូលទៅរស់នៅក្នុងដួងបេះដូងដ៏ប្រពៃប្រកបដោយក្តីប្រុងប្រយ័ត្នជាទីបំផុត ។

lxiv. ព្រះមុនី( សទាសីវ) ជាឃ្លាំងនៃទ្រព្យសម្បត្តិដែលជាព្រះធម៌ ជាពេជ្រចរណៃ ដែលជាចារឹកដ៏ត្រឹមត្រូវ ជាមហាសាគរនៃទីដែលជាកំណែតម្រូវ ជាស្រែពជ្រោះដែលជាមោទនភាព ។

lxv. សូត្ររៀនសារដើមវិញឥតឈប់ឈរនូវសារធាតុអាគមគាថា នៃសិល្បសាស្ត្រដែលត្រូវរៀន ( សទាសិវៈ) បានបង្រៀនសីល្បសាស្ត្រនេះដល់អ្នកដទៃ ។ ជារៀងរាល់ថ្ងៃលោកថ្វាយកម្រងបុប្ផាប្រាំបីមុខ ដើម្បីបូជាព្រះភ្លើងនិងព្រះសិវា ។
ទោះបុទុមបុប្ផានៃហប្ញទ័យរបស់សទាសិវៈ ដក់ដោយប្រាជ្ញារីកស្គុះស្គាយផ្សព្វផ្សាយក្លិនក្រអូបតាមសញ្ចិៈ និងសិល្បសាស្ត្រដទៃតាមសំនួររបស់អ្នកប្រឆាំងប្រៀបដូចភ្លមរាបក់បោកដោយវាយោនៃចំណេះដឹងឈ្លាសវៃ មិនបានផ្តល់កំរៃនៃការស្នាក់អាស្រ័យដ៏ស្ងប់ស្ងៀម ។

lxvi. ជាជំរកនៃប្រាជ្ញាញាណដ៏ខ្ពង់ខ្ពស់ ជារតនាគារនៃគម្ពីរភាពនៃគុណភាពដទៃភ្លឺឆើតឆាយដូច កែវរតនាប្រកបដោយកុសលធម៌ដ៏ប្រពៃ សទាសីវៈអាចប្រៀបបានទៅនិងមហាសាគរ ។

lxvii. ទោះបីសទាសិវៈអោយទានឥតស្តាយដល់ពួកព្រាហ្មណ៍ដែលឧស្សាហ៍ព្យាយាម ហើយសមនិង ទទួលទ្រព្យជាកែវរតនៈនិងរបស់ដទៃទៀត លោកតែងខឹតខំក្រេបជញ្ជាក់យក

កំណប់ទ្រព្យលាក់បំបាំងក្នុង ប្រាជ្ញាញាណរបស់អ្នកទាំងនោះ ដោយមានបំណងខ្លាំងក្លា គ្មាននរណាធ្វើដូច ។

lxviii. នេត្រារបស់លោកតែងទាក់ទាញឆ្ពោះទៅការប្រព្រឹត្តដ៏ត្រឹមត្រូវហើយមិនមែន ទាក់ទាញទៅរកសាច់ស្រស់ឈាមស្រស់ទេ ដោយហេតុថាលោកជាជនបរិសុទ្ធក្នុង គំនិត នៃសេចក្តីស្នេហា គឺកុសលធម៌ដែលត្រូវទទួល ។ ទាំងអស់នេះជាវត្ថុបំណងដែល លោកតែងប៉ងប្រាថ្នា ហើយមិនមែន សូរសំលេងនិងកាយឥន្ទ្រិយារម្មណ៍ដទៃឡើយ ។

lxix. លោកមានរូបរៀងសោភណ៍ មានអំណាចសក្តិសិទ្ធមានកិត្តិនាមល្បីល្បាញ មានវិជ្ជា ជ្រៅជ្រះមានគុណធម៌ លោកជាជនសកម្មប្រកបដោយគុណធម៌ខាងប្រាជ្ញខ្សៀវក្លា ហើយ ក៏ប៉ុន្តែលោកគ្មានអំនួត ។ លោកចេះប្រគំតូរ្យតន្ត្រី លោកបានរៀនសិល្បៈនានា គឺ មានវិជ្ជាបច្ចេកទេស ហោរាសាស្ត្រ វិជ្ជាពេទ្យ និងវិជ្ជាដទៃទៀត ។ មិនតែប៉ុណ្ណោះ លោកចេះធ្វើសក្ការៈបូជាព្រះអទិទេពទៀតផង ។

lxx. លោកមានការពិសោធន៏ការងារ លោកជាអ្នកប្រាជ្ញ ជាអ្នកមានទ្រព្យ ហើយមាន ឈ្មោះល្បីល្បាញដោយសារសប្បុរសធម៌ចំពោះជនានុជន លោកមានទេពកោសល្យ ខាងតូរ្យតន្ត្រី លោកចេះធ្វើអោយដួងចិត្តអ្នកហែរហមរីករាយ តាមចំណងទាំងប្រាំ នៃសេចក្តីគួរសម ។

lxxi. ព្រះបាទសូរ្យវរ្ម័ន(ទី១) បានបញ្ចូលលោកតាមវិធីសាសនា មកក្នុងស្ថានភាពជាជន គ្រហស្ថ ដោយផ្សឹកពីបួសហើយផ្សំផ្គុំរៀបអាពាហ៍ពិពាហ៍លោកជាមួយព្រះនាងភគិនី របស់អគ្គមហេសី វិរៈលក្សី ។

lxxii. ជាមហាកវីដ៏ឆ្នើម ជាកំពូលបុរសប្រកបដោយទេពកោសល្យ ជាអ្នកប្រាជ្ញដ៏ល្បីល្បាញ ហើយដោយមានភក្តីចំពោះព្រះមហាក្សត្រ(សទាសិវៈ) បានទទួលថានន្តរនាមដ៏ សមរម្យ ពោរពេញដោយសេចក្តីសង្ឃឹមជាទេវៈជយេន្ទ្របណ្ឌិត ។

lxxiii. ដួងចិត្តពោរពេញដោយភក្តីភាពចំពោះព្រះករុណាព្រះបាទសូរ្យវរ្ម័នទេវៈ ដែលជា លំនៅនៃសុភមង្គលដ៏ភ្លឺថ្លា សទាសិវៈបានទទួលអំណោយ គ្រែស្នែងមាសនិងរបស់ដទៃ ព្រមទាំងគោរមងារជាអធិបតីនៃអង្គមន្ត្រីកមិន្ទ្រៈ ។

lxxiv. ជាអ្នកកាន់អំណាចមួយដ៏សំខាន់នៅស្រុកភទ្រគិរីនិងនៅទីដីទៃ ដែលស្ថិតនៅក្រុង ឥន្ទ្របុរៈសទាសិវៈបានកសាងនូវកុសលផលបុណ្យចំពោះព្រះរូបអទិទេពដែលត្រូវបាន កសាងឡើងនៅទីនេះ ដោយជីកត្រពាំង និងស្ថាបនកម្មដទៃ ហើយលោកបាន ប្រតិស្ឋានតាមពិធីធ្វើបុណ្យ នូវបដិមានានានៃព្រះសិវានិងអទិទេពដទៃ ។

lxxv. នៅភទ្របដ្តនៈ លោកបានប្រតិស្ឋានតាមវិធីបុណ្យ នូវព្រះសិវៈលិង្គនិងព្រះបដិមាពីរ ទៀត ព្រមទាំងបានសាងសង់ប្រាសាទវលភី ពទ្ធ័ជុំវិញដោយកំពែងសិលា ។

lxxvi. បន្ទាប់ពីបានថ្វាយដល់ព្រះអទិទេពទាំងបីនូវ សម្បត្តិទ្រព្យគ្រប់គ្រាន់មានទាំងអ្នកបំរើ ប្រុសស្រីនិងរបស់ដទៃទៀត លោកបានលើកទំនប់ ជីកត្រពាំងទឹក ដើម្បីជាសុភមង្គល ដល់តំបន់នោះ ។

lxxvii. នៅភទ្រវាសៈ លោកបានប្រមែប្រមូលសម្បត្តិទ្រព្យយ៉ាងច្រើន ហើយបានថ្វាយដល់ ព្រះវិហារព្រះនាងសរស្វតី ព្រមទាំងបានសាងសង់ស្រះទឹក សួនឧទ្យាន និងទំនប់ទឹក ។

lxxviii. លោកបានសាងសង់នៅក្នុងដីនៃវត្តអារាមភជ្រាជ្រ នូវអាស្រមមួយរចនាដោយ ស្នាដៃ លោកផ្ទាល់ លោកបានសង់ក្រោលមួយពោរពេញដោយគោញី ហើយបានលើកទំនប់ ទឹកមួយ ។

lxxix. នៅវិសហរទៈ លោកបានថ្វាយសម្បត្តិទ្រព្យដែលបានសន្សំដល់ព្រះអទិទេព លោកបាន កសាងស្រះជុំវិញប្រាសាទ បានលើកទំនប់ទឹក ហើយបានជីកត្រពាំងទឹក ដើម្បី សុភមង្គលនៃតំបន់ ។

lxxx. នៅក្នុងដែនដីអមោឃបុរៈ លោកបានទទួលរាជទានពីព្រះបាទស្រីសូរ្យវរ្ម័ននូវដីភូមិ មួយ ឈ្មោះចំការដែលជាកេរដំណែលនៃវង្សត្រកូលខាងមាតា ។

lxxxi. នៅក្នុងដែនដីដដែល លោកបានទទួលដីភូមិមួយនៅទិសបូព៌ានៃត្រពាំងមហារថ និងនៅ ត្រើយម្ខាងនៃទន្លេ ។

lxxxii. ដីទាំងអស់នេះដែលបានមកដោយអំណោយ ( ព្រះមហាក្សត្រ ) ឬដោយការទិញដូរ លោកបានថ្វាយជាដង្វាយដល់ព្រះវិហារស្ថាបនានៅវិសហរទៈ និងបានជូនជាអំណោយ ដល់វង្សត្រកូលរបស់លោក ។

lxxxiii. នៅលើដីភូមិនានានៅនាគសុន្ទរៈ(ជារបស់) វង្សត្រកូល និងនៅ(ដែនដី) អមោឃបុរៈ លោកបានកសាងភូមិមួយសំបូរសប្បាយ ហើយបានថ្វាយដល់ព្រះសម្ភូនៅភទ្របដ្ដនៈ ។

lxxxiv. កាលបានប្រតិស្ឋានរូបព្រះនាងសរស្វតីនៅព្រហ្មបុរៈរួចហើយ នៅទីនោះលោកបាន ថ្វាយអ្នកបំរើប្រុសស្រី បានជីកត្រពាំង បានលើកទំនប់ទឹក ។

lxxxv. នៅក្នុងបូរីកុដិ បន្ទាប់ពីបានស្ថាបនាប្រាសាទ លោកបានប្រតិស្ឋានបដិមាសិវលិង្គ ដែល ជាស្នាដៃផ្ទាល់ ហើយបានថ្វាយសម្បត្តិទ្រព្យជាច្រើន មានទាំងខ្ញុំបំរើប្រុសស្រីនិងរបស់ ដ៏ទៃទៀត ។

lxxxvi. លោកបានសុំអំណោយពីព្រះបាទសូរ្យវរ្ម័ន(ទី១) នូវដីភូមិនៃវ៉ាហុយុទ្ធនៅក្នុងបុរី ជើងទ្នប់ ដែលត្រូវបានបោះបង់ចោល លោកបានទទួលយកដីភូមិនោះ ហើយថ្វាយដល់ ព្រះវិហារព្រះឥសូរនៅកុដិ និងបានជូនដល់វង្សត្រកូលរបស់លោក ។

lxxxvii. លោកជាប់សាច់ញាតិខាងបិតានិងព្រះគ្រូវាគិន្ទ្រកវី ហើយលោកបានក្រាបប្រណិបត្តិ ព្រះគ្រូ ដើម្បីរៀនវិជ្ជាសាស្ត្រ មានរៀនវេយ្យាករណ៍ជាដើម ។

lxxxviii. ក្នុងការកសាងសំណង់នានា .... លោកបានស្ថាបនាព្រះអាស្រមមួយពោរពេញដោយ ទ្រព្យសម្បត្តិ ថ្វាយជាគុណូបការៈដល់ព្រះគ្រូ ដោយឧទ្ទិសថ្វាយដល់ព្រះឥសូរ ។

lxxxix. (លោកជា) មហាបុរសដែលមាន ឫទ្ធានុភាពពិសេសក្នុងឋានៈជាព្រះរាជគ្រូ របស់ ព្រះបាទឧទយាទិត្យាវរ្ម័នបានទទួលឋានន្តរសក្តិជាធូលីជើងនៅខាងមុខនិងពាក្យវរ្ម័ន នៅខាងក្រោយ ដែលជាឋានន្តរៈសក្តិដ៏ខ្ពង់ខ្ពស់គ្មាននរណាដល់ ។

xc. លោកទទួលការគោរពពីវិញ្ញូជនផងទាំងឡាយ ដោយសារលោកមានប្រាជ្ញាញាណភ្លឺ ស្វាង លោកបានបង្ហាត់បង្រៀនព្រះករុណាព្រះបាទឧទយាទិត្យា(វរ្ម័ន) ប្រៀបដូច ព្រះអត្រីឬព្រះកាស្យបៈ បង្រៀនព្រះឥន្ទ្រ ឬព្រះចន្ទ្រ នូវវិជ្ជាខាងនយោបាយនិង វិទ្យាសាស្ត្រដ៏ទៃទៀត ។

xci. ព្រះអង្គជាព្រះមហាក្សត្រលើមហាក្សត្រទាំងឡាយ ហើយបានរៀនច្បាប់ទំលាប់នៃ ការប្រព្រឹត្តន៏ .... រីករាយហឫទយ៍ បានទទួលអភិសេកតាមពិធីបុណ្យបានទៅជា អ្នកប្រាជ្ញមួយរូប ព្រះអង្គបានធ្វើគារវកិច្ចគោរពដល់ព្រះរាជគ្រូ ដោយផ្តល់រាជ អំណោយដ៏ថ្លៃថ្លាបំផុត ។

xcii. បន្ទាប់មក នៅក្នុងមន្ទីរប្រាសាទ(របស់ជយេន្ទ្របណ្ឌិត) ព្រះមហាក្សត្រមានហឫទ័យត្រេកត្រអាលផ្តល់នូវទម្រង់និងសញ្ញានៃកិត្តិយសដ៏រុងរឿងបំផុត មានទាំងពិធីលៀងសាយភត្តដ៏គគ្រឹកគគ្រេងនិងពិធីដ៏ទៃទៀត ។

xciii. ប្រាសាទនោះបានត្រូវរចនាដោយរូបបដិមាធ្វើពីសិលាចម្លាក់ជាប្រាសាទគួរជាទីចាប់ ចិត្តព្រោះលំអរនិងរំលេចដោយរូបនារីនានា ហើយតើអោយ នរណានឹកគិតដល់សោភណ័ភាពអ្វីក្រៅទៀត ? ។

xciv. មកុដវេណិកាមួយដ៏ប្រពៃ រយ៉ាត្រចៀកដ៏ល្អមួយគូ ខ្សែដៃនិងខ្សែកនានា ព្រមទាំងគ្រឿងអលង្ការដ៏ទៃ និងចិញ្ចៀនមួយរយគ្រឿង ។

xcv. ថូទឹកធ្វើពីមាស ផ្តិតបក់ (កេត្តិយស) អាសនៈភ្លឺផ្លេក គ្រែស្នែងមានរាងជាពស់ក្បាលបីខ្ពស់ភ្លឺស្អាត ។

xcvi. ត្បូងចរណៃព្រមទាំងត្បូងទទឹមគរជាគំនររាប់ពាន់គ្រាប់ មានទាំងប្រដាប់លាងដៃ មានថូទឹកមាស ភាជនៈមួយព្រមទាំងខ្សងសង្ខ័មួយ ។

ប្រដាប់លាងដៃមួយនិងជើងពាន ជើងពានមួយ(ទៀត) និងខ្សងសង្ខ័ ក្អមស្ពាន់មួយនិងកន្ថោរព្រមទាំងរបស់របរភ្លឺផ្លេកមួយចំនួន ។

ចានទៀបនិងក្អមស្ពាន់ដាក់ទុកដោយបែងចែកជាថ្នាក់ ហើយថ្នាក់និមួយៗមានវត្ថុរាប់ពាន់។

xcvii. ភាជនៈសំណប៉ាហាំងរាប់ពាន់ . . . .ខោអាវរាប់ពាន់បន្ទាស់និងសំលៀកបំពាក់សក្តិសមជាមហាក្សត្រ អាវវែងចំនួនមួយរយ ។

xcviii. សំលៀកបំពាក់ ៤០០០បន្ទាស់ ខោអាវ ៤០០ បន្ទាស់ ប្រេងកប៊ូរបីកដ្ឋិកា ព្រមទាំងកស្តូរមួយកដ្ឋិកា ។

xcix. គ្រឿងក្រអូបមួស្អាត ៤ ខារិខា ម្រេច ១០ ខារិខា ម្រេចខ្មៅ ២០ ខារិកា ។

c. ធញ្ញជាតិអស្សផេទីដាទម្ងន់ ១ ទូល (គ្រាប់) គុមិនដ៏ឈ្មុយ១ ខារិកា ប្រេងវេតីវេរដ៏ក្រអូប និងរំដេង ២៥ ខារិខា ។

ci. ២ ខារិខា . . . . . . . .(វុក្ខជាតិ) លវ: ១ ខារិខា ឬសកុស្មុស និងម្រេចវែង ១ ខារិខា ។

cii. ទឹកដមខ្លឹមចាន់ ១ភារៈ មានខ្លឹមចន្ទន៍ក្រឹស្ណាជាច្រើនមាន ( ប្រេង) ស្ពឹភាក្រអូប និង សិង្ហមូត្រ ៥កាដ្ឋិកា ។

ciii. ( ឬស ) ដែរគៀម ២ទ្រោណៈ ក្រវាញ ៥ខារិខា ផ្កាឃ្លាំភូ ១000 បាច់ ។

civ. ដំរីសារ ២00មានឈ្មោលនិងញី ព្រមទាំងទ្រនាប់ដណ្តប់ ក្បាំងទ្រូង កណ្តឹង ដឹក ដោយពួកហ្មដំរីដែលមានកង្វានិងប្រលូញ ។

cv. សេះរត់ប្រណាំង ១00 ហើយបណ្តាសេះទាំងនេះ មានសេះត្រចៀកខ្មៅ ដែលអូស រទេះញាក់និងដឹកនាំដោយពួកអ្នកបរ ធ្វើអោយឮសូរសំឡេងទ្រហឹងនៃកណ្តឹង ។

cvi. គោញីមានបូកមានកូនចំនួន ២00ក្បាល ក្របី ២៥0ក្បាល ចៀមនិងជ្រូកចំនួន មួយរយៗ ។

cvii. នារីស្នៀកពាក់សំលៀកឆើតឆាយ ១00រូប កំដរដោយទាសីអ្នកប្រគុំតន្ត្រី មានពិណ និងប៉ី ១00គ្រឿងនិងគ្រឿងតូរ្យដន្ត្រីដទៃដែលបន្លឺសំលេងភ្លេងដ៏ពិរោះ ។

cviii. មានតូរ្យដន្ត្រី ៥0វង់ មានគ្រឿងឆឹងធ្វើពីស្ពាន់ មានស្គរនិងគ្រឿងដន្ត្រីដទៃទៀត មាន ភូមិដែលមានខ្ញុំបំរើប្រុសស្រីរស់នៅទីនោះ ។

cix. មានរទេះ៤00 ទឹមដោយសត្វគោដ៏មាំមួន ហើយពោរពេញដោយល្ង ព្រមទាំងមាន អ្នកបររទេះដ៏រហ័សរហួន ។

cx. មានពូថៅមានដងរឹងមានមុខស្រួចស្រិល មួយមុខ១000 មានអាវុធសំរាប់បុះ ព្រម ទាំងលំពែងដែលមានចំនួនរាប់ពាន់ ។

cxi. មានគោញីធាត់ធំទាំងឡាយដែលដឹងផ្លូវ ហើយមានគោ១000ក្បាលក្នុងមួយហ្វូងៗ ។

cxii. មានស្រូវអង្កររាប់ពាន់រាប់អសង្ខៃយគ្រាប់ ។ របស់ទាំងអស់នេះបានត្រូវប្រទានជា អំណោយដោយព្រះមហាក្សត្រដល់ សទាសិវៈជយេន្ទ្របណ្ឌិត ។

cxiii. ទាំងនេះជាការរៀបរាប់របស់របរជាអំណោយប្រទានក្នុងមួយដងដោយព្រះមហា- ក្សត្រដល់ព្រះរាជគ្រូរបស់ព្រះអង្គ ។ នៅចំពោះសប្បុរសធម៌ដ៏សំបើមបែបនេះ តើគេអាចដឹងបានថាមានចំនួនប៉ុន្មានមកហើយ ?

cxiv. ព្រះរាជគ្រូបានទទួលគារវកិច្ចដ៏កក់ក្តៅពីព្រះមហាក្សត្រ ហើយជារៀងរាល់ថ្ងៃ លោកបានទទួលព្រះរាជទានជាសំលៀកបំពាក់ភោជនាហារ ជាគ្រឿងភេសជ្ជៈ ជាគ្រឿងក្រអូប និងជាវត្ថុដទៃទៀត ។
ព្រះរាជគ្រូដ៏សប្បុរសបានធ្វើអំណោយទានគ្មានឈប់ឈរដល់ព្រះវិហារភទ្រេស្វរៈ និងដល់ព្រះវិហារដទៃទៀតនូវសម្បត្តិទ្រព្យដ៏សំបើម មានគ្រឿងមាសប្រាក់ ត្បូងរតនៈដ៏មានតំលៃផងទាំងឡាយ ។ ព្រះរាជគ្រូរមែងគិតជានិច្ចទៅដល់សុខទុក្ខអ្នកផងទាំងពួង លោកបានសាងសង់ផ្ទះសំណាក់ ស្រះទឹកទាំងឡាយតាមដងផ្លូវនានា ដើម្បីសំរួលដល់ក្បួនដំណើរ និងអ្នកថ្មើរជើងផងទាំងពួង ។

cxv. ព្រះមហាក្សត្រសព្វព្រះហឫទ័យប្រកបដោយក្តីសោមនស្សនិងសមាន្យចិត្តចំពោះព្រះរាជគ្រូ ដែលមានបំណងស្ថាបនាព្រះវិហារនៅលើដីភូមិរបស់លោក ។ ព្រះអង្គទ្រង់បានកសាងប្រតិស្ឋានសិវលិង្គដោយផ្តល់នូវរាជអំណោយដ៏បរិបូរនៅ លើដីនោះ ដែលព្រះអង្គបានហៅថាបុរីភទ្រនិកេតនៈ ។

cxvi. ដោយមិនរៀបរាប់តែបុរីឈ្មោះភទ្រនិកេតនៈ ទេដែលមានលក្ខណៈដូចនាមឈ្មោះរបស់បុរីបុរាណភទ្រយោគៈនិងបុរីដ៏ទៃទៀត ព្រះមហាក្សត្រនៅឱកាសធ្វើអំណោយទានមាសត្បូងរតនៈដ៏មានតំលៃ មានទាំងដីរសេះជាដើម ព្រះអង្គ បានពោលពាក្យសច្ចាប្រណិធានដូចតទៅ ៈ សូមអោយ(ព្រះរាជគ្រូ)សិវៈជយេន្ទ្រវរមេស្វរៈ បញ្ចាំងនៅជុំវិញខ្លួន នូវរស្មីនៃប្រាជ្ញាញាណ ប្រកបដោយមហិទ្ធិឫទ្ធដ៏ភ្លឺចាំងចែងអចិន្ត្រៃយដោយកិត្តិនាមនិងជោគជ័យរហូតដល់ទីអវសាន្ត ដើម្បីបំបាត់នូវភាពងងឹតអន្ធការទាំងឡាយ ។

cxvii. ព្រះអាទិត្យនិងព្រះគ្រោះដ៏ទៃបានស្ថិតនៅក្នុងកុម្ភរាសី (versveau) កញ្ញារាសី (vierge) តុលារាសី កុម្ភរាសី មីនារាសី(poisson) កុម្ភរាសី កុម្ភរាសី និង មិនារាសី ។ នក្ខត្តយោគព្យាករណ៍ស្ថិតនៅធនុរាសី (jagittaire) ហើយភវៈបានស្ថិតនៅទីនេះគឺឆ្នាំបញ្ជាក់ដោយសញ្ញារន្ធ (៩) បពត៌(៧) និងវេទ(៤) (គឺឆ្នាំប្រាំបួនរយចិតសិបបួននៃមហាសករាជ) ។

cxviii. ព្រះបាទឧទយាទិត្យវរ្ម័នបានប្រទានដោយភក្តីភាពដល់ (ព្រះរាជគ្រូ) សម្តុជយវរ- មេស្វរៈ នូវដីភូមិដែលលាតសន្ធឹងនៅក្រៅភូមិគ្រឹះទៅខាងទិសបូព៌ានិងទិសដ៏ទៃ ដោយបានកំណត់ទំហំនិងមានគោលសីមាច្បាស់លាស់ ។

cxix. (ព្រះរាជគ្រូ) ជយេន្ទ្រវរ្ម័នជឿជាក់ដល់ហឫទ័យរាក់ទាក់នៃព្រះមហាក្សត្របានតបស្នង សងគុណូបការៈដ៏ស្មោះស្មគ្រ័ចំពោះព្រះអង្គ គឺជាកត្តាបណ្តាលអោយសេចក្តីចំរុងចំរើន ជៀសផុតពីឧបសគ្គនានា ដែលអាចប្រៀបបាននិងព្រះអត្រិ ។

cxx. ល្អាងទឹកដ៏ធំហើយជ្រៅប្រកបដោយគង្គាថ្លាខ្យង បណ្តាលអោយមានសេចក្តីស្នេហា នៃសត្វហង្សចំពោះបុទុមបុប្ផា គឺជាក្តីរីករាយសប្បាយដល់ពួកព្រាហ្មណ៏ផងទាំង ឡាយ ។ (ល្អាងទឹកនោះ) ត្រូវបានសាងសង់ឡើងជានិមិត្តរូបអត្តចារិកនៃការប្រព្រិត្តន៍ និងឥរិយាបទរបស់ព្រះរាជគ្រូ ក្រោមរូបភាពនៃសំណង់ទំនប់ទឹក ។

cxxi. មហាបុរសដ៏សប្បុរស ស្របតាមពិធីបុណ្យសាសនា បានស្ថាបនារូបបដិមា (មហាព្រាហ្មណ៏) ហិរណ្យទាមៈ បានស្ថាបនារូបបដិមា (ព្រះមុនី) សិវកៃវល្យៈ សិវស្រម (ជាព្រះបដិមា) មានឫទ្ធានុភាពស្មើព្រះព្រហ្ម ស្មើព្រះវិស្ណុ និងព្រះសិវា ។

cxxii. កាលណាបានឃើញនូវជីវភាពរស់នៅដ៏ល្អប្រពៃ ជារបស់ទីមួយនៅលើផែនដី ឬ គ្រាន់តែបានឮសូរគេនិយាយ បុគ្គលគ្រប់រូបរមែងមានស្មារតីស្ងប់ស្ងៀម ហើយដួងចិន្តា ជ្រះថ្លាបរិសុទ្ធចំពោះសុគតិភព ។ ទ្រព្យសម្បត្តិរបស់ព្រះសិវានឹងបណ្តាលអោយមាន មហន្តរាយដល់ជន ទាំងឡាយណាដែលប៉ងប្រាថ្នាកេងប្រវ័ញ្ចលួចយកទៅ ។ (ផ្ទុយទៅវិញ) គេនិងទៅជាជនសម្បូរដោយទ្រព្យសម្បត្តិ មានសេចក្តីថ្កុំថ្កើនរុងរឿង កាលគេប៉ងប្រាថ្នាថ្វាយអំណោយទានដល់ព្រះសិវា ។

# វិធីកម្លាយក្នុងភាសាខ្មែរបុរាណ

រៀបរៀងដោយ មាឃ ប៉ូរ៉ា

------

នៅគ្រប់ភាសាទាំងអស់ទោះបីស្ថិតនៅក្នុងអម្បូរភាសាណាក៏ដោយ តែងតែមានលក្ខណៈបង្កើតពាក្យទៅតាមការកែច្នៃនិងពិនិត្យទៅលើភាសានីមួយៗនោះ ហើយបង្កើតក្បួនខ្នាតទៅតាមការប្រើប្រាស់ ។ វិធីកម្លាយនេះក៏ជាវិធីមួយសម្រាប់បង្កើតពាក្យនៅក្នុងភាសាខ្មែរដែរ ដោយប្រើមូលបទនីយកម្ម (ផ្នត់នីយកម្ម) ត្រួវនឹងពាក្យបារាំង (Affixations) យកទៅផ្សំជាមួយពាក្យឫសបង្កើតពាក្យថ្មីមួយទៀត ហើយវិធីកម្លាយនេះអាចធ្វើឱ្យមានការប្រែប្រួលនូវវាក្យសព្ទផងដែរ ។ ក្នុងការប្រើប្រាស់វិធីកម្លាយនេះ នៅសម័យបុរេអង្គរមានការប្រើប្រាស់នូវមូលបទ(ផ្នត់)ត្រូវនិងពាក្យបារាំងហៅថា "Affixes" និង ឧបមូលបទ (présumés-affixes) ឬអឌ្ឍផ្នត់ត្រូវនិងពាក្យបារាំង ហៅថា "semi-affixes"។

## ការប្រើប្រាស់មូលបទ :

មូលបទជាទម្រង់ដើមមួយសម្រាប់បង្កបង្កើតពាក្យនៅក្នុងភាសាខ្មែរ ដែលមានកំណើតតាំងពីយូរយារណាស់មកហើយ អាចកើតមានឡើងតាំងពីមនុស្សចេះប្រើប្រាស់ភាសា និងអក្សរ មកម្លេះ ។

គេអាចចែកមូលបទសម័យមុនអង្គរជាពីរក្រុម :

**ក្រុមទី១ : មូលបទមិនពេញលេញ** (Faux affixes) :

មូលបទបទមិនពេញលេញនេះវាក៏ជាមូលបទដែរ ហើយមានតួនាទីសម្រាប់បង្កើតពាក្យ ដូចជាមូលបទដែរ តែវាពុំមានន័យច្បាស់លាស់ដូចជាមូលបទ ។ បានសេចក្តីថាកាលណាយកទៅផ្សំជាមួយពាក្យឫស ពាក្យកម្លាយ វាមិនសម្តែងន័យស្របទៅតាមពាក្យឫសនោះឡើយ វាខុសអំពីមូលបទពិតប្រាកដកាលណាយកទៅផ្សំជាមួយពាក្យឫស ពាក្យកម្លាយវាមានន័យស្របជាមួយពាក្យឫស នោះដូចករណី [ ប ], [ ន ],[ ម ] ជាដើម ។ សូមបញ្ជាក់ផងដែរថា មូលបទមិនពេញលេញនេះនៅសម័យមុនអង្គរក៏ជាធាតុមួយសម្រាប់បង្កើត នរនាម ស្ថាននាម ផងដែរ ។

**គេអាចចែកមូលបទមិនពេញលេញជាទម្រង់ :**

**១. បុព្វបទមិនពេញលេញទម្រង់** (Faux préfixes forms) [ព- ] [ C- ] :

បុព្វបទទម្រង់នេះគឺជាទម្រង់ដែលកើតឡើងដោយសារព្យញ្ជនៈដំបូងបង្អស់មួយ យកទៅផ្សំជាមួយនឹងពាក្យឫស បង្កើតបានជាពាក្យកម្លាយឯកព្យាង្គ តែបុព្វបទនេះវាពុំមានលក្ខណៈទៀងទាត់អាចសំគាល់បានថា ជានាមភ្នាក់ងារ នាមឧបករណ៍ ឬនាមលទ្ធផលបានឡើយ ។ តាមការសង្កេតទៅលើសិលាចារឹក

ឃើញថាបុព្វបុរសយកបុព្វបទនេះទៅផ្សំជាមួយពាក្យឫសដើម្បីបង្កើតនរនាម (Proper name)។ តាមទម្រង់នេះឃើញថាមិនមានស្រៈកប់តួ ឡើយនៅក្នុងក្រុមព្យញ្ជនៈដើមឡើយ ។

ហើយបុព្វបទទម្រង់នេះសំខាន់ៗមាន : [ ក៑ -] k- , [ ច៑-] c- , [ ត៑ -] t- , [ស៑ -] s- ។

- បុព្វបទ [ ក-] [k-] បុព្វបទ :

បុព្វបទ [ក-]នេះបើពិនិត្យទៅលើសិលាចារឹកឃើញថា ច្រើនសម្តែងលក្ខណៈជាមេ ឬ ជាអ្នកដឹក និងសម្តែងនូវភាពស្និទស្នាល ។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ក៑-] + ចន៑ can > ក្ចន៑ kcan , វ៉ា ក្ចន៑ vā kcan K.140,676.A.D,l. 14 ន.ន.បុំ , បុរសឈ្មោះ ក្ចន ។

[ក៑-] + ចិ ci ( បុព្វជន ជីតា) > ក្ចិ kci , វ៉ា ក្ចិ vā kci K.51,VII.A.D,l.10 , ន.ន.បុំ , បុរសឈ្មោះ ក្ចិ ។

[ក៑-] + ចៅ cau ( ចៅ) > ក្ចៅ kcau , វ ក្ចៅ va kcau K.137,VII.A.D,l.20 ន.ន.បុំ , បុរសនាម ក្ចៅ ។

- បុព្វបទ [ ច៑ -] c- :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ច៑-] + កប៑ kap( កប ប្រកប) > ច្កប៑ ckap , វ៉ា ច្កប៑ vā ckap K.66B,VII.A.D,l.11, ន.ន.បុំ . បុរសឈ្មោះ ច្កប ។

[ ច៑ -] + កោប៑ kop( កើប ប្រមូល) > ច្កោប៑ ckop , គេ ត ច្កោប៑ ឧចិត សំវត្សរ ge ta ckop ucita saṃvatsara K.44B.674.A.D,l.4 , អ្នកទារពន្ធប្រចាំឆ្នាំ ។

[ ច៑ -] + បោង៑ poṅ ( បង) > ច្បោង៑ cpoṅ , អញ ត ច្បោង ក្វន កន្ហេង កម្រ តាង អញ ស្រី ជយេន្ទ្រ añ ta cpoṅ kvan kanheṅ kamratāṅ añ çrī jayendra K.124,803.A.D,l.4 , ព្រះរាជបុត្រីច្បងរបស់ព្រះអង្គម្ចាស់ក្សត្រី ស្រី ជយេន្ទ្រ ។

-បុព្វបទ [ត៑-] t- : នាពេលនោះមិនទាន់ឃើញបង្កើតជានាមទូទៅនៅឡើយទេ ក្រៅអំពីនរនាម ឬ ស្ថាននាម។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[តិ -] + គុះ guḥ(តែប៉ុណ្ណោះ) > ត្គុះ tguḥ , កុ ត្គុះ ku tguḥ K.739,VII-VIII.A.D,l.6, ន.ន.ឥ . នារីឈ្មោះ ត្គុះ ។

[តិ -] + គោរិ gor(គោរ ន.ន) > ត្គោរិ tgor , វ ត្គោរិ va tgor K.24A,VI-VII.A.D,l.8, ន.ន.ប៉ុ .បុរសនាម ត្គោរ ។

[ តិ -] + គៅ gau(គៅ ន.ន) > ត្គៅ tgau , វ៉ា ត្គៅ vā tgau K.133B,VIII.A.D,l.2, ន.ន. ប៉ុ ,បុរសនាម ត្គៅ ។

- បុព្វបទ [ សិ -] s- :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[សិ-] + តេកិ tek(ដែក) > ស្តេកិ stek, ច្មបិ ស្តេកិ cmap stek K.137,VII.A.D. l.21, ន.ន.ឥ, (នារីអ្នកបម្រើ)នាម ឆ្មប ស្តេក។

[សិ-] + តោងិ toṅ(ដូង) > ស្តោងិ stoṅ , កុ ស្តោងិ ku stoṅ K.755,VII.A.D,l.1 ន.ន.ឥ . នារីអ្នកបម្រើឈ្មោះ ស្តោង ។

[ សិ -] + តោយិ toy(ដោយ ដោយតាម) > ស្តោយិ stoy, អ្មេ ស្តោយិ ªme stoy K.956,VII. A.D,l.6 ន.ន.ឥ, (អ្នកម្តាយ) អ្មេ ស្តោយ ។

**២. បុព្វបទមិនចេញលេញទម្រង់** (Faux préfixes forms) [ពសិ-] cv- :

បុព្វបទដំបូងឯកព្យាង្គ ការណាយកទៅផ្សំជាមួយនឹងពាក្យឫសទាំងឡាយ វាបង្កើតពាក្យកម្លាយ ដែលមានខ្យល់ស្រះនៅអាស្រ័យ ។ ហើយបុព្វបទទម្រង់នេះ បើតាមទស្សនៈលោកសាស្ត្រាចារ្យបណ្ឌិត ពុំ ម៉ល់ លោកបានហៅបុព្វបទបែបនេះថាជា"បរៈមូលបទ" ត្រូវសងពាក្យបារាំងថា "para-affixe" គឺវត្ថុធាតុមួយបែបដែលជិតដូច/សិងដូចមូលបទដែរគឺជាសូរខាងដើមរបស់ពាក្យខ្លះ ដែលគេទ្វេដើម្បីឱ្យបញ្ញត្តិ ឬ ន័យរបស់ពាក្យនោះមានន័យដដែលផ្ទួនៗឡើង ដូចជា "កូរ > កកូរ "(កកូរ គឺកូរហើយកូរទៀត)"[១] ។ បើតាមទស្សនៈនេះឃើញថា នៅសម័យបុរាណមិនមានការប្រើប្រាស់មូលបទបែបនេះទេ បានសេចក្តីថានៅសតវត្សទី៦-៨នេះ គ្រាន់តែយកបុព្វបទទាំងនេះទៅផ្សំជាមួយពាក្យឫសទាំងឡាយ ដោយមិនមានវិធីផ្ទួនពាក្យឡើយ។

ហើយបុព្វបទទម្រង់នេះមាន : [ក-] k- , [ច-] c- , [ត -] t- ,[ស-] s- ។

---

[១] ពុំ ម៉ល់ : << លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យ ក្នុងភាសាខ្មែរ >> នៅក្នុង : *ទស្សនាវដ្តីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី២ លេខ២ ២០០១ ទំព័រ ៧១ ។

- បុព្វបទ [ក-] k- :

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ ក -] + អញ៑ añ (ខ្ញុំ) > កអញ៑ ka añ , កអញ៑ ka añ K.138, 620.A.D,l. 4 " ឈ្មោះ ឋាទន្តរ នាមនៃអភិជន"[២] ។

[ ក -] + ឧន៑ on (តូច) > កឧន៑ ka-oṅ, វា កឧន៑ vā ka-on K.24B,VI-VII.A.D,l.10 , ន.ន.ប៉ុ .បុរសនាម កឧន ។

[ ក-] + ឧរ៑ or(ឧរ ) > កឧរ៑ ka-or, វា កឧរ៑ vā ka -or K.109,655.A.D,l.19 , ន.ន.ប៉ុ .បុរសឈ្មោះ កឧរ ។

- បុព្វបទ [ច-] c- :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ ច-] + ឧយ៑ oy (ឱ្យ) > ចឧយ៑ ca-oy . កុ ចឧយ៑ ku ca-oy K.149,VII-VIII.A.D. l.22, ន.ន.ឥ . នារីនាម ចឱយ ។

[ ច-] + ចាក៑ cāk( ចាក ) > ចចាក៑ cacāk ,ស្រេ ចចាក៑ sre cacāk K.808,VII-VIII. A.D.l.5, ឋ.ន. .ស្រែនៅតំបន់ ចចាក ។

[ ច-] + អាប៑ *āp > ចអាប៑ ca-āp, កុ ចអាប៑ ku ca-āp K.559A,VII.A.D. l.3 , ន.ន.ឥ . នារីអ្នកបម្រើឈ្មោះ ចអាប ។

[ ច-] + ឧយ៑ oy (ឱ្យ) > ចឧយ៑ ca-oy , កុ ចឧយ៑ ku ca-oy K.149,VII.A.D. l.22, ន.ន.ឥ . នារីនាម ចឧយ ។

- បុព្វបទ [ត-] t- :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ត-] + ចង៑ caṅ(ចង់) > តចង៑ tacaṅ , កុ តចង៑ ku tacaṅ K.600E,611.A.D.l.7 , ន.ន.ឥ . នារីនាម តចង ។

[ត-] + ចុះ cuḥ (ចុះ) > តចុះ tacuḥ , វា តចុះ vā tacuḥ K.149,VII.A.D.l.8,ន.ន.ប៉ុ .បុរសនាម តចុះ ។

---

[២] ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* (តាមរយៈសិលាចារឹកបុរេអង្គរ សតវត្សទី៦-៨ ភ្នំពេញ. ឆ្នាំ២០០០. ទំព័រ៦១

[ ត-] + តាង tāṅ( តាំង តែងតាំង) > តតាង tatāṅ , វា តតាង vā tatāṅ K.451,680. A.D. l.4 , ន.ន.ប៉ុ . បុរសនាម តតាង ។

**៣. បុព្វបទមិនពេញលេញទម្រង់** (Faux préfixes forms) **[៣ស / ៣-] cvc- :**

ជាបុព្វបទទ្វេព្យាង្គ បុព្វបទទាំងនេះកើតឡើងដោយការផ្សំរវាងព្យញ្ជនៈច្រមុះ ឬយើងអាចហៅម្យ៉ាងទៀតថា ជាបណ្តាសព្ទ (កលារូបសព្ទ) ត្រូវនឹងពាក្យបារាំង (Allomorphe) របស់បុព្វបទដំបូងដែលមានលក្ខណៈឯកព្យាង្គ ។ ហើយបុព្វបទទ្វេព្យាង្គនេះផ្សំជាមួយពាក្យឫស បង្កើតពាក្យកម្លាយទ្វេព្យាង្គ ។ បុព្វបទទម្រង់នេះសំខាន់ៗរួមមាន :

[កង-] kaṅ- , [កញ-] kañ- , [កន-] kan- , [កម- ,កំ-] kam- , kaṃ- , [កល-] kal- , [ចង-] caṅ- , [ចន-] can- , [ចម-, ចំ-] cam-, caṃ- , [តង-] taṅ- , [តន-] tan- , [តម , តំ-] tam- , taṃ-, [ទន-] dan- , [ទំ-]daṃ-, [សង-] saṅ- , [សញ-] sañ- , [សន-] san- , [សម-, សំ-] sam- , saṃ-

- **បុព្វបទ [កង-] kaṅ- :** ជាបុព្វបទទ្វេព្យាង្គ កើតឡើងដោយបុព្វបទ[ក-] និងខ្យល់ ច្រមុះ [ង-] ។

ឧទាហរណ៍ :

| បុព្វបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|

[កង-] + វល *val( វល់ វិលវល់ ខ្វល់) > កង្វល kaṅval , កុ កង្វល ku kaṅval K.22, VII.A.D.l.16, ន.ន.ឥ , នារីនាម កង្វល់ ។

- **បុព្វបទ [កញ-] kañ- :** ជាបុព្វបទកើតឡើងដោយបុព្វបទ [ក-] និងខ្យល់ច្រមុះ[ញ-] ។ ហើយ បុព្វបទនេះច្រើនបញ្ជាក់ពីលក្ខណៈបន្ទុះបន្ទាប់ ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[កញ-] + ចារ cār( ចារ ឆ្លាក់ > កញ្ចារ kañcār , វា កញ្ចារ vā kañcārK.926,624.A.D. l.6 ,ន.ន.ប៉ុ . បុរសនាម កញ្ចារ ។

[កញ-] + ចញ cañ( ចាញ់) > កញ្ចញ kañcañ ,កុ កញ្ចញ ku kañcañ K.562B,VII.A.D. l.14-5 , ន.ន.ឥ .នារីឈ្មោះ កញ្ចញ ។

[កញ-] + ចស cas( ចាស់) > កញ្ចស kañcas , វ កញ្ចស va kañcas K.51,VII.A.D. l.9, ន.ន.ប៉ុ .បុរសនាម កញ្ចស ។

- **បុព្វបទ [កន-] kan- :** ជាបុព្វបទកើតឡើង ដោយបុព្វបទ [ក-] និងខ្យល់ច្រមុះ [ន-] ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[កន-] + លេង leṅ (លែង) > កន្លេង kanleṅ , វ កន្លេង va kanleṅ K.684, VII.A.D.l.11 , ន.ន.បុំ ,បុរសនាម កន្លេង ។

[កន-] + លោង loṅ (ខ្លោង ធំ) > កន្លោង kanloṅ , កន្លោង ឥត kanloṅ it K.939,VII.A.D.l.9 ,ឋ.ន., ប្រាសាទឥដ្ឋ ។

[កន-] + លោញ loñ (ឋានន្តរនាម)> កន្លោញ kanloñ , កុ កន្លោញ ku kanloñ K.689A,VII-VIII.A.D.l.13 ,ន.ន.ឥ , នារីឈ្មោះ កន្លោញ ។

**- បុព្វបទ [កម-,កម់-]kam-kaṃ- :** ជាបុព្វបទទ្វេព្យាង្គ កើតឡើងដោយសារបុព្វបទ [ក-] ផ្សំជាមួយព្យញ្ជនៈច្រមុះ [ម-] នៅខាងចុង និងបុព្វបទ[កំ-] កើតឡើងដោយសារបទឡំរវាង បុព្វបទ [ក-] ផ្សំជាមួយអន្តរបទ –aṃ- ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[កម-] + ខ្វល *khval( វល់ វិលវល់ ខ្វល់) > កម្វល kamval , វា កម្វល ប្រមះ vā kamval pramaḥ K.138,620.A.D.l.6 ,ន.ន.បុំ , បុរសឈ្មោះ កម្វល ជាអ្នកកិនលំអិតគ្រឿងក្រអូប ។

[កម-] + ទោត dot ( ទូត ជីទូត) > កំទោត kaṃdot , វា កំទោត vā kaṃdot K.109N, 655.A.D.l.12 ,ន.ន.បុំ , បុរសឈ្មោះ កំទោត ។

[កម-] + បង pan( បង់ បាំង) > កំបង kaṃpaṅ , តៃ កំ ១ អ្មេ កំបង ១ tai kaṃ 1 [a]me kaṃpaṅ 1 K.134,781.A.D.l.23 , ន.ន.ឥ ,នារីឈ្មោះ កំបង ១ និង ស្ត្រីចំណាស់ កំបង ១ ។

**- បុព្វបទ [កល-] kal- :** ជាបុព្វបទទ្វេព្យាង្គ ដែលកើតឡើងដោយសារបុព្វបទ [ក-] ផ្សំជាមួយនឹងព្យញ្ជនៈ [ល-] ឬព្យញ្ជនៈខ្យល់រនាវ (liquide) ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[កល-] + កប kap( កប ល្អ) > កល្កប kalkap , កុ កល្កប ku kalkap K.129,VII-VIII.A.D.l.14 , ន.ន.ឥ , នារីឈ្មោះ កល្កប ។

[កល-] + បិត pit > កល្បិត kalpit , វា កល្បិត vā kalpit K.66,VII.A.D, l.8, ន.ន.បុំ ,បុរសនាម កល្បិត ។

[កល៑-] + វំម៑ *vaṃm(ក្រពុំ ខ្ពស់) > កល្វំម៑ kalvaṃm , វា កល្វំម៑ vā kalvaṃm K.155A,VII-VIII.A.D.l.19 , ន.ន.បុំ .បុរសនាម កល្វំម ។

- បុព្វបទ [ចង៑-] caṅ- : ជាបុព្វបទដែលកើតឡើងដោយបុព្វបទ [ច-] ឯកព្យាង្គផ្សំជាមួយព្យញ្ជនៈច្រមុះ [ង-] ខាងចុង ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ចង៑-] + ចុង៑ cuṅ( ចុង ខាងចុង) > ចង៑ចុង៑ caṅcuṅ , វា ចង៑ចុង៑ vā caṅcuṅ K.149, VII. A.D.l.13 ,ន.ន.បុំ បុរសនាម ចងចុង ។

- បុព្វបទ [ចន៑-] can- : ជាបុព្វបទដែលកើតឡើងដោយបុព្វបទ [ច-] ឯកព្យាង្គផ្សំជាមួយព្យញ្ជនៈច្រមុះ [ន-] ខាងចុង ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ចន៑-] + ទល៑ dal( ទល់ ទ្រ ទប់) > ចន្ទល៑ candal , ចន្ទល៑ បថវិ candal pathavi K.877B,VII-VIII.A.D.l.17 , ចន្ទល់ផែនដី ។

[ចន៑-] + ហោយ៑ *hoy( ហុយ) > ចន្ហោយ៑ canhoy , ចន្ហោយ៑ មាស៑ ចន្ហោយ៑ ប្រាក់ canhoy mās canhoy prāk K.388,VII.A.D.l.14 , ភាជន៏មាស ភាជន៏ប្រាក់ ។

[ចន៑-] + ហោរ៑~ហ្វារ៑ *hor~hvar( ហួរ)> ចន្ហោរ៑ , ចន្ហ្វារ canhor, canhvar ,ករោំ វ្រៃ ឆ្ទិង៑ ចន្ហ្វារ , karoṃ vrai chdiṅ canhvar K.341,682.A.D.l.9 , ដីទំនាប ព្រៃ ស្ទឹង ចង្ហួរ ។

-ស្រែ ឰ ចន្ហោរ៑ តាង៑ ចិ វ្រៅ sre ai canhor tāṅ ci vrau K.726,VII.A.D.l.1, ស្រែនៅឯ ចង្ហួរ (ព្រែក) របស់មន្ត្រីតាងចិវ្រៅ ។

- បុព្វបទ [ចម៑-,ចំ-]cam-,caṃ- : ជាបុព្វបទដែលកើតឡើងដោយសារ បុព្វបទឯកព្យាង្គ [ច-] ផ្សំជាមួយនឹងខ្យល់ព្យញ្ជនៈច្រមុះ [ម-] នៅខាងចុង ។ ចំណែកឯបុព្វបទ [ចំ-] កើតឡើងដោយសារបុព្វបទឯកព្យាង្គ [ច-] ផ្សំជាមួយនឹងអន្តរបទ -aṃ- ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ចម៑-] + បេង៑ peṅ( បែង បែងចែក) > ចម្បេង៑ campeṅ , កុ ចម្បេង៑ ku campeṅ K.357,VII.A.D.l.15 ,ន.ន.បុំ , នារីនាម ចម្បេង ។

[កបិ-] + កបិ kap (កប់) > ចំកបិ caṃkap , វា ចំកបិ vā caṃkap K.480,VII.A.D.l.12 ,ន.ន.ប៉ុ បុរសនាម ចំកប ។

- បុព្វបទ **[តង៑-] taṅ- :** ជាបុព្វបទទ្វេព្យាង្គ កើតឡើងដោយសារបុព្វបទឯកព្យាង្គ [ត-] ផ្សំជាមួយនឹងព្យញ្ជនៈខ្យល់ច្រមុះ [ង-] នៅខាងចុង ។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[តង៑-] + តោង៑ toṅ (តោង ព្យួរ) > តង្តោង៑ taṅtoṅ , បល្លង្ក តង្តោង៑ pallaṅka taṅtoṅ K.505, 639.A.D.l.19 , បល្លង្ក និង (វត្ថុសម្រាប់ពិធីសក្ការបូជា) តង្តោង ។

[តង៑-] + ថ្វាយ៑ thvāy (ថ្វាយ) > តង្ហ្វាយ៑ taṅhvāy , តង្ហ្វាយ៑ ត្បល គ៌ុ យោង៑ ក្មៅ ១ taṅhvāy gui yoṅ kmau 1 K.9,639,A.D.l.19 , តង្វាយ (ចំពោះព្រះមហាក្សត្រ) នូវច្បារដំណាំ និង (ឈ្មោះ) យោង ក្មៅ១ ។

- បុព្វបទ **[ តន៑-] tan- :** ជាបុព្វបទនេះកើតឡើងដោយសារបុព្វបទ[ត-] ផ្សំជាមួយនឹង ព្យញ្ជនៈខ្យល់ច្រមុះ [ន-] នៅខាងចុង ។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[តន៑-] + ហោរ៑ *hor (ហូរ) > តន្ហោរ៑ tanhor , ស្រែ វ្នុរ ញង៑ តន្ហោរ៑ សរេ ២ sre vnur ñaṅ tanhor sare 2 K.155B,VII-VIII.A.D.l.13 , ស្រែនៅជិតទួលតន្ហោរ ទំហំពីរសរេ ។

[តន៑-] + ត្លោង៑ tloṅ (វង្វាស់) > តន្លោង្ង៑ tanloṅṅ , តបិ តន្លោង្ង៑ tap tanloṅṅ K.76,VII.A.D.l.10 , (ស្រូវ) ដប់តន្លោង ។

- បុព្វបទ **[ តម៑-,តម់ -] tam-, taṃ- :** ជាបុព្វបទកើតឡើងដោយសារបុព្វបទ [ត-] ផ្សំជាមួយនឹងព្យញ្ជនៈច្រមុះ [ម-]នៅខាងចុង ។ ឯបុព្វបទ [តំ-] កើតឡើងដោយសារបុព្វបទ [ត-] ផ្សំជាមួយនឹង អន្តរបទ -aṃ- ។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[តម៑-] + ត្បេះ~បេះ *tpeḥ ~peḥ[៣] (បេះ ,កេះ) > តម្បេះ tampeḥ , តម្បេះ កុ មេ ភេ tampeḥ ,

[៣] ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* ជ.ឯ.ម. ទំព័រ ២៦៦ ។

tampeḥ ku me bhe K.137,VII.A.D.l.17 , នារីមេភេ ជាអ្នកលេងភ្លេង ។

[តម់-] + បោញ poñ( គោរម្យងារ) > តំបោញ tampoñ , វា តំបោញ vā tampoñ K.357,VII.A.D.l.10 , ន.ន.បុំ ,បុរសនាម តំបោញ ។

[តម់-] + លិង liṅ (ឈ្មោះរង្វាស់ទម្ងន់) > តំលិង tamliṅ , តំលិង ប្រក ៥ tamliṅ prak 5 K.41,VII.A.D.l.6 , ប្រាក់ប្រាំតម្លឹង ។

- **បុព្វបទ [ទន-] dan- :** ជាបុព្វបទដែលកើតឡើងដោយសារបុព្វបទ[ទ-] ផ្សំជាមួយនឹងព្យញ្ជនៈខ្យល់ច្រមុះ [ន-] ។

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ទន-] + តប tap( ដប់) > ទន្តប dantap , វ្រះ កំម្រតាង អញ បិ ទន្តប vraḥ kammratāṅ añ pi dantap K.389,VII.A.D.l.5 , រូបព្រះបដិមាដប់បី ។

[ទន-] + ធុំ dhuṃ( ធុំ ធុំក្លិន) > ទន្ធុំ danhuṃ , វ្នេ ង្នៅ ទន្ធុំ vṅe ṅnau danhuṃ K.600N,611.A.D.l.3 , ផ្កាង្កៅ គ្រឿងក្រអូប ។

**៤. បុព្វបទមិនចេញលេញទម្រង់** (Faux préfixes forms) **[ ពព/ស-] ccv- :**

ជាបុព្វបទដែលកើតឡើងដោយសារការផ្សំរវាងព្យញ្ជនៈដើមនិងព្យញ្ជនៈខ្យល់រនាវ (liquide)(r) ។ បុព្វបទទម្រង់ នេះសំខាន់រួមមាន :

[ក្រ-] kra- , [ច្រ-] cra- , [ត្រ-] tra- , [ទ្រ-] dra- , ។

- **បុព្វបទ [ក្រ -] kra- :**

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ក្រ-] + កប kap (កប់) > ក្រកប krakap , វា ក្រកប vā krakap K.904,713.A.D.l.23 , ន.ន.បុំ , បុរស( អ្នកបម្រើ) ឈ្មោះ ក្រកប ។

[ក-] + សោប sop ( ឱប ) > ក្រសោប krasop , វា ក្រសោប vā krasop K.904A,713.A.D.l.22 , ន.ន.បុំ , បុរស( អ្នកបម្រើ) ឈ្មោះ ក្រសោប ។

- **បុព្វបទ [ច្រ-]cra- :**

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ច្រ-] + កាង៝ kāṅ (កាង រាំង) > ច្រកាង៝ crakāṅ , វា ច្រកាង៝ vā crakāṅ K.149,VII.A.D.l.7 ,ន.ន.ប៉ុ .បុរស (អ្នកបម្រើ) នាម ច្រកាង ។

[ច្រ-] + លក៝ lak (លាក់ ធ្លាក់) > ច្រលក៝ cralak , គេ ត ហ្វហ៝ គិយ៝ គេ ត ច្រលក៝ គិយ៝...ge ta hvaḥ giy ge ta cralak giy... K.502,VII.A.D.l.16 , អ្នកណាវះ ឬបំបែកនៅទីនេះ អ្នកណាលាក់ ឬធ្លាក់នៅទីនេះ ... ។

- **បុព្វបទ [ត្រ-] tra- :**

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ត្រ-] + វង៝ vaṅ (វង់ វង្វង់) > ត្រវង៝ travaṅ , ត្រវង៝ កុរាក៝ travaṅ kurāk K.38,VII.A.D.l.4 , ឋ.ន , ត្រពាំង កុរាក ។

- **បុព្វបទ [ទ្រ-] dra- :**

ឧទាហរណ៍ :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ទ្រ-] + ទាប៝ dāp (ទាប) > ទ្រទាប៝ dradāp , កុ ទ្រទាប៝ ku dradāp K.129, VII-VIII.A.D.l.15 , ន.ន.ឥ ,នារី (អ្នកបម្រើ) ឈ្មោះ ទ្រទាប ។

[ទ្រ-] + ទាស៝ dās (ងាកចេញ) > ទ្រទាស៝ dradās , កុ ទ្រទាស៝ ku dradās K.562,VII.A.D.l.7 ,ន.ន.ឥ , នារី (អ្នកបម្រើ) នាម ទ្រទាស ។

[ទ្រ-] + ទិហ៝ diḥ (ពាក្យសំគាល់អ្នកបម្រើ) > ទ្រទិហ៝ dradiḥ , យានហស្តិនី ទ្រទិហ៝ yanahastini dradiḥ K.259,VIII.A.D.l.26 , ក្រៃស្នែង ទ្រទិះ ។

<u>ក្រុមទី២</u> **: មូលបទ (Affixes)**

ក្រុមទី២នេះជាមូលបទប្រកបទៅដោយលក្ខណៈខ្សែងទាត់ កាលណាយកទៅផ្សំជាមួយពាក្យឫស វាបង្កើតបានទូវនាមភ្នាក់ងារ នាមឧបករណ៍ និងនាមលទ្ធផល ។

**គេអាចចែកមូលបទនេះជាពីរចម្រង់ :**

**១. <u>បុព្វបទ</u> :**

គឺជាបុព្វបទមួយដែលកើតឡើងដោយសារព្យញ្ជនៈដើមឯកព្យាង្គយកទៅផ្សំជាមួយនឹងពាក្យឫស បង្កើតពាក្យកម្លាយជាឯកព្យាង្គ បើបុព្វបទទ្វេព្យាង្គពាក្យកម្លាយ បើតាមអត្ថបទមួយរបស់លោកសាស្ត្រា-

ចារ្យបណ្ឌិត ឡុង សៀម បានសរសេរថា " នៅក្នុងភាសាខ្មែរបុរាណបុព្វបទ ឬផ្នត់ទាំងឡាយដែលគ្មានលក្ខណៈជាព្យាង្គ (គឺថាផ្នត់ដែលកើតឡើងដោយព្យញ្ជនៈតែមួយ (c) ស្រៈណឹតតែមួយ a អ (r) ឬ មួយរួមផ្សំដោយព្យញ្ជនៈដើមព្យាង្គនិងស្រៈណឹត (Cr) អាចចាត់ទុកថាជាផ្នត់ដំបូង១)"[៤] ។ ហើយ បុព្វបទនេះមិនត្រឹមតែមានលក្ខណៈឯកព្យាង្គក្នុងការបង្កើតពាក្យប៉ុណ្ណោះទេ បានសេចក្ដីថាការបង្កើតពាក្យថ្មីដោយប្រើនូវមូលបទនីយកម្មពហុព្យាង្គផងដែរ ។ ហើយ យើងអាចនិយាយបានម្យ៉ាងទៀតដែរ មូលបទនីយកម្មពហុព្យាង្គនេះកើតឡើងដោយសារបុព្វបទជាឯកព្យាង្គផ្សំជាមួយនិងខ្យល់ច្រមុះ " ង ញ ន ម " ឧទាហរណ៍ : បុព្វបទ p-តាមមតិរបស់លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម លោកមានប្រសាសន៍ [p-] មានបណ្ដាសូររបស់វាមាន paṅ , pañ , pan , paṃ ជាដើម ។ តែយើងអាចថាម្យ៉ាងទៀតថាបណ្ដាសូរ ទាំងនេះជាការផ្សំបុព្វបទឯកព្យាង្គជាមួយនិងព្យញ្ជនៈច្រមុះការផ្សំបែបយើងអាចហៅថា មូលបទនីយកម្មទ្វេព្យាង្គ ។

**១.១ - <u>បុព្វបទទម្រង់</u> [ព -] C- :**

បុព្វបទទម្រង់នេះគឺជាទម្រង់ដែលកើតឡើងដោយសារព្យញ្ជនៈដំបូងបង្អស់ ដោយយកទៅផ្សំជាមួយនឹងពាក្យឫស បង្កើតបានជាពាក្យកម្លាយឯកព្យាង្គ ។ តាមទម្រង់នេះឃើញថា មិនមានស្រៈកប់តួឡើយ នៅក្នុងក្រុមព្យញ្ជនៈដើមឡើយ ។

- បុព្វបទ **p- [ប៊-]** មានន័យថា "ធ្វើឱ្យ" ជាមូលបទសម្រាប់ផ្សំជាមួយពាក្យឫស ជាកិរិយាសព្ទបង្កើតហេតុកិរិយា ។ ហើយបុព្វបទ [p-] មានកលារូបសព្ទ (allomorphes) របស់វាដូចជា paṅ- [បង៊-] , pañ- [បញ៊-] , pan-[បន៊-] , paṃ- [បម៊-] pra-, [ប្រ-] ។ សូមបញ្ជាក់ ផងដែរថា បណ្ដាសូរដែលជាទ្វេព្យាង្គទាំងនេះយើងធ្វើការអធិប្បាយនៅផ្នែកខាងក្រោយ ។

ឧទាហរណ៍ :

| បុព្វបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|

[ប៊ -] + ចម៊ cam(ចាំ) > ប្ចម៊ pcam , កុ ប្ចម៊ ku pcam K.764.VII-VIII.A.D, l.3. ន.ន.ឥ ,នារីនាម ប្ចម ។

[ប៊ -] + តោយ៊ toy(ដោយ ដោយតាម) > ប្តោយ៊ ptoy , កុ ប្តោយ៊ ku ptoy K.755, VII.A.D,l.1. ន.ន.ឥ ,នារីឈ្មោះ ប្តោយ ។

---

[៤] ឡុង សៀម << ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យស័ព្ទតាមបម្រើបម្រាស់ផ្នត់នីយកម្ម នៅក្នុងភាសាខ្មែរបុរាណ>> នៅក្នុង : *ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា* ឆ្នាំទី៣ លេខ ៣ ទំព័រ ៨៩ ។

[ប -] + តោច toc(ដូច) > ប្តោច ptoc , ស្រេ អំវិ ត កុមារសំភុ មករ សុមិត្រា ត្វារ តេល គេ បាទមូល បញ្ជាហ្វ នុ ប្តោច អាជ្យសេស . sre aṃvi ta kumāraçaṃbhu makara sumitrā tvar tel ge pādamūla pañjāhv nu ptoc ājyaçeṣa K.726,VIII.A.D.l.13-4 ,ស្រែដែលបានទទួលពីកុមារសំភុ,មករ,សុមិត្រា ដោយព្រះតេជគុណប្តូរជាមួយនឹងប័រសម្រាប់ធ្វើពិធីសក្ការបូជា ។

- បុព្វបទ r- [រ -] :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[រ -] + លំ laṁ(ដួលរលំ) > រលំ rlaṃ, រលំ ស្រេ វ្នុរ rlaṃ sre vnur K.341N, 700. A.D.l.9, ដីរលំ(ដីបាក់) ស្រែទួល ។

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[រ -] + វង *vaṅ(វង់ មូល) > រហ្វង rhvaṅ , ត្រវង រហ្វង travaṅ rhvaṅ K.115, 665. A.D.l.17 , ត្រពាំងរហ្វង ( ត្រពាំងរាងមូល) ។

- បុព្វបទ [ ល -] l- :

| បុព្វបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[ ល -] + *vāṅ(វាំងព័ទ្ធ) > ល្វាង lvāṅ , អ្នក ល្វាង ᵃnak lvāṅ K.44B,674. A.D.l.5 , អ្នកស្នាក់នៅក្នុងដីវត្តអារាម ។

[ ល -] + * vāc(វាវក ) > ល្វាច lvāc , គេ ត ល្វាច...ge ta lvāc... K.341N. 700.A.D.l.10 , អ្នកដែលលួច... ។

**១.២ - <u>បុព្វបទទម្រង់</u> [ពស -] CV- :**

បុព្វបទដំបូងឯកព្យាង្គកាលណាយកទៅផ្សំជាមួយនឹងពាក្យឫសទាំងឡាយ បង្កើតពាក្យកម្លាយដែលមានខ្យល់ស្រៈនៅអាស្រ័យ ។ ហើយបុព្វបទទម្រង់នេះបើតាមទស្សនៈលោកបណ្ឌិត សាស្ត្រាចារ្យ ពុំ ម៉ល់ លោកបានហៅបុព្វបទបែបនេះថាជា "បរៈមូលបទ" ត្រូវសងពាក្យបារាំង ថា"para-affixe" គឺវត្ថុធាតុមួយបែបដែលជិតដូច/សិងដូចមូលបទដែរ គឺជាសូរខាងដើមរបស់ពាក្យខ្លះ ដែលគេទ្វេដើម្បីឱ្យបញ្ញត្តិ ឬ ន័យរបស់ពាក្យនោះមានន័យដដែល ផ្ទួនឡើង "[៥] ។

---

[៥] ពុំ ម៉ល់ : << លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យ ក្នុងភាសាខ្មែរ >> នៅក្នុង : *ទស្សនាវដ្តី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី២ លេខ២ ២០០១ ទំព័រ ៧១។

- **បុព្វបទ [ប-] p- :** យើងឃើញថាបុព្វបទ [ប-] នេះមិនត្រឹមតែបង្កើតកិរិយាហេតុប៉ុណ្ណោះទេ វាអាចបង្កើតនូវនាមផងដែរ កាលណាយកទៅផ្សំជាមួយនឹងពាក្យឫស ។

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ ប-] + អញ aññ(ខ្ញុំ) > បអញ pa-añ , តាង ចិ បអញ tāṅ ci pa-añ K.79,639. A.D.l.8 ,ន.ន.ប៉ុ , មន្ត្រី ចិ បអញ ។

[ ប-] + ឱច *oc(និយាយអ៊ូចៗ) > បឱច pa-oc , កុ បឱច ku pa-oc K.910,651. A.D.l.7 , ន.ន.ឥ , នារីឈ្មោះ បឱច ។

[ប-] + ឱន *on(តូច) > បឱន pa-on , វា កុមារទត ១ បឱន វា ១ vā kumāradat 1 pa-on vā 1 K.562,VII.A.D.l.16 , ន.ន.ប៉ុ , បុរសឈ្មោះ កុមារទត និងប្អូនប្រុសមួយ ។

- **បុព្វបទ [រ-] r- :**

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[រ-] + ងប *ṅap(ងប់ ងប់ងុល) > រងប raṅap , កុ រងប ku raṅap K.600E,611. A.D.l.7 ,ន.ន.ឥ , នារីនាមរងប ។

[រ-] + ជោង *joṅ(ជង់) > រជោង rajoṅ , ស្រេ ឮ រជោង sre ai rajoṅ K.155,VII-VIII.A.D.l.19 , ឋ.ន., ស្រែនៅឯតំបន់រជោង ។

- **បុព្វបទ [ល-] l- :**

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ល-] + ចក cak(រុក្ខជាតិ ចក) > លចក lacak ,កុ លចក ១ កោន កុ ៣ ku lacak 1 kon ku 3 K.557,611.A.D.l.2 ,ន.ន.ឥ ,នារីនាម លចក ព្រមទាំងកូនស្រីបីនាក់ ។

[ល-] + យា yā (ជីដូន យាយ) > លយា layā , កុ លយា ku layā , K.115,665. A.D.l.11 , ន.ន.ឥ ,នារីឈ្មោះ លយា ។

[ល-] + យេ ye (នារីចំណាស់) > លយេ laye , កុ លយេ ku laye K.66B,VII.A.D.l.14 , ន.ន.ឥ ,នារីនាម លយេ ។

- **បុព្វបទ [ ស -] s- :**

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ស-] + អប *ap(ស្អប់ មិនចូលចិត្ត) > សអប sa-ap , កុ សអប ku sa-ap anyāya K.74,697.A.D.l.5 , ន.ន.ឥ , នារីស្អប់ អយុត្តិធម៌ ។

[ស-] + ឧយ៎ *uy(ស្អុយ) > សឧយ៎ sa-uy , វ៉ា សឧយ៎ vā sa-uy K.557,611.A.D. l.5 , ន.ន.បុំ ,បុរសឈ្មោះ ស ឧយ ។

[ស-] + អុត *ot(អុត) > សអុត sa-ot , កុ សឧត ku sa-ot K.562,VII.A.D. l.7, ន.ន.ឥ ,នារីឈ្មោះ ស ឱត ។

**១.៣ - បុព្វបទទ្រច់ [ពស/ព -] CVC- :**

ជាបុព្វបទទ្វេព្យាង្គ បុព្វបទទាំងនេះកើតឡើងដោយការផ្សំរវាងព្យញ្ជនៈច្រមុះ ឬយើងអាចហៅម្យ៉ាងទៀតថា ជាបណ្ដាសូរ(កលារូបសព្ទ)របស់បុព្វបទដំបូង ដែលមានលក្ខណៈឯកព្យាង្គ ។ ហើយបុព្វបទទ្វេព្យាង្គផ្សំជាមួយពាក្យឫស បង្កើតពាក្យកម្លាយទ្វេព្យាង្គ ។

- **បុព្វបទ [បង-] paṅ- :** ជាបុព្វបទកើតឡើងដោយសារបុព្វបទ [ប-] ផ្សំជាមួយនឹងព្យញ្ជនៈខ្យល់ច្រមុះ [ង-]ឬអាចហៅម្យ៉ាងទៀតថាបុព្វបទ[បង-]នេះជាកលារូបសព្ទរបស់បុព្វបទ p- ដែលមានន័យថា "ធ្វើឱ្យ" ។

ឧទាហរណ៍ :

| បុព្វបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|
| [បង-] | + | កេត ket(កើត) | > | បង្កេត paṅket , វ៉ា បង្កេត vā paṅket K.133.VIII.A.D.l.2 , ន.ន.បុំ . បុរសឈ្មោះ បង្កេត ។ |
| [បង-] | + | តិង tiṅ(ដឹង) | > | បង្ទិង paṅtiṅ , pañ paṅtiṅ ti loḥ nu sre K.22,VII.A.D.l.24 , (ឈ្មោះ) បញ ប្រាប់ឱ្យដឹងថានឹងលោះដីស្រែ ។ |

- **បុព្វបទ [បញ-] pañ- :** ជាបុព្វបទកើតឡើងដោយសារបុព្វបទ [ប-] ផ្សំជាមួយនឹង ព្យញ្ជនៈច្រមុះ [ញ-] ឬជាកលារូបសព្ទរបស់[ប-] មានន័យថា "ធ្វើឱ្យ" ។

ឧទាហរណ៍ :

| បុព្វបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|
| [បញ-] | + | ជា jā (ជា) | > | បញ្ជា pañjā , កន្តៃ មន ឧយ ...យជមាន វ្រះ ត ជោន បញ្ជា ត... kantai man oy…yajamān vraḥ ta jon pañjā ta… K.138, 620.A.D.l.2-3 , នារីដែលប្រគល់ឱ្យអ្នកធ្វើពិធីសក្ការបូជាថ្វាយចំពោះអាទិទេព ដើម្បីឱ្យគេបានទៅជា... ។ |
| [បញ-] | + | ជាហ្វ jāhv(ជាវ ទិញ) | > | បញ្ជាហ្វ pañjāhv , គេ សន្មេ និ បញ្ជាហ្វ គិ ស្រែ ៜ តេំ ហ្វរ បរេង តេំ មហានវមីយ៎ ge sanme ni pañjāhv gi sre ai teṃ hvar pareṅ teṃ mahānavamīy K.726A,VIII.A.D.l.6,ពួកគេបានរួមគ្នាដើម្បីជាវយកស្រែនៅដើមវល្លិ៍ប្រេង និងនៅដើមមហានវមីយ ។ |

- **បុព្វបទ [សង-] saṅ- និង បុព្វបទ [សញ-] sañ- :** ជាបុព្វបទកើតឡើងដោយសារបុព្វបទ [ស-] ផ្សំជាមួយនឹង ព្យញ្ជនៈច្រមុះ [ង-, ញ-] ក៏ប៉ុន្តែបុព្វបទនេះមិនទាន់ឃើញប្រើប្រាស់ នៅឡើយទេ ។
- **បុព្វបទ [សន-] san- :** ជាបុព្វបទកើតឡើងដោយសារការផ្សំជាមួយនឹងបុព្វបទ [ស-] និងព្យញ្ជនៈខ្យល់ច្រមុះ [ន-] ។

ឧទាហរណ៍ :

| បុព្វបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|
| [សន-] | + | ទល dal(ទល់) | > | សន្ទល sandal , សន្ទល ប្រក ១ ត្នស ប្រណាល ២ sandal |

prak 1 tnas praṇāla2 K.877,VII-VIII.A.D.l.12 , ចន្ទល់ប្រាក់មួយស្រោមចង្វូរបង្ហូរទឹកមន្តពីរ ។

- **បុព្វបទ [សម-,សម់-] sam-, saṃ- :** ជាបុព្វបទកើតឡើងដោយសារការផ្សំជាមួយនឹងបុព្វបទឯកព្យាង្គ [ស-] និងព្យញ្ជនៈខ្យល់ច្រមុះ [ម-] ។

ឧទាហរណ៍ :

| បុព្វបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|
| [សម់-] | + | តោយ toy (ចុះចូល ទៅតាម) | > | សំតោយ saṃtoy , កុ សំតោយ ku saṃtoy |

K.657,VII.A.D.l.3 , ន.ន.ឥ , នារីនាម សំតោយ ។

| | | | | |
|---|---|---|---|---|
| [សម់-] | + | ពុះ puḥ (ពុះ) | > | សំពុះ saṃpuḥ , វា សំពុះ vā saṃpuḥ |

K.357,VII.A.D.l.18 , ន.ន.ប៉ុ , បុរសនាម សំពុះ ។

**១.៤. <u>បុព្វបទទម្រង់</u> [ពព/ស-] ccv- :**

ជាបុព្វបទដែលកើតឡើងដោយសារការរួមផ្សំរវាងព្យញ្ជនៈដើមនិងព្យញ្ជនៈខ្យល់រនាវ (liquide) (r) ដែលជាមូលបទប្រកបទៅដោយព្យញ្ជនៈ"រ" ។

- **បុព្វបទ [ប្រ-] pra- :**

បុព្វបទជាកលារូបសព្ទរបស់បុព្វបទ [ប-] ដែលមានន័យថា"ធ្វើឱ្យ" ហើយបុព្វបទ [ប្រ-] បើតាមទស្សនៈលោកបណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម លោកមានប្រសាសន៍ថា ជាមូលបទ ម្យ៉ាងដែលបង្កើតកិរិយាសព្ទ Réciproque ដែលជាប្រភេទកិរិយាសព្ទមានសកម្មភាពទៅវិញទៅមកដូចជា ប្រដាល់ ប្រឡែង ប្រជែង ជាដើម ។ តែនៅសម័យមុនអង្គរ ផ្នត់នេះពុំទាន់បំពេញតួនាទីជាផ្នត់ដែលបង្កើតកិរិយាសព្ទ Réciproque នៅឡើយទេ ។ ហើយមូលបទ [ប្រ-]នាសម័យមុនអង្គរនេះប្រើប្រាស់នៅមានកម្រិតនៅឡើយ ។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ប្រ-] + រុង ruṅ " ធំ ទូលាយ "[៦] > ប្រលុង praluṅ , ក្លស សំរិត្ត ប្រលុង klas saṃritt praluṅ K.788BVII-VIII.A.D.l.14 , ក្លស់សំរិទ្ធមួយធំ ។

[ប្រ-] + វេង veṅ ( វែង ) > ប្រហ្វេង prahveṅ, ឆន្ទ ប្រហ្វេង យោ១ chada prahveṅ yau 1 K.424B,VII.A.D.l.4 , សម្លៀកបំពាក់ឆន្ទៈប្រវែងមួយយោ ។

[ប-] + ហ្វេល hvel ( វិល វិលត្រឡប់)> ប្រហ្វេល prahel , កុ ប្រហ្វេល ku prahvel K.24,VI-VII.A.D.l.12 , ន.ន.ឥ , នារី( អ្នកបម្រើ) នាមប្រហ្វេល ។

- **បុព្វបទ [ម្រ-] mra- :** ជាបុព្វបទសម្រាប់បង្កើតនាមភ្នាក់ងារ នាមជីវចល និងជាពិសេស ជាធាតុសម្រាប់បង្កើតឋានន្តរនាម ដោយយកទៅផ្សំជាមួយនិង កិរិយាសព្ទ ។

ឧទាហរណ៍ :

បុព្វបទ ពាក្យឫស > ពាក្យក្លាយ

[ម្រ-] + តាង tāṅ ( តាង តែងតាំង) > ម្រតាង mratāṅ , ម្រតាង អន្តារ mratāṅ antār K.600E,611.A.D.l.1, ឋ.ន.ន , បព្វជិតជាន់ខ្ពស់ព្រះនាម អន្តារ ។

[ម្រ-] + សិរ sir ( ចារ សរសេរ) > ម្រសិរ mrasir , កុរាក កុរាក kurāk mrasir K.73,VII.A.D.l.14 , ចៅហ្វាយ( ជា) អ្នកសរសេរ ។

[ម្រ-] + សោយ *soy ( សោយ) > ម្រសោយ mrasoy , បិង ម្រសោយ piṅ mrasoy K.73,VII.A.D.l.7 , ឋ.ន. បឹង ម្រសោយ ។

## ២. <u>អន្តរបទ</u> :

ជាមូលបទម៉្យាងសំខាន់នៅក្នុងភាសាខ្មែរបុរាណសម្រាប់បង្កបង្កើតពាក្យថ្មី ហើយ បណ្តាអន្តរបទទាំងអស់ បើកាលណាប្រើប្រាស់ជាមួយកិរិយាសព្ទ ហើយ បណ្តាពាក្យកម្លាយអាចសំគាល់បានថា ជានាមភ្នាក់ងារ នាមឧបករណ៍ ឬក៏សំគាល់បានថាជាហេតុកិរិយា ជាដើម ។ អន្តរបទប្រភេទនេះបើតាមទស្សនៈលោក អៀវ កើស លោកប្រើពាក្យថា បទជ្រែក ។

### ២.១ - <u>អន្តរបទទម្រង់</u> [-ព-] -C- :

---

[៦] សូមមើល ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* ជ.ឯ.ម. ទំព័រ ៤២២ ។

ជាអន្តរបទឯកព្យាង្គដែលមានព្យញ្ជនៈដើមមួយ ទៅជ្រៀតចូលនៅកណ្តាលនៃពាក្យឫសទាំងឡាយ ដើម្បីបង្កើតពាក្យថ្មីមួយទៀត ហើយបណ្តាមូលបទទាំងនេះសំខាន់ៗរួមមាន :

[-ន-] -n- [-ប-] -p- , [-ម-] -m- ។

**- អន្តរបទ [-ន-] -n- :**

អន្តរបទ [-ន-] ជាអន្តរបទមួយសម្រាប់បង្កើតនាមឧបករណ៍។ ហើយអន្តរបទ [-ន-] មានកលា-រូបសព្ទរបស់វាដូចជា [-អន-] –an- ,[- អម់ / ន-] -aṃ/n- ។

ឧទាហរណ៍ :

អន្តរបទ ពាក្យឫស > ពាក្យក្លាយ

[-ន-] + កិបិ kip ( កឹប) > ក្និបិ knip , អ្នក វ្រះ ចស តេល ឱយ ក្និបិ ត វ្រះ កម្រតាង៑ ឧក្ក ªnak vraḥ cas tel oy knip ta vraḥ kamratāṅ ukk K.493,657.A.D.l.28, មនុស្សរបស់ ព្រះចាស់បានថ្វាយក្នឹបដល់អាទិទេព ។

[-ន-] + កោបិ kop ( ក្ដោប ក្រវាត់) > ក្នោបិ knop, ត្មោ បិ វ្នាក ត គុិ វ្នាក ក្នោបិ tmo pi vnāk ta gui vnāk knop K.21,VII.A.D.l.4 , , ត្បូងថ្មបីដុំដាំ នៅខ្សែក្រវាត់ ។

[-ន-] + ចំ caṃ ( ចាំ) > ច្នំ cnaṃ , ឧត្សវ ត ពោន ហ្វត ត គុិ ច្នំ ត មោយ្យ utsava ta pon hvat ta gui cnaṃ ta moyy K.90,VII.A.D.l.9 , , ពិធីបុណ្យបួន រៀងរាល់មួយឆ្នាំ ។ បើតាមរយៈឧទាហរណ៍នេះ ឃើញថា ពាក្យឆ្នាំក៏ជាឧបករណ៍មួយ សម្រាប់យើងរងចាំជារៀងរហូត ដូចសព្វថ្ងៃយើងមានពិធីបុណ្យចូលឆ្នាំរៀងរាល់មួយឆ្នាំម្តង ។

[-ន-] + បាង៑ pāṅ ( បិទបាំង) > ប្នាង៑ pnāṅ , កំ តិ រុះ ប្នាង៑ kaṃ ti ruḥ pnāṅ K.723,VII-VIII.A.D.l.5 , , ហាមរុះរើ ជញ្ជាំងខ័ណ្ឌ ។

[-ន-] + បង៑ paṅ ( បាំង គ្រប) > ប្នង៑ pnaṅ , ប្នង៑ បនាង៑ វសា បំនោស៑ pnaṅ panāṅ varṣā paṃnos K.155,VII-VIII.A.D.l.8 , ភួយដណ្តប់រដូវវស្សា សម្រាប់ បព្វជិត ។

[-ន-] + សាបិ sāp ( សាប សាបព្រោះ) > ស្នាបិ snāp , ស្រេ រ្លោង៑ ស្នាបិ ត្លោង ១០ ,src rloṅ snāp tloṅ 10 K.689A,VII-VIII.A.D.l.16 , ស្រែថ្នាលសំណាប ទំហំ១០ត្លោង ។

**- អន្តរបទ [-ប-] -p- :**

ជាអន្តរបទសម្រាប់បង្កើតពាក្យថ្មីក្លាយពីកិរិយាសព្ទទៅជានាមសព្ទ និងដើម្បីបង្កើតហេតុកិរិយា ដោយយកពាក្យឫសផ្សំជាមួយអន្តរបទរបស់[-ប-]នេះ ហើយអន្តរបទ[-ប-]មានកលារូបសព្ទ "-អន ប-,-

anp- , -អម ប-,-amp-"[៧] ។ សូមបញ្ជាក់ផងដែរថាអន្តរបទ [-ប-] នាសម័យមុនអង្គរ ក៏អាចបង្កើតនាមភ្នាក់ងារបានដូចជាអន្តរបទ [-ម-] ផងដែរ ។

ឧទាហរណ៏ :

| អន្តរបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|

[-ប-] + សិត sit (ចាក់ទឹក សិតទឹក) > ស្បិត spit , អំបល អំនោយ ស្បិត ទិក ត វ្រះ ampal amnoy spit dik ta vraḥ K.137,VII.A.D.l.3 , តង្វាយទាំងអស់ចំពោះអាទិទេពមានការប្រោះព្រំទឹក ។

[-ប-] + តញ tañ (ត្បាញ) > ត្បញ tpañ "ជាងតម្បាញ"[៨] , វា ត្បញ vā tpañ K.138,620.A.D.l.22, ន.ន.បុំ , បុរសនាម ត្បញ ។

**- អន្តរបទ [-ម-] -m- :**

អន្តរបទ[-m-]ជាមូលបទសម្រាប់បង្កើតនាមភ្នាក់ងារ ដោយយកទៅផ្សំជាមួយកិរិយាសព្ទ ហើយយើងក៏អាចចាត់ទុកថាជាមូលបទមានលក្ខណៈរូបសព្ទតា ដែលយើងអាចសំគាល់បានថា ពាក្យនេះជានាមសព្ទពាក្យនោះជាកិរិយាសព្ទជាដើម ។ ហើយមូលបទនេះវាមានលក្ខណៈប្រាកដនិយម កាលបើយកទៅផ្សំជាមួយកិរិយាសព្ទ ពាក្យក្លាយទាំងអស់សុទ្ធតែសំគាល់នាមភ្នាក់ងារ ។

ឧទាហរណ៏ :

| អន្តរបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|

[-ម-] + តាញ tāñ (ត្បាញ) > ត្មាញ tmāñ , ត្មាញ ចន្លេក tmāñ canlek K.956,VII,A.D.l.2 , អ្នកត្បាញសម្លៀកបំពាក់ ។

[-ម-] + តិរ tir (ដើរ) > ត្មិរ tmir , ត្មិរ ស្លិក tmir slik K.137, VII. A.D.l.15 , អ្នកដើរស្លឹក ។

[-ម-] + តិង tiṅ (ដេញ , ប្រគំភ្លេង) > ត្មិង tmiṅ , ចម្រេង ១១ ត្មីង វិណ កញ្ចង លាហ្វ camreṅ 11 tmiṅ viṇa kañjaṅ lāhv 4 K.600E,611.A.D.l.1 , អ្នកចម្រៀង១១នាក់ អ្នកដេញពិណ កញ្ចងលាហ្វ ៤នាក់ ។

---

[៧] ឡុង សៀម <<ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យស័ព្ទតាមបច្រើបម្រាស់ផ្ទត់នីយកម្មនៅក្នុងភាសាខ្មែរបុរាណ>> ដ.ឯ.ម.ទំព័រ ៩៨ ។

[៨] ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* ដ.ឯ.ម. ទំព័រ ២៩៦ ។

[-ម-] + សាង sāṅ (សាង ,សាងសង់) > ស្មាង smāṅ , គេ ស្មាង ប្លេ ជ្នង សោំ ទោង ច្មំ ទិក្ក ទោង ច្មំ ស្ញក្ក ge smāṅ ple jnaṅ soṃ doṅ cmaṃ dikk doṅ cmaṃ sñakk. K.939, VII.A.D.l.8 , អ្នកសាងសង់ប្លេ ជ្នង បានសុំ ឆ្នាំទឹក និងឆ្នាំស្ទឹក ។

[-ម-] + សោន son (សូនរូប) > ស្មោន smon , ស្មោន វ ត អង smon va ta aṅ K.137,VII.A.D.l.21 , អ្នកស្មូន (អ្នកធ្វើឆ្នាំង) ឈ្មោះ តអង ។

**២.២ - <u>អន្តរបទទម្រង់</u> [-សព-] -vc- :**

អន្តរបទទម្រង់នេះកើតឡើងដោយសារបន្សំរវាង ស្រះ+ព្យញ្ជនៈឬជាកលារូបសព្ទរបស់អន្តរបទ -n-,-m- ។ អន្តរបទទម្រង់នេះមាន : [-អម់-]-am- , [-អំម់-] -ôm-, [-អន-] -an- ។

**- អន្តរបទ [-អម់-] -aṃ- :**

អន្តរបទ [-អម់-] ជាកលារូបសព្ទរបស់ [-m-] នៅសម័យមុនអង្គរអន្តរបទនេះ សម្រាប់បង្កើតនាមរូបិយ៍ នាមជីវចល នាមភ្នាក់ងារ កាលណាយកទៅផ្សំជាមួយនឹងពាក្យឫស និងជាពិសេសយកអន្តរបទនេះ យកទៅធ្វើវិធីកម្លាយសម្រាប់ដាក់ឈ្មោះ មនុស្ស វត្ថុ និងទីកន្លែង ថែមទៀត ។

ឧទាហរណ៍ :

| អន្តរបទ | | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|---|

[-អម់-] + ត្វេ tve (ធ្វើ) > តំវេ taṃve , ក្ញុំ តំវេ ស្រែ kñuṃ taṃve sre K.155B,VII-VIII.A.D.l.20 , អ្នកបម្រើជាអ្នកធ្វើស្រែ ។

[-អម់-] + ប្រេ pre (ប្រើ) > បំរេ paṃre , វ បំរេ ក្រលា វ្រះ va paṃre kralā vraḥ K.600E,611.A.D.l.2 , អ្នកបម្រើនៅក្នុងព្រះវិហារ ។

[-អម់-] + ច្រេង creṅ (ច្រៀង) > ចំរេង caṃreṅ , រមំ ៧ ចំរេង ១១ amaṃ 7 caṃreṅ 11 K.600E,611.A.D.l.1 , នាដការិនី៧នាក់ អ្នកចម្រៀង១១នាក់ ។

[-អម់-] + ក្រង kraṅ (ក្រង) > កំរង kaṃraṅ , កុ កំរង ku kaṃraṅ K.480, VII.A.D.l.17 , ន.ន.ត . នារីឈ្មោះ កំរង ។

[-អម់-] + ច្រេន *cren (ច្រើន) > ចំរេន caṃren , សត្រ ចំរេន ត គិ ថ្ងៃ វ្រះ satra caṃren ta gi tṅai vraḥ K.451,680.A.D.l.10 ,សំណែនត្រូវបានធ្វើរាល់ថ្ងៃសីល ។

**- អន្តរបទ [-អំម់-] –ôṃ- :**

អន្តរបទ [-អំម់-] ក៏ជាកលារូបសព្ទរបស់ [-ម-] ដែរ ។ ហើយអន្តរបទនេះ វាអាចបង្កើតនាមឧបករណ៍ផងដែរ ដោយការផ្សំជាមួយនិងពាក្យឫស ។

ឧទាហរណ៍ :

អន្តរបទ ពាក្យឫស > ពាក្យក្លាយ

[-អំម់-] + រលោង raloṅ (ចំណិតដី) > រំលោង ramloṅ , បាក រំលោង pāk ramloṅ K.1,VII-VIII. A.D.l.20 , ចំណិតដីបាក់ ។

[-អំម់-] + វ្រាហ vrah (សាប ព្រោះ) > វំរាហ vamrah , ស្រេ មា វំរាហ គុិ sre mā vamrah gui 20 K.926,624.A.D.l.10 , ស្រែមាន២០ មាវំរហ (វំរហ ជាឈ្មោះរង្វាស់) ។

**- អន្តរបទ [-អន-] -an- :**

ជាកលារូបសព្ទរបស់ [-ន-] ហើយអន្តរបទនេះសម្រាប់ផ្សំជាមួយពាក្យ ឫសបង្កើតនាមសព្ទដែរ ។

ឧទាហរណ៍ :

អន្តរបទ ពាក្យឫស > ពាក្យក្លាយ

[-អន-] + តំ tam (ដាំ) > អន្តម antam , តោង ស្លា ឈេ អន្តម toṅ slā jhe antam K.54,629.A.D.l.17 , ដូង ស្លា ឈើ ដំណាំ ។

[-អន-] + លេ *le (លើ ខាងលើ) > អន្លេ anle, មោយ អន្លេ moy anle K.590B, VIII.A.D.l.7 , កន្លែងមួយ ។

[-អន-] + សំ sam (ផ្សំ បង្រួម) > អន្សំ ansam , កុ អន្សំ ku ansam K.910,651.A.D.l.8 , ន.ន.ឥ . នារីអ្នកបម្រើឈ្មោះ អន្សំ ។

**២.៣ – <u>អន្តរបទទម្រង់</u> [-សព / ព-] -vc/c- :**

អន្តរបទទម្រង់នេះកើតឡើងដោយសារការផ្សំរវាង ស្រះ + ព្យញ្ជនៈ + ព្យញ្ជនៈ អន្តរបទទម្រង់នេះ ក៏ជាកលារូបសព្ទរបស់អន្តរបទ [-ម-] ផងដែរ ។ ពាក្យមួយចំនួនធំត្រូវបានបុព្វបុរសបង្កើតឡើង ដោយប្រើមូលបទនេះ និងជាពិសេសអន្តរបទនេះជាជំនួយក្នុងការបង្កើតទម្រង់ប្រយោគកត្តុវាចកៈ ។

ហើយទម្រង់នេះសំខាន់រួមមាន :

**- អន្តរបទ [-អម់ / ន-] -am /n- :**

ឧទាហរណ៍ :

អន្តរបទ ពាក្យឫស > ពាក្យក្លាយ

[-អម់ / ន-] + ចៀ cya (ស៊ី ឆី) > ចំន្យ camṇya , ស្រែ វ្នុរ ចំន្យ ថ្មុរ ស្តុក បិង ផោង sre vnur camṇya thmur stuk piṅ phoṅ K.341N, 700.A.D.l.9 , ស្រែ ទួល វាលស្មៅ គោ ព្រមទាំងបឹងផង ។

[-អម់ / ន-] + ចោំ coṃ (បិទបាំង) > ចំនោម camṇo(m) , វ្រៃ វ្នុរ ចំនោម ត្មុរ vrai vnur camṇo(m) tmur K.44B,674.A.D.l.2 , ព្រៃ ទួល ក្រោលគោ ។

[-អម់ / ន-] + បោស pos (បួស សាងផ្នួស) > បំនោស pamṇos , បំនោស ត បោស ត គិ នោះ វ្នំ pamṇos ta pos ta gi noḥ vnaṃ K.44B,674.A.D.l.9 , បព្វជិតដែលបានបួសនៅក្នុងភ្នំ (វិហារ) នោះ ។

[-អម់ / ន-] + ឪយ oy (ឱ្យ) > អំនោយ amṇoy , ក្ញុំ វ្រះ មនីស្វរ អំនោយ អាចាយ៌្យ កន្ទិន kñuṃ vraḥ manīçvara amṇoy ācāryya kandinK.600E,611.A.D.l.9 , អ្នកបម្រើអាទិទេព មណីស្វរៈបានឱ្យដោយអាចារ្យកន្ទិន ។

**- អន្តរបទ [-អិម់ / ន -] :**

ឧទាហរណ៍ :

| អន្តរបទ | ពាក្យឫស | > | ពាក្យក្លាយ |
|---|---|---|---|

[-អិម់ / ន-] + ជាហ្វ jāhv (ជាវ ទិញ) > ជំនាហ្វ jamṇāhv , គិ ស្រែ ជំនាហ្វ ផោង gi sre jamṇāhv phoṅ K.18,726.A.D.l.30 , ស្រែដែលបានទិញផងទាំងឡាយ ។

[-អិម់ / ន-] + ជោន jon (ជូន ឱ្យ ថ្វាយ) > ជំនោន jamṇon , ក្ញុំ អាការ តវ្រះកម្រតាងអញ kñuṃ ākāra ta vraḥ kamratāṅ añ K.561,681.A.D.l.36, អ្នកបម្រើ ដែលបានថ្វាយទុកជាពន្ធអាករ ចំពោះអាទិទេព ។

[-អិម់ / ន-] + ទុញ duñ (ទិញ) > ទំនុញ damṇuñ , ស្រែ ត្នៃ កេត ត្រវង បោញ ភាគយុង ទំនុញ ត បោញ ភទ្រវិសេស sre tṅai ket travaṅ poñ bhāgayuṅ damṇuñ ta poñ bhadraviçeṣa K.22,VII.A.D.l.32, ស្រែខាងកើតត្រពាំងបោញ ភាគយុង ត្រូវបានទិញពី បោញភទ្រវិសេស ។

## គន្ថនិទ្ទេស

- កេង វ៉ាន់សាក់: *មូលភាពនៃការបង្កើតពាក្យថ្មី* ភ្នំពេញ រោងពុម្ពទេព ១៩៦៤ ។
- ក្រសួងអប់រំ: *វេយ្យាករណ៍ថ្នាក់ទី៥* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ ។
- ក្រសួងអប់រំ: *វេយ្យាករណ៍ថ្នាក់ទី៦* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨២ ។
- ក្រសួងអប់រំ: *វេយ្យាករណ៍ថ្នាក់ទី៧* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ ។
- ក្រសួងអប់រំ: *វេយ្យាករណ៍ថ្នាក់ទី៨* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៦ ។
- ពុទ្ធសាសនបណ្ឌិត : ***វចនានុក្រមខ្មែរ*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ ។
- ព្រុំ ម៉ល់: << លទ្ធភាពបង្កើតពាក្យ និងការបង្កើតពាក្យក្នុងភាសាខ្មែរ >> នៅក្នុង : *ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* លេខ២ ឆ្នាំទី២ ២០០១ ។
- ឡុង សៀម: << វាក្យស័ព្ទសំស្រ្កឹតដំបូងក្នុងភាសាខ្មែរបុរាណ និងស្ថាននាម មានប្រភពចេញពីសំស្ក្រឹត >> នៅក្នុង : *ទស្សនាវដ្ដីកម្ពុជសុរិយា* លេខ១ ឆ្នាំទី៥០ ១៩៩៦ ។
- ឡុង សៀម: << ទំរង់វេយ្យាករណ៍នៃនរនាម( ឯកសារសិលាចារឹកកម្ពុជា) នៅក្នុង : *ទស្សនាវដ្ដីកម្ពុជសុរិយា* លេខ២ ឆ្នាំទី៥០ ១៩៩៧ ។
- ឡុង សៀម: *ស្ថាននាមវិទ្យាខ្មែរ* ភ្នំពេញ ពុទ្ធសាសនបណ្ឌិត ១៩៩៧ ។
- ឡុង សៀម: *បញ្ហាវចនស័ព្ទវិទ្យា* ភ្នំពេញ ១៩៩៩ ។
- ឡុង សៀម: *វចនានុក្រមខ្មែរបុរាណ* ភ្នំពេញ បោះពុម្ពដោយរោងពុម្ពភ្នំពេញ ២០០០ ។

## មាតិកាអត្ថបទ

**ការប្រើប្រាស់មូលបទ** ............ ទំព័រ៥១
ក្រុមទី១ : មូលបទមិនពេញលេញ ............ ---៥១
១- បុព្វបទមិនពេញលេញទម្រង់ [ព-] ............ ---៥១
២- បុព្វបទមិនពេញលេញទម្រង់ [ពស-] ............ ---៥៣
៣- បុព្វបទមិនពេញលេញទម្រង់ [ពស/ព-] ............ ---៥៥
៤- បុព្វបទមិនពេញលេញទម្រង់ [ពព/ស-] ............ ---៥៩
ក្រុមទី២ : មូលបទ ............ ---៦០
១- បុព្វបទ ............ ---៦០
១.១- បុព្វបទទម្រង់ [ព-] ............ ---៦១
១.២- បុព្វបទទម្រង់ [ពស-] ............ ---៦២
១.៣- បុព្វបទទម្រង់ [ពស/ព-] ............ ---៦៤
១.៤- បុព្វបទទម្រង់ [ពព/ស-] ............ ---៦៦
២- អន្តរបទ ............ ---៦៧
២.១- អន្តរបទទម្រង់ [-ព-] ............ ---៦៧
២.២- អន្តរបទទម្រង់ [-សព-] ............ ---៦៩
២.៣- អន្តរបទទម្រង់ [-សព/ព-] ............ ---៧១
**គន្ថនិទ្ទេស** ............ ---៧៣

## សម្ភាសន៍អក្សរសាស្ត្រ សម្ដេចសង្ឃរាជ ជួន ណាត

ដកស្រង់ និង អត្ថាធិប្បាយបន្ថែម ដោយ បណ្ឌិត ផែល ថោង

សេចក្ដីណាមួយដែលវិទ្យុផ្សាយដំណឹងដោយឡែក បើនិយាយទៅ ប្រែថា ដោយឡែក ហើយ សេចក្ដីនោះមិនមែនជាសាធារណៈ គឺវាមានដោយឡែក វាប្លែកមកគេថា ដំណឹងពិសេស រួចនាងម៉េចក៏ខឹងនឹងពិសេសហ្នឹង ។ ពិសេសហ្នឹងមិនមែនសម្រាប់តែសម្ដេចព្រះប្រមុខរដ្ឋទេ ប្រើបានជាសាធារណៈទៅទាំងអស់។ យើងក៏ប្រើបានរបស់អីតែវាប្លែក ដែលគេមិនសូវយកមកនិយាយមកថា អាហ្នឹងជាពិសេស អញ្ចេះណា! ។ ដូចជាល្មមស្ដាប់បានហើយ មើលអាត្មាថាម៉េច មានកត់ទុកទេ... ។

នែ ! អានេះពិសេសមួយទៀតអញ្ចោះ អាហ្នឹងគេប្រើវិសេសដែរ គឺមនុស្សបើតាមបាលីនោះគេថា ការុណា ការុណាំ មញ្ញត្តិ ជានាតីតិ មនុស្សោ ។ បានជាហៅថា មនុស្សហ្នឹង ប្រែថា សត្វ សត្តវិសោ ឬ វិសេសសត្តោ ពីព្រោះយកបទដទៃមកផ្សំទៅប្រែថាម៉េច មនុស្សនោះ ? មនុស្សមកអំពី មន ( ម៉ាន់) ឬ មន ថាទៅចុះ គេប្រែថា ដឹងហើយផ្សំនឹងឧស ( អុស-សៈ) ឧស Suffixe ឧសបច្ច័យ មន និង ឧសទៅជាមនុស្ស Manuss សរសេរអក្សរ នែ! រ៉ូម៉ាំងទៅឃើញហើយ ។ មើល៍ៗ លោក ឡូត មកសរសេរបន្តិច សរសេរទៅ man ហើយនឹងឧសៗពីរទេមិនមែនអញ្ចឹងទេ plus + ជើងក្អែក អើអញ្ចឹង ហើយឧសនោះ សពីរ អេសពីរ អើ man + uss ចុះ uss មកពីអី ? uss នេះ Suffixe បច្ច័យសំរាប់ចុះមកឱ្យទៅជានាមសព្ទ ពីព្រោះ ម៉ាន់ ប្រែថា ដឹង ដល់ទៅបំបែក Verbe ទៅជា មនតិ = គេដឹង មនន្តិ = គេទាំងឡាយដឹង វាអញ្ចឹងទៅវិញ អាហ្នឹងបំបែក Verbe ដូចជា Je suis , Tu es អញ្ចឹង ដូចជា បារាំងអញ្ចឹង ។ ចុះឥឡូវ បើឱ្យមកជានាម មកនឹងពាក្យនេះ ជាផ្សំឧស ឧសបច្ច័យទៅជាយ៉ាងម៉េច ទៅជា manuss ប្រែថា អ្នកដឹងនូវការខុសត្រូវ ដឹងនូវហេតុខុសនិងត្រូវ ។ ចុះបើយើងយកពាក្យ នោះមកនិយាយថាស្អី អ្នកដឹងខុស និង ត្រូវថាសត្វពិសេស ។ គេហៅសត្វវិសេស ពីព្រោះថាសត្វ ទាំងអស់គ្នា ជាសត្វតែទាំងអស់គ្នា គោក៏សត្វ ក្របីក៏សត្វ មនុស្សយើងក៏សត្វ ព្រហ្មទេព្ដាអីក៏សត្វ ពីព្រោះសត្តៈ នេះ ប្រែថា អ្នកជាប់ជំពាក់ដោយអារម្មណ៍ ដោយគំនិតហ្នឹង គេហៅសត្ត ប្រែថាមនុស្សដែលនៅជំពាក់ទាក់ទិននឹងការខុសត្រូវ ការអាក្រក់ ការល្អសព្វគ្រប់ហ្នឹង គេហៅថាសត្វ ។

ចុះមនុស្សនេះជាអ្វី ? ថាសត្វដែរ ប៉ុន្តែសត្វនោះ សត្វវិសេស ។ ម៉េចហៅសត្វវិសេស ? ថាសត្វដែលទីទៃ ពី គោ ក្របី អាហ្នឹង បើយើងនិយាយឱ្យជ្រៅទៅ គេនិយាយអញ្ចឹង ។ សត្វពិសេសជាអ្នកដឹងខុសត្រូវ អាហ្នឹងហៅមនុស្ស ។ ចុះបើមនុស្សស្រីទៅជាមនុស្សី ប៉ុន្តែយើងមិនដែលប្រើមនុស្សីទេ ប៉ុន្តែបើបាលីគេមាន មនុស្សោ សត្វវិសេសប្រុស មនុស្សប្រុស មនុស្សី មនុស្សស្រី ។

តែបើឥឡូវ យើងយកអាហ្នឹងមកប្រែថា នែ! ឃើញមានមនុស្សម្នាក់ដើរទៅឯជើងទេ ? នោះវាមិនដែលចេះសោះ តែមនុស្សស្រី មនុស្សប្រុស ។ ប៉ុន្តែត្រូវជ្រាបថា មនុស្សហ្នឹងមកពីប្រែថា អ្នកដឹងខុសត្រូវ ។

មួយទៀត មានន័យមួយទៀតក្រៅពីព្រះពុទ្ធសាសនា មកពី (មនុហើយនឹងអបច្ចះ) ។ អបច្ចប្រែថា កូនចៅ ថាពូជពង្ស ។ មនុស្សគឺព្រះចៅមនុ ដែលជាសេចក្តីកើតដំបូងបំផុត គេហៅថា បឋមក្សត្រនោះ ដែលកើតមានទឹកមានដីនៅអឹឥណ្ឌានោះទេ មិនមែននៅស្រុកខ្មែរយើងទេ ប្រទេសកម្ពុជាកាលនោះនៅជាសមុទ្រទេ ។ រួចស្តេចនោះហើយដែលជាដំបូងបំផុត បានគេហៅថា ក្សត្រិយៈ ហៅតាមសំស្ក្រិតថា ក្សត្រិយៈ ។ ហៅតាមបាលីថា ខត្តិយ ប្រែមកថាម៉េច ? ជាម្ចាស់ស្រែមេស្រែ ពីព្រោះដើមដំបូងមានប្រយោជន៏អី គ្រាន់តែត្រួតត្រាលើចំការអញ្ចឹង មួយឆ្នាំៗគេជូន គេថ្វាយស្រូវអង្ករអីមកលោកចេះតែទទួលសោយសេចក្តីសុខទៅ ។

ព្រះចៅដែលនៅដំបូងបំផុតនោះ ទ្រង់ព្រះនាមព្រះបាទមនុ មានក្មួយឈ្មោះមនោសារៈ ។ មនោសារៈនេះជាគ្រូច្បាប់ ។ ឯកឧត្តមមិនជ្រាបទេច្បាប់បុរាណ គេមានទមស្សការគោរពមនោសារៈហ្នឹង ។ ហ្នឹងគឺជាក្មួយរបស់ព្រះចៅមនុ បានជាពួកកើតតៗគ្នាមកហៅថាមនុស្ស ។ម៉េចក៏ហៅមនុស្ស?ថាជាពូជពង្សរបស់ព្រះចៅមនុ ។

អាបែបនេះមួយ បើនិយាយក្រៅពីរបៀបព្រះពុទ្ធសាសនា តាមពង្សាវតាលោក ។ នែ!នេះអាត្មាធៀបដោយខ្សែកផ្សេងៗទេនិយាយពីវិសេសហ្នឹង គេហៅសត្វវិសេសហ្នឹង ជាពិសេស ដោយពិសេស ។ ឧបមាថា គេនិយាយអញ្ចឹងទៅក្នុងជំនុំចំណោម ដូចសម្តេច អ៊ីវ៉ាន់ លោកស្តេចទៅ ខេត្តក្រៅ ទៅអញ្ចឹងទៅ មានលោកចៅហ្វាយខែត្រ មានលោកបាលដ្ឋ ស្រុកភូឈួយអី ឬមេឃុំអីជាដើម ។ រួចគេសង់សាលារៀនស្អីអញ្ចឹងទៅ ព្រះអង្គលោកទៅសម្ពោធប្រទានកាត់ខ្សែបូរអញ្ចឹងទៅ ។ ប៉ុន្តែក្នុងបណ្តាមនុស្សទាំងអស់ ដែលមកជួបជុំនឹង តើដែលធ្វើការហ្នឹងអ្នកណាដែលចេញប្រាក់កាសច្រើនជាងគេអ្នកណាដែលយក ចិត្តទុកដាក់ជាងគេ ។ គេនិយាយ អញ្ចឹង ដូចសម្តេចលោកថា សម្តេចឪ មានព្រះទ័យរីករាយ ត្រេកអរណាស់... នឹងអស់កូនចៅដែលបានកសាង នែ! សាលារៀនធំជុំនេះ ល្អស្អាត ថ្កុំថ្កើងនេះ សុំអរគុណទាំងអស់គ្នា ដែលបានជួយពូតដៃគ្នាធ្វើនេះ ជាពិសេស អរគុណចំពោះលោកចៅហ្វាយខែត្រ ។

លោកចៅហ្វាយខេត្តនោះ គេធំជាងណា៎ គេផ្តើមការហ្នឹង ហ្នឹងជាពិសេស ។ រួចនាងកញ្ញាប្រកាន់ថា សម្រាប់តែស្តេចព្រះមុខរដ្ឋ សម្តេចក៏ប្រើបាន យើងនោះក៏ប្រើបាន ។ ដូចយើងទៅឯណាៗ បុណ្យទានអីឬ យើងទៅជាភ្ញៀវពន្លឺគេ យើងនិយាយថា ខ្ញុំសូមអរគុណបងប្អូនទាំងអស់គ្នា ជាពិសេស គឺមីងម៉ៅ ។ មីងម៉ៅ គាត់ចាត់ការ ហ្នឹង គឺគាត់ទ្បើយហត់ជាងគេណាស់ អញ្ចឹងក៏យើងនិយាយបានគឺថាដោយខ្សែក ។ Spécialiste ប្រហែលជាស្តាប់បានហើយ នាងកញ្ញា ប៉ុណ្ណឹងហើយអាត្មាសូមដោះស្រាយ នាងកុំឆ្ងល់នឹងពិសេសហើយវិសេស អេ!នាងនេះនិយាយ...ណាស់...អាត្មាមិនមើលទេ ថាតែឮវិទ្យុថា ដំណើងវិសេស ចង់

តែមិនសួរចង់ស្តាប់ខឹងណាស់ម៉េចក៏ប្រញាប់អញ្ចឹង កុំខឹងអី ។ ខំរៀនទៅ ទេឯងចង់ចំអន់នាងហ្នឹងបន្តិច ។ ទេ! មើលទៅក្រញើតក្រញ៉ាំង ថប់តែដល់មានផ្ទះសម្បែងទៅ ថប់តែឈ្លោះនឹងប្តីទេអញ ។ ដូចជាបែបមុតមាំណាស់ សូមទោស ទៅចុះ នាងឯងកុំខឹងអាត្មា ។ ដោះស្រាយរួចហើយ និយាយឱ្យសើចទៅ អស់ប៉ុណ្ណឹងហើយ ។

អូ! អាត្មាឮសួរវិទ្យុ សុំទោសដល់អ្នកអានវិទ្យុ ពីថ្ងៃ១៤ ខែកក្កដានេះ នៅម៉ោង២១កន្លះ អានមិនដឹងជាត្រង់រឿងអ្វីទេ ឮ វិញ្ញនៈ វិញ្ញនា...។ ប៉ុន្តែ គេបដិសេធ ( នី) ដាក់ឱ្យទៅ គេថា តែប្រវិញ្ញនី (ប្រវ៉ាញ់) ការប្រវិញ្ញនី ។ រួចទៅអានឮថា វិញ្ញនា ( វ៉ាញ់-ចាក់-នា) វិញ្ញនា ចុះលោកអ្នកអានម្តេចក៏មិនគិត ក៏ចេះតែរអិលមាត់ ។ មិនពិបាកសោះ អក្សរ “ ច ” នៅពីលើ “ ន ” ពាក្យតែមួយម៉ាត់ ។ បើ “ ច ” ដាក់ជើង “ ្ច ” គេអាន “ ច្ន ច្នា ” ចុះម៉េចទៅជា ( វ៉ាញ់-ចាក់-នា ) ទៅវិញក៏មិនថា “ វិញ្ញណា ” ប្រវិញ្ញនា ដូចមិថុនាអញ្ចឹង ។ មិថុនា អាត្មាឮ ន់! កាលសមាជលោកបាត់ដំបង ហើយលោកសៀមរាប សំដីសំដៅក៏សព្វព្រះរាជហឫទ័យណាស់ ប៉ុន្តែវ៉ាទាស់ នឹងអានខែ “ មិថុ-នា” ។

យេ!លោកនេះគ្មានស្តាប់គេសោះ គេអាន “ មិថុ -ណា១ ” អាហ្នឹងមិនចាំបាច់អ្នកណាបង្គាប់ទេ មិថុហើយនិង “ ន ” វ៉ាភ្ជាប់គ្នា “ ថ ” ដាក់ជើង “ ថ្ន ” គេថា “ ថ្នង ” គេថា “ ថ្នាំ ” គេថាថ្នាំ គេមិនថា ធងឯណា ។ ចុះម៉េចក៏ទៅជា (មិថុ-នា) ទៅវិញ ។ បន្តិចលោកថា ចុះបើ ន នា មិនឱ្យគេថា “ នា ”យ៉ាងម៉េច ? អញ្ចឹងមានតែ (ព្រះពុទ្ធសាស-នា) ទៀតហើយ ។ អាហ្នឹង “ ន” ដែរ (ព្រះពុទ្ធសាសនា) (ក្រសួងឃោស-នា-ការ ) អើ វ៉ាសនា នោះក៏វ៉ា “ ន” អញ្ចឹងដែរ ម៉េចមិនហៅ ( វ៉ាស-នា ) ទៅ ។ អក្សរខ្មែរនោះវ៉ាមានគោលរបស់គេ ពាក្យតូច ពាក្យធំ សម្លេងក៏មិនខុសគ្នាដែរ ។ ទេ! អស់លោកណាចង់សួរអីបន្តិច ។

លោកអីនេះ! លោក រ៉ូ លោកអីនេះ ទើប ទើបនឹងបានសេចក្តីជាពីរ បីយ៉ាង សូមអាត្មាជំរាបមកពីភ្លេចទេ រៀនរួចហើយ ។ កាលណាបើបច្ចុប្បន្នជិត អតីតកាល ជិតអឌិត គេថា ទើប ។ ឧបមាថា នែ! លោកមា អញ្ជើញមកយូរហើយអ្វី ? ថាទេខ្ញុំទើបនឹង មកដល់អំបាញមិញហ្នឹងឯង ! ។ បើយើងនិយាយតាមពាក្យសាមញ្ញថា ខ្ញុំទើបនឹងមកអំបាញមិញនេះហ្នឹង ។ បើគេសួរថា គាត់មកយូរហើយ ? ថាគាត់ ទើបនឹងមកអំបាញមិញហ្នឹង មុនអ្នកមកប៉ុណ្ណឹង ។ គឺអានេះគេហៅថាបច្ចុប្បន្ន វ៉ាទៅជិតខាងអតីតកាលដែលកន្លងទៅហើយ ។ អានេះ ទើបស្តាប់បានទេ ? តែមិនដាក់អាហ្នឹងមក ដឹងថាម៉េច? ហ្នដឹងថាគាត់មកពីអង្កាល់? គឺ គាត់និយាយថារួចហើយ ក៏ប៉ុន្តែយូរនេះ មិនមែនយូរទេ ទើបថ្មីនេះ! អាហ្នឹងទើប អញ្ចឹងហៅថាបច្ចុប្បន្នជិតអតីតកាល ។បច្ចុប្បន្នកាលជិតអតីតកាលនេះសម្រាប់តែចំពោះកិរិយាសព្ទទេ ។ ប៉ុន្តែមានទៀតអាត្មានិយាយពីរ ទើបនឹងឱ្យអស់បានជាលោកសួរអញ្ចឹងទៅហើយ ។ ទើបមួយទៀត ជាពាក្យកិរិយានុគ្រោះពាក្យនេះ គឺថា ពាក្យនេះខានប្រើមិនបានទេ ។ ដូចជានិយាយថា... ជជែកគ្នាទៅមួយថា ឱ្យតវ៉ាន់មកខ្ញុំមុន

ទៅនែ! ចាំថ្ងៃស្អែកស៊ីមយកប្រាក់មកជូន ។ ថាទេ ! មិនកើតទេ ខ្ញុំតែរវល់អញ្ចឹងហ្នឹង វាសាន់វ៉ាន់វររអស់ហើយអ្នកនេះក៏ជំពាក់...អ្នកនោះក៏ជឿហេតុហ្នឹងខ្ញុំមិនព្រមទេ ទោះបីអ្នកឯងនៅឆ្ងាយនោះផងទាល់តែឱ្យប្រាក់មកខ្ញុំទើបបានខ្ញុំឱ្យអីវ៉ាន់ខ្ញុំទៅ ។ ទិញសំពត់ទើបខ្ញុំឱ្យសំពត់ទៅ ។ អាហ្នឹងទើបបាននេះឯង គេនិយាយក្លាយមកពីភាសាសាមញ្ញថា ទៈបានអាហ្នឹង វចនានុក្រមមិនបានប្រើ...អង្កាល់គេធ្វើនោះវាខ្វះ ។ គឺគេអានថា ទៈ បាន គេសរសេរ ទ ចុចពីរទៅ បើចង់ឱ្យច្បាស់ ប បា និង ន ទៅគេថា ទៈបាន។ បើលុះតែវាស្រុះគ្នា ធ្វើការហ្នឹងគ្នាន ដូចជាវាស្រុសដៃគំនិតគ្នាស្រោកឡើងទៅ ទៈ បាន ការនោះវាហើយ ស្រេច ទៈបានការនេះវាឆាប់ហើយ ។

គេមិនថា បានទទេទេ ។ គេថា ទៈ បាន នោះគឺទើបបាន អានេះទើបនឹង ទៅលើកិរិយាសព្ទ័ គេហៅថាបច្ចុប្បន្នជិតអនាគត ។ ទូលបង្គំយល់ហើយអញ្ចឹង ប៉ុន្តែថា...ទេឥឡូវនេះ អាត្មាបានជានិយាយ ត្រង់ហ្នឹងផង សព្វថ្ងៃនេះ គេមិននិយាយអញ្ចឹងច្រើនណាស់ គេថា...បើ...ទេ...ធ្វើការជិតដល់ម៉ោងទៅហើយ នែ! ទាល់តែ យើងស្រុះគ្នា ទៅជួយគ្នា ជួយចាប់មួយដៃមួយជើងម្នាក់... បានការហ្នឹងបានហើយ ។

វាបាត់អា ទើបនឹង ទៅ វាបាត់អា ទៈ បាន នឹងទៅ ។ វាទៅជា បាន បាន តែម្តងទៅ លុះតែឱ្យលុះតែឱ្យឥវ៉ាន់មកខ្ញុំ បានខ្ញុំឱ្យប្រាក់ទៅអ្នក បានខ្ញុំឱ្យវាបាត់អាទើបនឹងទៅវាបាត់អាទៈបាន នឹងទៅ ។ នឹងតោងតែយល់ បើមិនអញ្ចឹងដឹងថា ប្រយោគនោះ ថាម៉េច ។ អាហ្នឹងគឺ ទើបបាន តែដល់ចង់ប្រញាប់គេថាទៈ បានវាដូចជាពាក្យ បារាំង ពាក្យអីអញ្ចឹង គួរតែធៀបទៅ ណាឯកឧត្តម ។ C'est -à -dire គេថា សែតាដៀគេមិនថា សែអាដៀ ឯណា គេនិយាយឱ្យវារហ័ស ។ Tou ce là / tu:sela /... សូមក្រាបទូលសួរដូចជាមួយទៀត ដូចជាភាសាខ្មែរសោះហើយនឹងជាប់ថាសំស្ក្រិតអីខ្លះ ចុះដូចជាពាក្យថា "ក្រុមមឿង"១នេះ ។ ទេអានេះ...ពាក្យនេះវាមួយកំណាត់យើងមួយទៀតមួយកំណាត់សំស្ក្រិត ហើយមួយកំណាត់ទៀតជាភាសាជិតខាងយូរហើយ ។ គេមិនដែលអានក្រុមមឿងទទេទេ កាលនោះអាត្មារំលឹកមកវិទ្យុច្រើនដង ប៉ុន្តែ គេមិនព្រមស្តាប់អាត្មាទេអ្នកខ្លះស្តាប់ លោកខ្លះគេមិនស្តាប់ ។ គេមិនដែលអាន ក្រុមមឿង គេមិនដែលអានហ្នឹងគឺសុទ្ធតែ " មៈ មៈ" អញ្ចឹងដូចជា " ក្រុម-មៈ-លួង " ក្រុម-មៈ-ឃុន ក្រុម-មៈ-ព្រះ ក្រុម-មៈមឿង ។ គេមិនដែលអាន ក្រុមឃុន ក្រុមព្រះ ដូចជា សម្តេចក្រុមព្រះអញ្ចឹងទេ ។

គេអាន សម្តេច ក្រុម-មៈ-ព្រះ អ្នកណាទៅអាន សម្តេចក្រុមព្រះម៉េច .?

១ក្រុមមៈមឿង៖ គេនិយាយតាំងពីកាលណាមក អ្នកណាក៏គេនិយាយ ក្រុមមឿង ដែរ ។ ពីដើមគេមិនថា ក្រុងទេ មិនថាចៅហ្វាយក្រុងទេ គេមិនថារាជការក្រុងទេ គេថា រាជការក្រុម មៈ មឿងនោះ ជាពាក្យ លាវ សៀម គេថា ស្រុក ។ រួចក្រុមនោះមកពី ពាក្យសំស្ក្រិត គេថា ( ក្រុមៈ) ប្រែថា ពួកថាលំដាប់

ថា របៀប យល់ហើយនៅ ? គោងអានថា ( ក្រុម-មៈ-មឿង ) មិនមែនអាន ក្រុមមឿងនោះ គេស្រែក គេសើចណាស់ ។ ក្រោយៗកុំនិយាយអញ្ចឹង បើនិយាយអញ្ចឹងហ្នឹង នែ! ហ្នឹងដូចជាលោកមួយអង្គ អាត្មាឮ សម្ដេចក្រុមព្រះ តែមិនគួរតំណាលទេ ព្រោះសម្ដេច ក៏ព្រះអង្គសោយទីវង្គតទៅហើយ ។

លោកតំណាលប្រាប់អាត្មាថា មានលោកមួយអង្គ ទេសនាទៅព្រះតំណាក់ រួចអានថា " នាមរូបរូប-ធមិ នាមធមិ " រួចដល់ទីបញ្ចប់ សម្ដេចលោកថា នែ! ព្រះករុណាទេសនាគ្រាន់បើហើយ តែដល់ចាស់ដៃចាស់ជើងទៅ ប៉ុន្តែនៅអានឆ្គងណាស់ នែ! គេមិនហៅ ( រូបធមិ្ម នាមធមិ ) អញ្ចឹងទៅ ។ គេថា រូប បៈ ធមិ , មិនថា រូបធមិម៉េច ? បើ "ប" គ្មានជើង ។ បានសម្ដេចថា យី ! ឯងថាជួយ បើអញ្ចឹង ថា...មានមនុស្សម្នាក់ទៅដល់ជួបគ្នា សួរថា មកពីណា ? ថាមកពី " រាជវាំង មកដល់ប្រទះ រាជបុត្រនៅជិតនឹងសាលា រួចណា " ។

សាលារចនា គាត់ថា សាលារចនាទៅព្រោះ " ច " គ្មានជើង ។ ឯពាក្យ រាជកិច្ច រាជប្រកាស រាជក្រម លោកគ្រូនោះអង្គុយស្ងៀម ។ សម្ដេចមានព្រះបន្ទូលថា ខ្ញុំកូណាអត់មិនបាន លោកអីក៏ចចេសអីក៏ចចេសប្រ៉េះ ឯងថាឱ្យលោកចេះ លោកមិនចេះ លោកតវ៉ាថា គ្មានជើង ។ ឥឡូវអាចារ្យឯង តវ៉ាថា " ម " គ្មានជើង អាត្មាទាល់ហើយ ។ ចាំជើងអី បើបាលីហ្នឹងវាអញ្ចឹង ។ រួចគេអាន ព្រះ ប រមៈ -រាជ-ជៈ-វាំង មាន ជើងឯណា បើទៅអាន ព្រះ អាម៉េច...ព្រះបរម រាជ វាំង តែម្ដង វាមិនអស់សំដី ។

គេអានបរម រាជវាំង គេអាន បរមបរពិត្រ គេអានថា បរមចេស្ដា បរមសព ។ នេះ "ម " មានជើងឯណា ? អត់! អាហ្នឹងគេហៅ...គេហៅអី ? យើង បាលីគេហៅ " វាចាសុវិទ្ធកៈ" គេហៅថា សម្រួលមាត់ឱ្យស្រណុកថា ឱ្យស្រណុកស្ដាប់ ។ បើយើងថាក្រុម មឿង អញ្ចឹង ទៅក៏បាន តែក្រុមមឿង វាទៅជាក្រុមហ្នឹង ម៉ាពួកហ្នឹងទៅឯណាទៅ ពួកនោះនៅឯណាទៅ មាន...រួចមឿងនោះដោយខ្លួនទៅ ។

ឯក្រុមមឿង គេបានសេចក្ដីទៅថា ជាកិច្ចការ ក្នុងក្រុងទាំងមូល ។ គេនិយាយពីដើមទេ មិនមែនយើងបង្កើតថ្មីទេ ពាក្យនេះ ។ រួចដល់អ្នកមើលហ្នឹងមិនទាន់ឮ ទៅនិយាយ អានក្រុមមឿង ចុះមកដល់ក្រុមព្រះសម្ដេចក្រមព្រះថា មៈដែរម៉េចក៏មិនថាក្រមព្រះ ? ហ្នឹងហើយមកពីគិតវាតិច ។ ម៉េចឆ្ងល់នោះលែងហើយនៅ ? នែ! ដូចជាមិញនោះ និយាយពីពតិមាននោះ តាមពិតទៅ គេអាន ពតិម៉ាន នោះបានវាត្រូវ ប៉ុន្តែដល់ឥឡូវ បើ ចាស់ទុំយើងអានពតិមាននោះមកជោគជាក់មកហើយ ! យើងទៅកែ ពតិម៉ាន នោះយ៉ាងម៉េច ?វាគោងតែអនុលោមទៅតាមអញ្ចឹង! ឯតាមពិតនោះវា ពិតម៉ាន៖ ព័រ-តៈ-ម៉ាន) វា ( ប៉ាត់-តិ-ញ៉ាន) វាមិនមែន ប៉ាត់ តៈ ញាន ទេ ។

ប៉ុន្តែ បើហៅវាខុសមកហើយ ធ្វើម៉េច ? អាហ្នឹង យើងទៅ ជាពាក្យហ្នឹងហៅ គេហៅអី ? គេហៅថា " អញ្ញត្រសព្ទ " ទៅហើយឥឡូវ ។ ដូចជាជាតិដទៃ គេដេញជើងយើង គេថា ចុះអក្សរ ឥ នៅលើ ម

ម៉េចក៏ មិនថា តៈ ម៉ាន ? ម៉េចក៏មិនថា ពតិមាន ទៅវិញ ? ថាទេ ត ម៉ាន នោះត្រូវហើយ កុំដោះស្រាយទៀត កុំឈ្លោះនឹងគេ ។ តែប៉ុណ្ណឹង ទេអ្វី ! ថាទេអ្វី ! អន្តរៈ ( អន់-តៈ-រ៉ាក់) កុំអាន (អាន់ -តៈ-រ៉ាក់ ) នោះអក្សរ ត វានៅពីលើ គោង ត ដល់ ត គ្រវាត់នឹង រ គេថា ត្រា គេមិនថា ទ្រ ទេ ។ អន្តរជាតិកុំថា អន្តរាក់ នោះ គេថា អា សា វ៉ៈ ។ គេថា ព្រះ អរិ យៈ សា វៈ ។ រួចទៅនិយាយ សាវក សាអីនេះនោះវាធំៗណាស់ ។ ឯគ្រយ ឯគ្រម គ្រលគោ គ្រលក្របីអីនេះ ។ ក្រោយមិនថា ក្រោយទេ ថាគ្រយ ចាំគ្រយៗទៅ ។ គេអានអន្តរៈ អន្តរ ពាក្យបាលី សំស្ក្រឹត គេថា អន្តោ រ ប្រែថាចន្លោះ ប្រែថា ចន្លោះ ថារវាង ។ អានេះគឺ...វាដូចជា entre អញ្ចឹងដែរ ។ អាំងទែរ (inter) អន្តរ entre ប្រហែលជាបារាំង យកពីឡាតាំងមកទេ ក៏មិនដឹង ។ អន្តរ នេះប្រែជា រវាង ប្រែជា ចន្លោះ ប្រែថា ចម្ងាយក៏បាន ។

ចុះអន្តរជាតិនោះ បានសេចក្តីថាម៉េច ? ថាជាតិដទៃពីគ្នា ។ អន្តរ ហ្នឹង ទៅជាដទៃ ប៉ុន្តែវាភ្ជាប់គ្នា វាមានចន្លោះនែ! ឧបមា ថាដូចជា យើង ប្រទេសកម្ពុជា វាមានព្រំដែនត្រឹមនោះៗ រួចវាទៅប៉ះគ្នានឹង ញយៗទៅ ទៅទង្គិចគ្នា វាចន្លោះៗអញ្ចឹង...បានជាគេហៅ អន្តរជាតិ អន្តរទ្វីប អន្តរកាល ។ ដល់ទៅ អន្តរធាន មកពី អន្តរៈ ថា ជាចន្លោះ ឬប្រែថា អីទៅ ។

អាហ្នឹងវាទៅជាអីទៅ ទៅជា Prefix ហើយរួច ធាន ហ្នឹងមកអំពី " ធា" រា ចិន "ធា" កិរិយា ដើមឡើយថា " ធា " ប្រែថា ទ្រទ្រង់ ថាកាន់ដល់ទៅចុះ យុ បច្ច័យ ចុះបច្ច័យ អនៈ ទៅ វាទៅជាធាន (ធា-ណៈ) ទៅជានាមសព្ទ ប្រែថា ទ្រទ្រង់ ប្រែថា នៅ ។ ដល់អន្តរ និង ធានៈ ថាបាត់ទៅវិញ ពីព្រោះ អំណាច អន្តរ វាទៅសង្កត់ពីលើ ទាញអាដែង ធានៈ ដែលប្រែថាទ្រទ្រង់ ថាថិតនៅ ឱ្យថាបាត់ទៅវិញ ថា ខូចវិញ ។ ដូចជាថា ទេវបុត្រ ហ្នឹងបានចុះមកបានគាល់ព្រះទូលសួរអញ្ចេះមួយៗ (តថេវន្តថាយិ តថេវន្តរ ធាយី សុ បើគ្នាវាច្រើន ។ ថាបាត់ទៅក្នុងទីនោះ ត្រង់ទីនោះ បើថា តថ ឯវ អន្តរ ធាយិ គឺវាបាត់ទៅ ស្រាប់ តែមើលមិនឃើញទៅនឹងខ្មែរហៅ អន្តរធាននោះ គឺវាបាត់ទៅ... វាខូចទៅ រួចអន្តរ មកដោយជើងម៉េចនឹង កើតសព្ទនឹងប្រែមិនចេះចប់ គេហៅ Prefix គេហៅបុព្វបទ ។

ឱ ! អន្តរ បើឃើញតែឯង ទៅជានាម យើងប្រែថា ចន្លោះ ប្រែថា រវាង ។ អន្តរទ្វីប អន្តរជាតិ អន្តរអន្តរប្រទេស ហៅបានទាំងអស់ ។ តែយើងហៅ អន្តប្រទេស អន្ត ទ្វីប វាមិនសម ប៉ុន្តែបុរាណ អន្តរធាន ហ្នឹង គេអានថា អន់ ដ ធាន ហ្ន! អញ្ចឹង ។ បាត់ឯ រ ទៅ អា អន់ ដ ធាន ។ រួចហើយ អីវ៉ាន់ គាត់ខឹងចៅគាត់ កូនគាត់ គាត់ជេរមិនឱ្យធ្ងន់ គាត់ថា... អាគ្នាចំណាំតែឮ នែ! អាឯង រាងអញវ៉ៃ ឥឡូវ អា អន់ ដ មិនដល់ ធាន ទេ ។ គាត់ខូច តែដល់ ធាន វាដាក់បណ្តាសា ចៅ គាត់ ។ គាត់ថា អាអន់ ដ ។ អន្តរធាន ប្រែថា បាត់ថាខូចវិនាស ។ ម៉េចអាចារ្យឆ្ងល់ម៉េចទៀត ។អត់ទេអេ!...អស់ឆ្ងល់...យេ! បន្តទៅនេះ មានការសាកសួរក្រៅបន្តិចទៀត អំពីអន្តរជាតិ និង ពាក្យអន្តរធាន ហើយហាក់ដូចជា មានបាត់សេចក្តី

ខ្ទះ៧) អក្សរហាក់ដូច ជាដូចគ្នា អន្តរជាតិ ដូចជាជាតិ៧ អន្តរធាន វិញ អត់... មិនមែនទេ ពីព្រោះ អន្តរ ហើយនឹងធានៈ នោះវាផ្សំ គ្នា នេះ អន្តរ ហើយនិងជាតិ ។

លោក កែ ប៊ាន ឃុំខ្សា ស្រុកបាកាន ជាស្មីលោក ជាកសិករ...។ អើ យើងមើលតែម្ដង លោក កែប៊ាន នេះសួរដល់ណាហើយ...។ នារាត្រីថ្ងៃមួយ ទូលព្រះបង្គំបានចាប់ផ្ដើមបើក សៀវភៅរបស់ក្មេងរៀន មួយដែលមានចំណងជើងថា មូលវិជ្ជាខេមរភាសា សម្រាប់មធ្យមថ្នាក់ឆ្នាំទី២ និង ឧត្តមដ្ឋាន ភាគ២ ដើម្បីអានកំសាន្តកែអផ្សុក ។ អផ្សុកនេះ ដាក់ខុសទេ ដាក់ អ ប មានជើង ្ស ហើយសុខនៅមុខ ។ អផ្សុក មកពី អ ផា សុ ភៈ ។ ឥឡូវ គេនិយាយដែរ គឺថាវាសប្បាយគ្មានឈឺ គ្មានចាប់អី គេហៅ ផា សុ ភៈ ។ យើងអាន ផាសុក សុក ហ្នឹងគ្មាន ខ ពីមុខទេ ។ គេដាក់ អក្សរ ក ទេ ។ រួចដល់មាន អ អៈ នៅពីលើ វាបដិសេធទៅ ផាសុកៈ ផាសុក ហ្នឹងប្រែថាស្រួល សប្បាយខ្លួនប្រាណ មិនមានជំងឺ តំកាត់អ្វី គេហៅ ផាសុកៈ ។

តែយើងថា ផាសុក ។ រួចដល់ អៈ ផា សុកៈ ហ្នឹងគឺថាវាមិនស្រួល វាតប់ប្រមល់ វាចេះតែក្រេស ក្រួស អីចេះចុះ គេហៅ អផាសុក ដល់និយាយក្លាយៗទៅជាអផាសុកគឺ អផាសុកៈ ទេ គេមិនមែនដាក់អប្ប សុខ នោះទៅជាប្រែថា មានសុខតិចទៅវិញក៏សមរម្យដែរ តែវាមិនត្រូវនឹងបាលីហ្នឹងទេ ។ ឯ លោកសរសេរ នេះ លោកថា អប្បសុខ បានសេចក្ដីទៅថា សុខបន្តិចបន្តួច ។ ឯពាក្យថា អផ្សុកនេះ គឺវាចេះតែក្រេសក្រួស មិនសុខមិនសាប់នោះ ហៅថា អផ្សុក ។ ហើយប្រទះឃើញនូវអត្ថបទមួយ និយាយ អំពីលិង្គរបស់វចនៈ ទំព័រ ៣៣៥ ត្រង់វគ្គដែលនិយាយពីសម្មតិលិង្គ សម្មត្តិលិង្គ គឺជាលិង្គដែលសន្មតខុស ទំនងអំពីកំណើត ។ល ។

តាមបញ្ញត្តិនៃក្បួនហោរា នាមរបស់ស្រុក ភូមិ នគរ ខេត្ត វត្ត និង វត្ថុ ជាគ្រឿងប្រដាប់ល្បែង ដូចជា អង្គញ់ អង្គញ់ទៅដាក់អង្គុញ នែ! ចេះតែច្រឡំខ្មែរយើង ។ ដូចជាវត្តថ្វាយដង្គំ ជាវត្តស្វាយដង្គុំ មកពីរាប់គុំ គាំ គាំ គះ ហ្នឹងហើយដែលអាត្មានិយាយពីមុន ។ រួចដល់រាប់ គុំ គំ គាំ គះ ហ្នឹង ដាក់អក្សរ ម្ដុំហ្នឹងមិនត្រូវ ទេ គំ ជា គុំ ជា គំ ហើយនេះគេហៅថា អង្គញ់...អ ង ជើង គ ក្រោម ញ ប្រកបសង្កត់ ពីលើមក ទៅជាអានថា អង្គញ់ មិនមែន អង្គុញ ទេ ។ មេប្រមឹក មេអាប៉ោង ជា អត្ថិលិង្គ ។ ទូលបង្គំ រកគិតមិនយល់ សោះ ដែលក្បួនហោរាបញ្ញតយ៉ាងហ្នឹង មិនដឹងជាបានអ្វីជាគ្រឿងសំគាល់ ថាជាសម្មត្តិលិង្គ ។

( ចប់ខ្សែអាត់ទី១ )

## សិក្សាអត្ថបទទី៣ ខ្មែរអាត់ទី១

-បញ្ហាដែលលើកយកមកពិចារណា ក្នុងពេលនេះគឺមាន :

-បញ្ហាទី១-ប្រវត្តិស្តេច មនុ និង ក្បួនច្បាប់របស់ស្តេច មនុ

-បញ្ហាទី២-ការប្រើ ណ ន ក្នុងពាក្យ ឃោសនា

-បញ្ហាទី៣-ការប្រើពាក្យ ទើបបាន (ទៈបាន)

-បញ្ហាទី៤-ការប្រើពាក្យ ក្រម ( ក្រំ ) និង ( ក្រុម )

បញ្ហាទី១ -ប្រវត្តិស្តេច មនុ [១]

ពាក្យថា ម័ន ថា មនុ មានរឹសគល់ជាមួយគ្នាជាភាសាឥណ្ឌូអឺរ៉ុប ។ ភាសាអង់គ្លេសថា man men ដែលប្រែថាមនុស្សប្រុសនេះ គឺមានរឹសគល់តែមួយជាមួយគ្នានឹងភាសាសំស្ក្រឹតដែរ (Little,1973,p.1068) ស្តេច មនុ គឺជាអ្នកចាត់ចែងក្បួនខ្នាតពិធីការបូជាយញ្ញ និង វិធីការសាសនាក្នុងព្រហ្មញ្ញសាសនា ( Monier-Williams, 1999.p.784 ) ។ " ស្តេច មានុ ត្រូវបានគេទទួលស្គាល់ថា ជាអ្នកបង្កើតនូវសណ្តាប់ធ្នាប់ និង សីលធមិសង្គម ជាមេដឹកនាំរបស់មនុស្សនិងជាឫស្សី ដែលបានទទួលនូវចំណេះវិជ្ជាសក្តិសិទ្ធ ព្រមទាំងជាអ្នកដែលបង្កើតនូវពិធីបូជាយញ្ញ និង ជាអ្នកនិពន្ធនូវច្បាប់ផ្សេងៗផង " ( Max Muller, 1964,p. LVIII ) ។

តើក្នុងគម្ពីរស្តេចមនុ មានចែងពីអ្វីខ្លះ ? ប្រវត្តិគម្ពីរស្តេចមានុ នេះ មានរឿងរ៉ាវជាច្រើនដែលធ្វើឱ្យអ្នកស្រាវជ្រាវមានយោបល់ផ្សេងៗគ្នា ស្តីពីប្រភពនិង ពេលវេលានៃការចាប់ផ្តើមគម្ពីរនេះ ។ គម្ពីរនេះជាក្បួនខ្នាតផង ជាច្បាប់ផង ។ ជាក្បួន គឺទាក់ទងដល់សាសនាពិធីផ្សេងៗក្នុងព្រហ្មញ្ញសាសនា និង ក្បួននៃជីវភាពជាព្រាហ្មណ៍ប្រុសស្រី ដូចជាច្បាប់ប្រុសសម្រាប់ព្រាហ្មណ៍ជាប្តី និង ច្បាប់ស្រី សម្រាប់ព្រាហ្មណ៍ជាប្រពន្ធ ជាដើម ។

ជាច្បាប់គឺ មានច្បាប់រដ្ឋបវេណី និង ច្បាប់ស្តីអំពីឧក្រិដ្ឋកម្ម ។ ក្រៅពីនេះ មានអត្ថាធិប្បាយអំពីការកកើតឡើងនៃពិភពលោកក្នុងកាលជាដំបូង ។

បញ្ហាទី២ -ការប្រើ ណ ន ក្នុងពាក្យ ឃោសនា

ក្នុងរវាង ៥០ ឆ្នាំប៉ុណ្ណោះ មានការប្រែប្រួលសំណេរ ពី វាស្នា ទៅជា វាសនា សាស្នា ទៅជាសាសនា ឃោស្នា ទៅជា ឃោសនា ។ ក្នុងទីនេះ ខ្ញុំសិក្សាប្រវត្តិរបស់ពាក្យ ឃោសនា ដើម្បីបង្ហាញពីការវិវត្តន៍របស់វា ដែលទាក់ទងទៅនឹងការប្រើប្រាស់តួអក្សរ ណ និង ន ផងដែរ ដោយលើកយកសំណេរពីសិលាចារឹកមួយមកបង្ហាញ ។ ពាក្យថា ឃោបណា ( ឃោសនា ) តូវបានរកឃើញក្នុងភាសាខ្មែរបុរាណ

---

[១] វចនានុក្រមខ្មែរ ទំ. ៨៥២ ។

ដែលមានប្រើនៅក្នុងអត្ថបទអក្សរថៃ សិលាចារឹកឈ្មោះព្រះគុហាហ្លួង K44 ។ គេចារនាឆ្នាំ ៦៧៤ គ.ស ។[២] សិលាចារឹកនេះ គេរកឃើញនៅខែត្រកំពត ។ យើងពិនិត្យមើលភាសាថៃម្តងចំពោះពាក្យដដែលនេះ โฆษณา ( Haas, 1964,p.102 ) វចនានុក្រមដទៃទៀត ក៏គេប្រើតែសំណេរមួយនេះដែរ ។ ថ្វីបើថៃមានតួអក្សរ น ( ន ) ក៏ដោយ ។ តួ ណ ណ គឺសម្រាប់តែពាក្យខ្ចីពីបាលី ឬ សំស្ក្រឹត ។ ភាសាថៃពុំមានធ្វើថៃយានកម្មភាសាសំស្ក្រឹតបាលីដល់កម្រិតមួយ ដូចខេមរយានកម្មទេ គឺភាគច្រើន គេអនុវត្តត្រឹមតែក្បួនរក្សាជាតិសព្ទតែប៉ុណ្ណោះ ។ ថៃយានកម្មបានប្រព្រឹត្តទៅចំពោះសំណេរពាក្យខ្មែរ ដែលគេបានខ្ចីយកទៅប្រើប្រាស់ ។

កត្តានេះជាទិដ្ឋភាពមួយដែលអាចឱ្យយើងដឹងពី ឈ្មោះទីតាំង ទឹកដីភូមិសាស្ត្រខ្មែរ ដែលថៃកាន់កាប់ ។ យើងគួរចាប់អារម្មណ៍ ទៅលើពាក្យថៃនេះដែលប្រើអក្សរ ៥ តួនេះ ៃប ។ យើងអាចសន្និដ្ឋានថាថៃដែលចេះភាសាខ្មែរយ៉ាងជ្រៅជ្រះ ឬ អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរដែលបានជួយរចនាតួអក្សរថៃនេះ ។ ក្នុងកាលដំបូងនោះ គឺបានសិក្សាតួអក្សរខ្មែរដោយកែច្នៃរូបរាងឱ្យងាយស្រួល ប្រហែលជាអ្នកភាសាវិទូខ្មែរសម័យនោះបានជួបប្រទះនឹងបញ្ហាសំណេរខ្មែររួចទៅហើយ ។

ໄ នេះជាសញ្ញាស្រៈ ដែលមានសូរសម្លេងប្រហែលនឹងស្រៈ ូ និង ៃ-ា ខ្មែរ ។ គេកែច្នៃដោយទំលាក់សញ្ញាស្រៈ ា ចោល និងធ្វើដោយធ្វើសញ្ញាស្រៈ ៃ ខ្មែរឱ្យខ្ពស់ ហើយជាតំណាងស្រៈ ( អិ ឬ អោ ) ໂ (មហាស៊ីរី ១៩៧ ? ទំ.ខ )[3] ฆនេះជាព្យញ្ជនៈ ដែលមានសម្លេងនិងរូបរាងប្រហែលនឹងព្យញ្ជនៈ ឃ របស់ខ្មែរ ។

គេកែច្នៃដោយកាត់ចោលពាក់កណ្តាលហើយបំបាត់សក់ ។ រួចតម្លើងគួចមូល ធ្វើជាបញ្ចុចប្រមទាំងគួចគុថខាងឆ្វេងផង ។ ษ នេះជាសញ្ញាព្យញ្ជនៈ ដែលមានរូបរាងប្រហែលនឹងព្យញ្ជនៈ ប (ស ប ) របស់ខ្មែរ ។

គេកែច្នៃដោយកាត់ចោលតែសក់របស់វាតែប៉ុណ្ណោះ អ្វីដទៃទៀត គឺនៅស្ទើរតែទាំងអស់ ។ ณ នេះជាស ញ្ញាព្យញ្ជនៈដែលមានសម្លេងនិងរូបរាង ប្រហែលនឹងព្យញ្ជនៈ ណ របស់ខ្មែរ ។ គេកែច្នៃដោយកាត់ចោលតែផ្នែកខាងចុង រួចបន្ថែមគួចខាងស្តាំនិងបញ្ចុចខាងឆ្វេងនៃព្យញ្ជនៈណ របស់ខ្មែរតែប៉ុណ្ណោះ ។ អ្វីៗដទៃទៀតគឺនៅទាំងអស់ ។ ថៃយានកម្មតួអក្សរជាស្រៈនិងព្យញ្ជនៈខ្មែរផង ហើយថែមទាំងខ្ចីទាំងស្រុងផង ។

---

[២] Coedes , Vol. 2

[៣] លោក មហាស៊ីរី ក្នុងទំព័រដដែល បានបញ្ជាក់ថា ថៃគេមិននិយមប្រើសញ្ញាស្រៈពេញតួទាំងនេះទេ ฤ ฤๅ ฦ ฦๅ (ឫ ឬ ឭ ឮ) ចលនាចង់កែប្រែសំណេរទៅជា រី រឺ លី លឺ ក៏កើតមានរវាងសម័យជាមួយគ្នាក្នុងគំនិតដូចគ្នាដែរ ក្នុងសតវត្សទី ៦០ ។ ឧទាហរណ៍ ថៃនៅពេលមុនយល់ខុសថា ពាក្យចារឹក ជាពាក្យខ្ចីពីបាលីសំស្ក្រឹត គេសរសេររក្សាជាតិសព្ទ ล า ฤ ก តែក្រោយមកដឹងថា ពាក្យនេះខ្ចីពីខ្មែរ គេក៏ដូរសំណេរទៅតាមខ្មែរវិញ ล าฤ ก ។

អក្សរ ប និង ណ នេះជាតួយ៉ាងរបស់ឥទ្ធិពលខ្មែរទៅលើភាសាថៃ ហើយប្រហែលជារចនាដោយថ្វីដៃខ្មែរទៀត ។ ពាក្យខ្មែរបុរាណមួយម៉ាត់នេះ (ឃោសនា សរសេរជាអក្សរថ្ម)មានន័យទំនាក់ទំនងបំភ្លឺប្រវត្តិសាស្ត្រអក្សរសាស្ត្រខ្មែរ-ថៃបានមួយជ្រុងតូច ។

គួរកត់សំគាល់ថា រហូតមកដល់ឆ្នាំ ១៨៨០ គេពុំឃើញមានពាក្យថា ឃោសណា នេះទេក្នុងវចនានុក្រមភាសាថៃ ។ ថៃនៅប្រើ គ ប រហូតមកដល់ពេលនេះ ប៉ុន្តែគេមិនទទួលយកការបន្លឺសម្លេងតាមបែបភាសាសំស្ក្រឹតទេ ។ ឥឡូវនេះ យើងនាំគ្នាពិចារណាអំពីបញ្ហា ណ ន ខ្មែរតែម្តង ។ ការប៉ុនប៉ងធ្វើខេមរនីយកម្មភាសាសំស្ក្រឹតនៅសតវត្សទី៨ តាមផ្ទាំងសិលាចារឹកខាងលើនេះ ជាតឹកតាងមួយរបស់ភាសាខ្មែរនៅសម័យនោះដែលបានគិតទៅដល់សំណេររក្សាជាតិសព្ទ ។ សូមប្រៀបធៀបសំណេរពាក្យ ឃោបណា[៤] សិលាចារឹក K44 និងសំណេរបច្ចុប្បន្ន ។ យើងសួរថា ហេតុអ្វីបានជាដូនតាយើង បានបង្កើតតួអក្សរ ន ណ ។ កាលបើយើងប្រៀបធៀបពាក្យ ឃោប្ណា និង ឃោសនា យើងនឹងឃើញនិន្នាការដែលជាក្បួនរក្សាជាតិសព្ទ និង ក្បួនសំណេរភាសាខ្មែរសុទ្ធ ។

ភាសាថៃមានប្រើអក្សរ ន ណ ឈ น ដែរ តែគេពុំមានបញ្ហា ន ណ ដូចខ្មែរទេ ។ អាស្រ័យដោយហេតុថា គេគោរពក្បួនសំណេរ រក្សាជាតិសព្ទយ៉ាងខ្ជាប់ខ្ជួន ដូចជាពាក្យថា អក្សរ ឣក្សរ ភាសា ภาษา សិក្សា ศึกษา សាសនា ศาสนา ទូរសព្ទ โทรศพท ។ ជាសម្មតិកម្ម ខ្ញុំយល់ថា ខ្មែរយើងវង្វេងក្បួន ដោយសារអ្នកចេះដឹងស្លាប់ក្នុងសង្គ្រាមស៊ីវិល ឬ ត្រូវគេបង្ខំឱ្យនិរទេស ព្រមទាំងបាត់បង់ក្បួនទាំងនោះផង ។ ក្បួនទាំងឡាយបានទៅនៅថៃ “ សៀមមិនចោលក្បួន ” ឯខ្មែរបានត្រឹមតែ “ មិនចោលចែចូវ ” តែប៉ុណ្ណោះ ។

វិបត្តិអក្សរសាស្ត្រខ្មែរកើតមានជានិច្ចនៅក្រោយរាល់ពេលសង្គ្រាម ។ ហេតុអ្វី ? ព្រោះតែរឿងភ្លេចក្បួនប៉ុណ្ណោះ ហើយភ្លេចចំសម័យដែលមានអ្នកចេះតិចតួចពេក ។ សង្គ្រាមស៊ីវិលខ្មែរម្តងៗ ស៊ីពេលយ៉ាងតិចក៏ ១០ឆ្នាំដែរ ។ ក្រោយសង្គ្រាម មេដឹកនាំខ្មែរទោះបីជាអ្នកនោះពូកែយ៉ាងណាក៏ដោយ ក៏មានការលំបាកជាច្រើនក្នុងការដឹកនាំ និងស្ថាបនាជាតិព្រោះពលរដ្ឋខ្មែរ ប្រមាណជាង ៦០ ទៅ ៧០ ភាគរយ ជាអនក្ខរជន។ អក្សរជាតិក៏មិនចេះ សីលធម៌ក៏រលត់ ឯព្រលឹងខ្មែរនោះក៏រលាយ ។ វារត់ចេញពីខ្លួនខ្មែរបាត់ទៅហើយ ។ ខ្មែរត្រូវធ្វើពិធីជញ្ជាត់ព្រលឹងមកវិញ នេះមិនមែនជាការងាយទេ ។ ស្ថានភាពស្រុកខ្មែរបច្ចុប្បន្ន ជាតួយ៉ាងស្រាប់ ។ ខ្មែរបានធ្លាក់ដោយចេតនា ក្នុងលង្វែកសាសនា និងអក្សរសាស្ត្រ ជាគំរប់៤ដងហើយ ។ នេះគប្បីជា

---

[៤] សំណេរពាក្យ ឃោប្ណា បែបនេះយើងពុំទាន់ឃើញមាននៅក្នុងសិលាចារឹកខ្មែររហូតមកដល់ពេលនេះ តែយើងសង្កេតឃើញមានមានពាក្យថា វិស្ណុ ។ ជំពោះភាសាថៃវិញ គេសរសេរពាក្យ ឃោសនា នេះតាមលំនាំសំណេររក្សាជាតិសព្ទ បែបសិលាចារឹកខ្មែររហូតមកដល់ពេលនេះ ។

ប្រធានបទ ដែលខ្មែរត្រូវសិក្សាដើម្បីគេចផុតពីលង្វែកបែបនេះក្នុងពេលខាងមុខ ។ សម្មតិកម្មរបស់ខ្ញុំមួយទៀត ដែលជាលទ្ធផលនៃការសិក្សាភាសាខ្មែរ គឺធ្វើឱ្យខ្ញុំមានការសង្ស័យថា បញ្ហាអក្សរសាស្ត្រ និងអក្សរសិល្ប៍ខ្មែរជាទូទៅ និងជាពិសេស បញ្ហាអក្សរសាស្ត្រ និង អក្សរសិល្ប៍ខ្មែរដែលទាក់ទងដល់សាសនាធំៗពីរ នៅសម័យអង្គរ ក៏ជាកត្តាចំបងមួយដែរ ក្នុងការធ្វើឱ្យមានវិនាសកម្មដល់សម័យរុងរឿង នៃមហានគរខ្មែរ ។ អ្នកចេះដឹងខ្មែរចែកជាពីក្រុម គឺក្រុមនិយមខ្មែរ-សំស្ក្រឹត និងក្រុមនិយមខ្មែរ-បាលី ដោយធ្វើឱ្យជំលោះសាសនាកាន់តែខ្លាំងក្លាឡើង ។ យើងអាចលើកឧទាហរណ៍ រឿងធម៌ចាស់ ធម៌ថ្មី ជាទីសំអាងបាន ។ សម្មតិកម្មនេះ សំអាងលើលក្ខណៈរក្សានិយម ដែលពុំបានផ្ដល់លទ្ធភាពគ្រប់គ្រាន់ និងឱ្យទាន់ពេលវេលាដើម្បីជួយជំរុញ ការអភិវឌ្ឍនីសាសនាធំៗទាំងពីរ និងភាសាទាំងបី ( ខ្មែរ-សំស្ក្រឹត និងបាលី ) ឱ្យចំរើនលូតលាស់ទាន់ផ្នែកគំនិត និងស្មារតី ក្នុងវិស័យនយោបាយនិងសិល្បៈនាសម័យនោះ ។ ស្ថាបត្យកម្មខ្មែរជាតឹកតាងបញ្ជាក់ពីការលូតលាស់ ផ្នែកគំនិតស្មារតី និង ចំណេះវិជ្ជាមួយដ៏ខ្ពង់ខ្ពស់ នៅសម័យនោះ។ វិសមភាពរវាងកត្តាទាំងនេះហើយ ដែលជាកត្តានាំមកនូវមហន្តរាយឱ្យខ្មែរនៅសម័យអង្គរ ។ ចំពោះបញ្ហាបច្ចុប្បន្ននៃសំណេរខ្មែរ គឺជារឿងខេមរយានកម្មមិនទាន់ចប់ ហើយវាមិនខុសអ្វីពីស្ថានភាពនយោបាយស្រុកខ្មែរទេដូចសំដី លោក ទួន ឃឿន ដែលបានសរសេរថា "បដិវត្តន៍មិនទាន់ចប់" ។ តើមានសំអាងអ្វីខ្លះក្នុងរឿងនេះ? ជាភស្តុតាងខ្លះៗនោះ យើងអាចសង្កេតមើលការវិវត្តន៍របស់ពាក្យខ្មែរខ្លះៗព្រមទាំងពាក្យដែលខ្ចីពីបាលី និងសំស្ក្រឹត : ឃោសនា វាសនា សាសនា ភាសា អក្សរ និង ពាក្យ វិស្ណុ ។ ពាក្យខ្មែរដែលមានឫសគល់រាប់សតវត្សមកទៅហើយនោះក្ដី ក៏មានការកែប្រែពីខុសទៅត្រូវ និង ពីត្រូវទៅខុសដែរ។ អោយ អំនោយ ឱ្យ អំណោយ ( សិលាចារឹកខ្មែរ ) ។ ជាបន្តពីសិលាចារឹកសម័យអង្គរ គឺនៅមាន **សិលាចារឹកនគរវត្ត** និង **បទានុក្រម** ដែលយើងអាចដកស្រង់ពាក្យខ្លះៗមកបង្ហាញក្នុងទីនេះ ដើម្បីបង្ហាញពីការវិវត្តន៍សំណេរខ្មែរ : ព្រះសាស្នា ទំ. ៧, ១០ ,១១ , ១២ កំនេត ទំ. ១៥៤ ( កំនើត ) ព្រះអំនាច ទំ.១១៣(ព្រះអំណាច ) ។ ហេតុផលទាំងនេះ គឺបណ្ដាលមកពី " បដិវត្តន៍អក្សរសាស្ត្រមិនទាន់ចប់ " ឬ " ខេមរយានកម្ម មិនទាន់ចប់ " ដោយសារ " ការបាត់បង់និងការវង្វេងក្បួន " ។ វិបត្តិបែបនេះ កើតមានជាហូរហែ ដូចកាលនៅ ថ្ងៃសៅរ៍១រោច ខែ ពិសាខ ឆ្នាំមមែ ត្រីស័ក ព.ស ២៤៧៤ រវាងខ្មែរអ្នកនិយមធម៌ចាស់ និង អ្នកនិយមធម៌ថ្មី ។

ភាពច្របូកច្របល់នោះ មានឆ្លុះបញ្ចាំងដោយឃ្លាកំណាព្យរបស់លោក ក្រមង៉ុយ ដែលលោកបានសរសេរថា : "គេប្រាប់ថា ខុសប្រកាន់ខឹង មិនដឹងថាខ្លួនរៀនមិនដល់ មិនដែលសួរគេ ព្រោះមិនឆ្ងល់ សំគាល់ថា ខ្លួនត្រូវមិនខុស" ( ក្រមង៉ុយ ១៩៧២ ទំ.៨៦ ) និង វគ្គដទៃទៀតដែលថែងថា : "ប្រកាន់តែខាងខុស រហូត មិនរៀនមេសូត្រឱ្យចេះដឹង អាងចេះតែ កកា ប៉ុណ្ណឹង ខំប្រឹងចំអើតអួតខ្លួនត្រូវ ។ ក្ដៅណាស់ពីរឿង យោជាយ៉ោ ដំឡើងភ្នែកស្លោមុខក្រញូវ ថាធ្លាប់យោនាពីខ្មោចឪ ឥឡូវយោណាមិនសុខចិត្ត ។ ...អ្នកបួស

គ្រប់វត្តគ្រប់នគរ ស ដាក់ ជើង ល រាប់សួស្លា បើ ស ជើង ម រាប់ សួស្មា អ្នកមានប្រាជ្ញាល្អមស្តាប់បាន ។ កុំល្ងង់ទាល់ងាប់ធ្លាប់មិនដឹង បើខឹងខ្ញុំឃាត់ថាឱ្យខាន ខ ដាក់ជើង ម ពីបុរាណ ក្មេងតូចប៉ុន្នានស្គាល់ ខ្មា" (ក្រមង៉ុយ ១៩៧២ ទំ.៨៦) វិបត្តិខ្មែរសម័យនោះមិនមែនសាបរលាប ទៅដោយសារការព្រមព្រៀងដោះស្រាយរវាងខ្មែរនិងខ្មែរនោះទេ។

ប៉ុន្តែដោយសារបញ្ហានិងស្ថានការណ៍ស្រុកទេសជំរុញឱ្យខ្មែរគិតពីរឿងឯករាជ្យនៃប្រទេសជាតិម្តង។

បញ្ហាទី៣ -ការប្រើពាក្យ ទើបបាន ( ទះ បាន )

តើសង្កត់ និង បន្ធើរសម្លេងធ្លាក់លើព្យាង្គណា ? តើយើងអាចធ្វើជាក្បួនច្បាប់ បានដែរឬទេ ? យើងអាចពិចារណា លើពាក្យមួយចំនួន ដើម្បីស្វែងយល់លើរឿងនេះ :

ក្រមា ( ក-ម៉ា ) ក្រមុំ ( ក-ម៉ុម ) ក្រមាច់ (ក-ម៉ាច់ ) ច្របាច់ ( ច-បាច់ ) ច្របូក ( ច-បូក ) ច្របល( ច-បល់ ) ត្រណម ( ត-ណម ) ត្រណោត (ត-ណោត ) ទ្រនំ ( ទ-នំ ) ទ្រនាប់ ( ទ-នាប់ ) កណ្តាប់ ( ក-ដាប់ ) កណ្តឹង ( ក-ដឹង ) កណ្តៀរ ( ក-ដៀ ) កណ្តុរ ( ក-ដុល ឬ កដោ ) កន្ទេល ( ក-ទេល ) កន្ទុយ ( ក-ទុយ ) កន្ទប ( ក-ទប ) ប្រអប់ ( ប៉-អប់ ) ប្រវ៉ារ ( ប៉-វ៉ា ) ប្រវ៉ាញ់ កំដរ ( ក-ដរ ) ។ ភាសាអ្នកភ្នំពេញនិយាយថា : "មីងមកពីណា ? មីងមកពី ក-ដរ ពូឯងនៅគេងពេទ្យ " ? ការនិយាយថា កំដរ ( ក-ដ ) និង ទើបបាន( ទះ-បាន ) ក្នុងទម្រង់ cvc-cv និង cvc-cvc ត្រូវបានអានត្រឹមតែ cv-cv និង cv-cvc ។ ចំណែកឯស្រះក្នុងព្យាង្គទី១ ត្រូវបានដូរទៅជាស្រះដែលបន្លឺជាកន្លះមាត្រទៅវិញ។ តាមទិន្នន័យទាំងនេះ យើងអាចធ្វើសម្មតិកម្មថា ព្យាង្គទី១ cvc និង ccv ត្រូវគេអានត្រឹមកន្លះមាត្រប៉ុណ្ណោះ ។ ត្រង់នេះមានន័យថា ព្យាង្គទី១របស់ពាក្យខ្មែរដែលលើកយកមកសំអាងនេះ ត្រូវគេអានដោយបន្ធើរស្ទួរ ( unstress syllable ) ។ តាមលក្ខណៈភាសាវិទ្យាស្រះនៃព្យាង្គទី១ គឺទៅជាស្រះបន្ធើរស្ទួររបស់ស្រះខ្មែរដែលកត់ត្រា សូរសម្លេងដោយប្រើសញ្ញា / * / ( scwa ) ។

សេចក្តីនេះ វាស្របទៅនឹងទស្សនះរបស់លោក Gorgoniyev ( 1966 p.31 ) និង លោកស្រី Jacob (1968p.14) ដែលបានសរសេរថា ការសង្កត់ស្ទួរក្នុងពាក្យខ្មែរដែលមានពីរព្យាង្គគឺ ធ្លាក់ទៅលើព្យាង្គទី២ ឯព្យាង្គទី១ គឺជាព្យាង្គបន្ធើស្ទួរ ។ ក្នុងការអាន អត្ថបទសរសេរតាមសូត្រ គណៈមេប្រយោគបានអនុម័តឱ្យអានតាមសំណេរទាំងអស់ ហើយមានទាំងហាមឃាត់មិនឱ្យលោកគ្រូ អ្នកគ្រូ ដែលមានដើមកំណើតនៅកម្ពុជាក្រោម អានអត្ថបទសរសេរតាមសូត្រផង តែលោកគ្រូ អ្នកគ្រូទាំងនោះ អាចកែវិញ្ញាសាសរសេរតាមសូត្របាន ។

បញ្ហាអានព្យាង្គ រៈ ក្នុងពាក្យខ្ចីពីបាលី

" អន្តរធាន វិញ អត់...មិនមែនទេ ពីព្រោះ អន្តរ ហើយនិង ធានៈ នោះវាផ្សំគ្នានេះ អន្តរ ហើយនឹងជាតិ " វចនានុក្រមខ្មែរ ទំ. ១៦៣១ -១៦៣២ បានប្រាប់ពីវិធីអានពាក្យ " អន្តរ ( អ័ន-ដ ឬ អន់-តរៈ " អន្តរកប្ប " ( អន់-ដ-រ់ៈក័ប ឬ អន់-ដ-ក័ប ) និង " អន្តរធាន " ( អន់-តរ៉ៈធាន ឬ អន់-ដ-ធាន ) ប៉ុន្តែ ពាក្យថា អន្តរជាតិ គេអានថា ( អន់-តៈរៈជាតិ )។ យើងសង្កេតឃើញថា បើអានតាមបែបខ្មែរ បុព្វបទ "អន្តរ " គេអានថា ( អន័-ដ ) ហើយអ្នកស្រុកតែងនិយាយថា ( អន់-ដ-ធាន ) ( អន់-ដ-កាប់ ) ។ ន នេះអានត្រឹមកន្លះមាត្រា ឬស្ទើរតែមិនឮផង ។ សព្ទ "អន្តរធាន " នេះ ខ្មែរធ្វើនិយកម្មផ្នែកសព្ទសូរ សព្ទន័យ ព្រមទាំងវាក្យសព្ទប្រភេទផង ។

បញ្ហាទី៤ ការប្រើពាក្យ ក្រម និង ក្រុម

វចនានុក្រមខ្មែរ ទំព័រ ៨៦ បានប្រាប់ឱ្យអានពាក្យខាងក្រោមនេះ ដោយបន្ថែមសូរសម្លេង (មៈ) នៅបន្ទាប់ពីពាក្យក្រុម : ក្រុមមឿង ក្រុមវាំង ក្រុមម៉ឺន ក្រុមហ្មឺន ក្រុមឃុន ក្រុមហ្លួង សុទ្ធតែអានថា ក្រុម-មៈ ។ តើខ្មែរយើងអានពាក្យដូចតទៅនេះថាដូចម្តេច ? ក្រុមជីវពល ក្រុមមន្ត្រី ក្រុមប៉ូលីស ក្រុមរាជតម្រួត ក្រុមអាវុធហត្ថ ក្រុមសិស្ស ក្រុមចារកិច្ច ក្រុមចោរ ក្រុមអាចារ្យ ក្រុមប្រដាល់ ក្រុមកីឡាករ...។

យើងអាចនិយាយដោយគ្មានព្យាង្គតំណ មៈ នេះទេ ។ តើយីហេតុអ្វី ? ជាសម្មតិកម្មបណ្តោះអាសន្ន គេអាចឆ្លើយថាពាក្យ ក្រុមមឿង ក្រុមវាំង ក្រុមឃុន...គឺជាសមាសនាម ដោយគេពុំអាចបំបែក ឬបន្ថែមពាក្យថា ក្រុមរបស់មឿង ក្រុមរបស់វាំង ក្រុមរបស់ឃុន ទេ ។ ចំណែកឯពាក្យថា ក្រុមជីវពល ក្រុមមន្ត្រី ក្រុមប៉ូលីស គេអាចបំបែកឱ្យមានន័យថា ក្រុមរបស់ពួកជីវពល ក្រុមរបស់ពួកមន្ត្រី ក្រុមរបស់ពួកប៉ូលីសបាន ។

ឧទាហរណ៍ ពាក្យ ក្រមការ ( ក្រំ មៈ-កា ) ( បា. កម្មការ = អ្នកធ្វើការ ) ( សំ. ក្រម + ការ = អ្នកធ្វើការតាមលំដាប់) ងារតំណែងរាជការឃុំ[៥] ។ ពាក្យថា ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និង ក្រមង៉ុយ អានដោយគ្មានព្យាង្គតំណរ ( មៈ ) ទេ ។ តើហេតុអ្វី ? ចម្លើយបញ្ហានេះ អាចដោះស្រាយបានដោយសំអាងទៅលើសម្មតិកម្មខាងលើនេះដែរ ។ តើព្យាង្គ ម : នេះជាព្យាង្គតំណពាក្យ ឬ មួយយ៉ាងណា? ជាសម្មតិកម្មបណ្តោះអាសន្ន គេអាចសន្និដ្ឋានបានថា ព្យាង្គ ( មៈ ) នេះ គឺដើម្បីសម្រួលត្រចៀក និងរក្សាជាតិសព្ទ ព្រោះពាក្យនេះជាពាក្យពីរព្យាង្គ ដែលខ្មែរយើងខ្ចីពីភាសាសំស្រ្កឹត ។ តាមមួយបែបទៀត គេអាចសិក្សាដោយសំអាងទៅលើវិធីសាស្ត្ររបស់ការបន្លឺសូររបស់ព្យញ្ជនៈ ម ។ ព្យញ្ជនៈ ម ត្រូវអានដោយបិទបបូរមាត់ទាំងពីរ ។ កាលបើបើកវាវិញ នៅពេលបន្លឺព្យាង្គប្រកបដោយព្យញ្ជនៈ ម រួចហើយគឺតែងមានសម្លេង ម ឬ

---

[៥] វចនានុក្រមខ្មែរ ទំ. ៧៦ ។

មះ នេះជាព្យាង្គបន្ថែរស្នូរជូនកាលព្ធ ជូនកាលមិនព្ធ ។ ដើម្បីឱ្យមានភាពប្រាកដនិយម ក្នុងបញ្ហាខាងលើនេះ គេត្រូវការសិក្សាដោយប្រើទិន្នន័យទូលំទូលាយច្រើនជាងនេះទៅទៀត ។ យោបល់ខាងលើនេះ គឺគ្រាន់តែជាការស្វែងរកប្រកដោះស្រាយខ្លះៗ តែប៉ុណ្ណោះ ហើយពុំអាចយកធ្វើជានិយាមអ្វីមួយបានឡើយ ។

## គន្ថនិទ្ទេស


- ពុទ្ធសាសនបណ្ឌិត្យ ១៩៥៨ សិលាចារឹកនគរវត្ត ភ្នំពេញ : ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ។
- មហាស៊ុរី ១៩៧ ? ការប្រៀបធៀបរវាង ស្រះ ព្យញ្ជនៈ និង ពាក្យ ខ្មែរ-ថៃ ភ្នំពេញ : ការផ្សាយរបស់អ្នកនិពន្ធ ។
- ឡុង ស. ២០០០ វចនានុក្រមភាសាខ្មែរ-បុរាណ សតវត្ស ទី៦-៨ ភ្នំពេញ : មូលនិធិតូយ៉ូតា ។
- អ៊ូ (ព្រះភិរម្យភាសា ហៅង៉ុយ) ១៩៧២ ច្បាប់ក្រមង៉ុយ : ភ្នំពេញ :ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
- Bradley, G. 1873 .Dictionary of the Siamese language.BangKok.
- Coedes, G 1942 .Inscription du Cambodge , vol.2.Hanoi : EFFO .
- Gorgoniyev ,Y.A.1966. The Khmer Language. Moscow : Nauka publication House.
- Haas ,M.s.1964 .Thai –English Student 's Dictionary. Stanford, California : Stanford University Press .
- Ith Chhun 1971 ( 2 nd ed ) Glossaire des Inscriptions Khmères ( sous la direction du Venerable Brah Mahaviriya Pandito Pang Khat ) Phnom Penh .
- Jacob, J.1968 .Inscription to Cambodian. London,Bombay ,Kulala Lumpur : Oxford University Pree .
- Little ,W.1973. The shorter Oxford English dictionary on historical principles.London : Clarendon Press .
- Max Muller, F.1964 ,( ed ).The law of Manu ( translation by G.Buhler ).In Sacred Books of the East, vol. 25.Delhi, Varanasi, Patna : Motilal Banarssdass.
- Monier-Williams,M.1999.A Sanskrit English Dictionary.Delhi: Motilal Banarsidass Publisher .

# លក្ខណៈវិនិច្ឆ័យនៃពាក្យសមាសក្នុងភាសាខ្មែរទំនើប

The Criteria of Compound Words in
the Modern Khmer Language

រៀបរៀងដោយ វង្ស មេង

---------

## ១. ប្រវត្តិពាក្យសមាស ( Literature Review of Compound Words)

ពាក្យសមាស សមមូលនឹងភាសាបារាំងថា Mots Composés និង ភាសាអង់គ្លេសថា Compound Words ម្យ៉ាងពាក្យសមាសជាប្រភេទបច្ចេកស័ព្ទដែលមានអ្នកនិពន្ធ និង ភាសាវិទូ ជាច្រើនបានហៅឈ្មោះ និង ប្រើប្រាស់ ទៅតាមការយល់ឃើញផ្សេងៗគ្នា ។ ក្នុងនោះយើងសង្កេតឃើញ មានៈ

សាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ ក៏បានប្រើបច្ចេកស័ព្ទ ជា **ពាក្យសមាស** ផងដែរ ដោយលោកបានសរសេរថាៈ "*បញ្ហាបន្លែក រវាងកន្សោមសេរី និង ពាក្យសមាស ជាបញ្ហាចម្បងនៃវចនាលេខនៈ (**Lexicographie**) ឬកិច្ចការអ្នកធ្វើវចនានុក្រម ។ សព្វថ្ងៃនៅប្រទេសខ្មែរ គេតែងតែផ្អែកលើអព្ភន្តរញាណ (**Intuition**) ឬ លើអញ្ញថាភាពដើម្បីសម្រេចថា កន្សោមពាក្យណាជាកន្សោមសេរី ហើយកន្សោមណាជាពាក្យសមាស ។*"[១]

លោក កេង វ៉ាន់សាក់ បានប្រើបច្ចេកស័ព្ទ **សមាសសព្ទ** ក្នុងការសម្គាល់ Mots Composés ដោយលោកបានសរសេរថាៈ"*សមាសសព្ទ (**Mots composés**) ជាពាក្យកើតឡើងដោយសារ សមាស (**Composition**) ។*"[២]

លោក អៀវ កើស បានប្រើបច្ចេកស័ព្ទ ពាក្យផ្គុំ ក្នុងការសម្គាល់ Mots Composés ហើយលោកបានសរសេរនៅក្នុងស្នាដៃរបស់លោកថាៈ "*បើនិយាយឱ្យដល់ទៅពាក្យគន្លាស់កាត់ អាចរាប់បញ្ចូលក្នុងចំពូកពាក្យផ្សំ ( **Mots dérivés** ) ពាក្យគូអាចរាប់បញ្ចូលចំពូកពាក្យគួប ហៅថាពាក្យផ្គុំ (**Mots Composés**) ។* "[៣]

---

[១] ព្រុំ ម៉ល់: "អំពីលក្ខណៈវិនិច្ឆ័យរូបនិយម" នៅក្នុង: *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី៣ លេខ៣ ខែឧសភា ២០០២ ទំព័រ៤៤ ។

[២] កេង វ៉ាន់សាក់: *មូលភាពក្នុងការបង្កើតពាក្យថ្មី* ភ្នំពេញ ១៩៦៤ ទំព័រ៣៥៩ ។

[៣] អៀវ កើស: *ភាសាខ្មែរ (ការល្បងពិនិត្យដោយរកហេតុផល)* បោះពុម្ពផ្សាយឡើងវិញដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន ១៩៩៥ ទំព័រ១៦៧-១៦៨ ។

ចំពោះក្រុមអ្នកនិពន្ធនៃក្រសួងអប់រំ វេយ្យាករណ៍ថ្នាក់ទី៥ បានប្រើបច្ចេកស័ព្ទ ពាក្យផ្សំ ក្នុងការសម្គាល់ Mots Composés ដោយបានសរសេរថា: *"ពាក្យផ្សំ គឺជាពាក្យដែលកើត ឡើងដោយពាក្យមួយរូប និង ពាក្យមួយទៀត ។"* [៤]

វេយ្យាករណ៍ថ្នាក់ទី៦ បានប្រើបច្ចេកស័ព្ទ ពាក្យផ្សំ ដែរ ។ ក្នុងស្នាដៃនេះ បានសរសេរថា ពាក្យផ្សំមានពីរបែបគឺ: ពាក្យផ្សំបែបទី១ និង ពាក្យផ្សំបែបទី២ ។[៥]

ចំពោះវេយ្យាករណ៍ថ្នាក់ទី៧ ក៏បានប្រើបច្ចេកស័ព្ទដូចវេយ្យាករណ៍ថ្នាក់ទី៥ និង ទី៦ដែរ គឺ ពាក្យផ្សំ ដោយមានសរសេរថា ពាក្យផ្សំអាចមានពាក្យផ្សំជានាម ពាក្យផ្សំជាគុណនាម ពាក្យផ្សំជា កិរិយាស័ព្ទ ពាក្យផ្សំដោយលុបពាក្យ "និង" និង ពាក្យផ្សំដោយមានពាក្យគន្លាស់កាត់ ។[៦]

លោក ហិដលី រ៉ូប៊ឺត ឃើត (Robert Kirt Headly) លោក តង់ ដា (S. Tandart) និង លោក ដានីញ៉ែល អាឡាំង (Alain Daniel) បានប្រើបច្ចេកស័ព្ទ **បទសមាស** ក្នុងការសម្គាល់ Mots Composés ។[៧]

តាមរយៈការបង្ហាញពីប្រវត្តិខាងលើ ក្នុងនោះគេសង្កេតឃើញ ពាក្យសមាសមានលក្ខណៈស៊ាំញ៉ាំ និង ស្មុគ្រស្មាញ លក្ខណៈទាំងនោះគឺ លក្ខណៈវិនិច្ឆ័យ និង ការកំណត់កន្សោមណាមួយជាពាក្យសមាស ។ ប៉ុន្តែទោះជាបីយ៉ាងណាក៏ដោយ ក៏យើងខិតខំប្រឹងប្រែងធ្វើឱ្យពាក្យសមាសមាន លក្ខណៈសម្គាល់ និង មូលដ្ឋានក្នុងការសង្កេតតាមភាសាវិទ្យាទំនើប គឺផ្អែកលើលក្ខណៈវិនិច្ឆ័យរូបនិយម (Critères Formels) ។ លក្ខណៈវិនិច្ឆ័យរូបនិយមនេះ នាំឱ្យយើងងាយយល់ទៅតាមភាសាវិទ្យា ទៅតាមទិដ្ឋភាពរូបិយដែលស្តែងចេញជាសូរស្តាប់ឮ ឬចេញជា សញ្ញាមើលឃើញ ។ លក្ខណៈវិនិច្ឆ័យរូបនិយម ផ្អែកលើលក្ខណៈរូបសាស្ត្រ

---

[៤] ក្រសួងអប់រំ: ***វេយ្យាករណ៍ថ្នាក់ទី៥*** មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ ទំព័រ៧៩ ។

[៥] សូមមើល (Cf.): ***វេយ្យាករណ៍ថ្នាក់ទី៦*** មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨២ ទំព័រ១១-២១ ។

[៦] សូមមើល (Cf.): ***វេយ្យាករណ៍ថ្នាក់ទី៧*** មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ ទំព័រ១២-១៣ ។

[៧] សូមមើល (Cf.): Robirt Kirt Headly et al., "***Cambodian-English***", Washington DC, The Catholic University of American Press, 1977, p. 1085., S. Tandart "***Dictionnaire Cambodgien-Français***", Deuxième Partie de ប à ឡ, 1935, p. 2164 and Alain Daniel "***Dictionnaire Pratique Cambodgien-Français***", Paris, Institut de L'Asie du sud-est, 1985, p. 629.

សូររលកក្នុងល្បះ កម្ពស់សូរសំឡេង និង លក្ខណៈសម្ព័ន្ធ[៨]។

ម្យ៉ាងទៀតដើម្បីជាទុនក្នុងការសិក្សានេះ គប្បីស្គាល់និយមន័យនៃពាក្យសមាសឱ្យបានច្បាស់លាស់ជាមុនសិន។

**២. និយមន័យ**

ពាក្យសមាសត្រូវបានអ្នកសិក្សាផ្នែកភាសាវិទ្យាយល់ឃើញ និង ឱ្យនិយមន័យខុសៗគ្នា ដូចជាៈ

លោក ជែក រីដឆាត (Jack C. Richards) បានឱ្យនិយមន័យថាៈ *"ពាក្យសមាសជាការផ្សំពាក្យពីរ ឬ ច្រើនដើម្បីបង្កើតមុខងារជាពាក្យណាមួយផ្សេង និង ន័យផ្ទាល់"*[៩]។

តាមទស្សនៈរបស់សាស្ត្រាចារ្យបណ្ឌិត ថោង ថែល បានឱ្យនិយមន័យថាៈ" *ពាក្យសមាសជាឯកតាន័យ កើតឡើងពី មូលស័ព្ទ មូលន័យពីរឬច្រើន ដែលដាក់ប្រឈមគ្នា និង ស្លបញ្ចូលគ្នាដើម្បីបង្កើតជាសមាសធាតុរួមគ្នា"*[១០]។ ចំណែកឯ វចនានុក្រម ***Le Petit Larouse*** បានកំណត់និយមន័យថាៈ" *ពាក្យសមាស ជាពាក្យដែលកើតឡើងដោយសមាសធាតុ ឬ ធាតុផ្សំច្រើន ដើម្បីបង្កើតជាពាក្យមួយដែលមានន័យជាក់លាក់ច្បាស់លាស់"*។[១១]

ជារួមៈ *ពាក្យសមាស ជាពាក្យកើតឡើងដោយសារពាក្យឫស និង ពាក្យឫស ដោយមានលក្ខណៈស្ថិតមិនអាចបំបែកចេញពីកន្សោមរបស់ខ្លួនវាបាន។*

ឧទាហរណ៍ៈ សៀតផ្កា កូនកាត់ ចង្កៀលខ្យង[១២] រានហាល កូនសោ ពាក់កណ្ដាល ចុងអង្ករ[១៣] ផ្កាយដុះកន្ទុយ ជាងកាត់សក់[១៤]។

---

[៨] សូមមើល (Cf.)ព្រុំ ម៉ល់ៈ " អំពីលក្ខណៈវិនិច្ឆ័យរូបនិយម " ដូចឯកសារមុន ទំព័រ៣៨-៣៩។

[៩] Jack C. Richards, John Platt & Heidi Platt, ***Longman Dictionary of Language Teaching and Applied Linguistics***, 2nd edition, Singapore, Longman Group, 1992, p.72. (*A Compound Word is a Combination of two words which functions as a single word.)*

[១០] Thel Thong, ***Compound Nouns in Cambodian***, Thesis of Linguistics, Monash University, Melbourne, February 1978, p.10. *(A Compound is a one sense unit represented by two or more individual morph semes which are not simply juxtaposed but also amalgamated so as to form together a content segment.)*

[១១] ***Encyclopédique Dictionaire***, Larousse, 1995, p.252. *(Mot Composé ou Composé est le mot constitué de plusieurs mots ou elements et formant une unite significative.)*

[១២] អៀវ កើសៈ *ភាសាខ្មែរ( ការល្បងពិនិត្យដោយរកហេតុផល)* ភ្នំពេញ បោះពុម្ពផ្សាយឡើងវិញដោយពុទ្ធសាសនបណ្ឌិត្យ រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន ១៩៩៥ ទំព័រ២១៦។

[១៣] Judith M.Jacob, ***A Concise Cambodia-English Dictionary***, Great Britain, Antony Rowe Ltd, Chippenham, 1990, p.xxv.

ក្នុងឧទាហរណ៍ខាងលើ កន្សោម " សៀតផ្កា កូនកាត់ ចង្កៀងខ្យង រានហាល កូនសោ ពាក់កណ្ដាល ចុងអង្គរ ផ្កាយដុះកន្ទុយ ជាងកាត់សក់ " កកើតពី ពាក្យឫស និង ពាក្យឫស។

កន្សោម "សៀតផ្កា" កកើតពីពាក្យឫស "សៀត" ដែលជាកិរិយាស័ព្ទ មានន័យថា: ដាក់អ្វី១ ញាត់ញៀតផ្ទាប់, ដាក់ ស៊កផ្ទាប់ដូចជា: សៀតបារី ជាដើម[១៥]។ ចំណែកពាក្យឫស "ផ្កា" មានថ្នាក់ពាក្យពីរយ៉ាង។ ថ្នាក់ពាក្យទី១ជានាមស័ព្ទមានន័យថា: ជាអវយវៈនៃរុក្ខជាតិ, តិណជាតិជាដើម ដែលចេញពីមែក, ពីធាង, ពីក្នុងចន្លោះត្រួយ, ពីសន្លឹក, ឬចេញពីដើម សម្រាប់ក្លាយកើតជាផ្លែ ឬ មិន កើតជាផ្លែក៏មាន ឬក៏ជារូបសណ្ឋានជាផ្កានៅផ្ទៃសំពត់ជាដើម: សំពត់ផ្កា, ព្រៃផ្កា[១៦]។ ក្នុងករណីជាន័យ ធៀប "ផ្កា" មានន័យថា ជារដូវរបស់ស្ត្រី ឧទាហរណ៍: ស្រីមានផ្កា គឺសំដៅស្រីមានរដូវនេះឯង។ ជាន័យ ម្យ៉ាងទៀតមានន័យថា: ជាឈ្មោះបុណ្យផ្កាមួយយ៉ាងដែលទាយកហែផ្កាទៅបូជាព្រះពុទ្ធរូប ព្រមទាំងទេយ្យទានយកទៅប្រគេនព្រះសង្ឃផង ដូចជា បុណ្យផ្កា, ហែផ្កា (ធ្វើតាមទំនៀមប្រទេស)។ ថ្នាក់ពាក្យ ទី២ "ផ្កា" ជាកិរិយាស័ព្ទ មានន័យថា: ចេញផ្កា, បញ្ចេញផ្កា, មានផ្កា ឧទាហរណ៍: ដូងផ្កា, ឈើផ្កា។ ដូច្នេះ កន្សោម "សៀតផ្កា" ជានាមស័ព្ទមានន័យថា ជាសរីរប្បទេសត្រង់បន្ទាប់ចុងភ្នែកទាំងពីរ ខាងមុខគុម្ព ត្រចៀកមនុស្ស (ហៅតើក១ក៏បាន ព្រោះត្រង់កន្លែងនោះមានខ្យល់ជីពចរលោតតើក១ជានិច្ច)។[១៧] កន្សោម "សៀតផ្កា" នេះមិនអាចបំបែកចេញពីគ្នាបានទេ ករណីញែកចេញពីគ្នាបានដូចខាងលើមានន័យផ្សេងគ្នាទៅវិញ គឺមិនសំដៅលើកន្សោម "សៀតផ្កា" នោះទេ។ កន្សោម "សៀតផ្កា" ខុសពី "សៀត" ខុសពី "ផ្កា"។

កន្សោម "កូនកាត់" កើតពីពាក្យឫស "កូន" និង ពាក្យឫស "កាត់"។ ពាក្យឫស "កូន" ជានាមស័ព្ទ មានន័យថា: មនុស្ស, សត្វដែលកើតអំពីមាតាបិតា មេបាៈ កូនប្រុស កូនស្រី, កូនឈ្មោល, កូនញី។ ឬថា ជាមនុស្សនៅក្នុងបន្ទុកឱវាទចៅហ្វាយនាយ ឬ មេតម្រួតដូចជា: កូនក្មួយ, កូនឈ្នួល...។ មានន័យម្យ៉ាងទៀតថា ជាវត្ថុអ្វី១ជាគូគ្នា មួយមានរូបតូចជាងមួយ ឧទាហរណ៍: កូនប្រអប់, កូនសោ[១៨]។ ចំណែកពាក្យឫស "កាត់" មានថ្នាក់ពាក្យពីរយ៉ាង។ ថ្នាក់ពាក្យទី១ជាកិរិយាស័ព្ទ មានន័យថា: ផ្ដាច់ដោយប្រដាប់

---

[១៤] Khin Sok, ***La Grammaire Du Khmer Moderne វេយ្យាករណ៍ ភាសាខ្មែរ*** Paris, Édition You-Feng Libraire Éditeur, 1999, p.193.

[១៥] វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ រោងពុម្ពកម្ពុជា ១៩៦៧-៦៨ ទំព័រ១៣៩៧។

[១៦] ដដែល ទំព័រ៧០១-៧០២។

[១៧] ដដែល ទំព័រ១៣៩៧។

[១៨] វចនានុក្រមខ្មែរ ដូចឯកសារមុន ទំព័រ៤៤។

មានមុខមុតមានកន្ត្រៃ, រណារជាដើម ដូចជា: កាត់ឈើ, កាត់សក់, កាត់សំពត់[១៩]។ ថ្នាក់ពាក្យទី២ ជាគុណនាមមានន័យថា: ដែលកើតអំពីមាតាបិតាទីទៃពីគ្នា ឬ អំពីមេបាដែលមានជាតិ ឬ ទ្រង់ទ្រាយពីគ្នា ឧទាហរណ៍: កូនកាត់, កូននេះកាត់ទៅខាងម្ដាយ[២០]។ ដូច្នេះកន្សោម "កូនកាត់" មានន័យថា ជាមនុស្ស ដែលឪពុកម្ដាយរបស់គេ មានសញ្ជាតិផ្សេងគ្នា[២១]។ កន្សោម "កូនកាត់" ខុសពី ពាក្យឫស "កូន" ខុសពី ពាក្យឫស "កាត់" ដូចបង្ហាញជូនខាងលើ។

កន្សោម "ចង្កៀលខ្យង" កកើតពីពាក្យឫស "ចង្កៀល" និង ពាក្យឫស "ខ្យង"។ ពាក្យឫស "ចង្កៀល" ជានាមស័ព្ទ មានន័យថា ជាប្រដាប់សម្រាប់ឆ្កៀលដូចជា ចង្កៀលត្រចៀក, ចង្កៀល អាកោ[២២]។ ចំណែកពាក្យឫស "ខ្យង" ជានាមស័ព្ទមានន័យថា: ឈ្មោះសត្វសន្តានទឹងស័ង្ខ សំបកសន្តាន ខ្មៅតែរូបធំជាង ខ្ចៅជាងគ្រែង ខ្លះមានពុកមាត់, ខ្លះគូទស្រួច, ខ្លះទាល, គូទស្រួចហៅខ្យងគូទស្រួច, គូទទាលហៅខ្យងគូទ ទាល, មានទឹកជាលំនៅខ្លះ, នៅលើគោកខ្លះ។ ស្រុកខ្លះហៅ ខ្ចង ព្រោះគេយល់ថា គូ នឹង ខ្ចៅ, គេនិយាយថា ខ្ចងខ្ចៅ, ប៉ុន្តែតាមពិត ខ្យងនេះប្រើមកយូរណាស់ហើយ[២៣]។ កន្សោម "ចង្កៀលខ្យង" មិនមែនមានន័យដូច ពាក្យឫស "ចង្កៀល" និង ពាក្យឫស "ខ្យង"នោះទេដូចមានការឱ្យនិយមន័យពាក្យទាំងនេះជូនខាងលើជា ភ័ស្តុតាងស្រាប់។

ដូចគ្នានេះដែរ កន្សោម "រានហាល" ខុសពីពាក្យឫស "រាន" និង ពាក្យឫស "ហាល"។ កន្សោម "កូនសោ" ខុសពីពាក្យឫស "កូន" និង ពាក្យឫស "សោ"។ កន្សោម "ពាក់កណ្ដាល" ខុសពីពាក្យឫស "ពាក់" និង ពាក្យឫស "កណ្ដាល"។ កន្សោម "ចុងអង្គរ" ខុសពីពាក្យឫស "ចុង" និង ពាក្យឫស "អង្គរ"។ កន្សោម "ផ្កាយដុះកន្ទុយ" ខុសពីពាក្យឫស "ផ្កាយ" ពាក្យឫស "ដុះ" និង ពាក្យឫស "កន្ទុយ"។ កន្សោម "ជាងកាត់សក់" ខុសពីពាក្យឫស "ជាង" ពាក្យឫស "កាត់" និង ពាក្យឫស "សក់"។

### ៣. លក្ខណៈវិនិច្ឆ័យនៃពាក្យសមាស

តាមការសិក្សាវាក្យស័ព្ទរបស់ពាក្យសមាស កត់សម្គាល់ឃើញថា ពាក្យសមាសមានលក្ខណៈ វិនិច្ឆ័យ៣ យ៉ាងជាមូលដ្ឋាន គឺ សទ្ទិ តេស្ត និង សម្ព័ន្ធ។

---

[១៩] ដដែល ទំព័រ៣២។

[២០] ដដែល ទំព័រ៣២។

[២១] Webster's New WorldTM College Dictionary, 3rd edition, Victoria Neufeldt (editor in chef) David B. Guralnik (editor in chief Emeritus), USA, Macmillan, 1996, p. 607.

[២២] វចនានុក្រមខ្មែរ ដូចឯកសារមុន ទំព័រ១៧៦។

[២៣] ដដែល ទំព័រ១១៣។

## ៣.១. លក្ខណៈវិនិច្ឆ័យផ្អែកលើសន្ធិ

### ៣.១.១. និយមន័យសន្ធិ

*" សន្ធិ ជាវិធីតអក្សររបស់បទមួយៗឱ្យជាប់គ្នា "*[២៤]

នៅក្នុងភាសាខ្មែរវិធីសន្ធិ[២៥] មានពីរយ៉ាង ដែលអាចផ្ដល់លទ្ធផលក្នុងការសម្គាល់ពាក្យសមាស ។ វិធីទី១គឺ សម្គាល់ពាក្យសមាសតាមវិធីសន្ធិនៃភាសាសំស្ក្រឹត-បាលី ដែលបានប្រើចំពោះភាសាខ្មែរ និង ពាក្យសមាសខ្មែរដែលមានការខ្ចីពីភាសាសំស្ក្រឹត-បាលី[២៦] ។ វិធីទី២ គឺសម្គាល់ពាក្យសមាស ដោយប្រើសន្ធិបែបខ្មែរ ក្នុងការសម្គាល់ពាក្យសមាសបែបខ្មែរផង និង ចំពោះពាក្យសំស្ក្រឹត-បាលីផង។ ចំពោះ វិធីទី២ អាចសម្គាល់បានត្រឹមតែពាក្យសមាសណា ដែលយើងខ្ចីពីភាសាសំស្ក្រឹត-បាលីមកប្រើជារបៀប ខ្មែរក្នុងភាសាខ្មែរ។ ជាទូទៅវិធីសន្ធិនេះ អាចសម្គាល់ពាក្យសមាសបាន ត្រឹមតែជាពាក្យសមាស សំស្ក្រឹត-បាលី និង ពាក្យសមាសខ្មែរដែលបានខ្ចីពីភាសាសំស្ក្រឹត-បាលីតែប៉ុណ្ណោះ។ យើងមិនអាចសម្គាល់ពាក្យសមាសទូទៅបានឡើយ ។

វិធីទី១: ពាក្យសមាសប្រើវិធីសន្ធិសំស្ក្រឹត-បាលី ឧទាហរណ៍: សុខាភិបាល (មកពី សុខ និង អភិបាល) ។ រាជានុញ្ញាត (មកពី រាជ និង អនុញ្ញាត) ។ ព្រឹទ្ធាចារ្យ (មកពី ព្រឹទ្ធ និង អាចារ្យ) ។ មហិទ្ធិឫទ្ធិ (មកពី មហា និង ឥទ្ធិឫទ្ធិ) ។[២៧]

វិធីទី២: ពាក្យសមាសប្រើវិធីសន្ធិបែបខ្មែរ ឧទាហរណ៍: សង្គមអារម្មណ៍ (មកពី សង្គម និង អារម្មណ៍)[២៨]

ចំពោះពាក្យសមាស " ព្រឹទ្ធាចារ្យ " យើងសង្កេតឃើញថា ពាក្យ " ព្រឹទ្ធ " ក្នុងភាសាខ្មែរ មិនទាន់ជាពាក្យពេញលេញនៅឡើយ ពីព្រោះក្នុងភាសាខ្មែរពាក្យនេះពុំមានប្រើតែឯកឯងក្នុងប្រយោគទេ ពិតមែនតែមានក្នុងពាក្យ *ចាស់ព្រឹទ្ធចាស់ព្រេង ព្រេងព្រឹទ្ធ*។ ពាក្យ " ព្រឹទ្ធ " មាន ន័យកាលណា

---

[២៤] វចនានុក្រមខ្មែរ ដូចឯកសារមុន ទំព័រ១២៦២។

[២៥] វិធីសន្ធិមានច្រើនយ៉ាងពិសេសក្នុងភាសាសំស្ក្រឹត-បាលី។ ចំពោះភាសាខ្មែរវិធីសន្ធិ គឺគ្រាន់តែជាការបន្សំរវាង ពាក្យ និង ពាក្យ ឱ្យចូលគ្នាជាពាក្យសមាស។ សូមមើល (Cf.) អៀវ កើស: *ភាសាខ្មែរ(ការល្បងពិនិត្យដោយរកហេតុផល)* ដូចឯកសារមុន ទំព័រ២២០-២២៨។

[២៦] សូមមើល (Cf.) សេ អឿន: *ពាក្យកម្ចីសំស្ក្រឹត-បាលី ក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ជំនាន់ទី១ មុខជំនាញភាសាវិទ្យា ២០០២។

[២៧] អៀវ កើស: *ភាសាខ្មែរ(ការល្បងពិនិត្យដោយរកហេតុផល)* ដូចឯកសារមុន ទំព័រ២២៣-២២៤។

[២៨] ក្រសួងអប់រំ: *វេយ្យាករណ៍ថ្នាក់ទី៧* ដូចឯកសារមុន ទំព័រ៣៨។

ពាក្យនេះរលាយខ្លួនចូលរួមជាមួយស័ព្ទដទៃទៀត ដូចមានក្នុងឧទាហរណ៍ខាងលើជាភ័ស្តុតាងស្រាប់ ។ ជាសន្និដ្ឋាន យើងបានពាក្យ " ព្រឹទ្ធាចារ្យ " ជាពាក្យសមាសបែបសំស្ក្រឹតបាលី ។

### ៣.១.២. **លក្ខណៈវិនិច្ឆ័យផ្អែកលើតេស្ត**

វិធីធ្វើតេស្តនេះ មានវិធី៤យ៉ាងគឺ : តេស្តជែក តេស្តតំណាក់កត្តារួម តេស្តកំណាត់ និង តេស្តតំណួរ ។[២៩]

វិធីធ្វើតេស្តទាំង៤ខាងលើ យើងយកតែ កន្សោម " កូនសោ " មួយមកធ្វើជាឧទាហរណ៍ ។

#### ៣.១.២.១. **តេស្តជែក** (Test de séparabilité/d'insertion)

យើងយកគុណនាម" *ថ្មី* " មកជែកកន្សោម " *កូនសោ* " គេបាន " *កូនថ្មីសោ* " ប៉ុន្តែយើងមិនអាចថា " *កូនថ្មីសោ* " បានទេ គេត្រូវថា " *កូនសោថ្មី* "ទើបស្តាប់បាន និង ត្រឹមត្រូវតាមទម្លាប់នៃការនិយាយស្តីរបស់ខ្មែរ ។

ផ្ទុយទៅវិញ កន្សោម " *កូនប្រុស និង កូនស្រី* " នេះ អាចទទួលយកបាននូវ គុណវិសេសន៍[៣០] បានដូចជា: " *កូនជាប្រុស* " ឬ " *កូនជាស្រី* " ។ តែយើងមិនអាចថា " *កូនជាសោ* " បានទេ ។

ជាសន្និដ្ឋាន យើងបាន កន្សោម " *កូនសោ* " ជាពាក្យសមាស ។

#### ៣.១.២.២. **តេស្តតំណាក់កត្តារួម** (Test de mise en facteur commun)

នៅក្នុងភាសាខ្មែរ ការដាក់កត្តារួមក៏មានប្រើផងដែរ ។ យើងពិនិត្យមើលឧទាហរណ៍ខាងក្រោម:

*រដ្ឋអាជ្ញាក៏បានរកឃើញឧបករណ៍ស្រូបសម្លេង និង កាមេរ៉ាថតសម្ងាត់នៅក្នុងការិយាល័យ និងរថយន្តរបស់ឈ្លូ ។*[៣១]

*ប៉ុន្តែប្រទេសកម្ពុជា និង ថៃ បានបង្ហាញនិងអនុវត្តនូវកម្មវិធី... ។*[៣២]

---

[២៩] សូមមើល (Cf.) ព្រុំ ម៉ល់: " អំពីលក្ខណៈវិនិច្ឆ័យរូបនិយម" ដូចឯកសារមុន ទំព័រ៤៦-៤៨ ។

[៣០] គុណវិសេសន៍ (Complétif/Subordinate) ជាការយកនាមទៅប្រើប្រាស់ដូចគុណនាម ឧទាហរណ៍: " ផ្ទះខ្ញុំ " ពាក្យ " ខ្ញុំ " ជា គុណវិសេសន៍របស់ " ផ្ទះ " ឯពាក្យ ជា ជាគុណវិសេសន៍របស់កន្សោម *កូនប្រុស* ក្នុងកន្សោម *កូនជាប្រុស* ។

[៣១] រស្មីកម្ពុជា ថ្ងៃទី១១-១២ ខែកុម្ភៈ ឆ្នាំ២០០២: *រឿងអាស្រូវកាសែតវីដេអូសិចរបស់អ្នកនយោបាយស្រីតៃវ៉ាន់ឡើងដល់តុលាការ* ទំព័រខ៣ ។

[៣២] រស្មីកម្ពុជា ថ្ងៃទី១១-១២ ខែកុម្ភៈ ឆ្នាំ២០០២: *អេដស៍ក្នុងតំបន់នៃពិភពលោក* ទំព័រក៣ ។

ក្នុងឧទាហរណ៍ទី១ កន្សោម " *ក៏បានរកឃើញ* " ត្រូវភ្ជាប់ទៅ " *ឧបករណ៍ស្រូបសម្លេង* "ផង និង " *កាមេរ៉ាថតសម្ងាត់* "ផង និង កន្សោម " *នៅក្នុង* " ត្រូវភ្ជាប់ទៅ " *ការិយាល័យ* " ផង និង " *រថយន្ត* " ផង។ " *ក៏បានរកឃើញ* " ជាកត្តារួមនៃកន្សោម " *ឧបករណ៍ស្រូបសម្លេង* " និង " *កាមេរ៉ាថតសម្ងាត់* " និង " *នៅក្នុង* " ជាកត្តារួមនៃកន្សោម " *ការិយាល័យ* " និង " *រថយន្ត* " ។

ក្នុងឧទាហរណ៍ទី២ ពាក្យ " *ប្រទេស* " ភ្ជាប់ទៅនឹង " *កម្ពុជា* "ផង និង " *ថៃ* "ផង។ ពាក្យ *ប្រទេស* ជាកត្តារួមរបស់ពាក្យ *កម្ពុជា* និង *ថៃ*។ យើងអាចនិយាយថា *ប្រទេសកម្ពុជា* និង *ប្រទេសថៃ*។

ចំពោះកន្សោម *កូនស្រី* និង *កូនសោ* យើងអាចដាក់ជាកត្តារួមបាន គឺ*កូនស្រី* និង *សោ*។ កត្តារួមនេះមិនសមស្របតាមការប្រើប្រាស់របស់ខ្មែរទេ ការដែលយក កូន( ស្រី និង សោ) ជាកត្តារួមបែបនេះ មិនអាចទទួលយកបានទេ ពីព្រោះ *កូនស្រី* និង *សោ* មានន័យផ្សេងគ្នា។

ជាសន្និដ្ឋាន យើងបានកន្សោម *កូនសោ* ជាពាក្យសមាស ពីព្រោះការដាក់ជាកត្តារួម លទ្ធផលដែលបានមកមិនត្រឹមត្រូវតាមការនិយាយស្តីនៃទម្លាប់ក្នុងភាសាខ្មែរទេ។

**៣.១.២.៣. តេស្តកំណាត់** (Test de répétition partielle)

លោកសាស្ត្រាចារ្យបណ្ឌិតព្រុំ ម៉ល់ បានបញ្ជាក់ថា:" *ក្នុងតេស្តកំណាត់ គេកាត់កន្សោមពាក្យចោលមួយភាគ ក្រោយពីបានប្រើកន្សោមនោះទាំងមូលម្តងមកហើយ។ បើគេកាត់មិនបានទេ (ពីព្រោះបើគេកាត់ គេបានន័យផ្សេងទៅវិញ) កន្សោមនោះជាពាក្យសមាស។* "[៣៣]

ឧទាហរណ៍ទី១: " ពូបានហុចកូនសោពីរឱ្យក្មួយប្រុស កូនពីរទៀតឱ្យក្មួយស្រី " ។

ផ្ទុយពីនេះគេអាចនិយាយថា: "គាត់មានកូនប្រុសពីរនាក់ កូនគាត់ទាំងពីររៀនពូកែណាស់។"

ក្នុងឧទាហរណ៍ទី១ ពាក្យ *កូន* បានត្រូវកាត់ពីកន្សោម *កូនសោ*។ *កូន* និង *កូនសោ* មានន័យផ្សេងគ្នា កន្សោម *កូនសោ* មិនអាចកាត់ពាក្យ *កូន* ចេញពី *សោ* បានទេ កាលណាគេកាត់កន្សោម *កូនសោ* មានន័យផ្សេងទៅវិញ។

ដូច្នេះ គេមិនអាចថា:" ពូបានហុចកូនសោពីរឱ្យក្មួយប្រុស កូនពីរទៀតឱ្យក្មួយស្រី "បានទេ។ យើងត្រូវថា:" ពូបានហុចកូនសោពីរឱ្យក្មួយប្រុស កូនសោពីរទៀតឱ្យក្មួយស្រី។"

តាមរយៈតេស្តកំណាត់នេះ យើងអាចសន្និដ្ឋានថា កន្សោម *កូនសោ* ជាពាក្យសមាស។

**៣.១.២.៤. តេស្តតំណូរ** (Test de commutation)

*តេស្តតំណូរ ជាវិធីប្តូរចំណែក ឬ សមាសភាពណាមួយនៃកន្សោមដែលយើងចង់ស្ទង់ ជាមួយ*

---

[៣៣] ព្រុំ ម៉ល់: " អំពីលក្ខណៈវិនិច្ឆ័យរូបនិយម " ដូចឯកសារមុន ទំព័រ៤៦។

*ពាក្យណាមួយយកមកពីខាងក្រៅ រើសឱ្យសមស្របតាមស្ថានភាព។*[៣៤]

យើងអាចដូរ *កូនសោ* ទៅជា *កូនប្រុស* តាមវិធីនេះ យើងបានបំបែកចេញពីកន្សោម *កូនសោ* នូវពាក្យ *កូន* និង *សោ*។ ប៉ុន្តែពាក្យ *កូន* តែមួយមិនអាចសម្គាល់ *កូនសោ* បានទេ។

ផ្ទុយពីនេះ បើយើងដូរកន្សោម *កូនប្រុស* ជា *កូនស្រី* យើងសង្កេតឃើញថា *កូន* បំបែក កន្សោម *កូនប្រុស* រក្សាន័យដើមដដែល។

ជាសន្និដ្ឋាន យើងអាចថា *កូនសោ* ជាពាក្យសមាស។

**៧.២. លក្ខណៈវិនិច្ឆ័យផ្អែកលើសម្ព័ន្ធ**

សម្ព័ន្ធ ជាទិដ្ឋភាពកើតឡើងក្នុងប្រយោគ។ ពាក្យមួយដែលមានរូបសាស្ត្រដូចគ្នា កាលណាមានសម្ព័ន្ធក្នុងប្រយោគផ្សេងគ្នា អាចស្ថិតក្នុងប្រភេទផ្សេងគ្នា។

ឧទាហរណ៍ទី១: ក្លឹបកម្សាន្តអ័រគីដេប្រមូលផ្តុំក្មេងស្ទាវ*ញៀនថ្នាំ*គ្រវីក្បាល។[៣៥]

ឧទាហរណ៍ទី២: ...ក្មេងស្ទាវ១មានប្រុសមានស្រីពី៨០ទៅជាង១០០នាក់ប្រើ*ថ្នាំញៀន*ស្រវឹងគ្រវីក្បាលនាំគ្នាចូលទៅ...។[៣៦]

នៅក្នុងឧទាហរណ៍ទី១ ពាក្យ *ញៀន* ក្នុងកន្សោម *ញៀនថ្នាំ* ជា កិរិយាស័ព្ទ។ ឯក្នុងឧទាហរណ៍ទី ២ ពាក្យ *ញៀន* ក្នុង កន្សោម *ថ្នាំញៀន* ជានាមស័ព្ទ។

ចំពោះកន្សោម *កូនសោ* កាលណាគេប្តូរជា *សោកូន* នោះកន្សោម *សោកូន* មិនមែនជាកន្សោម *កូនសោ* ទេ។ ពីព្រោះពេលគេប្តូរសម្ព័ន្ធ កន្សោម *កូនសោ* មានន័យផ្សេង ដែលធ្វើឱ្យគេស្តាប់មិនបាន។

ជាសន្និដ្ឋានយើងបាន កន្សោម *កូនសោ* ជាពាក្យសមាស។

**សេចក្តីសង្កេត :**

កន្សោម "ភាសាជាតិ, សភាជាតិ, " លោកកេង វ៉ាន់សាក់ យល់ថា ជាកន្សោមពាក្យ[៣៧] ពីព្រោះលោកយល់ថា ភាសាជាតិ កកើតពីពាក្យ "ភាសា" ដែលជានាមស័ព្ទ រីឯពាក្យ "ជាតិ" ជានាមស័ព្ទដែលមានមុខងារជាគុណនាម។ កន្សោម "ភាសាជាតិ" ចងភ្ជាប់គ្នាដោយលុបនិបាតស័ព្ទ "នៃ ឬ របស់" ។ម្យ៉ាងទៀត

---

[៣៤] ដដែល ទំព័រ៤៦។

[៣៥] រស្មីកម្ពុជា ថ្ងៃទី២៧-២៨ ខែសីហា ឆ្នាំ២០០១: *ក្លឹបកម្សាន្តអ័រគីដេប្រមូលផ្តុំក្មេងស្ទាវញៀនថ្នាំគ្រវីក្បាល* ទំព័រក១។

[៣៦] ដដែល ទំព័រក១

[៣៧] លោក កេង វ៉ាន់សាក់ ប្រើបច្ចេកស័ព្ទ " កម្រងពាក្យ ឬ សហស័ព្ទ ឬ ពាក្យជាក្រុម"។ សូមមើល (Cf.): កេង វ៉ាន់សាក់: *មូលភាពក្នុងការបង្កើតពាក្យថ្មី* ដូចឯកសារមុន ទំព័រ៦៤-៣៦៦ និង ទំព័រ៣៨០-៤០៦។

កន្សោម "ភាសាជាតិ" លោកយល់ថា មកពី "ភាសារបស់ជាតិ" ពោលគឺពេលយកមកប្រើដោយលុបនិបាតស័ព្ទ "របស់" ចេញ។ ដូចគ្នានេះផងដែរ កន្សោម "សភាជាតិ" មកពី "សភារបស់ជាតិ"។ ក្នុងបញ្ហានេះ លោក បានគូសបញ្ជាក់ថា: *"សហសព្ទបែបខ្មែរ គឺជាកម្រងពាក្យ កើតដោយសារសហសព្ទវិធីបែបខ្មែរដែលរៀបគុណសព្ទ ឱ្យនៅពីក្រោយនាម ហើយដែលចងបច្ច័យរវាងនាម នឹង នាម ដោយប្រើនិបាតសព្ទ " នៃ, របស់, ឬអំពី " ជាដរាប។"*[៣៨]

## សេចក្តីសន្និដ្ឋាន

តាមការបង្ហាញខាងលើ អាចឱ្យយើងសន្និដ្ឋានថា ពាក្យសមាសមានលក្ខណៈវិនិច្ឆ័យបីយ៉ាងជាមូលដ្ឋានគឺ វិធីសន្ធិ វិធីតេស្ត និង វិធីសម្ព័ន្ធ។ វិធីសន្ធិ អាចសម្គាល់ពាក្យសមាសក្នុងភាសាសំស្ក្រឹត-បាលី និងពាក្យ សមាសដែលយើងខ្ចីពីភាសាសំស្ក្រឹត-បាលី គឺមិនអាចសម្គាល់ពាក្យសមាសខ្មែរទូទៅបានទេ។ វិធីតេស្ត មានតេស្តជែក តេស្តតំណាក់កត្តារួម តេស្តកំណាត់ និង តេស្តតំណូរ។ ក្នុងវិធីតេស្តនេះ ក្នុងភាសាខ្មែរចំពោះពាក្យសមាស លទ្ធផលដែលបានមក គួរជាទីពេញចិត្តដូចតេស្តក្នុងភាសាបារាំងដែរ។ វិធីសម្ព័ន្ធ លទ្ធផលដែលទទួលបាន ត្រឹមតែធ្វើឱ្យពាក្យសមាសមានថ្នាក់ពាក្យផ្សេងគ្នាប៉ុណ្ណោះ។ លើសពីនេះ វិធីសម្ព័ន្ធអាចញែកពាក្យសមាសឱ្យមានលក្ខណៈខុសគ្នាពីកន្សោមពាក្យបានតាមវិធីសួររលកក្នុងល្បះ។ ទោះបីជាមានលក្ខណៈវិនិច្ឆ័យបែបនេះ ក៏ពាក្យសមាសនៅក្នុងភាសាខ្មែរនៅតែចោទជាបញ្ហា និងមិនទាន់ច្បាស់លាស់នៅឡើយ។ គោលបំណងនៃការសិក្សានេះ គ្រាន់តែជាវិភាគទានមួយតូចសម្រាប់ជួយជម្រុញនិងអភិវឌ្ឍភាសាខ្មែរឱ្យមានការរីកចម្រើន លើសពីនេះការសិក្សានេះគឺជាជាត្រួសត្រាយផ្លូវសម្រាប់អ្នកជំនាន់ក្រោយឱ្យមានភាពងាយស្រួល។

---

[៣៨] កេង វ៉ាន់សាក់: *មូលភាពក្នុងការបង្កើតពាក្យថ្មី* ដូចឯកសារមុន ទំព័រ៣៨៥។

## ឯកសារយោង

### ១. សៀវភៅ : វចនានុក្រម សារណា និង អត្ថបទ

- កេង វ៉ាន់សាក់ : *មូលភាពក្នុងការបង្កើតពាក្យថ្មី* ភ្នំពេញ ១៩៦៤ ៦៦២ទំព័រ។
- ក្រសួងអប់រំ : *វេយ្យាករណ៍ថ្នាក់ទី៥* មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ ១៤៧ទំព័រ។
- ក្រសួងអប់រំ : *វេយ្យាករណ៍ថ្នាក់ទី៦* មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨២ ១៥០ទំព័រ។
- ក្រសួងអប់រំ : *វេយ្យាករណ៍ថ្នាក់ទី៧* មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ ២០២ទំព័រ។
- ក្រសួងអប់រំ :*វេយ្យាករណ៍ថ្នាក់ទី៨* គ្រឹះស្ថានបោះផ្សាយអប់រំ ភ្នំពេញ ១៩៨៦ ១៧៨ទំព័រ។
- ក្រសួងមហាផ្ទៃ : *ប្រកាសលេខៈ៤៩៣ ប្រ. ក. ស្តីអំពី ការកំណត់ចំនួនឈ្មោះ និង ព្រំប្រទល់ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា* ២០០១ ៣៦៩៧ទំព័រ។
- ខៀវ ជុំ : *វេយ្យាករណ៍យើង* (សម្រាប់បឋមសិក្សាបឋមភូមិអាទិកដ្ឋាន) ភ្នំពេញ បោះពុម្ពផ្សាយដោយ ទៀន ហុងសេង ១៩៦៦ ១៧៤ទំព័រ។
- គីម សែត : *វេយ្យាករណ៍ទំនើប នឹងវិធីសម្ពន្ធ* (សម្រាប់សិស្សថ្នាក់ទី៤ នឹងទី៣ទំនើបនៃវិទ្យាល័យ និង អនុវិទ្យាល័យ) ការផ្សាយរបស់បណ្ណាគារ វង់ រស្មី កំពង់ចាម ឆ្នាំ? ១០៩ទំព័រ។
- ដួង ហេង : *វេយ្យាករណ៍បារាំងពន្យល់ជាខ្មែរ* ***Grammaire Française Explequée en Khmer*** បោះពុម្ពលើកទី១ ភ្នំពេញ ១៩៧៣ ៣៣៤ទំព័រ ។
- ឌឹក គាម : " ភាសាសាស្ត្រ នឹង អក្សរសាស្ត្រ " នៅក្នុងៈ *ទស្សនាវដ្តី កម្ពុជសុរិយា* ឆ្នាំទី៣៤ លេខ៥ ខែឧសភា ១៩៦២ ទំព័រ៥៥៥-៥៦៥។
- ឌឹក គាមៈ " ភាសាសាស្ត្រ នឹង អក្សរសាស្ត្រ " នៅក្នុងៈ *ទស្សនាវដ្តី កម្ពុជសុរិយា* ឆ្នាំទី៣៤ លេខ៦ ខែមិថុនា ១៩៦២ ទំព័រ៦៦៧-៦៨៤។
- ឌឹក គាមៈ " ភាសាសាស្ត្រ នឹង អក្សរសាស្ត្រ " នៅក្នុងៈ *ទស្សនាវដ្តី កម្ពុជាសុរិយា* ឆ្នាំទី៣៤ លេខ៧ ខែកក្កដា ១៩៦២ ទំព័រ៧៧៦-៧៩០។
- ឌឹក គាមៈ " ភាសាសាស្ត្រ នឹង អក្សរសាស្ត្រ " នៅក្នុងៈ *ទស្សនាវដ្តី កម្ពុជាសុរិយា* ឆ្នាំទី៣៤ លេខ៨ ខែសីហា ១៩៦២ ទំព័រ៩០១-៩១៤។

- តិប យក់ និង ថាវ គន្ធ: *វចនានុក្រមបារាំង-ខ្មែរ* ***Petit Dictionnaire Français-Khmer,*** 1ère édition បណ្ណាគារភ្នំពេញ ១៩៦៧ ១៣៧៧ទំព័រ។

- ថោង ផៃលៈ " កម្មវាចកៈក្នុងភាសាខ្មែរ " នៅក្នុងៈ *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ២៥-៣៨។

- ថោង ផៃល : "សម្ភាសន៍អក្សរសាស្ត្រសម្ដេចសង្ឃរាជ ជួន ណាត" នៅក្នុង : *ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី៣ លេខ៣ ខែឧសភា ឆ្នាំ២០០២ ទំព័រ១២១-១៣៤ ។

- នៅ ស៊ុន : " ភាសាខ្មែរក្នុងចំណោមភាសាអ៊ីស្សូឡង់ និង ភាសាមិនមែនអ៊ីស្សូឡង់ " នៅក្នុង : *ស៊ន សំណាង ( អ្នកបោះពុម្ពផ្សាយ) ខេមរវិទ្យា ( ចំណេះដឹងអំពីអតីតកាល និង ការរួមវិភាគទានក្នុងការស្ដារ និង ស្ថាបនាប្រទេសកម្ពុជាឡើងវិញ )* ភាគទី២ ១៩៩៨ ទំព័រ៧៣៨-៧៤០។

- ពូវ អ៊ុម : *វេយ្យាករណ៍ខ្មែរ* ( សំរាប់ថ្នាក់មធ្យមដ្ឋាន និង ឧត្ដមដ្ឋាន) ភ្នំពេញ បណ្ណាគារគីម សេង បោះពុម្ពលើកទី៥ ១៩៧២ ១១២ទំព័រ។

-ព្រុំ ម៉ល់ : " លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យក្នុងភាសាខ្មែរ " នៅក្នុង : *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ៦៥-៨២។

-ព្រុំ ម៉ល់ : " អំពីលក្ខណៈវិនិច្ឆ័យរូបនិយម " នៅក្នុង : *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី៣ លេខ៣ ខែឧសភា ឆ្នាំ២០០២ ទំព័រ៣៧-៥២។

- រស់ ឆោម : *គន្លឹះអនុពាក្យ ( សម្គាល់ពាក្យខ្មែរ និង ចំណាំអក្សរ រ)* ភ្នំពេញ បណ្ណាគារវិជ្ជាទិព្វ ១៩៧២ ២៥៦ទំព័រ។

- លី ធាមតេងៈ *សិក្សាសង្ខេបអំពីអារ្យធម៌ខ្មែរ* ភ្នំពេញ បណ្ណាគារសេង ងួនហួត បោះពុម្ពលើកទី២ ១៩៦៩ ៨៥ទំព័រ។

- វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ រោងពុម្ពកម្ពុជា ១៩៦៧-៦៨ ១៨៥៨ទំព័រ។

- វង្ស មេង : *ពាក្យផ្ទួនក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់មហាវិទ្យាល័យ ថ្នាក់បរិញ្ញាប័ត្រ អក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២០០០ ៧២ទំព័រ។

- សុង ស៊ីវ : *ចលនាអារ្យធម៌* ភាគទី១ ភាគទី២ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ព លើកទី១ ១៩៧១ ៣០៦ទំព័រ។

- សុង ស៊ីវ : *ភាសាវិវុទ្ធិ ( ការនិយាយនឹងការអានត្រឹមត្រូវតាមលំនាំភាសាជាតិ)* ការផ្សាយរបស់រោងពុម្ពជាតិ ១៩៥៨ ៤២ទំព័រ។

- សេខ នាង : *បាលីវេយ្យាករណ៍* (សម្រាប់សិស្សសាលាពុទ្ធិកបឋមសិក្សាថ្នាក់ដំបូង) បោះពុម្ពផ្សាយដោយគីម សេង បោះពុម្ពគ្រាទី៤ ១៩៦៨ ២៧១ទំព័រ ។
- ហួត តាត : *គន្ថមាលាទី៧ វេយ្យាករណ៍សំស្ក្រឹត* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៩៩ (បោះពុម្ពឡើងវិញ តាមច្បាប់ដើមដែលបោះពុម្ពលើកទី២ ១៩៥៦) ១៨៣ទំព័រ ។
- ឡុង សៀម : *បញ្ហាវចនសព្ទវិទ្យា (Problèmes de Lexicologie Khmère)* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ១៩៩៩ ១១៣ទំព័រ ។
- ឡុង សៀម : " អំពីកិត្យានុភាព និង ការអភិវឌ្ឍន៍ភាសាខ្មែរ " នៅក្នុង: *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ១៧-២៣ ។
- ឡុង សៀម : " កំណកំណើតវាក្យស័ព្ទតាមផ្នត់នីយកម្មក្នុងភាសាខ្មែរបុរាណ " នៅក្នុង : *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី៣ លេខ៣ ខែឧសភា ឆ្នាំ២០០២ ទំព័រ៨៩-១០០ ។
- ឡុង សៀម: " សិលាចារឹកកម្ពុជា (ស.វ ទី៦-១៤) និង ការអភិវឌ្ឍន៍សង្គមវប្បធម៌ នៅតំបន់ភ្នំដងរែក " នៅក្នុង: *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី៣ លេខ៣ ខែឧសភា ឆ្នាំ២០០២ ទំព័រ១-៦ ។
- ឡុង សៀម : *ស្ថាននាមវិទ្យាខ្មែរ (តាមឯកសារសិលាចារឹកប្រទេសកម្ពុជា សតវត្សទី VI-XIV* ***(Toponymie Khmère : D'après Les inscriptions du Cambodge du VIe-XIVe siecles)*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ រោងពុម្ពខ្មែរអន្តរជាតិ បោះពុម្ព លើកទី១ ១៩៩៧ ១៥០ទំព័រ ។
- ឡុង សៀម : *ទំនាក់ទំនងភាសាមន-ខ្មែរ ជាមួយភាសាផ្សេងៗ* ***(Contacts Externes des Langues Mon-Khmer)*** បកប្រែពីភាសាបារាំងដោយ ប៊ី សុខគង់ រាជបណ្ឌិតសភាកម្ពុជា វិទ្យាស្ថានភាសាជាតិ ១៩៧៨ ៤៧ទំព័រ ។
- ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦-៨)* បោះពុម្ពដោយរោងពុម្ពភ្នំពេញ ២០០០ ៦៤១ទំព័រ ។
- អៀវ កើស : *ភាសាខ្មែរ (ការល្បងពិនិត្យដោយរកហេតុផល)* បោះពុម្ពផ្សាយឡើងវិញដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន ១៩៩៩ ៣៦៧ទំព័រ ។

**កាសែតរស្មីកម្ពុជា**

**ទស្សនាវដ្តីស្វែងរកការពិត** : លេខ១០, លេខ១៣ , លេខ១៤ , លេខ១៥ , លេខ១៦ , លេខ១៧ , លេខ១៨ , លេខ១៩ , លេខ២០ , លេខ២២ , លេខ២៤ , លេខ២៥ , លេខ២៧ ។

- Aitchison (Jean), ***Linguistics***, $3^{rd}$ ed., London, Hodder and Stoughton, 1987, 206p.
- Bolinger (Dwight), ***Aspects of Language***, $2^{nd}$ edition, New York, Chicago, San Francisco, Atlanta, Harcourt Brace Jovanovich, Inc, 1975, 682p.
- Chau Seng, ***Modern Writing Cambodian***, Phnom Penh, Université Buddhique Preah Sihanouk Raj, 1962, 59p.
- ***Cambridge Iternational Dictionary of Idiom***, Cambridge University Press, 1998, 587p.
- Cheng Lim (Tan), ***200 Hints on Practical English Structures***, Singapore, Hillview Publications Pte Ltd, 1989, 426p.
- Chevalier (Jean-Claude) et al., ***Grammaire Larousse du Français Contemporain***, Paris, Librairie Larousse, 1964, 495p.
- Daniel (Alain), *វចនានុក្រមខ្មែរ-បារាំង dictionnaire pratique Cambodgien-Français*, Paris, Institut de L'Asie du sud-est, 1985, 629p.
- Eastwood (John), ***Oxford Guide to English Grammar***, Oxford University Press, 1994, 446p.
- Finegan (Edward), Blair (David) and Collins (Peter), ***Language. Its structure and use***, $2^{nd}$ edition, Sydney, Harcourt Brace, 1997, 526p.
- ***Harrap's Shorter French and English Dictionary***, Edited by MANSION, J. E., complete in one volume with supplements, London, Toronto, Wellington, Sydney, George G. Harrap & Company LTD, 1958, 1628p.
- Heny (Frank), "Syntax: The structure of sentences" in: Virginia P. Clark, Paul A. Eschholz & Alfred F. Rosa (Editor), ***Language. Reading in Language and Culture***, $6^{th}$ edition, Boston, New York, Bedford/St. Martin's, 1998, p.189-224.
- Headley (Robert Kirt) et al., ***Cambodian-Enlish Dictionnary*** , Washington DC, The Catholic University of America Press, 1977, 1495p.
- Huffman (Franklin E.) and Proum (Im), ***English-Khmer Dictionary*** *វចនានុក្រម អង់គ្លេស-ខ្មែរ*, New Haven and London, Yale University Press, 1978, 690p.
- ***International Encyclopedia of the Social Science***, David L. Sills Editor, volume9, New York, The Macmillan Company & The Free Press, London, Collier-Macmillan Publishers, 1968, p. 351-386.
- Jacob (Judith M.), ***A Concise Cambodian-English Dictionary***, $1^{st}$ pulished, Oxford University Press, Antony Rowe Ltd, Chippenham, 1974, 242p.
- Jacob (Judith M.), ***Introduction to Cambodian***, Oxford University Press, 1990, 341p.
- Jacob (Roderick A.), ***English Syntax: A Grammar for English Language Professionals***, Oxford University Press, 1995, 378p.
- Khin Sok, ***La Grammaire du Khmer Moderne*** *វេយ្យាករណ៍ ភាសាខ្មែរ*, Paris, edition You-Feng, Librairie éditeur, 1999, 620p.
- ***Le Petit Larousse Encyclopédique***, direction éditoriale, Patrice Maubour Guet, Paris, Larousse, 1995, 1784p.
- Maspero (Georges), ***Grammaire de la langue Khmère***, Paris, Imprimerie Nationale, 1915, 486p.
- Martinet (André), ***Elements of General Linguistics***, Translated by Elisabeth Palmer, London, Faber and Faber Ltd, 1960, 228p.

- McCarthy (Michael), O'Dell (Felicity) and Shaw (Ellen), ***Vocabulary in use upper intermediate***, Cambridge University Press, 1997, 291p.
- ***Oxford Advaced Learner's Encyclopedic Dictionary***, Jonathan Crowther (editor), Oxford University Press, 1992, 1081p.
- Petit (CH.) & Savage(W.), ***Dictionnaire Français Anglais***, Librairie Hachette. 1946, 1379p.
- Quirk (Randolph) et al., ***A Grammar of comtemporary English***, 1st edition, Singapore, Longman Group Ltd, 1972, 1120p.
- Redman (Stuart) with Shaw (Ellen), ***Vocabulary in use intermediate***, Cambride University Press, 1999, 266p.
- Richards (Jack C.), Platt (John) & Platt (Heidi), ***Longman Dictionary of Language Teaching and Applied Linguistics***, 2nd edition, Singapore, Longman Group, 1992, 423 p.
- Sharpe (Pamela J.), ***How to prepare for the TOEFL Test( Test of English as a foreign Language)***, 9th edition, New York, Barron's Educational Series, Inc, 1999, 696 p.
- Sak-Humphry (Chhany), ***Khmer Nouns and Nouns Phrases. A Dependency Grammar Analysis***, 353p. A Dissertation of Linguistics, a Dissertation submitted for the Degree of Doctor of Philosophy in Linguistics, University of Hawaii, UMI Company, 1996.
- Saussure (Ferdinand de), ***Course in General Linguistics***, Translated by Wade Baskin, New York, Toronto, London, McGraw-Hill Book Company, 1959, 240p.
- Thong Thel, ***Compound Nouns in Cambodian***, 257p. Thesis submitted for the degree of Master of Arts in the Department of Linguistics, Monash University, Malbourne, February 1978.
- Thong Thel, ***Noun Formation in Cambodian***, 101p. Minor thesis submitted to the department of Linguistics, Monash University, Malbourne, February 1976.
- Tandart (S), ***Dictionnaire Cambodgien-Français***, deuxième Partie de ប៊ à ឡៀ. Phnom Penh, Imprimerie Albert Portail, 1935, 2466p.
- ***Webster's New World™ College Dictionary***, 3rd edition, Victoria Neufeldt (editor in chief) David B. Guralnik (editor in chief Emeritus).USA, Macmillan, 1996, 1574p.

## មាតិកាអត្ថបទ

១. ប្រវត្តិពាក្យសមាស ........ ទំព័រ៨៩
២. និយមន័យ ........ --៩១
៣. លក្ខណៈវិនិច្ឆ័យនៃពាក្យសមាស ........ --៩៣
៣.១.លក្ខណៈវិនិច្ឆ័យផ្អែកលើសន្ធិ ........ --៩៤
៣.១.១. និយមន័យសន្ធិ ........ --៩៤
៣.១.២. លក្ខណវិនិច្ឆ័យផ្អែកលើតេស្ត ........ --៩៥
៣.១.២.១. តេស្តដែក ........ --៩៥
៣.១.២.២. តេស្តតំណាក់កត្តារូម ........ --៩៥
៣.១.២.៣. តេស្តកំណាត់ ........ --៩៦
៣.១.២.៤. តេស្តតំណូរ ........ --៩៦
៣.២. លក្ខណៈវិនិច្ឆ័យផ្អែកលើសម្ព័ន្ធ ........ --៩៧
សន្និដ្ឋាន ........ --៩៨
**គន្ថនិទ្ទេស** ........ --៩៩

# ចំណុចគួរកត់សម្គាល់ ក្នុង ភាសាខ្មែរបច្ចុប្បន្ន

វិភាគដោយ សាស្ត្រាចារ្យបណ្ឌិត ពុំ ម៉ល់

----------

ក្នុងទស្សនាវដ្ដីលេខ២ ចេញនៅខែមិថុនាឆ្នាំ២០០១ របស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ខ្ញុំបានចុះផ្សាយអត្ថបទមួយស្ដីពីការបង្កើតពាក្យក្នុងភាសាខ្មែររួចម្ដងមកហើយ ប៉ុន្តែ ដោយអត្ថបទនោះមានលក្ខណៈទូទៅទូលំទូលាយពេក ខ្ញុំឥតបានពិនិត្យចំណុចបច្ចុប្បន្នភាពអោយបានគ្រប់ជ្រុងជ្រោយទេ។ លើកនេះ ខ្ញុំសុំ ( អនុញ្ញាត ) យកការបង្កើតពាក្យមកពិនិត្យពិចារណាឡើងវិញ ដោយសង្កត់លើចំណុចបច្ចុប្បន្នភាព ព្រមទាំងចំណុចបច្ចុប្បន្នភាពផ្សេងៗខ្លះទៀត បើមានឱកាសល្អ ។

ក្នុងការពិនិត្យពិចារណាលើចំណុចទាំងប៉ុន្មាន ខ្ញុំនឹងគោរពគោលការណ៍គ្រឹះមួយចំនួន គឺ : ១- មិនត្រូវច្រឡំ/លាយឡំភាសានិងអក្ខរាវិរុទ្ធរបស់ភាសាទេ ; ២-ចៀសការបង្កើតក្បួនក្រៅភាសាដើម្បីបង្ខំអោយភាសាដើរតាម ; ៣-បញ្ញត្តិគន្លឹះណា ដែលមិនទាន់រត់របត់ ត្រូវទទួលការកំណត់ន័យអោយច្បាស់លាស់ ( ដូចក្នុងគណិតវិទ្យា/រូបវិទ្យាដែរ) ដើម្បីអោយមានព្រំដែនជាក់លាក់ក្នុងការពិនិត្យពិចារណា កុំអោយមានការលាយឡំនាំអោយច្រឡំ ។

## ១- ការសង្កេតប្រមើលមើល :

### ១.១- ស្ថានភាពវិជ្ជមាន :

ចំពោះការបង្កើតពាក្យ សមាជជាតិ[១] ស្ដីពីភាសាខ្មែរកាលពីឆ្នាំ២០០០ បានស្នើអោយយកវិធីកម្លាយនិងវិធីសមាសបែបខ្មែរសុទ្ធសាធជាជម្រើសទី១ មុននឹងឈានទៅដល់វិធីផ្សំធាតុបាលី (ឬ សំស្ក្រឹត) ឬ វិធីសមាស[២] បែបបាលី/សំស្ក្រឹត ។ ចំពោះវិធីបែបបាលី/សំស្ក្រឹតនោះទៀត ខ្មែរមួយចំនួនតែងតែទទូចសុំអោយយកពាក្យ ដែលមានស្រាប់ក្នុងភាសាខ្មែរ មកបំបែកដើម្បីអោយមានជាសន្តានពាក្យ កុំអោយពាក្យក្នុងភាសានេះមានភាពរប៉ាត់រប៉ាយ ។ ស្របនឹងសំណើទាំងនេះ យើងសង្កេតឃើញមានពាក្យថ្មីៗ ដូច

---

(១) - សមាជរៀបរៀងដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា នៅថ្ងៃ ៧-៩ កញ្ញា ឆ្នាំ២០០០ ភ្នំពេញ ។

(២) - ខ្ញុំប្រើកន្សោម "វិធីផ្សំធាតុ" និងកន្សោម "វិធីសមាស" ក្នុងន័យប្លែកគ្នា : វិធីផ្សំធាតុទាក់ទងនឹងការផ្សំធាតុ (ដែលត្រូវមានកម្ទេចពាក្យមួយរូបយ៉ាងតិច) ដើម្បីបង្កើតពាក្យថ្មី ដូច ប្រជាធិបតេយ្យ/អនុប្រធាន,... រីឯវិធីសមាសវិញ វាជាវិធីផ្សំពាក្យ គឺ ពាក្យ + ពាក្យ ដូច ព្រះពុទ្ធសាសនា (សាសនាព្រះពុទ្ធ) សប្បុរសជន (ជនសប្បុរស) -ល-។ ចំពោះវិញ្ញត្តិ "កម្ទេចពាក្យ " គប្បីសាធារណជនជ្រាបថា វិញ្ញត្តិនេះ (ខ្ចីពីលោក អៀវ កើស) សម្គាល់ធាតុដែលមិនមែនជាពាក្យឯករាជ្យក្នុងភាសា មានរូបស័ព្ទ (morphèmes) ទាំងប៉ុន្មាន និង ធាតុបាលី/សំស្ក្រឹតប្រើក្នុងភាសាខ្មែរ ដូច ប្រជា ( ប្រជាជន /ប្រជាករ/ប្រជាជាតិ/ប្រជាប្រិយ,... ) ប័ត្រ (សញ្ញាប័ត្រ/វិញ្ញាបនប័ត្រ/ព្រឹត្តិប័ត្រ,... ) -ល- ។

កំណើនសេដ្ឋកិច្ច ប្រាក់កម្ចី[៣] ខ្មាន់កាំភ្លើង ធុរជន (businessman) កសិដ្ឋាន/កសិផល វិនាសកម្ម វិចារណកម្ម ពលកម្ម/ពលករ និរទណ្ឌភាព ឯកោ ឯកតោភាគី -ល- ដែលជាផលិតផលដ៏វិជ្ជមាន ។

**១.២ - ស្ថានភាពអវិជ្ជមាន :**

ក្រៅពីអភិវឌ្ឍន៍ដ៏សមស្របខាងលើ យើងក៏បានប្រទះឃើញស្ថានភាពអវិជ្ជមានផងដែរ គឺ ការបង្កើតពាក្យក្នុងស្ថានភាពមិនស្របនឹងប្រព័ន្ធកម្លាយពាក្យដែលមានមកស្រាប់ ការបង្កើតពាក្យក្នុងភាពស្ទាក់ស្ទើរ/ស្ទាបស្ទង់ និង ការបង្កើតពាក្យថ្មីដើម្បីជំនួសពាក្យចាស់ ដោយឥតសមហេតុផល គ្មានការចាំបាច់-ល-។

**១.២.១ - ការបង្កើត/ប្រើពាក្យក្នុងស្ថានភាពមិនស្របនឹងប្រព័ន្ធកម្លាយពាក្យដែលមានមកស្រាប់ :**

ថ្មីៗនេះ ខ្ញុំបានឃើញ ក្នុងប្រកាសមួយដែលបិទលើទ្វារនៃបន្ទប់រៀនមួយ នូវពាក្យ "រង្វាយតម្លៃ" ក្នុងន័យថា "ការវាយតម្លៃ"។ ពីមុនៗមក នាមស័ព្ទ ដែលកើតពីបុព្វបទ/រង់-/ សុទ្ធតែជាពាក្យសម្គាល់ឧបករណ៍ ឧ. រង្វាស់ = ឧបករណ៍សម្រាប់វាស់ ; រង្វាល់ = ឧបករណ៍សម្រាប់វាល់ ; រង្វឹង = ប្រដាប់សម្រាប់ព័ទ្ធសូត្រ/ អំបោះ -ល- ។

ធាតុ ដែលគេប្រើក្នុងស្ថានភាពមិនស្របនឹងគំរូដែលមានមកស្រាប់ គឺធាតុ "រំ" និង ធាតុ "លំ" ប្រើជាបុព្វបទ។ ខ្ញុំបានប្រទះឃើញពាក្យ :

- ភាពរំញ័រ : "កុំឱ្យមានភាពរំញ័រនិងខ្ទរសម្លេងយន្តហោះប៉ះទៅលើភាពរង្កើរដល់ប្រាសាទអង្គរវត្ត"[៤] ។
- ការលំបាក់ដី : "ការលំបាក់ដីសម្លាប់មនុស្សពានាក់នៅឥណ្ឌូនេស៊ី"[៥] ។

**១.២.២ - ការបង្កើត/ប្រើពាក្យក្នុងស្ថានភាពស្ទាក់ស្ទើរ :**

គេប្រទះឃើញមានការស្ទាក់ស្ទើរពីរបែប : មួយបែបគឺ ស្ទាក់ស្ទើរក្នុងការប្រើប្រាស់ធាតុក្នុងពាក្យកម្លាយចេញពីពាក្យឫសតែមួយ និង មួយបែបទៀតគឺ ស្ទាក់ស្ទើរក្នុងការប្រើប្រាស់ធាតុដែលមានរូបផ្សេងគ្នា តែន័យដូចគ្នា ដើម្បីបង្កើតពាក្យកម្លាយសម្គាល់គំនិតអ្វីមួយ។

**ករណីទី១** : គេប្រទះឃើញ :

- ការ[៦] លំបាក់ដីផង និង ការបាក់ដីផង : ក្នុងអត្ថបទដែលមានចំណងជើងថា : "ការលំបាក់ដីសម្លាប់មនុស្ស

---

[៣] - ក្នុងវចនានុក្រមខ្មែរនៃពុទ្ធសាសនបណ្ឌិត្យ យើងអាចឃើញពាក្យ "កម្ចី" ដែរ ប៉ុន្តែ ជាកម្ចីនៃផ្លែឈើដែលមិនទាន់ទុំ ។

[៤] - "រស្មីកម្ពុជា" ថ្ងៃចន្ទ ០៤-អង្គារ ០៥-០៣-០២ ទំព័រក៥ (< ការកសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប ... ) ។

[៥] - "រស្មីកម្ពុជា" ថ្ងៃសុក្រ ០៨-០២-០២ ទំព័រក៨។ ពាក្យនេះមានប្រើក្នុងលេខក្រោយៗទៀតផងដែរ ដូចជាលេខចេញនៅថ្ងៃចន្ទ ១៦-អង្គារ ១៧-០៩-០២ ទំព័រខ៨ ជាដើម។

[៦] - តាមត្រូវ "លំបាក់ដី" មានន័យថា "ការបាក់ដី" ដូច្នេះហើយ យើងមិនបាច់ប្រើពាក្យ "ការ" ថែមលើ "លំបាក់ដី" ទេ ។

ពានាក់ទៅតណ្ហូនេស៊ី" គេប្រទះឃើញ ក្នុងអត្ថាធិប្បាយ នូវពាក្យ "ការបាក់ដី" ក្នុងល្បះ : "ពួកមន្ត្រីបានបញ្ជូនការព្រមានទៅឱ្យអ្នកស្រុកស្ដីពីលទ្ធភាពនៃការបាក់ដី តែពួកគេមិនព្រមចាកចេញ"[៧] ។

- សកលភាវូបនីយកម្មផង សកលូបនីយកម្មផង & សកលនីយកម្មផង : ពាក្យ "សកលភាវូបនីយកម្ម" ត្រូវបានគេផ្សាយចេញពីស្ថានប័នមួយចំនួនជាញឹកញាប់ ប៉ុន្តែ អ្នកប្រើប្រាស់ភាសាខ្លះហាក់ដូចជាមិនពេញចិត្ត ហើយ បានប្រើពាក្យ "សកលលូបនីយកម្ម" ជំនួសវិញ ដូចមានក្នុងល្បះនេះ : "នៅក្នុងពិភពលោកដែលកំពុងតែមានសកលូបនីយកម្មនេះ ការរាលដាលនៃវប្បធម៌ពីប្រទេសមួយទៅប្រទេសមួយទៀតមិនអាចទប់ស្កាត់បានឡើយ"[៨] ។ លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម បានប្រើពាក្យ "សកលនីយកម្ម" ក្នុងអត្ថបទមួយរបស់គាត់ តែខ្ញុំមិនបានស្រង់ ។
- បច្ចេកវិជ្ជាផង & បច្ចេកវិទ្យាផង : ពាក្យ "បច្ចេកវិជ្ជា" ជាពាក្យបង្កើតដោយគណៈកម្មការវប្បធម៌ ផ្សព្វផ្សាយតាមវចនានុក្រមនិងសទ្ទានុក្រមនានា មានវចនានុក្រមរបស់លោក តិប យក់ & ថាវ គន្ធ ជាដើម ដែលគេស្គាល់ជាទូទៅ ដូច្នេះហើយ អ្នកដឹកនាំក្រសួងអប់រំក៏បានយកពាក្យនេះទៅដាក់ឈ្មោះគ្រឹះស្ថានសិក្សាមួយថា "វិទ្យាស្ថានបច្ចេកវិជ្ជា" ប៉ុន្តែ ដោយឆ្លងពី "គណិតវិទ្យា/រូបវិទ្យា/ប្រវត្តិវិទ្យា... " អ្នកខ្លះក៏បានប្រើពាក្យ "បច្ចេកវិទ្យា" ជំនួសវិញ : "ពង្រីកកម្រិតនៃបច្ចេកវិទ្យាឱ្យដើរស្របទៅនឹងការអភិវឌ្ឍន៍"[៩] / "និស្សិតយកចិត្តទុកដាក់កាន់តែខ្លាំងឡើងក្នុងវិស័យបច្ចេកវិទ្យា ពតិមានវិទ្យានេះ"[១០] ។
- សមាជិកព្រឹទ្ធសភាផង & ព្រឹទ្ធសមាជិកផង : "ព្រឹទ្ធសមាជិកអាមេរិកនិយាយថា ការចាត់ការអ៊ីរ៉ាក់អាចចាប់ផ្ដើមយ៉ាងសម្ងាត់"[១១] ។ អ្នកប្រើប្រាស់ភាសាមិនបានបង្កើតពាក្យ "រដ្ឋសមាជិក" សម្រាប់សម្គាល់សមាជិករដ្ឋសភាទេ ពីព្រោះ យើងមានពាក្យ "តំណាងរាស្ត្រ" រួចហើយ ពិតមែនតែពាក្យនេះឥតមានឫសគល់ជាមួយពាក្យ "រដ្ឋសភា" ក៏ដោយ ។

**ករណីទី២ :**

ការស្ទាក់ស្ទើរក្នុងករណីទី២អាចចាត់ទុកថា ជាជម្រើសរវាងធាតុផ្សេងគ្នា ដែលមានន័យដូចគ្នាសម្រាប់ពាក្យផ្សេងគ្នា តែ សម្គាល់ទង្វើ / លទ្ធផល ដូចគ្នា ។ គេប្រទះឃើញមានជម្រើសរវាង ធាតុ "កម្ម" ធាតុ "ឧបនីយកម្ម" និង ធាតុ "ភាវូបនីយកម្ម" :

---

(៧) - "រស្មីកម្ពុជា" ថ្ងៃសុក្រ ០៨-០២-០៣ ទំព័រ ក៨ ។

(៨) - "រស្មីកម្ពុជា" ថ្ងៃពុធ ១២-០២-០៣ ទំព័រ ក៥ (< ប្រេវិន ) ។

(៩) - "រស្មីកម្ពុជា" ថ្ងៃអាទិត្យ ១០-០១-០៣ ទំព័រ ខ២ (< គង់ហ៊ាន ) ។

(១០) - "រស្មីកម្ពុជា" ថ្ងៃចន្ទ ១៣ & អង្គារ ១៤-០១-០៣ ទំព័រក៦ (< វាសនា ) ។

(១១) - "រស្មីកម្ពុជា" ថ្ងៃពុធ ០៦-០៣-០២ ទំព័រ ក១ ។

- ធាតុ "កម្ម" : "ទំនើបកម្មប្រដាប់អាវុធ"[១២] / វិចារណកម្ម -ល- ។
- ធាតុ "ឧបនីយកម្ម" : "ក្រសួងនគរូបនីយកម្ម" (ដែលយើងស្គាល់គ្រប់គ្នា) / "តាមការស្រាវជ្រាវបុរាណវិទ្យា (...) បានឱ្យដឹងថា ឥណ្ឌារូបនីយកម្ម[១៣] បានចាប់ផ្ដើមឡើងតាំងពីសតវត្សទីពាមុនគ្រិស្តសករាជមកម្ល៉េះ"[១៤] ។
- ធាតុ "ភាវូបនីយកម្ម" : "នយោបាយភាវូបនីយកម្មប្រព័ន្ធផ្សព្វផ្សាយធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការបោះឆ្នោត"[១៥] / "ក្រសួងពាណិជ្ជកម្មនិងអង្គការកម្មសិទ្ធិបញ្ញាសកលលោកបានបើកធ្វើសិក្ខាសាលា (...) ស្ដីពី ពាណិជ្ជភាវូបនីយកម្ម"[១៦] / "អគ្គិសនីភាវូបនីយកម្មទៅតាមទីរួមខេត្តនានាបានដំណើរការជាបន្តបន្ទាប់"[១៧] ។ ដូចយើងបានឃើញរួចមកហើយ ក្នុងចំណោមពាក្យដែលកើតពីធាតុ "ភាវូបនីយកម្ម" ពាក្យ "សកលភាវូបនីយកម្ម" ត្រូវបានគេប្រើជាញឹកញាប់ជាងគេសព្វថ្ងៃនេះ ពីព្រោះ វាសម្គាល់បញ្ញត្តិទាក់ទិននឹងបច្ចុប្បន្នភាព (គំនិតដែលគេកំពុងផ្សព្វផ្សាយ) ។

### ១.២.៣ - ការបង្កើត/ប្រើពាក្យថ្មីដើម្បីជំនួសពាក្យចាស់

ក្នុងការបង្កើតពាក្យថ្មីដើម្បីជំនួសពាក្យចាស់ យើងអាចយល់មូលហេតុចំពោះពាក្យមួយចំនួន : ១- គេចង់បន្ថយចំនួននាមស័ព្ទដែលមាន "ការ" នៅខាងដើម ដូចពាក្យ "ចំណេះដឹង" ដែលជំនួសពាក្យ "ការចេះដឹង" ពាក្យ "ដំណោះស្រាយ" ដែលជំនួសពាក្យ "ការដោះស្រាយ" ,... ២- គេចង់បន្ថយចំនួននាមស័ព្ទកើតដោយធាតុបាលី ដូចពាក្យ "ផ្នត់ដើម" ដែលជំនួសពាក្យ "បុព្វបទ" ពាក្យ "ឈ្នាប់" ដែលជំនួសពាក្យ "សន្ធានស័ព្ទ" ពាក្យ "ធ្នាក់" ដែលជំនួសពាក្យ "និបាតស័ព្ទ" ....

ប៉ុន្តែ ចំពោះពាក្យថ្មីខ្លះទៀត គេពិបាករកមូលហេតុសមហេតុផលណាស់ : ១- បាលីជាបាលី ហើយគ្មានអ្វីគួរចាត់ទុកថាសមស្របជាងមុនទេ ដូចពាក្យ "គុណកិរិយា" ដែលជំនួសពាក្យ "កិរិយាវិសេសន៍" ពាក្យ "ប្រវត្តិរូប" (រូបនៃប្រវត្តិ) ដែលជំនួសពាក្យ "ជីវប្រវត្តិ" (ប្រវត្តិនៃជីវិត),... ២- ខ្មែរជាខ្មែរ តែយកនាមស័ព្ទកម្លាយជំនួសកិរិយាស័ព្ទដើម ហើយ បង្កើតនាមស័ព្ទមួយទៀត ដោយដាក់ "ការ" ខាងដើម :

---

[១២] - "រស្មីកម្ពុជា" ថ្ងៃអាទិត្យ ២០-០៧-០៣ ទំព័រ ខ១ (< រ៉ូហ្សា) ។

[១៣] - ក្នុងពាក្យ "នគរូបនីយកម្ម" មាន "នគរ" + "ឧបនីយកម្ម" ហើយក្នុង "ឥណ្ឌារូបនីយកម្ម" មាន "ឥណ្ឌា" + "រ" + "ឧបនីយកម្ម" បានសេចក្ដីថា មានព្យញ្ជនៈ [រ] បញ្ចើកែ្តកមួយ ដែលគេពុំអាចពន្យល់បាន តាមវិធីបង្កើតពាក្យខ្មែរដែលមានមកស្រាប់ ។

[១៤] - "រស្មីកម្ពុជា" ថ្ងៃសៅរ៍ ២៦-០៤-០៣ ទំព័រខ៣ (< សុពល) ។

[១៥] - "រស្មីកម្ពុជា" ថ្ងៃអាទិត្យ ០១-១២-០២ ទំព័រក១ ។

[១៦] - "រស្មីកម្ពុជា" ថ្ងៃអាទិត្យ ០១-១២-០២ ទំព័រក២ ។

[១៧] - "រស្មីកម្ពុជា" ថ្ងៃសុក្រ ២៣-១១-០១ ទំព័រ ក២ ។

កិរិយាស័ព្ទ "ទាក់ទង"> នាមស័ព្ទ "ទំនាក់ទំនង"> កិរិយាស័ព្ទ "ទំនាក់ទំនង"> នាមស័ព្ទ "ការទំនាក់ទំនង" ។

**១.២.៤ – ការប្រើត្រួតគ្នានូវពាក្យ/ធាតុដែលមានន័យដូចគ្នា :**

គេប្រទះឃើញពាក្យ "តម្លាភាព, គម្លាតភាព, អំពើភេរវកម្ម" -ល- ។ ពាក្យ "តម្លាភាព" ពិតមែនតែមានន័យថា "ភាពនៃភាពថ្លា" តែបានចាក់ឫសយ៉ាងមាំក្នុងស្មារតីខ្មែរម្នាក់ៗ ជាពាក្យដែលមិនអាចរួញទៅវិញអោយនៅសល់តែ "តម្លា" បានឡើយ ។ ពាក្យ "គម្លាតភាព" ត្រូវបានមន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងអប់រំប្រើក្នុងឱកាសតុមូលស្ដីពី "ប្រព័ន្ធអប់រំក្រៅបណ្ដាញ" នៅ ទ.ទ.ក ខែកញ្ញា ២០០២ : ភាគ "ភាព" អាចបាត់ទៅវិញ ។ កន្សោម "អំពើភេរវកម្ម" ដែលក្នុងនោះ "អំពើ"និង"កម្ម"មានន័យដូចគ្នា ត្រូវបានគេប្រើស្ទើរតែរាល់ថ្ងៃ ហាក់ដូចជាធាតុ "កម្ម" ម្នាក់ឯង (ដូចគ្នានឹងធាតុខ្លះទៀតដែរ) មានកម្លាំងមិនគ្រប់គ្រាន់ ។

**២ – ការស្វែងយល់ពីកម្លាយពាក្យក្នុងភាសាខ្មែរ & ការបំផុសអោយចេញជាប្រព័ន្ធ :**

**២.១ – ស្ថានភាព នៃ ស័ព្ទវេយ្យាករណ៍**[១៨] (outils grammaticaux) **:**

**២.១.១ – កង្វះឯកភាពក្នុងការប្រើពាក្យសម្គាល់ ស័ព្ទវេយ្យាករណ៍ សម្រាប់បង្កើតពាក្យ :**

ដើម្បីពណ៌នាពីប្រព័ន្ធកម្លាយពាក្យ យើងត្រូវការប្រើពាក្យបច្ចេកទេសមួយចំនួន ដែលត្រូវនឹងពាក្យ affixe, préfixe, infixe, suffixe នៃភាសាបារាំង/អង់គ្លេស ហើយ ដែលខ្មែរមិនទាន់មូលមតិគ្នា មិនទាន់ប្រើពាក្យដូចគ្នា នៅឡើយ ។

សមាជិកក្រុមជំនុំធ្វើវចនានុក្រមខ្មែរ ក្រោមអធិបតិយភាពនៃសម្ដេចព្រះសង្ឃរាជ ជួន ណាត បានប្រើពាក្យ "បុព្វបទ" ក្នុងន័យស្របនឹងពាក្យ "préfixe" នៃភាសាបារាំង តែអស់លោកទាំងនោះ ឥតមានការចាំបាច់ត្រូវប្រើពាក្យខ្មែរស្របនឹងពាក្យ"affixe"ទេ ។ ចំពោះពាក្យស្របនឹងពាក្យ "suffixe" គេអាចយកតាមវេយ្យាករណ៍បាលីដែលប្រើពាក្យ "បច្ច័យ" ប៉ុន្តែ នៅសម័យនោះ គេនៅខ្វះពាក្យខ្មែរស្របនឹងពាក្យ "infixe" នៃភាសាបារាំង/អង់គ្លេសនៅឡើយ ដូច្នេះហើយបានជាលោក អៀវ កើស[១៩] បានធ្វើសំយោគមួយ ដោយរក្សាទុកនូវពាក្យដែលមានស្រាប់និងបន្ថែមពាក្យថ្មី ដូចនេះ[២០] :

បទភ្ជាប់ (affixes) = បុព្វបទ (préfixes) + បទជ្រែក (infixes) + បច្ច័យ (suffixes) ។

---

(១៨) - ខ្ចីពាក្យ "ស័ព្ទវេយ្យាករណ៍"នេះពី លោក អៀវ កើស *ភាសាខ្មែរ* បណ្ណាគារមិត្តសេរី ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ ២១៧ ។

(១៩) - Ibid ទំព័រ ១៦៨-១៦៩ ។

(២០) - សូមកុំច្រឡំ "ដូចនេះ" ដែលជាកន្សោមសេរី ("ដូច" + "នេះ" : ដូចនេះ /ដូចនោះ /ដូចខាងក្រោមនេះ / ដូចខាងលើនេះ /ដូចពួសុខ / ដូចពួសៅ,... ) និង "ដូច្នេះ" ដែលជាកន្សោមផ្សារជាប់ ក្លាយទៅជានិបាតស័ព្ទ/កិរិយាវិសេសន៍ ហើយ មានន័យថា "អាស្រ័យហេតុនេះ ។

ដោយពាក្យខាងលើមានភាពរប៉ាត់រប៉ាយ លោក កេង វ៉ាន់សាក់[២១] បានបង្កើតពាក្យជាចង្កោម ដូចខាងក្រោមនេះ :

អក្ខាសបទ = បុព្វបទ + អន្តរាបទ + បច្ឆិមបទ ។

ប៉ុន្តែ ដោយមានបំណងចង់បន្ថយពាក្យកើតពីធាតុបាលី/សំស្ក្រឹត សិស្សានុសិស្សរបស់គាត់បានប្រើពាក្យ "ផ្នត់" ជំនួសវិញ[២២] :

ផ្នត់ = ផ្នត់ដើម + ផ្នត់ជែក + ផ្នត់ចុង ។

ខ្ញុំបានអានសៀវភៅលោក កេង វ៉ាន់សាក់ កាលជាងសាមសិបឆ្នាំមុន ខ្ញុំមិនចាំវាក្យស័ព្ទរបស់គាត់[២៣] ខ្ញុំបានប្រើពាក្យ "មូលបទ" ត្រង់កន្លែងដែលគាត់ប្រើពាក្យ "អក្ខាសបទ" នៅពេលដែលខ្ញុំសរសេរអត្ថបទស្ដីពីការបង្កើតពាក្យ ( ដូចខ្ញុំបានរំលឹកនៅខាងដើមអត្ថបទនេះ ) ដូច្នេះហើយ វាក្យស័ព្ទរបស់ខ្ញុំមានដូចតទៅ :

មូលបទ = បុព្វបទ + អន្តរបទ (> អន្តរាបទ > អន្តេបទ)[២៤] + បច្ឆិមបទ ។

ដើម្បីប្រែ[២៥] សៀវភៅរបស់គាត់សរសេរជាភាសាបារាំង ឈ្មោះថា "La grammaire du khmer moderne" លោក ឃិន សុខ បានសម្រេចចិត្តយកពាក្យ "បទ" ជំនួស "អក្ខាសបទ/មូលបទ/បទភ្ជាប់/ផ្នត់" ហើយគាត់ប្រើវិធីសមាសដូចក្រុមអ្នក "ផ្នត់និយម" ដែរ គឺ :

បទ = បទដើម + បទជែក + បទចុង ។

ខ្ញុំយល់ថា ចាប់ពីករណីដែលមានពាក្យជាចង្កោមមក ( ចាប់ពីវាក្យស័ព្ទរបស់លោក កេង វ៉ាន់សាក់) យើងចង់យកវាក្យស័ព្ទណាក៏បាន ប៉ុន្តែ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំសម្រេចចិត្តប្រើវាក្យស័ព្ទដែលមានធាតុបាលី គឺ :

អក្ខាសបទ/មូលបទ = បុព្វបទ + អន្តេបទ + បច្ឆិមបទ

ពីព្រោះ ខ្ញុំមិនចង់អោយពាក្យថ្មីជំនួសពាក្យចាស់ដោយគ្មានការចាំបាច់ផង និង មិនចង់អោយពាក្យបច្ចេក-

---

(២១) - កេង វ៉ាន់សាក់ "មូលភាពនៃការបង្កើតពាក្យថ្មី " រោងពុម្ពទេព ឆ្នាំ ១៩៦៤ ភ្នំពេញ ទំព័រ១៤២ ( អក្ខាសបទ) ទំព័រ១៤៣ ( បុព្វបទ) ទំព័រ១៥០ ( បច្ឆិមបទ) ទំព័រ១៥៩ ( អន្តរាបទ) ។

(២២) - ក្រៅពីពាក្យមួយចំនួន ដូច "ផ្នត់/ឈ្នាប់/ធ្លាក់,..." សិស្សានុសិស្សទាំងនោះបានទទួលយកគំនិតនិងពាក្យរបស់គ្រូគាត់ ដូចពាក្យ "កម្មបទ", "គុណកិរិយា" ជាដើម (Ibid ទំព័រ ៣៨១ និង ៦០៣) ដើម្បីជំនួសពាក្យ "កម្មរង" និង "កិរិយាវិសេសន៍" ដែលមានមកពីមុនរួចហើយ ។

(២៣) - ខ្ញុំទើបតែបានអានសៀវភៅនោះឡើងវិញ ។

(២៤) - បណ្ឌិត នៅ ស៊ុន បានស្នើអោយទុកពាក្យ "អន្តរាបទ" សម្រាប់ប្រែពាក្យបារាំងថា "interfixe" : ក្រោយពីបានពិចារណាយូរបន្តិចមក ខ្ញុំក៏បានយល់ស្របនឹងគំនិតរបស់គាត់ ហើយ ប្រែពាក្យបារាំង "infixe"ថា "អន្តេបទ" វិញ។

(២៥) - ខ្ញុំក៏បានរួមចំណែកក្នុងបម្រែនោះដែរ ។

ទេសក្នុងវេយ្យាករណ៍/ភាសាវិទ្យាមានភាពរប៉ាត់រប៉ាយ[២៦] ផង។ ម៉្យាងទៀត ក្នុងពាក្យបច្ចេកទេស យើងត្រូវការអរូបិយភាពខ្លាំង : ពាក្យបច្ចេកទេសដ៏ប្រសើរ គឺពាក្យដែលគ្មានន័យក្នុងភាសាខ្មែរសាមញ្ញ ហើយន័យរបស់វា គឺន័យដែលគេបានកំណត់អោយក្នុងភាពបច្ចេកទេស ដោយគ្មានពហុន័យ គ្មានន័យពាំត្រណោត។

**២.១.២ - កង្វះឯកភាពក្នុងការកំណត់ន័យអោយ ស័ព្ទវេយ្យាករណ៍ សម្រាប់បង្កើតពាក្យ :**

កង្វះឯកភាពក្នុងការប្រើប្រាស់ពាក្យជាបញ្ហាមួយ ប៉ុន្តែ ជាបញ្ហា "សើស្បែក" : កង្វះឯកភាពក្នុងការប្រើពាក្យមិនមែនជាឧបសគ្គធំចំពោះវេយ្យាករណ៍/ភាសាវិទ្យាទេ អោយតែដឹងថា "ផ្នត់" ត្រូវនឹង "បទ" ត្រូវនឹង "អព្ភាសបទ" ត្រូវនឹង "មូលបទ" ។

ប៉ុន្តែ កង្វះឯកភាពក្នុងការកំណត់ន័យជាបញ្ហាធំធេងខ្លាំង នាំអោយស្តាប់គ្នាមិនបានរវាងអ្នកវេយ្យាករណ៍/អ្នកភាសាវិទ្យា ។ ក្នុង "ភាសាខ្មែរ" របស់លោក អៀវ កើស[២៧] គេអាចសន្និដ្ឋានថា ពាក្យ "ស្រាយ" ជាប់ជាសន្តានជាមួយពាក្យ "ត្រាយ" ពីព្រោះ ពាក្យទាំងពីរនេះមានឫស "រាយ"ជាមួយគ្នា / ថា ពាក្យ "ស្រាយ" ជាប់សន្តានជាមួយពាក្យ "ស្អាប់" / "ស្អាល់" ពីព្រោះ ពាក្យទាំងបីនេះមាន "បុព្វបទ" "ស-" ជាមួយគ្នា / ថា "ត្រាយ" ជាប់សន្តានជាមួយពាក្យ "ថ្មៀប" / "ធ្លុះ" ពីព្រោះ ពាក្យទាំងបីនេះមាន "បុព្វបទ" "ត-" ជាមួយគ្នា -ល- ។ ដោយផ្អែកលើវិធីប្រហាក់ប្រហែលគ្នានេះ អ្នកខ្លះបានអះអាងថា ពាក្យ "ក្រមុំ" ជាប់ជាសន្តានជាមួយពាក្យ "ក្រពុំ" ជាមួយពាក្យ " ដុំ " ជាមួយពាក្យ " រុំ " -ល- / ថាពាក្យ "ទាហាន" ជាពាក្យផ្សំ កើតដោយ "ទា" (សត្វទា) + "ហ៊ាន" (កិរិយាស័ព្ទ) -ល- ។

ការសន្និដ្ឋាន ឬ ការអះអាងខាងលើសុទ្ធតែផ្អែកលើគំនិតដែលមិនទាន់បានទទួលការពិនិត្យពិចារណានិងការវិភាគថ្លឹងថ្លែងបែបវិទ្យាសាស្ត្រ គ្រប់ជ្រុងជ្រោយ នៅឡើយទេ : លោក អៀវ កើស បានដាក់ជាមួយគ្នាទូវធាតុដែលមានលក្ខណៈដូច affixes នៃភាសាបារាំង/អង់គ្លេស ផង និងធាតុដែលលោក J. Guesdon ហៅថា "racines primaires"ក្នុងវចនានុក្រមខ្មែររបស់គាត់ ហើយ ដែលលោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ហៅថា "lexèmes primaires" ក្នុងបទអន្តរាគមន៏របស់គាត់ចេញនៅពេលដែលគាត់ចូលរួមក្នុងសមាជអ្នកបូព៌ាវិទ្យាអន្តរជាតិ នៅក្រុងប៉ារីសឆ្នាំ១៩៧៣ ផង អាស្រ័យហេតុនេះ គប្បីយើងពិនិត្យវិភាគដោយផ្អែកលើលក្ខណៈវិនិច្ឆ័យកម្មវិស័យឡើង តាមដែលអាចទៅរួច ។

---

[២៦] - វាក្យស័ព្ទរបស់វេយ្យាករណ៍/ភាសាវិទ្យា ដែលមានមកស្រាប់ សឹងសុទ្ធជាពាក្យដែលមានធាតុបាលី/សំស្ក្រឹត ហើយនៅអនាគត យើងនឹងត្រូវការធាតុបាលី/សំស្ក្រឹតតទៅទៀត ពីព្រោះ យើងពិបាករកពាក្យខ្មែរសងពាក្យបារាំង/អង់គ្លេសណាស់ ដូច : morphème , sème , sémème ,... ជាដើម ។

[២៧] - op.cit. អៀវ កើស *ភាសាខ្មែរ* ពីទំព័រ១៦៦ ទៅទំព័រ២០៨ ។

### ២.២ – ប្រព័ន្ធកម្លាយពាក្យ បែបខ្មែរ -មន [២៨] :

### ២.២.១ – ការប្រើប្រាស់ស័ព្ទវេយ្យាករណ៍ :

#### ២.២.១.១ – អព្ភាសបទ/មូលបទ (affixes) :

ខ្ញុំចាត់ទុកថាជាអព្ភាសបទ/មូលបទ តែធាតុណាដែលមានលក្ខណៈដូច affixes នៃភាសាបារាំង/អង់គ្លេស ហើយ ខ្ញុំសុំកំណត់ន័យ [២៩] ដូចតទៅ : អព្ភាសបទ/មូលបទជាកម្មេចពាក្យ [៣០] ដែលមានន័យនឹងនរ រូបសាស្ត្រនឹងនរ (លើកលែងតែមានការសម្រួបសូរក្នុងវិស័យសូរវិទ្យា) ដែលគេប្រើសម្រាប់ដាក់ពីមុខ កណ្ដាល ឬ ពីក្រោយពាក្យឫស ដើម្បីបង្កើតពាក្យកម្លាយ : ឧ. អន្តេបទ /-ន-/ ដែលជាមូលបទមួយបែបក្នុងភាសាខ្មែរ តែងតែរក្សារូបដដែល និង ន័យដដែល ថា "ឧបករណ៍" ដូចពាក្យ : គាប + /-ន-/ ឃ្នាប (ឧបករណ៍សម្រាប់ គាប) ; កោស + /-ន-/ ខ្នោស (ឧបករណ៍សម្រាប់កោស -ល-) ។

ចំពោះការសម្រួបសូរ យើងអាចយកជាឧទាហរណ៍នូវបុព្វបទ /ប៉-/ សម្រាប់បង្កើតកិរិយាហេតុដែលអាចប្រែសូរបន្តិចបន្តួចតាមបរិបទ : បាក់ > បំបាក់ / ធើម > បំធើម / ទុក > បន្ទុក / ស៊ី > បន្ស៊ី / ចូល > បញ្ចូល / ខូច > បង្ខូច ,... ។ រូបផ្សេងៗ ដូច [ បំ-/បន់-/បញ់-/បង់-/,...] ជាបណ្ដាស័ព្ទ (ឬកលារូបស័ព្ទ) របស់រូបស័ព្ទ /ប៉-/ ។ ក្នុងករណីខ្លះ បុព្វបទ/ប៉-/ឥតទទួលឥទ្ធិពលនៃការសម្រួបសូរទេ : ដឹង > ប្ដឹង/ ទឹម > ផ្ទឹម / សឹក > ផ្សឹក [៣១] ។

មូលបទអាចជួបប្រទះនឹងបញ្ហាវេវចនស័ព្ទ ឬ បញ្ហាសទិសស័ព្ទ ។ ក្នុងករណីវេវចនស័ព្ទ គេសម្គាល់ឃើញថា ភាសាបារាំងមានបច្ឆិមបទ / -(a)tion / ផង / -age / ផង / -ment / ផង ដែលចែកគ្នាចេញមុខទៅតាមពាក្យកម្លាយសម្គាល់អំពើ/លទ្ធផល កើតពីកិរិយាស័ព្ទ ។ ភាសាខ្មែរក៏មានធាតុវេវចនស័ព្ទដែរដូច វេវចនស័ព្ទរវាងធាតុមួយចំនួនសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ ជាដើម : ឧ. អន្តេបទ /-ន-/ ដូចក្នុង " ឃ្នាប < គាប / រនាំង < រាំង " បុព្វបទ /អន់-/អង់-/អញ់-/ ,... ដូចក្នុង "អន្ទាក់

---

(២៨) – ខ្ញុំសន្មតប្រើវិញ្ញត្តិ "ខ្មែរ-មន" សម្រាប់សម្គាល់អ្វីៗដែលជាខ្មែរសុទ្ធសាធ ។ នៅពេលខាងមុខ ខ្ញុំនឹងប្រើវិញ្ញត្តិ "ខ្មែរ-ឥណ្ឌា" សម្រាប់សម្គាល់អ្វីៗដែលខ្ចីពីបាលី/សំស្ក្រឹត ។ រហូតមកដល់សព្វថ្ងៃ គេហាក់ដូចជាទុកពាក្យខ្ចីពីបាលី/សំស្ក្រឹតថាមិនមែនជាពាក្យខ្មែរ ។ តាមពិត ទោះខ្ចីពីណាក៏ដោយ ពាក្យដែលយើងប្រើជាអចិន្ត្រៃយ៍ ក្នុងភាសាខ្មែរ ជាពាក្យខ្មែរ : វិញ្ញត្តិ "ខ្មែរ-មន" និង "ខ្មែរ-ឥណ្ឌា" អាចបង្កើតផ្នត់គំនិតថ្មីទទួលស្គាល់ថាពាក្យទាំងពីរប្រភពជាពាក្យខ្មែរដូចគ្នាទាំងអស់ ។

(២៩) – ធាតុណា ដែលមិនទាន់អាចរាប់បញ្ចូលក្នុងក្រុមនេះបាន នឹងអាចបញ្ចូលនៅពេលក្រោយបន្តៗគ្នា កាលណាការស្រាវជ្រាវបែបវិទ្យាសាស្ត្របានញែកវាចេញពីភាពជិពាក់ចាក់ស្រែះជាមួយធាតុឯទៀត ហើយ រកឃើញព្រំដែនច្បាស់លាស់ ។

(៣០) – ខ្ញុំខ្ចីវិញ្ញត្តិ "កម្មេចពាក្យ" ពីលោក អៀវ កើស (Op.cit. អៀវ កើស *ភាសាខ្មែរ* ទំព័រ១៦៨) ។

(៣១) – អក្ខរាវិរុទ្ធនៃពាក្យ "ប្ដឹង" សរសេរជាមួយអក្សរ " ប៉ " នៃពាក្យ "ផ្ទឹម/ផ្សឹក" សរសេរជាមួយអក្សរ " ផ " គ្រាន់តែជាអក្ខរាវិរុទ្ធទេ : ការបន្លឺសូរឥតមានអ្វីប្លែកគ្នាទេ រវាងពាក្យទាំងបីនេះ ។

< ទាក់ / អង្រុត < រុត / អញ្ចុល < ជុល ,..." បុព្វបទ /រង់-/ ដូចក្នុង "រង្វាស់ < វាស់ " បុព្វបទ /រំ-/ ដូចក្នុង "រំពាត់ < វាត់" -ល-។ ចំពោះធាតុសទិសស័ព្ទ ភាសាបារាំងមានករណីបច្ច័យបទ "-eur" ដែលសម្គាល់ភ្នាក់ងារផង តាមរយៈនាមស័ព្ទកម្លាយកើតពីកិរិយាស័ព្ទ ដូច planteur < planter ,... និងសម្គាល់លទ្ធផល/ គុណភាពផង តាមរយៈនាមស័ព្ទកើតពីគុណនាម ដូច laideur < laid ,... ។

ក្រោយពីបានរំលឹកនិងបញ្ជាក់បន្ថែមលើគោលធំៗ ខ្ញុំសុំបង្ហាញឡើងវិញនូវប្រភេទមូលបទបែបខ្មែរ-មន ។ មូលបទជាពួកនេះមាន[៣២] :

(១) - អន្តេបទ :

(១.១) - អន្តេបទ /-ម-/ ប្រើក្នុងការបង្កើតនាមស័ព្ទកម្លាយសម្គាល់ភ្នាក់ងារ កើតពីកិរិយាស័ព្ទ :

ឆ្មាំ (chmam) < ចាំ (cam) / រ្មាំ (rmɔam) < រាំ (rɔam) ,...

(១.២) - អន្តេបទ /-ន-/ ប្រើក្នុងការបង្កើតនាមស័ព្ទកម្លាយសម្គាល់ឧបករណ៍ កើតពីកិរិយាស័ព្ទ :

ឃ្នាប (khnẹa:p) < គាប (kẹa:p) / ឆ្នុក (chnok) < ចុក (cok) ,...

(១.៣) - អន្តេបទ /-អម(ន)-/ -អំម(ន)-/[៣៣] ប្រើក្នុងការបង្កើតនាមស័ព្ទកម្លាយសម្គាល់លទ្ធផល/អំពើ កើតពីកិរិយាស័ព្ទ/គុណនាម : ចំណាយ (cαmna:j) < ចាយ (ca:j) / ទំនាប (tɔmnẹa:p) < ទាប (tẹa:p) ,...

(១.៤) - អន្តេបទ /-ប-/ ប្រើក្នុងការបង្កើតពាក្យសម្គាល់លទ្ធផល/អំពើ ទាក់ទងនឹងពាក្យដើមណា (កិរិយាស័ព្ទ/គុណនាម) ដែលមានព្យញ្ជនៈ /យ/រ/ល/ នៅខាងដើម : យោបល់ (< យ្បល់) < យល់ / របៀប (< រ្បៀប) < រៀប / ល្បាយ < លាយ ,... ។

(២) - បុព្វបទ :

(២.១) - បុព្វបទ /លំ-/ប្រើក្នុងការបង្កើតពាក្យសម្គាល់លទ្ធផល/អំពើចេញពីកិរិយាស័ព្ទដែលមានព្យញ្ជនៈ /ន/នៅខាងដើម ព្រមទាំងព្យញ្ជនៈមួយចំនួនផងទៀត ដោយមានការភាន់ច្រឡំពីសំណាក់គណៈ-កម្មការខេមរយានកម្ម : នាំ (nɔam) + /-អំម(ន)-/ ( /-ɔm(n)-/ ) > នំនាំ ( nɔmnɔam) (ដោយមានការពិបាកក្នុងការបញ្ចេញសូរ [ ន ] ជួនៗគ្នា បាតុភូតបំប្លែកសូរក៏បានបណ្តាលអោយ "នំនាំ" ក្លាយទៅជា "លំនាំ") ។ គណៈកម្មការខេមរយានកម្មបានពង្រីកការប្រើប្រាស់រូបប្រែកាឡា /លំ-/រហូតដល់ពាក្យឫសដែលមានព្យញ្ជនៈ /ញ/ & /ហ/ នៅខាងដើមថែមទៀត ដូច លំញ៉ែរ <

[៣២] - សម្រង់បណ្តោះអាសន្នទំរាំមានគំហើញធាតុថ្មីថែមទៀត ។

[៣៣] - ព្យញ្ជនៈ /ន/ ក្នុងវង់ក្រចកមានន័យថា ព្យញ្ជនៈនេះអាចមិនចេញក្នុងករណីខ្លះ ។

ញ៉ូរ / លំហាត់ < ហាត់ ,... ។

(២.២) - បុព្វបទ /ប៉-/ ប្រើក្នុងការបង្កើតកិរិយាហេតុចេញពីកិរិយាអកម្ម/គុណនាម :

ប្ដូរ (pdo:) < ដូរ (do:) / ភ្ជិត (phcit) < ជិត (cit) / ប្រលែង/ប្រឡែង (prɑlɛŋ) < លេង (leŋ)[៣៤] ,... ។

(២.៣) - បុព្វបទ /ក(ន)[៣៥] / ប្រើក្នុងការបង្កើតពាក្យសម្រាប់បន្ទុះបង្អាប់ ចេញពីនាម ឬ គុណនាម :

នាងសុខ > មីក្សុខ / បាក់ > អាកបាក់ / គឿ > អាកន្ទើ ,... ។

(២.៤) - <u>បុព្វបទវេវិចនស័ព្ទ</u> : /អន-/ រំ-/ រ-/[៣៦] ប្រើក្នុងការបង្កើតពាក្យមួយចំនួន សម្គាល់ឧបករណ៍ ចេញពីកិរិយាស័ព្ទ ដូច អន្ទាក់ < ទាក់ / អង្រុត < រុត / រំពាត់ < វាត់ ,... ។

(២.៥) - <u>បុព្វបទ /រ-/</u> ប្រើក្នុងការបង្កើតអកម្មកិរិយាអត្តផល ចេញពីសកម្មកិរិយា ដូច របក < បក / រលត់ < លត់ -លៈ ។

**២.២.១.២ - <u>បរៈមូលបទ</u> (para-affixes) :**

ការពិនិត្យឆ្លុះមើលផ្នែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់ បាននាំអោយយើងប្រទះធាតុមួយបែប ដែលមិនឆ្លើយនឹងនិយមន័យសម្រាប់អក្ខាសបទ/មូលបទទេ ពីព្រោះ វាមានន័យនឹងនរ តែមានរូបមិននឹងនរ : រូបវាផ្លាស់ប្តូរទៅតាមព្យញ្ជនៈដើមនៃពាក្យដែលជាដើមកំណើតនៃពាក្យកម្លាយ ដូច កកាយ < កាយ / ចបឹក < បឹក / ទទះ < ទះ / ងងឹត < ងឹត , ... ។ គឺទ្វេនិយកម្ម ដើម្បីសម្គាល់ទង្វើដដែលៗ (ឬ ភាពលើសលប់) បែបនេះហើយ ដែលហៅថា "បរៈមូលបទ" : បរៈមូលបទ គឺជាទ្វេនិយកម្មនៃព្យញ្ជនៈខាងដើមរបស់ពាក្យ ដែលជាដើមកំណើតនៃពាក្យកម្លាយសម្គាល់ទង្វើដដែលៗ (ឬ ភាពលើសលប់) : បរៈមូលបទមានព្រំដែនច្បាស់លាស់ មានន័យនឹងនរ តែមានរូបមិននឹងនរ ។

<u>កំណត់សម្គាល់</u> : ទ្វេនិយកម្មនៃពាក្យទាំងមូលសម្រាប់សម្គាល់ចំនួនច្រើន/ភាពលើសលប់ (ដូច នីមួយៗ / ក្មេងៗ . ភ្លាមៗ ,...) ក៏ជាធាតុសម្រាប់បង្កើតពាក្យដែរ : យើងអាចបញ្ចូលធាតុនេះក្នុងក្រុម "បរៈមូលបទ" ។

**២.២.២ - <u>ការសាកល្បងដោះស្រាយបញ្ហា</u> :**

ដោយបញ្ហាមួយចំនួនបានចោទឡើង (ដូចខ្ញុំបានពិពណ៌នាខាងលើ) ចំពោះការបង្កើតនាមស័ព្ទ

---

[៣៤] - យើងបានឮតាមវិទ្យុ/ទូរទស្សន៍ ឬ ឃើញក្នុងសារពត៌មានខ្លះនូវពាក្យ "ព្រលែង" ដូច "គេបានយកកូនត្រីទៅព្រលែងក្នុងទន្លេ" : តាមន័យនៃបុព្វបទ /ប៉-/ យើងអាចយល់ភ្លាមថា "គេមិនព្រលែងកូនត្រី"ទេ តែ "គេលែងវា" ។

[៣៥] - ព្យញ្ជនៈ /ន/តំណាងព្យញ្ជនៈនាសិកជៈទាំងអស់ (ម/ន/ញ/ង) ។

[៣៦] - ពាក្យកម្លាយដូច រណារ ឬ ទ្រនំ ជាពាក្យដែលបានឃ្លាតចេញពីសូរដើម ដែលមានរូបជាលំដាប់ ដូចនេះ : អារ / a: /aa/ + /-ន -/ (-n-) > អាណារ (a:na: < ana) / ទំ (tum) + /-ន-/ (-n-) > ទ្នំ (tnum) ។

កម្លាយសម្គាល់លទ្ធផល/អំពើ គប្បីយើងធ្វើសរុបនិទ្ទេសមួយបង្ហាញការប្រើប្រាស់មូលបទក្នុងករណីនេះ ។ ការសិក្សាតាមរយៈកាលនិងក្នុងដំណាក់កាល ស្វែងយល់ពីភាពប្រទាក់ក្រឡាវវាងធាតុ/មូលស័ព្ទ បានអោយយើងយល់ថា ធាតុ /លំ-/ ដែលភាសាខ្មែរប្រើក្នុងពាក្យ "លំនាំ / លំនៅ / លំនឹង ,..." ជាលទ្ធផលនៃបាតុភូតបំប្លែកសូរ : នាំ + /-អំម(ន)-/ > នំនាំ > លំនាំ ។ ពាក្យ "នំនាំ" បានក្លាយទៅជា "លំនាំ" (ដូចពាក្យ "នំនៅ / នំនឹង ,..." ដែរ) ពីព្រោះ អ្នកនិយាយស្ដីមានការពិបាកក្នុងការបន្លឺសូរ ប៉ុន្តែ ដោយមានការភាន់ច្រឡំ (ដូចយើងបានឃើញខាងលើ) គេក៏បានពង្រីកការប្រើប្រាស់ធាតុ /លំ-/ ទៅពាក្យមួយចំនួនដែលមានព្យញ្ជនៈ /ញ/ & /ហ/ នៅខាងដើម[៣៧] : ញ័រ > លំញ័រ / ហាត់ > លំហាត់ ។ ប៉ុន្តែ ទោះជាដោយសារការភាន់ច្រឡំក៏ដោយ ក៏គប្បីយើងប្រើធាតុ /លំ-/ តាមខុសតទៅទៀត ដើម្បីកុំអោយមានភាពបញ្ច្រសបញ្ច្រាសក្នុងភាសាខ្មែរ ហើយ យើងអាចពង្រីកការប្រើប្រាស់នេះទៅដល់ព្យញ្ជនៈនាសិកជៈទាំងអស់[៣៨] គឺ /ម , ន , ញ , ង/ (កុំអោយតែមានភាពអនាធិបតេយ្យរាលដាលដល់ព្យញ្ជនៈឯទៀត ដូចបាក់ > ✶ លំបាក់ / សូក > ✶ លំសូក ,...) ។

នៅទីបញ្ចប់ ចំពោះការបង្កើតនាមស័ព្ទកម្លាយសម្គាល់លទ្ធផល/អំពើ យើងមានប្រព័ន្ធមូលបទមួយ មិនពិបាកយល់ដល់សាធារណជនទេ គឺ :

(១) - អន្តេបទ /-ប-/ កាលណាពាក្យឬសមានព្យញ្ជនៈ / យ , រ , ល / នៅខាងដើម ដូច : យល់ > យ្បល់ > យោបល់ / រាំ > រ្បាំ > របាំ / លាយ > ល្បាយ ,... ។

(២) - បុព្វបទ /លំ-/ កាលណាពាក្យឬសមានព្យញ្ជនៈនាសិកជៈនៅខាងដើម ដូច : នាំ > លំនាំ / ញ័រ > លំញ័រ ,... ។ ក្នុងក្រុមនេះ គេអាចបញ្ចូល ហាត់ > លំហាត់ ផងដែរ ។

(៣) - អន្តេបទ /-អម(ន)-/-អំម(ន)-/ ប្រើក្នុងពាក្យឬសណាដែលមានព្យញ្ជនៈខាងដើមក្រៅពីព្យញ្ជនៈប្រើក្នុងករណីទាំងពីរខាងលើ (ក្រៅពី /យ , រ , ល , ម , ន , ញ , ង/) ឧ. : បុល > បំណុល/បាក់ > បំណាក់/ពូក > ពំនូក/តាង > តំណាង /ទាយ > ទំនាយ /កាត់ > កំណាត់ /គូស > គំនូស/សូក >សំណូក/ខូច >កំហូច[៣៩] / ឃ្លាត >គម្លាត/ឆ្ងាយ >ចម្ងាយ -ល- ។

---

[៣៧] - ខ្ញុំមិនរាប់បញ្ចូលពាក្យ "លំបាក់" ទេ ពីព្រោះ ពាក្យនេះមិនទាន់បានគេប្រើទូទាំងប្រទេស ។

[៣៨] - ព្យញ្ជនៈនាសិកជៈទាំងអស់មានលក្ខណៈបន្លឺប្រហាក់ប្រហែលគ្នា ប៉ុន្តែ ការពង្រាលការប្រើប្រាស់ /លំ-/ ទៅព្យញ្ជនៈ /ហ/បានបង្កើតបញ្ហាដ៏ចម្រូងចម្រាសមួយដល់របៀបរៀបរយនៃការបង្កើតពាក្យ ។ ម្យ៉ាងទៀត គប្បីកុំច្រឡំ /លំ-/ ក្នុងពាក្យ "លំហាត់" ជាមួយនឹង "លំ" ក្នុង "លំអ/លំអិត" ដែលគេអាចសរសេរ "លម្អ/លម្អិត" ផងដែរ ហើយ ដែលជាលទ្ធផលនៃការផ្ដុំ "ល្អ/ល្អិត" ជាមួយអន្តេបទ /-អំម-/ ។

[៣៩] - ដូចយើងបានឃើញក្នុងសទ្ទតាវិទ្យា ព្យញ្ជនៈធនិតខ្មែរ ខ/ឃ , ឆ/ឈ , ឋ/ឍ , ផ/ភ មិនមែនជាសទ្ទតាទេ : វាគ្រាន់តែជាសូរ គឺ ក + ហ / គ + ហ , ច + ហ / ជ + ហ -ល- ហេតុដូច្នេះហើយបានជា /ក.ហូច/ + /-អម-/ > /កអមហូច/ សរសេរ : "កំហូច" ។

**២.៣ – ប្រព័ន្ធកម្លាយពាក្យ បែបខ្មែរ -ឥណ្ឌា**[៤០] :

**២.៣.១ – ការប្រើប្រាស់ស័ព្ទវេយ្យាករណ៍** :

អ្នកគ្រប់គ្រងរដ្ឋនៅសម័យស្វ័យភាពបានយល់ពីការចាំបាច់ខាងវាក្យស័ព្ទ ហើយ បានបង្កើតគណៈ-កម្មការបច្ចេកស័ព្ទមួយហៅថា "គណៈកម្មការវប្បធម៌" ។ ពាក្យដែលគណៈកម្មការនោះបានបង្កើតឡើងសឹងសុទ្ធជាពាក្យផ្គុំធាតុបាលី/សំស្ក្រឹត ។ ដោយពាក្យនោះជាពាក្យសម្រាប់សងពាក្យបារាំង ហើយ ដោយពាក្យបារាំងមានមូលបទដដែលៗ ពាក្យនោះក៏ច្រើនតែមានធាតុបាលី/សំស្ក្រឹតដដែលៗ ដែរ : គឺធាតុដដែលៗនេះហើយ ដែលមានលក្ខណៈជាមូលបទ ហៅថាមូលបទបែបខ្មែរ-ឥណ្ឌា ។ ធាតុទាំងនោះឆ្លើយនឹងនិយមន័យសម្រាប់អព្ភាសបទ/មូលបទទាំងស្រុង គឺមាន :

- បុព្វបទ : បរៈ-, បុព្វ-, បុរេ-, ពហុ-, មហា-, អ-, អតិ-, អប្ប-, ឯក-, វិ-, អនុ-, ... ;
- បច្ឆិមបទ : -ករ/ការិនី, -ករណ៍, -ការណ៍, -វិទ្យា, -វិទូ, -សាស្ត្រ, -ឧបនីយកម្ម/-នីយកម្ម, ... ។

កន្សោមធាតុ "ភាវូបនីយកម្ម" ត្រូវបានគេច្រឡំថាជាបច្ឆិមបទ : តាមពិត យើងមាន "ភាវូប..." លុះណាពាក្យឫស ដែលជាដើមកំណើតនៃពាក្យកម្លាយ មានព្យាង្គ "ភាព"នៅខាងចុង ដូច "សេរីភាព, ឯកភាព " ជាដើម : សេរីភាព + ឧបនីយកម្ម > សេរីភាវូបនីយកម្ម / ឯកភាព + ឧបនីយកម្ម > ឯកភាវូបនីយកម្ម (-ភាព + ឧប- > ភាវឧប- > ភាវុប- > ភាវូប-) ។

**២.៣.២ – ការសាកល្បងដោះស្រាយបញ្ហា** :

ផ្អែកលើលក្ខណៈវិនិច្ឆ័យ.កម្មវិស័យ និង ក្នុងបំណងរកផ្លូវសមស្រប យើងអាចទទួលចាត់ទុកថាពាក្យ "សកលភាវូបនីយកម្ម"ជាពាក្យកើតដោយការផ្សំពាក្យ "សកល"(គុណនាម)ជាមួយធាតុ "-ភាព " អោយបានជានាមស័ព្ទ "សកលភាព " សិន រួចហើយទើបគេយកនាមស័ព្ទ"សកលភាព"ទៅផ្សំជាមួយនឹងធាតុ "ឧបនីយកម្ម" អោយបានពាក្យ "សកលភាវូបនីយកម្ម" នេះឡើង : ហេតុដូច្នេះ ពាក្យនេះល្មមអាចចាត់ទុកថាស្របនឹងវចនវិទ្យាខ្មែរដែរ[៤១] ប៉ុន្តែ យើងមិនអាចពន្យល់បានដូចគ្នានេះទេ ចំពោះពាក្យ "នយោ-បាយភាវូបនីយកម្ម/អគ្គិសនីភាវូបនីយកម្ម/ពាណិជ្ជភាវូបនីយកម្ម" ជាដើម លើកលែងតែសម្រេចចិត្ត

---

[៤០] - សូមអាន foot-note ទាក់ទងនឹងចំណុច ២.១ ។

[៤១] - ពាក្យ "សកលូបនីយកម្ម" (ដែលក្នុងនោះឥតមាន "ភាវ")ជាពាក្យសមស្រប ហើយ ពាក្យ "សកលនីយកម្ម" ជាពាក្យខ្លី កាន់តែស្រួលប្រើទៅទៀត ។

បង្កើតអោយមានបច្ឆិមបទថ្មី "-ភារូបនីយកម្ម" ដ៏វែងអន្លាយ លើស "ឧបនីយកម្ម" របស់គណៈកម្មការវប្បធម៌ ដែលវែងអន្លាយរួចទៅហើយ ។

## ២.៤ - ប្រព័ន្ធកម្លាយពាក្យ ក្នុង ស្ថានភាព វេយ្យាករណីយកម្ម :

### ២.៤.១ - ការប្រើប្រាស់ស័ព្ទវេយ្យាករណ៍ :

វេយ្យាករណីយកម្ម (grammaticalisation) គឺបាតុភូត ដែលធ្វើអោយពាក្យឯករាជ្យមួយចំនួនក្លាយបន្តិចម្តងៗទៅជា "ស័ព្ទវេយ្យាករណ៍" (outils grammaticaux) ជាពិសេស អោយក្លាយទៅជា អក្ខាសបទ/មូលបទ ។ ប៉ុន្តែ ដោយវេយ្យាករណីយកម្មកំពុងតែពង្រីកពង្រីង មិនទាន់ដល់ចំណុចបញ្ចប់នៅឡើយ ធាតុទាំងនោះត្រូវបានគេហៅថា "ឧបមូលបទ" (présumés-affixes) ឬ "អឌ្ឍមូលបទ" (semi-affixes) ។

ដើម្បីអោយមានឯកភាពក្នុងវិធីសាស្ត្រនិងក្នុងរចនាសម្ព័ន្ធនៃអត្ថបទ ខ្ញុំសុំកំណត់ន័យអោយអឌ្ឍមូលបទ ដូចនេះ : អឌ្ឍមូលបទជាធាតុដែលកើតចេញពីពាក្យឯករាជ្យ (ពាក្យពេញអង្គ) ។ សញ្ញាមួយចំនួនអនុញ្ញាតអោយយើងសន្និដ្ឋានថា ធាតុជំពូកនោះកំពុងបែកចេញពីពាក្យដើម ហើយ កំពុងក្លាយបន្តិចម្តងៗទៅជាមូលបទ ពីព្រោះ ផ្ទុយពីពាក្យឯករាជ្យពិតប្រាកដ ធាតុទាំងនោះអាចប្រើបានជាមួយកម្មេចពាក្យ ដូច "ភាព" ក្នុង "សមត្ថភាព/ស្នេហភាព" ជាដើម[៤២] ។ ធាតុនោះសឹងសុទ្ធជាអឌ្ឍបច្ឆិមបទ[៤៣] មាន : ភាព , កម្ម , ជន , ធម៌ , ឋាន/ដ្ឋាន , និយម , អាចារ្យ , ... ដូចក្នុង ស្នេហភាព/មិត្តភាព , កសិកម្ម/វិនាសកម្ម , យុទ្ធជន/សកម្មជន , វប្បធម៌/មនុស្សធម៌ , បូជនីយដ្ឋាន/យានដ្ឋាន , ឧត្តនិយម/ខ្មែរនិយម ព្រឹទ្ធាចារ្យ/សាស្ត្រាចារ្យ/គ្រូអាចារ្យ[៤៤] , ... ។

### ២.៤.២ - ការសាកល្បងដោះស្រាយបញ្ហា :

ផ្អែកលើការបង្កើតពាក្យ "ព្រឹទ្ធាចារ្យ/សាស្ត្រាចារ្យ" យើងអាចបង្កើតពាក្យ "ព្រឹទ្ធសភាចារ្យ" ឬ "បណ្ឌិតសភាចារ្យ" សាកមើល ។ ពាក្យទាំងពីរម៉ាត់នេះមានពាក្យសន្ដានក្នុងភាសាខ្មែរស្រាប់ ហើយ ឥតបានកាត់ចោលភាគទាំងមូលណាមួយនៃពាក្យដើមទេ ផ្ទុយពីពាក្យ "ព្រឹទ្ធសមាជិក" ដែលត្រូវបានបង្កើតសាកល្បងមកហើយ តែបានជម្រុសចោលនូវភាគ "សភា" ដែលជាភាគសំខាន់ក្នុងពាក្យដើម "ព្រឹទ្ធសភា" ។

---

[៤២] - និយមន័យនេះមិនទាន់មានលក្ខណៈរឹងប៉ឹងនៅឡើយទេ ខ្ញុំសង្ឃឹមថា នៅពេលក្រោយ ខ្ញុំនឹងរកឃើញលក្ខណៈវិនិច្ឆ័យ-កម្មវិស័យ ក្រោយពីបានទទួលការទិតៀនស្ថាបនាពីសំណាក់អ្នកអាន ។

[៤៣] - ការ/សេចក្តី/អ្នក ,... ហាក់ដូចជាកំពុងក្លាយទៅជាអឌ្ឍបុព្វបទ ប៉ុន្តែ ខ្ញុំមិនទាន់រកឃើញលក្ខណៈវិនិច្ឆ័យ.កម្មវិស័យ ដើម្បីចាត់ទុកវាជាធាតុជំពូកនេះ នៅឡើយ ។

[៤៤] - ខ្ញុំជ្រើសរើសឧទាហរណ៍ពីរសម្រាប់ធាតុនីមួយៗ : ឧទាហរណ៍មួយជាពាក្យដែលធាតុណាមួយអាចផ្សំជាមួយកម្មេចពាក្យ ឧទាហរណ៍មួយទៀតជាពាក្យដែលធាតុនោះអាចផ្សំជាមួយពាក្យឯករាជ្យ ។

៣ - **សេចក្ដីសន្និដ្ឋាន** :

ស្របតាមគំនិតរបស់លោកឆុមស្គី សង្គមភាសាវិទ្យាបានឆ្លុះពង្រីកអោយឃើញថា វេយ្យាករណ៍ជាប្រព័ន្ធនៃសក្ដានុពល ជាកម្រងនៃគំរូសម្រាប់ពាក្យថ្មីនិងល្បះថ្មី។ ភាសាបារាំង ដែលជាភាសាសម្បូរណ៍មួយនៅតែខ្វះពាក្យ ហើយ យើងមិននិយាយតែពីពាក្យសម្រាប់របស់របរថ្មីៗផង : ពាក្យធម្មតា ដូចពាក្យ "positiver" ឬ "enceinter"ជាដើម ក៏បុព្វបុរសបារាំងមិនទាន់បានជំរុញអោយមានអត្ថិភាពលេចចេញពីសក្ដានុពលដែរ។ ពាក្យ "positiver"ទើបត្រូវបានក្រុមហ៊ុន"Carrefour"បង្កើតឡើងនៅពេលថ្មីៗនេះ។ ពាក្យ"enceinter" ក៏ទើបត្រូវបានប្រទេសកូឌីវ៉រ ដែលប្រើភាសាបារាំងជាភាសាជាតិ បង្កើតឡើងនៅពេលថ្មីៗនេះដែរ។ ចំពោះករណីទាំងពីរ វចនវិទ្យាភាសាបារាំងមានគំរូទុកអោយជាស្រេច ដូចក្នុងកម្លាយ "actif > activer" , "lisse > lisser", las / lasse > lasser , "content > contenter" ជាដើម ហើយមនុស្សបារាំងម្នាក់ៗបានយល់ច្បាស់នូវប្រព័ន្ធកម្លាយពាក្យនៃភាសារបស់គេ ។

ប្រទេសបារាំងមានបណ្ឌិតសភាបារាំង (Académie Française) ដែលត្រូវបានគេបង្កើតឡើងនៅឆ្នាំ១៦៣៥ ក្នុងគោលបំណងថែទាំភាសាបារាំងកុំអោយបាត់សណ្ដាប់ធ្នាប់។ ចំពោះប្រទេសអង់គ្លេសវិញគេឥតមានបណ្ឌិតសភាអង់គ្លេសទេ ប៉ុន្តែ ភាសាអង់គ្លេសរក្សារបៀបរៀបរយរបស់ខ្លួនបានរហូតរៀងមក ហើយ ថែមទាំងបានទទួលការរីកចម្រើនប្រសើរជាងភាសាបារាំងផងទៀត ។ តើមកពីមូលហេតុអ្វី ? ខ្ញុំជឿជាក់ថាមកពីគេចេះបង្រៀនអោយមនុស្សអង់គ្លេសយល់ច្បាស់ពីទម្រង់នៃភាសារបស់គេ ជាពិសេសវចនវិទ្យា ហើយ គេក៏គោរពតាមគ្រប់ៗគ្នា ដោយស្មោះស្ម័គ្រ : គប្បីមនុស្សខ្មែរខំស្វែងយល់ពីវចនវិទ្យានៃភាសាខ្មែរនិងគោរពតាម ដោយស្មោះស្ម័គ្រ ដូចមនុស្សអង់គ្លេសផងដែរ ដរាបរៀងទៅ។

x x

x

## គន្ថនិទ្ទេស


I- Ouvrages & titres de connaissances de base :

- Benveniste (Émile), Problèmes de linguistique générale; Gallimard 1966;
- Bloomfield (Léonard), Le langage, Payot 1970;
- Chomsky (Noam), Structures syntaxiques, Seuil 1969;
- Chomsky (Noam), Aspects de la théorie syntaxique, Seuil 1971;
- Chomsky (Noam), Questions de sémantique, Seuil 1975;
- Gagnepain (Jean), Du vouloir dire – Traité d'épistémologie des sciences humaines
  - tome 1, Du signe & de l'outil, Éditions Livre & Communication , Paris 1990;
  - tome 2, De la personne & de la norme, Éditions Livre & Communication Paris 1991; - tome 3, Guérir l'homme, former l'homme, sauver l'homme, Éditions De Boeck & Larcier S.A, Bruxelles 1995;
- Gleason (H.A.), Introduction à la linguistique, Larousse 1969;
- Grammont (Maurice), Traité de phonétique, Delagrave 1960;
- Hjelmslev (Louis), Prolégomènes à une théorie du langage, Minuit 1968;
- Jakobson (Roman), Essai de linguistique générale, Minuit 1963;
- Lyons (John), Linguistique générale, Larousse 1970;
- Malmberg (Bertil), Les nouvelles tendances de la linguistique, PUF 1966;
- Malmberg (Bertil), La phonétique, PUF 1975;
- Martinet (André), Éléments de linguistique générale, A. Colin 1970;
- Martinet (André), La linguistique synchronique, PUF 1968;
- Martinet (André), Syntaxe générale, A. Colin 1985;
- Prum (Marc), "Esquisse d'un cadre théorique pour une sociolinguistique systémique", CIRL, n°32 décembre 1996, Institut de Linguistique Appliquée, Université d'Abidjan, (Côte d'Ivoire) ;
- Rey (Alain), La lexicologie, Klincksieck 1970;
- Saussure (Ferdinand de), Cours de linguistique générale, Payot 1960;
- Wartburg (Walther), Problèmes et méthodes de linguistique, PUF 1963;

II- Ouvrages & titres spécialisés :

ជាភាសាខ្មែរ :

- កេង វ៉ាន់សាក់ , មូលភាពនៃការបង្កើតពាក្យថ្មី , រោងពុម្ពទេព ភ្នំពេញ ឆ្នាំ១៩៦៤;
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ គីម សេង ភ្នំពេញ ១៩៥៨;
- ព្រុំ ម៉ល់ , "លទ្ធភាព និង ការបង្កើតពាក្យ ក្នុងភាសាខ្មែរ", ទស្សនាវដ្ដីលេខ២ នៃវិទ្យាស្ថានភាសាជាតិ នៃ រាជបណ្ឌិតសភាកម្ពុជា ភ្នំពេញ មិថុនា ២០០១ ;
- ឡុង សៀម , បញ្ហាវចនស័ព្ទវិទ្យាខ្មែរ, ផ្សាយដោយ អ្នកនិពន្ធ ចេញនៅខែកុម្ភៈ ឆ្នាំ១៩៩៩;

- អ៊ុំ ឈុំ , ពាក្យ , រោងពុម្ពខ្មែរ ភ្នំពេញ ឆ្នាំ១៩៥២ ;

- អៀវ កើស , ភាសាខ្មែរ , បណ្ណាគារមិត្តសេរី ភ្នំពេញ ឆ្នាំ១៩៦៧ ។

ជាភាសាបរទេស :

- Gorgoniyev (Y.A.), The Khmer language (traduit du russe), "Nauka" Publishing House, Central Department of Oriental Literature, Mouscou 1966;

- Huffinan (Franklin), Modern spoken Cambodian, New Haven & London, Yale University Press, 1970;

- Khuon (Sokhamphu) Le système phonétique de la langue khmère, thèse préparée et soutenue à l'Université Humbolt (RDA), 1969;

- Long (Seam), "Les lexèmes primaires et leur champ sémantique en khmer," 29e congré des Orientalistes à Paris août 1973;

- Martini (Fraçois), La langue cambodgienne, École Nationale des Langues Orientales, Paris;

- Prum (Moal), "Analyse sommaire des structures du cambodgien", revue Communauté Khmère d'Outre-Mer, n° 2- Paris , 1962;

- Prum (Moal), "Notion de genre et de nombre en cambodgien", revue Communauté Khmère d'Outre-Mer, n° 3- Paris , 1964;

- Prum (Marc), "Processus sociolinguistique de la transformation du système lexicologique du khmer", revue Tétralogiques, n° 7, mai 1989, UFR du Langage, Presse Universitaire Rennes II.

## មាតិការបស់អត្ថបទ


១- ការសង្កេតប្រមើលមើល ---១០៥

១.១- ស្ថានភាពវិជ្ជមាន ---១០៥

១.២- ស្ថានភាពអវិជ្ជមាន ---១០៦

១.២.១- ការបង្កើត/ប្រើពាក្យក្នុងស្ថានភាពមិនស្របនឹង ប្រព័ន្ធកម្ចាយពាក្យដែលមានមកស្រាប់ ---១០៦

១.២.២- ការបង្កើត/ប្រើពាក្យក្នុងស្ថានភាពស្ទាក់ស្ទើរ ---១០៦

១.២.៣- ការបង្កើត/ប្រើពាក្យថ្មីជំនួសពាក្យចាស់ ---១០៨

១.២.៤- ការប្រើត្រួតគ្នានូវពាក្យ/ធាតុដែលមានន័យដូចគ្នា ---១០៩

២- ការស្វែងយល់ពីកម្ចាយពាក្យក្នុងភាសាខ្មែរ & ការបំផុសអោយចេញជាប្រព័ន្ធ ---១០៩

២.១- ស្ថានភាពនៃស័ព្ទវេយ្យាករណ៍ ---១០៩

២.១.១- កង្វះឯកភាពក្នុងការប្រើពាក្យសម្គាល់ ស័ព្ទវេយ្យាករណ៍ សម្រាប់បង្កើតពាក្យ ---១០៩

២.១.២- កង្វះឯកភាពក្នុងការកំណត់ន័យអោយ ស័ព្ទវេយ្យាករណ៍ សម្រាប់បង្កើតពាក្យ ---១១១

២.២- ប្រព័ន្ធកម្ចាយពាក្យ បែបខ្មែរ-មន ---១១២

២.២.១- ការប្រើប្រាស់ស័ព្ទវេយ្យាករណ៍ ---១១២

២.២.១.១- អក្ខាសបទ/មូលបទ ---១១២

២.២.១.២- បរៈមូលបទ ---១១៤

២.២.២- ការសាកល្បងដោះស្រាយបញ្ហា ---១១៤

២.៣- ប្រព័ន្ធកម្ចាយពាក្យ បែបខ្មែរ-ឥណ្ឌា ---១១៦

២.៣.១- ការប្រើប្រាស់ស័ព្ទវេយ្យាករណ៍ ---១១៦

២.៣.២- ការសាកល្បងដោះស្រាយបញ្ហា ---១១៦

២.៤- ប្រព័ន្ធកម្ចាយពាក្យ ក្នុង ស្ថានភាព វេយ្យាករណីយកម្ម ---១១៧

២.៤.១- ការប្រើប្រាស់ស័ព្ទវេយ្យាករណ៍ ---១១៧

២.៤.២- ការសាកល្បងដោះស្រាយបញ្ហា ---១១៧

៣- សេចក្ដីសន្និដ្ឋាន ---១១៨

**គន្ថនិទ្ទេស** ---១១៩

# មធ្យោបាយញុាំងសកម្មភាពក្នុងភាសាខ្មែរសម័យទំនើប [១]

រៀបរៀងដោយ ផង់ ភិរុណ

----------

## ជំពូកទី១

## ប្រភេទនៃមធ្យោបាយញុាំងសកម្មភាព

**១ – ទស្សនៈលើការសិក្សាមធ្យោយញុាំងសកម្មភាព**

កន្លងមក យើងសង្កេតឃើញថា ទាំងអ្នកភាសាវិទ្យាខ្មែរ ទាំងអ្នកភាសាវិទ្យាបរទេស ក៏ដូចជាអ្នកប្រើប្រាស់ភាសាទូទៅតែងតែប្រើ "*ល្បះបញ្ជា*" ភ្ជាប់មកជាមួយជាដរាប នៅពេលដែលគេចង់ "*សំណូមពរ បង្គាប់បញ្ជា អង្វរករ ហាមឃាត់ ...*" ដើម្បីឱ្យនរណាមួយធ្វើអ្វី ឬ មិនឱ្យធ្វើមួយជាដើម...។

*- សូមមេត្តាមានប្រសាសន៍មក !* (ភូមិតិរច្ឆាន ទំ. ២៧) ។

*-នាង ! ចូរជួយពិគ្រោះបងពិសូជាត និង ណារិនបន្ថិច* ( សូផាត ទំ. ២៣ ) ។

**អ្វីទៅដែលហៅថា "មធ្យោបាយញុាំងសកម្មភាព" ?**

*មធ្យោបាយញុាំងសកម្មភាព* ក្នុងទីនេះ មិនមែនសំដៅតែទៅលើ "*ល្បះបញ្ជា*" ប៉ុណ្ណោះទេ មានន័យថា នៅមានធាតុបន្ថែមមួយចំនួនទៀត ដែលយើងលើកយកមកបង្ហាញក្នុងសារណានេះ ។ ដូចជា ÷ *ពាក្យ ឬ កន្សោមពាក្យ ភាសិត ល្បះ សូរសញ្ញា ផ្លាកសញ្ញា កាយវិការ* ។ ធាតុទាំងនោះសុទ្ធតែបង្កប់ន័យញុាំងសកម្មភាព ហើយគេប្រើដើម្បីញុាំងមនុស្ស ( អាចសត្វ ) ឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពអ្វីមួយ។ ទាំងនេះគេហៅថា ( មធ្យោបាយញុាំងសកម្មភាព ) នេះឯង ។

**២ – មធ្យោបាយញុាំងសកម្មភាពក្នុងន័យវិទ្យា** ( Semantics )

**ក – ពាក្យសព្ទដែលមានន័យញុាំងសកម្មភាព**

មធ្យោបាយញុាំងសកម្មភាពក្នុងន័យវិទ្យា ក្នុងទីនេះ គឺចង់បង្ហាញឱ្យឃើញថា ពាក្យសព្ទមួយចំនួនមានបង្កប់ន័យញុាំងសកម្មភាពក្នុងនោះរួចជាស្រេច ។ ក្នុងនោះ យើងសង្កេតឃើញថា ពាក្យខ្លះមានន័យជាបែប "*អង្វរករ បញ្ចុះបញ្ចូល ធ្វើសំណូមពរ ហាមឃាត់ ..*".។ល។

អន្ទង កិ. ដឹកនាំ ឬ បញ្ចុះបញ្ចូល ឱ្យព្រមតាម ឱ្យដើរតាម ( វចនានុក្រមខ្មែរ ទំ. ១៦៦៦ ) ។ ម្យ៉ាងទៀត ពាក្យសព្ទក្នុងន័យវិទ្យានេះមានពាក្យមួយចំនួនជាពាក្យកំលាយចេញពីផ្នត់ដើម ( Prefixe ) និង

---

[១] - អត្ថបទស្រាវជ្រាវនេះដកស្រង់ចេញពីសារណារបស់និស្សិត ផង់ ភិរុណ : ការពារនៅខែតុលា ឆ្នាំ ២០០២ ។

ផ្នត់ជែក ( Infixe ) ថែមទៀតផង ។ បង្រៀន កិ ញ៉ាំងអ្នកដទៃ ឱ្យរៀន ក្លាយពីពាក្យឫស ( រៀន ) តាមរយៈផ្នត់ដើម ( ប់ង- ) ។ ថ្នាក់ពាក្យខ្លះទៀតជា *"នាមស័ព្ទ"* ដូចជា កំហិត ( ន ) ការដាក់កំហិត ។ កំហិត គឺជាពាក្យក្លាយចេញមកពីពាក្យឫស ( ខិត )តាមរយៈផ្នត់ជែក (-អំម-) ទំរង់ (-សព-) ។

*ភាគច្រើននៃពាក្យទាំងនោះមានលក្ខណៈជាកិរិយាហេតុ* ( Causative Verbs ) ។ ដូចជា ÷ *បង្ហំ បង្រៀន បង្គាប់ បង្គាប់បញ្ជា ប្រដែប្រដៅ ...* " ជាដើម ។

ខ - <u>ពាក្យភាសិតដែលមានន័យញ៉ាំងសកម្មភាព</u> :

*ភាសិតក៏មានមុខងារបង្កប់ន័យញ៉ាំងមនុស្សឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពអ្វីមួយដែរ* ។ ក្នុងនោះយើងសង្កេតឃើញថា ភាសិតខ្លះទៀតមានអត្ថន័យជាបែប *"បង្គាប់បញ្ជា ហាមឃាត់ .អង្វរករ... "* ។

*-បើមិនជួយចូកជួយចែវកុំយកជើងរាទឹក* ( ប្រមូលភាសិតខ្មែរ ទំ. ១៥២ ) ។

ម្យ៉ាងទៀត យើងសង្កេតឃើញថា ក្នុងភាសិត មាន ឃ្លា ល្បះ មួយចំនួនមានការផ្លាស់ប្តូរទីតាំងនៃលំដាប់ពាក្យខុសប្លែកពី ឃ្លា ល្បះ ធម្មតា ។ ដូចជា គេប្តូរទីតាំងរបស់ *" កម្មបទ "* ត្រឡប់មកនៅខាងឆ្វេង *"កិរិយាស័ព្ទ"* វិញ ។

*ជ្រៃ ស្វាយ កន្ទ្រាញ និង កុកស* កុំត្រេកអរ កុំធ្វើត្រាប់តាម ។

↓ ↓

កម្មបទផ្ទាល់ កន្សោមកិរិយា

គ - <u>បន្សោបាយញ៉ាំងសកម្មភាពក្នុងន័យសម្ព័ន្ធវិទ្យា</u> : ( Syntaxes )

ក្នុងផ្នែកនេះ យើងយកល្បះមួយចំនួនមកបង្ហាញ ដែលល្បះទាំងនោះសុទ្ធតែបង្កប់ន័យញ៉ាំងសកម្ម-ភាព ។ ដូចជា ÷ *ល្បះបញ្ជាពេញលេញ ល្បះបញ្ជាមិនពេញលេញ ល្បះឧទាន ល្បះសំណូរ ល្បះមាន-លក្ខ័ខណ្ឌ* និង *ល្បះសម្រាប់ញ៉ាំងសត្វ* ជាដើម ។

ក - <u>និយមន័យល្បះបញ្ជា</u> :

ទាំងអ្នកភាសាវិទ្យាខ្មែរ ទាំងអ្នកភាសាវិទ្យាបរទេស បានឯកភាពគ្នាទៅលើនិយមន័យល្បះបញ្ជាថា ជា *" ល្បះដែលគេប្រើសម្រាប់ ធ្វើការបង្គាប់បញ្ជា សំណូមពរ អង្វរករ ហាមឃាត់ ធ្វើសេចក្តីសន្និដ្ឋាន ឬ បញ្ជាក់ពីសេចក្តីប៉ងប្រាថ្នា ...ជាដើម "* ។

*- ចូរឯងកុំភ្លេចទៅវត្តឧណ្ណាលោម* ( សូផាត ទំ. ១១ ) ។

ខ - <u>ការប្រើប្រាស់សព្វនាមបុរិសៈនៅក្នុងល្បះបញ្ជា</u>

ជាទូទៅ គេប្រើសព្វនាមបុរិសៈបុរសទី២ ទាំងឯកវចនៈ ទាំងពហុវចនៈ នៅក្នុងល្បះបញ្ជា ច្រើនជាងការប្រើសព្វនាមបុរិសៈបុរសទី ១ និង បុរសទី៣ ដែលមានពណ៌នាតែនៅក្នុងអត្ថបទវិចារណកថា ឬ នៅក្នុងអត្ថបទប្រលោមលោក ប៉ុណ្ណោះ ។

*-ព្រះមហាក្សត្រឱ្យអាមាត្យយកស្លឹកប្រយង់បង្អកគោ* ( ប្រជុំរឿងព្រេងខ្មែរ ភាគ៣ ទំ. ៧៤ ) ។

**ត - ល្បះបញ្ជាមិនពេញលេញ**

ល្បះបញ្ជាមិនពេញលេញ ជាល្បះដែលខ្វះធាតុណាមួយ ជួនកាល មានតែប្រធាន ជួនកាលទៀត មានតែកិរិយាសព្ទ ។ ដូចជា ÷

**ត.១ - ល្បះដែលប្រើកិរិយាស័ព្ទជាធាតុសំខាន់** ( Predicate )

ល្បះដែលប្រើតែកិរិយាស័ព្ទ ឬ កន្សោមកិរិយាគឺជាល្បះដែលគេយកកិរិយាសព្ទមកប្រើប្រាស់ដោយបង្កប់ន័យញុាំងសកម្មភាពនៅក្នុងនោះ ។ ដូចជា ÷ *ទៅៗ ! ក្រោក ច្រេក !* ។

**ត.២ - ល្បះដែលប្រើនាមជាធាតុសំខាន់**

ក្នុងល្បះប្រភេទនេះ គឺគេយកនាមមួយចំនួនមកប្រើប្រាស់ ដែលមានន័យញុាំងសកម្មភាព ។ ដូចជា ÷ *កាត យ៉ាណើ អ្នក !* ។

**ត.៣ - ល្បះដែលប្រើកិរិយាវិសេសន៍ជាធាតុសំខាន់** ( Adverb )

ល្បះដែលប្រើកិរិយាវិសេសន៍ជាធាតុសំខាន់ គឺជាល្បះដែលគេយកកិរិយាវិសេសន៍មកប្រើប្រាស់ដើម្បីញុាំងមនុស្សឱ្យធ្វើ ឬ មិនឱ្យធ្វើអ្វីមួយ ។ ដូចជា *តិចៗ ! លឿនឡើង ! ឆាប់ទៅ !* ។

**ត.៤ - ល្បះដែលប្រើគុណនាមជាធាតុសំខាន់** ( Adjective )

ល្បះប្រភេទនេះ គឺគេយកគុណនាមមកប្រើដើម្បីញុាំងមនុស្សឱ្យធ្វើសកម្មភាព ។ ដូចជា ÷ មួយ ពីរ... ជាដើម ។ គេប្រើគុណនាម (មួយ ពីរ) ដើម្បីបង្គាប់បញ្ជាមនុស្សឱ្យរត់ ឬ ព្យុះហយាត្រា នៅក្នុងជួរកងទ័ព...ជាដើម ។ល ។

**ត.៥ - ល្បះដែលប្រើនិបាតសព្ទ និង ឧទានសព្ទជាធាតុសំខាន់**

ក្រៅពីនេះ និបាតសព្ទ និង ឧទានសព្ទ ក៏ត្រូវបានគេយកមកប្រើប្រាស់ដើម្បីញុាំងមនុស្សឱ្យធ្វើសកម្មភាពបានដែរ ។ ដូចជា ÷

-*ហ៊ឺយ* និ. នែ ! ពាក្យសម្រាប់ប្រើប្រាស់ក្នុងការហៅគ្នា ឬ ប្រើជាសញ្ញាហាមឃាត់មិនឱ្យធ្វើអ្វីមួយ ជាដើម ។

-*អ្ហែ ! ឱ. សូរលាន់មាត់ បន្ទុច បន្ទោស ឃាត់ ( នែ ) អ្ហែ ! ម៉េចអីចេះ ? ខុសទេ !*

**យ – ល្បះឧទានដែលមានន័យញ៉ាំងសកម្មភាព :**

តាមនិយមន័យ ល្បះឧទាន គឺគ្រាន់តែជាល្បះមួយដែលគេប្រើសម្រាប់សំដែងពី *សញ្ចេតនា* ឬ ជា *ការសំដែងពីអារម្មណ៍គ្រប់បែបយ៉ាង... តែប៉ុណ្ណោះ* ។ ដោយឡែក ល្បះឧទាននៅក្នុងសារណានេះ គេយកមកប្រើប្រាស់ដើម្បីញ៉ាំងមនុស្ស ឬ សត្វឱ្យធ្វើមិនឱ្យធ្វើសកម្មភាពថែមទៀតផង ។

- *ខំអត់ទៅកូន ! លោកតាស្រោចឱ្យនាងជាប្អាំ !* ( ផ្កាស្រពោន ទំ.១១៦ ) ។

**ង – មធ្យោបាយញ៉ាំងសកម្មភាពក្នុងល្បះដែលមានប្រធានជាសព្វនាមមិនច្បាស់**

មធ្យោបាយញ៉ាំងសកម្មភាពក្នុងល្បះប្រភេទនេះ គឺគេយកសព្វនាមមិនច្បាស់មកប្រើប្រាស់ក្នុងល្បះដើម្បីធ្វើការបង្គាប់បញ្ជាទរណាមួយឱ្យធ្វើ ឬមិនឱ្យអ្វីមួយ ជាដើម ។

*បុគ្គលមិនគប្បីធ្វេសប្រហែសដោយគិតថា ...* (ស្រីហិតោបទេស ភាគ ៣ ទំ. ៥៩ ) ។

**ច – ល្បះសំណួរដែលមានន័យញ៉ាំងសកម្មភាព :**

ល្បះសំណួរមានបង្កប់ន័យញ៉ាំងសកម្មភាព គឺជាល្បះដែលគេប្រើជាការចោទសួរផងហើយបង្កប់ន័យញ៉ាំងសកម្មភាពនៅក្នុងនោះថែមទៀតផង ។

- *គួរតាំងអ្នកណា ឱ្យចាត់ចែងការពារបន្ទាយត្រៀមទុកទើបបានល្អ ?*

(ស្រីហិតោបទេស ភាគ៣ ទំ. ៣៦ )

**ឆ – ល្បះរណបមានលក្ខខណ្ឌក្នុងន័យញ៉ាំងសកម្មភាព**

ល្បះរណបមានលក្ខខណ្ឌក្នុងន័យញ៉ាំងសកម្មភាពគឺ ជាល្បះដែលគេប្រើឃ្លារណបបញ្ជាក់ពីការកំណត់លក្ខខណ្ឌ ឬ បញ្ជាក់ពីការសន្មត ជាការសន្យា ដើម្បីញ៉ាំងមនុស្សឱ្យធ្វើអ្វី ឬ មិនឱ្យធ្វើអ្វីមួយ ។

*បើបងប្អូនណាមិនទៅតាមយើងខ្ញុំទេ យើងខ្ញុំនឹងសម្លាប់ចោលមួយពូជ*

*សូម្បីតែកូននៅក្នុងអង្រឹង ក៏មិនទុកជីវិតឱ្យដែរ* ( *ភូមិតិរច្ឆាន* ទំ. ៧៤ ) ។

**ជ – ល្បះសម្រាប់ញ៉ាំងសត្វឱ្យធ្វើសកម្មភាព :**

ល្បះប្រើសម្រាប់ញ៉ាំងសត្វឱ្យធ្វើសកម្មភាព គឺជាល្បះដែលភាគច្រើនគេយក *ឧទានសព្ទ កិរិយាសព្ទ* ឬ *កិរិយាវិសេសន៍* មកប្រើប្រាស់សម្រាប់ប្រើជាមួយសត្វឱ្យធ្វើសកម្មភាព ។

ហាបៗ ! ( ស្រែកបញ្ជាគោឱ្យឈប់...) *បៀត ៗ* ( ស្រែកបញ្ជាឱ្យគោចូលខាង ) ... ជាដើម ។

## ជំពូកទី២

## ប្រភេទទំរង់ល្បះបញ្ជាក្នុងភាសាខ្មែរ

១- ទំរង់ល្បះបញ្ជាពេញលេញ :

ក- ចូរ + ប្រធាន + កន្សោមកិរិយា

- *ចូរបាចាំស្ដាប់បណ្ដាំឪពុកទុកចុះថា...* ( កូឡាបប៉ៃលិន ទំ. ៥ )

ខ- គួរ + ប្រធាន + កន្សោមកិរិយា

- *គួរយើងទៅរៀនឱ្យទាន់ពេល* ( វេយ្យាករណ៍ថ្នាក់ទី៧ ទំ. ១៣២ )

គ- គួរតែ + ប្រធាន + កន្សោមកិរិយា

- *សូមស្ដេចប្រយ័ត្ននាងណា កុំឱ្យយាត្រា លីលាទៅលេងស្រះស្រី...* ( ព្រះសុធន ទំ.៦ ) ។

២- ទំរង់ល្បះបញ្ជាមិនពេញលេញ :

ក- នាម ( កន្សោមនាម )

*-ម៉ាក់ !*

*-កាត !*

ខ- កិរិយាស័ព្ទ ( កន្សោមកិរិយា )

*ក្រោក ! ទៅ !*

គ- កន្សោមកិរិយា + ធាតុណាមផ្សេងទៀត :

*មើលយកសៀវភៅស៊ីក្លូមកមើល ...* ( ព្រះអាទិត្យថ្មីរះលើផែនដីចាស់ ទំ.១៩ ) ។

( សូមមើលទំរង់ល្បះបញ្ជាទាំងនោះនៅក្នុងឧបសម្ព័ន្ធផ្នែកទី៣ ចាប់ពីទំព័រ ១២ នៃសារណា ) ។

៣- ប្រភេទនៃសព្វនាមបុរិសៈបុរសទី៣ និង បុរសទី១ ដែលប្រើក្នុងល្បះបញ្ជា

ជាទូទៅ នៅក្នុងប្រភេទសព្វនាមបុរិសៈបុរសទី៣ និង បុរសទី១នេះ មានទំរង់ដូចខាងក្រោម ÷

- កិរិយាសព្ទ + ឱ្យ + កន្សោមនាម + កន្សោមកិរិយា

*គេចាត់ឱ្យកងអាវុធហត្ថស៊ើបអង្កេតភ្លាម* ( ប្រពន្ធ៍វាកិរិយាខ្ញុំ ទំ. ៣៦ )

-កិរិយាសព្ទ + កន្សោមនាម + ឱ្យ + កន្សោមកិរិយា

*ព្រះនាងប្រាប់ពួកអ្នកបំរើឱ្យរៀបព្រះទីនាំងដរី* ( ប្រជុំរឿងព្រេងខ្មែរ ទំ. ៩២ )

៤- លក្ខណៈនៃការបង្គាប់បញ្ជា

**ក – ការប្រើប្រាស់សូរស្រៈ**

ក្នុងភាសាខ្មែរ ការបង្គាប់បញ្ជាមួយចំនួន មានបង្កប់សូរស្រៈនៅក្នុងនោះ ។ ដូចជា ពាក្យ ( សូម ) ដែលមានសូរសំលេងបង្អូសវែងនៅក្នុងនោះ ។ មានន័យថា អ្នកនិយាយនោះជាអ្នកដែលមានឋានៈទាប និយាយទៅកាន់នរណាម្នាក់ដែលមានឋានៈខ្ពស់ ។

*- សូមព្រះស្វាមីប្រយ័ត្នខ្លួន* ( ឆន្ទមឿង ទំ. ៣៦ ) ។

ចំណែកសូរស្រៈខ្លី ( សុំ ) វិញ គេសំគាល់បានថា អ្នកធ្វើការបង្គាប់បញ្ជាជាមនុស្សមានឋានៈខ្ពស់ និយាយទៅកាន់អ្នកដែលមានឋានៈទាបជាងខ្លួន ។

*- សុំឯងនិយាយឱ្យឆាប់មក* ។

**ខ – ការបង្គាប់បញ្ជាដោយផ្ទាល់**

ការបញ្ជាប្រភេទនេះ គេយកកិរិយាសព្ទតែមួយធាតុមកប្រើ ។

*ដេក ! ទៅ ! មក !*

**គ – ការបង្គាប់បញ្ជាដោយប្រយោល**

ជាទូទៅ នៅក្នុងទំរង់ប្រភេទនេះ គេច្រើនប្រើកិរិយាសព្ទ ( ទៅ ចុះ មក៍ ) មកប្រើជាមួយ ដើម្បីបញ្ជាក់ពីការអនុញ្ញាត ឬ ជាការយល់ព្រម ឬ មួយបង្កប់នូវលក្ខណៈបង្ខំ ...ជាដើម ។

*- និយាយមក៍ ! យកទៅ !*

## ជំពូកទី៣

## មធ្យោបាយញ៉ាំងសកម្មភាពក្រៅភាសាវិទ្យា

យើងបែងចែក មធ្យោបាយញ៉ាំងសកម្មភាពក្រៅភាសានេះ ជាបួនផ្នែកសំខាន់ៗ ដូចជា "សូរសញ្ញា ផ្លាកសញ្ញា កាយវិការ និង សញ្ញាផ្សេងៗទៀត " ។

**១ – សូរសញ្ញាដែលមានន័យញ៉ាំងសកម្មភាព**

សូរសញ្ញាប្រភេទនេះមាន ដូចជា សូរកញ្ចែ សំលេងត្រែ សូរស៊ីរ៉ែន... ជាដើម ។ ល ។

*- រថយន្តអមដំណើរគណៈប្រតិភូបញ្ចេញសូរស៊ីរ៉ែនដើម្បីសុំផ្លូវទៅមុន*

**២ – ផ្លាកសញ្ញាដែលមានន័យញ៉ាំងសកម្មភាព :**

ផ្លាកសញ្ញាដែលពិណនានៅក្នុងទីនេះគឺ យើងសង្កតធ្ងន់ទៅលើផ្លាកសញ្ញាចរាចរ ។ សញ្ញាចរាចរមួយចំនួនដែលប្រើក្នុងន័យញ៉ាំងសកម្មភាពមានច្រើនប្រភេទដូចជា " សញ្ញាគ្រោះថ្នាក់ សញ្ញាហាមឃាត់ សញ្ញា

បញ្ហា សញ្ញាប្រាប់ដំណឹង ... "។ល។

*ភ្លើងស្តុបពណ៌លឿង ជាសញ្ញាប្រាប់ឱ្យអ្នកធ្វើចរាចរមានការប្រុងប្រយត្ន័*

*ពណ៌ក្រហម ជាសញ្ញាប្រាប់ឱ្យឈប់*

*រីឯពណ៌ខៀវ ជាសញ្ញាប្រាប់ឱ្យធ្វើដំណើរបន្ត ...* ។

**៣ – កាយវិការដែលមានន័យញ៉ាំងសកម្មភាព**

កាយវិការនៅក្នុងទីនេះមានដូចជា ញាក់ចិញ្ចើម ងក់ក្បាល គ្រវីក្បាល បក់ដៃ...។ល។ គេប្រើកាយវិការងក់ក្បាល ដើម្បីបង្ហាញពីការយល់ព្រមថា នឹងធ្វើអ្វីមួយតាមការស្នើសុំពីនរណាម្នាក់។ ចំណែកការគ្រវីក្បាលមានន័យថា បដិសេធនឹងចំពោះសកម្មភាពអ្វីមួយ ឬ ហាមនរណាមួយមិនឱ្យប្រព្រឹត្តអ្វីមួយ ...ជាដើម ។

**៤ – សញ្ញាផ្សេងៗទៀតដែលបង្កប់ន័យញ៉ាំងសកម្មភាព**

សញ្ញាប្រភេទនេះមានដូចជា *"សញ្ញាក្បាលខ្មោច សញ្ញារូបបារី ..."*។ គេប្រើសញ្ញាក្បាលខ្មោចនេះ *សម្រាប់ហាមប្រាម ឬ ប្រាប់មនុស្សឱ្យមានការប្រុងប្រយត្ន័ ចំពោះគ្រោះថ្នាក់ ដែលនឹងកើតមាននៅទីនោះ* (គ្រាប់មីន បន្ទប់ផ្ទុកចរន្តអគ្គិសនី ...) ជាដើម ។

## ជំពូកទី៤

## ការប្រើប្រាស់មធ្យោបាយញ៉ាំងសកម្មភាពក្នុងភាសាខ្មែរ

យើងសង្កេតឃើញថា ក្នុងសង្គមខ្មែរ ការប្រើភាសាទាក់ទងគ្នាអាចឱ្យយើងស្គាល់ពីលំដាប់ឋានៈលំដាប់អាយុនៃអ្នកប្រើប្រាស់ម្នាក់ៗបានច្បាស់លាស់ ។ ដូចជា ក្នុងពេលវេលាតែមួយ ទីកន្លែងតែមួយ អ្នកនិយាយជាមនុស្សដដែល តែមានការចែកដាច់គ្នារវាងគ្នានឹងគ្នា ។ ដូចជា នាងយុននារីនិយាយថា ÷

- *ទៅរើសដុំថ្មបីដុំមក ហើយរើសឧសបង្កាត់ភ្លើងផង* ( កូឡាបប៉ៃលិន ទំ. ៥៧ ) ។

- លោកបាឡាត់ អាណិតយកសាច់ដាក់កំប៉ុង មកឱ្យពីកំប៉ុង និង សណ្តែកបាឡាន់តាវផង (កូឡាបប៉ៃលិន ទំ. ៥៧ ) ។ ( សូមមើលខ្លឹមសារពេញលេញក្នុងសារណាទាំងមូល នៅទំ. ៣៦ )

**សេចក្តីសន្និដ្ឋាន**

រួមមក មធ្យោបាយញ៉ាំងសកម្មភាពក្នុងភាសាខ្មែរសម័យទំនើបដែលជាប្រធានបទក្នុងសារណានេះបានក្តោបយកធាតុសំខាន់ៗពីរយ៉ាងគឺ ធាតុខាងក្នុងភាសាវិទ្យា ដូចជា *"ពាក្យសព្ទ័ ពាក្យ ភាសិត ល្បះ"* និងធាតុក្រៅភាសាវិទ្យាខ្លះទៀតមាន *" សូរសញ្ញា ផ្លាកសញ្ញា កាយវិការ និង សញ្ញាផ្សេងៗ ទៀត "* ។

ធាតុក្នុងភាសា និង ធាតុក្រៅភាសា ទាំងនេះសុទ្ធតែមានបង្កប់ន័យញ៉ាំងមនុស្ស សត្វ ឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាព ដូចល្បះបញ្ជាដែរ ។ ដូចជា គេប្រើពាក្យ *ហាម បញ្ជា បង្គាប់បញ្ជា ព្រមាន ឃាត់* ...។

ធាតុនៃភាសិតមាន *កុំជិះចង្អេរលើកខ្លួនឯង ក្បាលទូកកញ្រ្ចែងកុំក្អេងក្អាង* ... (ប្រមូលភាសិតខ្មែរ ទំ. ៥ ) ។ល ។

ទាំងនេះគេហៅថា មធ្យោបាយញ៉ាំងសកម្មភាពក្នុងន័យវិទ្យា ។ ចំណែកល្បះ ដូចជាគេប្រើពាក្យថា ÷

- *សូមទានប្រណីក្ដីអនុញ្ញាត សង្ឃាតជ្រកក្រោមធូលី* ( តេជោដំឌិន ទំ. ៦០ ) ។

- *សម្រាក ប្រុង ឆ្វេងបែរ មួយ ពីរ នែ ! ហឺ ! ក្រោក អង្គុយ* ... ។

ទាំងនេះហៅថា មធ្យោបាយញ៉ាំងសកម្មភាពក្នុងន័យសម្ពន្ធ័វិទ្យា ។ ចំណែកឯធាតុខាងក្រៅភាសាវិទ្យាមានដូចជា ÷ *ការញាក់ចិញ្ចើម សូរកញ្ចែ ស៊ីរ៉ែន ភ្លើងស្តុប សញ្ញាហាមចត សញ្ញាគ្រោះថ្នាក់* និង *សញ្ញាក្បាលខ្មោច សញ្ញាហាមជក់បារី*...ជាដើម ។ល ។

ធាតុទាំងពីរនេះហើយ ( ធាតុខាងក្នុងភាសា និង ធាតុខាងក្រៅភាសា ) ដែលមនុស្សគ្រប់ឋានៈពណ៌សំបុរ គ្រប់វ័យ គ្រប់ជាតិសាសន៍ គ្រប់សម័យកាល តែងតែយកមកប្រើប្រាស់គ្រប់សកម្មភាពនៃទំនាក់ទំនងជាចាំបាច់ក្នុងសង្គម ។

មានន័យថា ទីណា ពេលណាក៏ដោយឱ្យតែមនុស្សប្រើភាសាទាក់ទងគ្នា ពេលនោះមនុស្សពិតជាមិនអាចបំភ្លេច មធ្យោបាយញ៉ាំងសកម្មភាព ភ្ជាប់មកជាមួយជាដរាប ។ ទោះជាយ៉ាងនេះក្ដី មធ្យោបាយញ៉ាំងសកម្មភាពក៏ជាអាវុធមុខពីរដែរ ព្រោះ បើយើងប្រើប្រាស់ខុសកាលៈទេសៈ វានាំឱ្យយើងមានការបែកបាក់ចំណងសាមគ្គីគ្នា តែបើយើងប្រើប្រាស់បានត្រឹមត្រូវ វានាំឱ្យយើងមានសាមគ្គីភាពនឹងគ្នាទាំងនៅក្នុងរង្វង់គ្រួសារ ក៏ដូចជានៅក្នុងសង្គមធំដែរ ។

ដូចនេះ មធ្យោបាយញ៉ាំងសកម្មភាព មិនត្រឹមតែជាចំណែកមួយក្នុងការអភិវឌ្ឍន៍ភាសាខ្មែរ ឬ ជាប្រទីបសម្រាប់អ្នកសិក្សាស្រាវជ្រាវផ្នែកភាសា និង អ្នកប្រើប្រាស់គ្រប់មជ្ឈដ្ឋានប៉ុណ្ណោះទេ វាក៏ជាឧបករណ៍នៃគំនិតយ៉ាងសំខាន់ ដែលធ្វើឱ្យសង្គមគ្រួសារក្ដី សង្គមជាតិទាំងមូលក្ដី អាចចងសម្ពន្ធ័ភាពគ្នា ស្រុះស្រួលគ្នា ឬ មួយជាមេបំបែកបំបាក់ ទាស់ទែងគ្នា ក៏ដោយសារមធ្យោបាយញ៉ាំងសកម្មភាពនេះដែរ ។

## គន្ថនិទ្ទេស

១- ឯកសារជាតិ :

-ក្រសួងអប់រំ : មជ្ឈមណ្ឌលនិពន្ធកម្មវិធីសិក្សានិងសៀវភៅសិក្សា *វេយ្យាករណ៍ ថ្នាក់ទី ៦* ភ្នំពេញ ១៩៨២.
មជ្ឈមណ្ឌលនិពន្ធកម្មវិធីសិក្សានិងសៀវភៅសិក្សា *វេយ្យាករណ៍ ថ្នាក់ទី ៧* ភ្នំពេញ ១៩៨៣.
មជ្ឈមណ្ឌលនិពន្ធកម្មវិធីសិក្សានិងសៀវភៅសិក្សា *កម្រងអត្ថបទអក្សរសិល្ប៍ ថ្នាក់ទី ៦* ភ្នំពេញ ឆ្នាំ ១៩៨២ ។

- ក្រសួងសាធារណការ ដឹកជញ្ជូន និង ប្រៃសណីយ៍ : *ច្បាប់ចរាចរផ្លូវគោក ភ្នំពេញ* ឆ្នាំ ១៩៩២ ។
- ខៀវ ជុំ : *វេយ្យាករណ៍យើង* រោងពុម្ព ទៀង សៀងហុង ភ្នំពេញ ឆ្នាំ ១៩៦៦ ។
- គយ សារុន : *កំណាព្យបុប្ផាខ្មៅ* រោងពុម្ព ភ្នំពេញ ឆ្នាំ ១៩៧០ ។
- គីម សែត : *វេយ្យាករណ៍ទំនើប និង វិធីសម្ពន្ធ័* បណ្ណាគារ វង់ រស្មី កំពង់ចាម ឆ្នាំ ១៩៦៣ ។
- គង់ ថាន់ : *សិល្បវិជ្ជាប្រាស្រ័យទាក់ទង* (ការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងប្រជាកថា) ភ្នំពេញ ១៩៩៧ ។
- គណៈកមាធិការតាក់តែងច្បាប់ នៃសាធារណរដ្ឋខ្មែរ : *គំរោងរដ្ឋធម្មនុញ្ញ* ភ្នំពេញ ឆ្នាំ ១៩៧០ ។
- ឃីង ហុកឌី : *ភោគកុលកុមារ* បោះពុម្ព នៅភ្នំពេញ ឆ្នាំ ១៩៩៥ ។
- ឃិន សុខ : *វេយ្យាករណ៍ភាសាខ្មែរ ភាគទី២* បារិស ឆ្នាំ ១៩៩៩ ។
- ឃិន សុខ : *សៀវភៅរៀនខ្មែរភាគទី១* Edition, You Feng, Librairie Editeur, Paris ,1999 ។
- ចាប ពិន : *ពាក្យចាស់បរិយាយ* ភ្នំពេញ ឆ្នាំ ១៩៥៩ ។
- ចន្ទ័ ឫទ្ធី : *ស្គាល់មនុស្សតាមរយៈកាយវិការ ភាគទី១* ភ្នំពេញ ឆ្នាំ ១៩៩៨ ។
- ជា ទន់ : *អនុពាក្យអនុវត្តសម្រាប់វិទ្យាល័យ អនុវិទ្យាល័យ* ភ្នំពេញ ឆ្នាំ ១៩៦៣ ។
- ឈឹម ស៊ុម : *សង្ខេបទសជាតក* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៥៩ ។
- ញ៉ុក ថែម : *ខេមរៈវេយ្យាករណ៍សង្ខេប* បណ្ណាគារ ភ្នំពេញ ឆ្នាំ ១៩៦៥ ។
- ញ៉ុក ថែម : *កូឡាបប៉ៃលិន* បណ្ណាគារ ភ្នំពេញ ឆ្នាំ ១៩៦៥ ។
- ញ៉ែម ខែម និង កែវ សំណាង : *វចនានុក្រម សុភាសិត ភាសិត អង់គ្លេស-ខ្មែរ* ភ្នំពេញ ១៩៩៥ ។
- ញ៉ុក នូវ : *វេយ្យាករណ៍ខ្មែរ* ភ្នំពេញ ឆ្នាំ ១៩៦៥ ។
- ឌឹក គាម និង ឌៀក អំ : *ភូមិតិរច្ឆាន* រោងពុម្ព គីម គី ភ្នំពេញ ឆ្នាំ ១៩៧២ ។
- ទូច ស៊ុន : *ឆន្ទមឿង* ការផ្សាយរបស់បណ្ណាគារ គីម គី ភ្នំពេញ ឆ្នាំ ១៩៥២ ។

- នួន ប៊ុត និង ជុំ មួង : *ប្រមូលភាសិតខ្មែរ* ការផ្សាយរបស់សមាគម សម្តេច ជួន ណាត ភ្នំពេញ ១៩៥១ ។
- នូ ហាច : *ផ្កាស្រពោន* ភ្នំពេញ ឆ្នាំ ១៩៦០ ។
- នូ ហាច : *មាលាដួងចិត្ត* ភ្នំពេញ ឆ្នាំ ១៩៧០ ។
- ប៉ាង ខាត់ : *ស្រីហិតោបទេស ខ្សែ១-៤* ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ ១៩៦០ ។
- បណ្ណាគារ គីម សេង : *រតនាវង្ស ពីខ្សែ ១-១២* ភ្នំពេញ ឆ្នាំ ១៩៧២ ។
- បណ្ណាគារ គីម គិ : *ច្បាប់ត្រីនេត្រ* ភ្នំពេញ ឆ្នាំ ១៩៥៥ ។
- បណ្ណាគារ គីម គិ : *ស្តេចដំរីស* ភ្នំពេញ ឆ្នាំ ១៩៥៦ ។
- បណ្ណាគារ គីម គិ : *ពស់កេងកង* ភ្នំពេញ ឆ្នាំ ១៩៥៥ ។
- បណ្ណាគារ សេង ងួនហួត : *ព្រះសុធន* ភ្នំពេញ ឆ្នាំ ១៩៦០ ។
- ពុទ្ធសាសនបណ្ឌិត្យ : *វចនានុក្រមខ្មែរ* ភាគ ១ ភាគ ២ ឆ្នាំ ១៩៦៥ ។
- ពុទ្ធសាសនបណ្ឌិត្យ : *ពុទ្ធិសែននាងកង្រី* ភ្នំពេញ ឆ្នាំ ១៩៥៩ ។
- ពុទ្ធសាសនបណ្ឌិត្យ : *ខ្យងស័ង្ខ* ភ្នំពេញ ឆ្នាំ ១៩៦១ ។
- ពុទ្ធសាសនបណ្ឌិត្យ : *ច្បាប់ក្រមង៉ុយ* ភ្នំពេញ ឆ្នាំ ១៩៧២ ។
- ពុទ្ធសាសនបណ្ឌិត្យ : *សុបិនកុមារ* ភ្នំពេញ ឆ្នាំ ១៩៦៦ ។
- ព្រុំ ឈាមន្ទា : *រាត្រីមួយ* ភ្នំពេញ ឆ្នាំ ២០០០ ។
- ពូរ៉ អ៊ុម : *វេយ្យាករណ៍ខ្មែរពិស្តារ* ការផ្សាយរបស់ បណ្ណាគារ គីម សេង ភ្នំពេញ ឆ្នាំ ១៩៧២ ។
- ទី ជីហួត : *វិលរកទ្រទំ* អការបោះពុម្ពផ្សាយវប្បធម ឆ្នាំ ១៩៨៤ ។
- មាស សាម៉ឿន : *តេជោដំឌិន* បណ្ណាគារ គីម គិ ភ្នំពេញ ឆ្នាំ ១៩៥២ ។
- យោធានិរន្ទវ៉ាន់ : *សេកសារិកា* ភ្នំពេញ ឆ្នាំ ១៩១១ ។
- យស ងិន : *ស្រទបចេក* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ ១៩៦៦ ។
- យក់ គុណ : *ល្បើកកុក-ញីឈ្មោល* រោងពុម្ព ណុប បូផាន់ ភ្នំពេញ ឆ្នាំ ១៩៨៣ ។
- រឹម គីន : *សូផាត* ភ្នំពេញ ឆ្នាំ ១៩៥៨ ។
- វ៉ា សំអាត : *ភ្លើងវិបល្លាស* ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ ភ្នំពេញ ឆ្នាំ ១៩៩៨ ។
- សែម សូរ និង សុត សារុន : *វិញ្ញាសាមធ្យមសិក្សាបត្រ* រោងពុម្ព គីម គិ ភ្នំពេញ ឆ្នាំ ១៩៦៥ ។
- សែម សូរ : *ក្រុងសុភមិត្រ* ការផ្សាយរបស់បណ្ណាគារ ប្រទីបខ្មែរ ភ្នំពេញ ឆ្នាំ ១៩៦៣ ។

- ស៊ុម ស៊ូល និង ស៊ុម សួង : *មរណាដួងចិត្តជីវិតតារាពាជី* ភាគទី១ ភ្នំពេញ ឆ្នាំ ១៩៧៤ ។
- សាង សាវ៉ាត : *មហាចោរទល់ដែន* ភ្នំពេញ ឆ្នាំ ១៩៥៥ ។
- សៀង ខ័នឌី : *វេយ្យាករណ៍ខ្មែរទំនើប* ការផ្សាយរបស់បណ្ណាគារ គីម គី ភ្នំពេញ ឆ្នាំ ១៩៥៦ ។
- ស៊ីសុវត្ថិ ប៊ូរក្ខស៊ី : *បរិវារសព្ទក្នុងភាសាខ្មែរ* ការផ្សាររបស់ សមាគមសម្ដេច ជួន ណាត ភ្នំពេញ ១៩៧៣ ។
- ហេង ៈមេងថៃ : *ក្រអូបឥតក្លិន* ការផ្សាយរបស់ រោងពុម្ពចតុមុខ ភ្នំពេញ ឆ្នាំ ១៩៧៤ ។
- ហង្ស ធុនហាក់ : *សុវណ្ណសាម* ក្រសួងវប្បធម៌ ភ្នំពេញ ឆ្នាំ ១៩៧០ ។
- ឡុង ជឹម : *ច្បាប់គោរពមាតាបិតា* ភ្នំពេញ ឆ្នាំ ១៩៦៧ ។
- ឡុង ជឹម : *សង្ខ័សិល្ប៍ជ័យ* ការផ្សាយរបស់បណ្ណាគារ ភ្នំពេញ ឆ្នាំ ១៩៥៩ ។
- អ៊ុក វិបុល : *វេយ្យាករណ៍ខ្មែរទំនើប ថ្នាក់ទី ១២* គ្រឹស្ថានបោះពុម្ព និង ចែកផ្សាយក្រសួងអប់រំ ភ្នំពេញ ឆ្នាំ ២០០១ ។
- អ៊ឹម ថុក : *តូលីកំណែន* ភ្នំពេញ ១៩៥៦ ។

២- <u>ឯកសារជាភាសាអន្តរជាតិ</u> :

-Arther Tom , ***Oxford componian to English Language*** , Oxford University Press,1992
-Alexander L -G , ***Longman English Grammar*** , London & New York , 1994 .
-Bijelac Ranka & Berton Roland , ***Du langue aux langages*** , Gallimard Librairie ,Paris, 1997 .
-Bérard Evelyne , lavenne Christiant , ***Modes d'emplois Grammaire utile du française***, centre de linguistique Appliquée de beramcon , Didier , Paris 1991 .
-Chevalier Jean Claude , Blanche Benveniste Claire , Arrivé Michel , Peytard Jean , ***Grammaire la rousse du Contemporain*** , Larousse , Paris , 1994 .
-Dubois Jean, Jouannom Guey, ***Grammaire et exercices de français***, Larousse , Paris, 1959 .
-Dubois Jean , Giacomo Mathée, Guispin Louis, Marcellesi Christiant , Baptiste Jean, Pièrre Mével Jean , ***Linguistique et des sciences de la langag*** , Larousse , Paris , 1994 .
-Dougal M Littell, ***Building English Skills*** , Printed in the United States of America, 1985 .
-Dubois –Jean & Lagane –René , ***Difficultés grammaticales*** , Larousse , Paris , 1995 .
-East Wood John , ***Oxford guide to English Grammar*** , OxfordUniversity Press , 1999.
-Fergusson Rosalin , ***The penguin Dictionary of proverb bloombery*** , Book London, 1983 .
-Gosse André , Greviss , ***Le bon usage grammaire française*** , Duculot , Paris , 1993.
-Greviss Maurice , ***Précis de grammaire française*** , Larousse , Paris , 1973 .
-Hamon Albert , ***Grammaire*** , Hachette livre , Paris , 1993 .
-Judith Jacob , ***Introduction to Cambodian*** , Oxford University Press , United States , 1985.

-Krebs W A , *Collins Australian school dictionary* , Oxford University Press , 1992.
-Léon-Robert & Wagner , *Grammaire du français* , Hachette, Paris ,1991 .
-Mauger G , *Grammaire practique du française d'haujourd'hui* , Hachette, Paris , 1968 .
-Mitterent Hanri Jolle , Pindon Pages, Roger Schmith , *Langue française, 3* éditions, Fernand Nathan , Paris ,1994 .
-Martinet André, *Éléments de linguistiques Générales* , Librairie Armand Colin , Paris , 1970 .
-Maspéro Goege , *Grammaire de la langue Khmère* , Imprimerie Nationale , Paris , 1915 .
-Thomson A J & Martinet A V, *A Practical English Grammar* , Oxford University London , 1985 .

៣- ឯកសារផ្សេងៗ :

-ស៊ន សំណាង " *Mémoie et thése l'art les méthods Préparation , Redaction soutenance*"
រាជបណ្ឌិតសភាកម្ពុជា ភ្នំពេញ ឆ្នាំ ២០០១ ។

- ទស្សនាវដ្ដីកីឡា ឆ្នាំទី ២ លេខ ០០៩ ភ្នំពេញ ឆ្នាំ ២០០២ ។

- សេចក្ដីជូនដំណឹងរបស់សាលាក្រុងភ្នំពេញ : *ការប្រមូលពន្ធលើមធ្យោបាយយានយន្ដ*
ចុះថ្ងៃទី១៦ កក្កដា ឆ្នាំ ២០០២ ។

## មាតិការបស់អត្ថបទ

**ជំពូកទី១ ប្រភេទនៃមធ្យោបាយញ៉ាំងសកម្មភាព** ... ទំព័រ១២៣

១- ទស្សនៈលើការសិក្សាមធ្យោបាយញ៉ាំងសកម្មភាព ... ---១២៣

២- មធ្យោបាយញ៉ាំងសកម្មភាពក្នុងន័យវិទ្យា ( Semantics ) ... ---១២៣

ក- ពាក្យសព្ទដែលមានន័យញ៉ាំងសកម្មភាព ... ---១២៣

ខ- ពាក្យភាសិតដែលមានន័យញ៉ាំងសកម្មភាព ... ---១២៤

៣- មធ្យោបាយញ៉ាំងសកម្មភាពក្នុងន័យសម្ព័ន្ធវិទ្យា ( Syntaxes ) ... ---១២៤

ក- និយមន័យល្បះបញ្ជា ... ---១២៤

ខ- ការប្រើប្រាស់សព្វនាមបុរិសៈនៅក្នុងល្បះបញ្ជា ... ---១២៤

គ- ល្បះបញ្ជាមិនពេញលេញ ... ---១២៥

គ.១- ល្បះដែលប្រើកិរិយាស័ព្ទជាធាតុសំខាន់ ( Predicate ) ... ---១២៥

គ.២- ល្បះដែលប្រើនាមជាធាតុសំខាន់ ... ---១២៥

គ.៣- ល្បះដែលប្រើកិរិយាវិសេសន៍ជាធាតុសំខាន់ ( Adverb ) ... ---១២៥

គ.៤- ល្បះដែលប្រើគុណនាមជាធាតុសំខាន់ ( Adjective ) ... ---១២៥

គ.៥- ល្បះដែលប្រើនិបាតសព្ទ និង ឧទានសព្ទជាធាតុសំខាន់ ... ---១២៥

ឃ- ល្បះឧទានដែលមានន័យញ៉ាំងសកម្មភាព ... ---១២៦

ង- មធ្យោបាយញ៉ាំងសកម្មភាពក្នុងល្បះដែលមានប្រធានជាសព្វនាមមិនច្បាស់ ... ---១២៦

ច- ល្បះសំណួរដែលមានន័យញ៉ាំងសកម្មភាព ... ---១២៦

ឆ- ល្បះរណបមានលក្ខខណ្ឌក្នុងន័យញ៉ាំងសកម្មភាព ... ---១២៦

ជ- ល្បះសម្រាប់ញ៉ាំងសត្វឱ្យធ្វើសកម្មភាព ... ---១២៦

**ជំពូកទី២ ប្រភេទទំរង់ល្បះបញ្ជាក្នុងភាសាខ្មែរ** ... ---១២៧

១- ទំរង់ល្បះបញ្ជាពេញលេញ ... ---១២៧

២- ទំរង់ល្បះបញ្ជាមិនពេញលេញ ... ---១២៧

៣- ប្រភេទនៃសព្វនាមបុរិសៈបុរសទី៣ និង បុរសទី១ ដែលប្រើក្នុងល្បះបញ្ជា ... ---១២៧

៤- លក្ខណៈនៃការបង្គាប់បញ្ជា ............................................ ---១២៧

ក- ការប្រើប្រាស់សូរស្រះ ............................................ ---១២៨

ខ- ការបង្គាប់បញ្ជាដោយផ្ទាល់ ............................................ ---១២៨

គ- ការបង្គាប់បញ្ជាដោយប្រយោល ............................................ ---១២៨

ជំពូកទី៣ មធ្យោបាយញ៉ាំងសកម្មភាពក្រៅភាសាវិទ្យា ............................................ ---១២៨

១- សូរសញ្ញាដែលមានន័យញ៉ាំងសកម្មភាព ............................................ ---១២៨

២- ផ្លាកសញ្ញាដែលមានន័យញ៉ាំងសកម្មភាព ............................................ ---១២៨

៣- កាយវិការដែលមានន័យញ៉ាំងសកម្មភាព ............................................ ---១២៩

៤- សញ្ញាផ្សេងៗទៀតដែលបង្កប់ន័យញ៉ាំងសកម្មភាព ............................................ ---១២៩

ជំពូកទី៤ ការប្រើប្រាស់មធ្យោបាយញ៉ាំងសកម្មភាពក្នុងភាសាខ្មែរ ............................................ ---១២៩

សេចក្ដីសន្និដ្ឋាន ............................................ ---១២៩

គន្ថនិទ្ទេស ............................................ ---១៣១

# វាសនាវិចថ្លែក នៃ សិល្បករចាប៉ីឈ្មោះលោកតា គង់ ណៃ

សម្ភាស & ចងក្រងដោយ លោក ជុំ ស៊ុនណាង

--------

សាកលវិទ្យាល័យវិចិត្រសិល្បៈបានលើកតម្កើងសិល្បៈធំៗ អស់ច្រើនទសវត្សមកហើយ ។ នៅពេលថ្មីៗនេះ គួបផ្សំនឹងសំណើពីសម្តេច ហ៊ុន សែន ផង គេក៏បានរៀបចំបង្កើតផ្នែក ចាប៉ី និង អាយ៉ៃ មួយទៀត ។

មកដល់បច្ចុប្បន្ន ចាប៉ី ហាក់ត្រូវគេមិនសូវទឹកនានិងមិនសូវស្គាល់ ពិសេសនៅក្នុងចំណោមយុវជន ។ សព្វថ្ងៃ អ្នកដែលចេះខាងឧបករណ៍តន្ត្រីបុរាណនេះកាន់តែមានចំនួនតិចទៅៗ ទន្ទឹមនឹងនេះ អ្នកនិយមចូលចិត្តស្តាប់ក៏មិនសូវសម្បូរ ភាគច្រើនជាមនុស្សដែលមានវ័យចំណាស់ទៅហើយ ។ ដើម្បីរួមចំណែកក្នុងការលើកស្ទួយសិល្បៈចាប៉ី លោកសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ ដែលទទួលបន្ទុកក្នុងការរៀបចំបោះពុម្ពទស្សនា-វដ្តីរបស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា បានចាត់អោយខ្ញុំទៅធ្វើសម្ភាសន៍ជាមួយសិល្បករចម្រៀងចាប៉ីមួយរូបឈ្មោះលោកតា គង់ ណៃ ដែលមានទីលំនៅ នៅផ្ទះលេខ៥៤ ភូមិ ២ ក្រុម ១១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២១ ខែសីហា ឆ្នាំ២០០៣ វេលាម៉ោង ៨ ខ្ញុំបានទៅដល់លំនៅដ្ឋានខាងលើ ។

អ្នកចម្រៀងចាប៉ី គង់ ណៃ បានលេចមុខនៅក្នុងវិស័យសិល្បៈចាប៉ីជាច្រើនឆ្នាំកន្លងមកហើយ គាត់ត្រូវបានគេស្គាល់តាមរយៈបទបង្គងក្អែក និងបទជាវខាន់ស្លា ។ សព្វថ្ងៃ គាត់បម្រើការនៅក្នុងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ គាត់បានក្លាយជាបុគ្គលិករបស់ក្រសួងនេះ តាំងពីឆ្នាំ១៩៩២មកម្ល៉េះ ។

លោកតា គង់ ណៃ កើតនៅឆ្នាំ១៩៤៥ នៅភូមិដូង ឃុំស្វាយទង ស្រុកកំពង់ត្រាច ខេត្តកំពត ។ ឪពុករបស់គាត់ឈ្មោះ គង់ ឡាយ ជាកសិករ និង ម្តាយឈ្មោះ ណុប ផែង ជាអ្នកចិញ្ចឹមនាង នៅភូមិឃុំខាងលើ ។ ឪពុកម្តាយរបស់គាត់មានកូនចំនួន១០នាក់ ស្រី៥នាក់ និង ប្រុស៥នាក់ គាត់ជាកូនទី៥ ។ បងប្អូនរបស់គាត់ទាំងអស់មិនមានប្រកបរបរអ្វីក្រៅពីកសិកម្មទេ ។ សង្គ្រាសត្វលោកមិនទៀង គាត់បានបាត់បង់បងប្អូនទាំងនោះស្ទើរទាំងអស់ ស្លាប់នៅសម័យសង្គមរាស្ត្រនិយម ៣នាក់, នៅសម័យលន់ ណុល ៣នាក់, និងជំនាន់ខ្មែរក្រហម ២នាក់ ។ សព្វថ្ងៃ គាត់នៅសល់តែប្អូនស្រីម្នាក់គត់ ជាកសិករនៅភូមិដូង ។

កាលនៅជាកុមារ អាយុបាន៤ឆ្នាំ គាត់កើតអុតធំ រហូតនាំអោយពិការភ្នែកទាំងពីរ ។ លុះធំដឹងក្តីឡើង ដោយយល់ថាខ្លួនពិការភ្នែកមិនអាចប្រកបរបរដូចអ្នកភ្នែកភ្លឺ គាត់ក៏ចាប់មាននិស្ស័យបណ្តាលចិត្តគាត់អោយចេះស្រឡាញ់ចាប៉ី ។ នៅរាល់ពិធីបុណ្យទាននៅក្នុងភូមិ ដែលមានលេងចាប៉ី គាត់សុំអោយឪពុកគាត់នាំគាត់ទៅស្តាប់ ។ ប៉ុន្តែ គាត់មិនទៅចូលក្នុងហ្វូងទស្សនិកជនទេ គាត់អោយឪពុកទុកគាត់អោយនៅឆ្ងាយពីគេ

ដើម្បីស្រួលស្តាប់បានច្បាស់។ ពេលអាយុបាន ៨-៩ឆ្នាំ ចាស់ៗតែងសុំអោយគាត់ច្រៀងកំសាន្តកំដរពិធីបុណ្យ ឬ កម្មវិធីអ្វីមួយនៅក្នុងភូមិ។ កាលនោះ គាត់មិនទាន់មានឧបករណ៍ចាប៉ីទេ គឺលេងដោយធ្វើមាត់។ គួររំលឹកថា ឪពុកម្តាយគាត់មិនមានឈាមជ័រជាអ្នកសិល្បៈទេ ប៉ុន្តែ គាត់មានឪពុកធំម្នាក់ចេះលេងសាដៀវនិងចាប៉ី។ លុះអាយុបាន១៣ឆ្នាំ ឪពុកគាត់បានទិញចាប៉ីអោយ ហើយ គាត់សុំឪពុកធំអោយជួយបង្ហាត់។

គាត់ចាប់ផ្តើមឡើងសម្តែងពិតប្រាកដ (ច្រៀងចាប៉ី) នៅអាយុ១៨ឆ្នាំ ជួនជាមួយគ្នានោះ គាត់ក៏បានត្រូវចាស់ទុំរៀបចំអោយមានគូរស្រករ។ ប្រពន្ធរបស់គាត់ឈ្មោះ តាត់ ឆេន កើតនៅឆ្នាំ១៩៤២ សព្វថ្ងៃជាមេផ្ទះ។ លោកយាយ តាត់ ឆេន មានបងប្អូនបង្កើត៩នាក់ ស្រី៦នាក់ ប្រុស៣នាក់។ គ្រួសារលោកតា គង់ ណៃ មានកូនទាំងអស់១១នាក់ រហូតដល់សព្វថ្ងៃ នៅរស់១០នាក់ : ប្រុស៦នាក់ ស្រី៤នាក់។ ក្នុងតួនាទីជាឪពុកដ៏ល្អម្នាក់ ទោះជាគាត់អភ័ព្វធ្លាក់ខ្លួនពិការភ្នែកតាំងពីកុមារនោះក្តី គាត់ក៏បានពុះពារគ្រប់ឧបសគ្គក្នុងអាជីពជាអ្នកចម្រៀងចាប៉ី រកចំណូលមកចិញ្ចឹមផ្គត់ផ្គង់ជីវភាពគ្រួសារដ៏ធំនេះ និង ផ្តួចផ្តើមអោយកូនប្រុសស្រីបានរៀនសូត្រស្មើរគ្រប់ៗគ្នា ប៉ុន្តែ ជាអកុសល កូនបងៗបានរៀនត្រឹមចេះអានបាន សរសេរបាន (កម្រិតបឋមសិក្សា) ហើយឈប់រៀន និងត្រូវបានរៀបចំអោយមានគ្រួសារ។ គាត់បានរៀបការកូនបានប្រាំបីនាក់ហើយ មកដល់ពេលនេះ។ គាត់មានចៅបង្កើត២៥នាក់។ កូនៗទាំងអស់របស់គាត់សុទ្ធតែមានផ្ទះសម្បែង និង មុខរបរចិញ្ចឹមជីវិតរៀងៗខ្លួនដែរ : កូនទីមួយឈ្មោះ គង់ ឈៀ (ស្រី) មានរបរជាអ្នកធ្វើស្រែ និង នេសាទ។ កូនទី២ (ប្រុស) ឈ្មោះ គង់ ណោ មានរបរជាអ្នកធ្វើស្រែ ជាងផ្ទះ និង លេងភ្លេងការ។ កូនទី៣ (ស្រី) គង់ ផល្លី មានរបរជាកសិករ និង ឡើងត្នោត។ កូនទី៤ (ប្រុស) ឈ្មោះ គង់ ពុទ្ធថា មានរបរជាអ្នកនេសាទ។ កូនទី៥ (ស្រី) គង់ ធារី មានរបរជាអ្នកនេសាទ។ កូនទី៦ (ប្រុស) ឈ្មោះ គង់ សម្ផស្ស មានរបរជាអ្នកនេសាទ។ កូនទី៧ (ស្រី) គង់ សុភ័ក្រ្ត មានរបរជាអ្នកចម្រៀងតន្ត្រីសម័យ។ កូនទី៨ (ស្រី) គង់ សារាង មានរបរជាអ្នកធ្វើស្រែ និង ច្រៀង។ លោកតា គង់ ណៃ នៅសល់កូនប្រុសពីរនាក់ទៀតស្ថិតនៅក្នុងបន្ទុកនៅឡើយ។ កូនប្រុស គង់ បុរាណ សិស្សថ្នាក់ទី៩ និងកំពុងរៀនខាងចាប៉ី និង កូនប្រុសពៅឈ្មោះ គង់ សម័យ កំពុងសិក្សានៅឯស្រុកកំណើត (អនុវិទ្យាល័យលក ខេត្តកំពត)។ ចំពោះកូនដែលនៅលីវទាំងពីរ គាត់មានបំណងអោយរៀនបានខ្ពស់នឹងគេ។ សរុបមក កូនរបស់គាត់៣នាក់មានរបរជាអ្នកសិល្បៈ។

លោកតា គង់ ណៃ ចាប់ប្រឡូកក្នុងវិស័យសិល្បៈតាំងពីអាយុ១៨ឆ្នាំ។ គាត់បានប្រកបរបរនេះរហូតដល់សម័យខ្មែរក្រហមកាន់កាប់បានមួយឆ្នាំ គឺចាប់ពីឆ្នាំ១៩៧៦ គាត់ក៏ត្រូវអង្គការ នាសម័យនោះអោយបោះបង់ចាប៉ី ទៅវាយជក់ត្នោត។

ដោយសារការប្រឹងប្រែងយកចិត្តទុកដាក់និងនិស្ស័យស្នេហាសិល្បៈចាប៉ីតាំងពីក្មេង នៅឆ្នាំ១៩៩០ គាត់បានចូលប្រឡងប្រជែងចាប៉ី ទទួលបានលេខមួយជាបន្តបន្ទាប់ តាំងពីថ្នាក់ស្រុករហូតដល់ថ្នាក់ខេត្ត។ នៅឆ្នាំ១៩៩១ ក្នុងការប្រឡងប្រជែងចម្រៀងចាប៉ីដងវែងទូទាំងប្រទេស គាត់ជាប់លេខមួយទៀត ហើយគួររំលឹកថា ក្នុងឱកាសប្រឡងនោះ គាត់លើកយករឿង *វ័យូវង្ស* មកច្រៀង។ នៅឆ្នាំ១៩៩២ ក្រោយពីទទួលជ័យលាភីបានមួយឆ្នាំ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានអញ្ជើញគាត់អោយមកបម្រើការនៅក្នុងក្រសួងនេះរហូតមក។

សព្វថ្ងៃ ឆ្លៀតពេលទំនេរពីការងាររាជការ គាត់បង្រៀនចាប៉ីដល់សិស្ស៧នាក់ (នៅភ្នំពេញ)។ ក្នុងចំណោមសិស្សទាំងនោះមានសិស្សស្រី៣នាក់ ។ សិស្ស៤នាក់ស្ថិតក្រោមការជួយឧបត្ថម្ភពីសមាគមព្រឹទ្ធាចារ្យ។ សមាគមនេះបានឧបត្ថម្ភដល់សិស្សម្នាក់ៗ : ចាប៉ីមួយ ប្រាក់អាហារូបករណ៍ក្នុងពេលសិក្សា និងចេញថ្លៃប្រាក់ខែគ្រូ។ រីឯ សិស្ស២នាក់ទៀតចេញថវិកាសិក្សាផ្ទាល់ខ្លួន។ សិស្សម្នាក់ទៀតជាកូនប្រុសរបស់គាត់។

ទាក់ទងនឹងបញ្ហាជីវភាពបច្ចុប្បន្ន លោកតា គង់ ណៃ ស្ថិតក្នុងសម្លៀកបំពាក់អាចារ្យ (អាវ៍.កត្រង់) បានបង្ហើបទស្សនៈផ្អែកលើកម្មផល ដោយមានប្រសាសន៍ថា : "ខ្ញុំសព្វថ្ងៃ បើគិតតាមធម៌ព្រះ ប្រហែលជាទទឹមនឹងអំពើបាបដែលខ្ញុំបានសាងពីជាតិមុននោះ ប្រហែលជាខ្ញុំបានសាងបុណ្យដែរ បានជាសព្វថ្ងៃ ខ្ញុំពិការភ្នែកអញ្ចឹងហើយ នៅមានគេអាណិត ហើយជួយឧបត្ថម្ភហូរហែរ"។ តាមប្រសាសន៍របស់គាត់ ប្រភពថវិការគ្រួសារប្រចាំខែ ក្រៅពីប្រាក់បៀវត្សមន្ត្រីរាជការ ប្រមាណចំនួន៧០.០០០រៀលក្នុងមួយខែ គាត់ក៏បានទទួលការជួយឧបត្ថម្ភពីសប្បុរសជន និង សមាគមមួយចំនួនរៀងរាល់ខែ ដូចជា : សម្តេច ហ៊ុន សែន ឧបត្ថម្ភ ៥០ដុល្លា (ត្រូវនឹងតម្លៃប្រាក់រៀលសព្វថ្ងៃ ២០០.០០០រៀល), ឯកឧត្តម មុត ខៀវ ឧបត្ថម្ភ៥០ដុល្លា. សមាគមព្រឹទ្ធាចារ្យឧបត្ថម្ភ៨០ដុល្លា ។ នៅពេលថ្មីៗនេះ ភោជនីយដ្ឋាន*មីលីនែរ* (Millionaire) បានអញ្ជើញគាត់ទៅច្រៀងរាល់យប់ ដោយទទួលកម្រៃ៧ដុល្លាក្នុងមួយយប់ ។ ក្រៅពីនេះ ថវិការខ្លះទៀតបានមកពីការច្រៀងតាមពិធីបុណ្យនានានិងតាម វិទ្យុ ទូរទស្សន៍ ។ ប្រាក់ចំណូលទាំងអស់ខាងលើ សរុបទៅច្រើនបង្គួរដែរសម្រាប់បំពេញតម្រូវការក្នុងគ្រួសារ ប៉ុន្តែ គាត់ទាំងពីរនាក់ប្តីប្រពន្ធបានអោយយើងដឹងទៀតថា ប្រាក់ទាំងនេះ ពួកគាត់បានយកទៅធ្វើបុណ្យ ចែកជូនចាស់ៗក្រីក្រទុរគតអស់មួយភាគធំ។ លោកយាយ តាត់ ឆេន មានប្រសាសន៍ដោយរីករាយថា : "លោកក្មួយអើយ លុយទាំងអស់ហ្នឹង បើសន្សំទៅប្រហែលធ្វើផ្ទះបានធំនឹងគេហើយ តែពួកខ្ញុំចេះតែធ្វើបុណ្យ ឃើញចាស់ៗនៅស្រុក ចេះតែអាណិត ហើយក៏ចេះតែជូនគាត់ ម្យ៉ាងទៀត ខំធ្វើទៅ ក្រែងអាចរំដោះកម្មពៀរ ក្រែងតាគាត់ (គង់ ណៃ) បានសាងអីមិនល្អពីជាតិ

មុន បានជាគាត់ទទួលបាបនៅជាតិនេះ ហើយប្រហែលជាផលនេះដែរ បានជាចេះតែមានគេអាណិត និង ជួយមិនដាច់ ខ្វះអីអ្នកពិការដូចគាត់គគោក..."។

លោកតា គង់ ណៃ មិនបានចូលរៀននៅសាលាទេ ប៉ុន្តែ គាត់ចេះប្រើពាក្យពេចន៍ជ្រៅៗ ដូចអ្នក ដែលមានចំណេះខាងអក្សរសាស្ត្រដែរ។ ទាក់ទងនឹងបញ្ហានេះ គាត់មានប្រសាសន៍ថា : "ខ្ញុំតែងតែសួរ និង សុំអោយអ្នកដែលគេចេះពាក្យទាំងនេះនិយាយអោយស្តាប់ ហើយជួនកាលអោយគេពន្យល់អត្ថន័យរបស់ ពាក្យនោះ ខ្ញុំក៏កត់ទុកក្នុងបេះដូង។ និយាយអោយចំទៅ បញ្ហានេះកើតឡើងពីឆ្ងល់ ហើយសួរ"។

ពាក្យកាព្យដែលគាត់ច្រៀង មានខ្លះកើតពីការរៀបរៀងដោយខ្លួនឯង និងខ្លះទៀតស្រង់ពីស្នាដៃ ចាស់ៗ។ បើត្រូវច្រៀងពីអ្វីមួយ គាត់អោយគេអាន ឬ និយាយខ្លឹមសារនៃប្រធានបទនោះ ច្រើនសារ ក្រោយមក គាត់រៀបចំចុងចួនដោយខ្លួនឯង។ ចំពោះពាក្យកាព្យស្រាប់ គាត់តម្រូវអោយគេអានមួយចប់ រួចហើយអានម្តងមួយឃ្លាៗ។ គាត់បានអះអាងថា : "កាលពីនៅក្មេង ខ្ញុំអាចទន្ទេញចាំពី១០ទៅ១២ទំព័រ ក្នុងមួយថ្ងៃ តែឥឡូវសតិបញ្ញាបានថមថយហើយមិនដូចពីមុនទៀតទេ"។

នៅលើឆាក មុននឹងច្រៀងរឿង ត្រូវចាប់លើកនិយាយពីពិធី (បុណ្យបច្ច័យបួន, បុណ្យកឋិន, បុណ្យផ្កា...) នោះបន្តិចសិន ឬ អាចបន្ថែមពាក្យទូន្មានណាមួយ នេះបើពេលវេលាវែង។

ឆ្លើយតបនឹងសំណួរថាចាប៉ីមានកំណើតតាំងពីពេលណាមក លោកតាបានបំភ្លឺថា : " ចាប៉ីកើតមុន អាយ៉ៃ។ ពាក្យចាប៉ីមកពីពាក្យ វាចា (សំដី) + បី (បីបម ថ្នាក់ថ្នម) រួមមកថា វាចាថ្នាក់ថ្នមបំពេ។ សឹងថា ចាប៉ីកើតមុន ឬ ក្នុងសម័យពុទ្ធកាល។ តាមពុទ្ធប្រវត្តិ គេឃើញព្រះឥន្ទចុះមកដេញចាប៉ីថ្វាយព្រះ មុនបាន ត្រាស់"។ ចាប៉ីមានខ្សែបី ខ្សែលើមានឈ្មោះថាខ្សែគ ខ្សែក្រោម គេហៅថាខ្សែឯក រីឯ ខ្សែកណ្តាលឈ្មោះ ថាខ្សែដោតខ្ទង់។ ឧបករណ៍នេះមាន១២ខ្ទង់ ទាំងចាប៉ីដងវែងឬដងខ្លី។ ក្រៅពីលេងតែឯង គេអាចយកចាប៉ី ទៅប្រគុំជាមួយឧបករណ៍តន្ត្រីឯទៀតៗ (ភ្លេងការ)។ ចាប៉ីអាចលេងបទ ផាត់ជាយ, នគររាជ, សំពោង, ផាត់ជាយក្លាយ...។ នៅជំនាន់ដើម គេលេងចាប៉ីក្នុងពិធីលៀងអារក្ស ថ្វាយគ្រូ ជាដើម។ នៅក្នុងពេលគេ ច្រៀងចាប៉ី យើងជួនកាលឮគេច្រៀងហើយបានដេញ និង ជួនកាលគេដេញបណ្តើរគេច្រៀងបណ្តើរ។ ចំពោះ បញ្ហានេះ លោកតាបានពន្យល់ថា : "បញ្ហានេះវាអាស្រ័យលើអ្នកច្រៀងដែរ ព្រោះថា អ្នកលេងខ្លះមិនអាច ច្រៀងផងដេញផងបានទេ ព្រោះគេមិនសូវពូកែចាំ។ ម្យ៉ាងទៀត គេចាំបាច់ត្រូវការច្រៀងផងដេញផង សម្រាប់បទបំពេ ឬ ជាវខាន់ស្លា "។ ចាប៉ី គេអាចច្រៀងឆ្លងឆ្លើយគ្នា ឬ ច្រៀងតែឯង ស្រេចទៅលើបំណង អ្នកជួល។ ដៃគូចាប៉ី ជួនកាលជាអ្នកដែលធ្លាប់ស្គាល់គ្នា និង ជួនកាលដៃគូទាំងសងខាងមិនដែលស្គាល់គ្នាទេ។ ការច្រៀងចោទឆ្លើយច្រើនទាក់ទងដល់ការស្រាយប្រស្នារ ឬ បញ្ហាអ្វីមួយ រីឯការច្រៀងទោលច្រើនច្រៀង

រឿង។ ដៃគូររបស់គាត់ ដែលធ្លាប់ជួបគ្នាញឹកញាប់នៅលើឆាក មាន លោកប្រាជ្ញឈួន និង នាយប៉ែ ។

ចំពោះការបើកផ្នែកចាប៉ីនិងអាយ៉ៃនៅសាកលវិទ្យាល័យវិចិត្រសិល្បៈ គាត់មិនបានចូលរួមធ្វើការនៅទីនោះទេ។ សិល្បករបុរាណដែលត្រូវបានគេអញ្ជើញអោយទៅធ្វើការនៅទីនោះ មាន លោកឈិន ឈៀង លោកយស់ សាធ និង សិល្បករបុរាណមួយចំនួនទៀត។ បញ្ហាមិនបានចូលរួមនៅក្នុងការបណ្តុះបណ្តាលនេះ គាត់បានមានប្រសាសន៍ថា : "ប្រហែលជាខ្ញុំពិការភ្នែកទើបគេមិនហៅ ថាអញ្ចឹង ព្រោះ លោកពូ ប្រាជ្ញ ឈួន ដែលជាអ្នកចម្រៀងចាប៉ីជើងចាស់ មានឈ្មោះបោះសំឡេងឃូរឃារមកហើយនោះ ក៏មិនបានទៅដែរ"។

ការប្រឹងប្រែងក្នុងការបណ្តុះបណ្តាលសិស្សរបស់គាត់បានចេញជាលទ្ធផលគួរកោតសរសើរ : ក្នុងចំណោមសិស្សរបស់គាត់ សិស្សប្រុសឈ្មោះ ស៊ឹង ប៊ុច បានទទួលជ័យលាភីលេខមួយនៅក្នុងការប្រលងចាប៉ីដងវែងទូទាំងប្រទេសនៅឆ្នាំ២០០២ និង សិស្សស្រីឈ្មោះ ស៊ិន សយ បានទទួលជ័យលាភីលេខបី។

នៅចុងបញ្ចប់នៃកិច្ចសម្ភាសន៍ លោកតា គង់ ណៃ បានអំពាវនាវសូមអោយថ្នាក់ដឹកនាំជាតិគិតគូរអោយបានច្រើនក្នុងការលើកស្ទួយវិស័យសិល្បៈខ្មែរ ពិសេសចាប៉ី ព្រោះថា ចាប៉ីកំពុងឈានទៅរកការបាត់បង់បន្តិចម្តងៗ បើមិនមានការយកចិត្តទុកដាក់ទេ កូនខ្មែរនឹងលែងស្គាល់ឧបករណ៍នេះទៀតហើយ។ ចាប៉ីមិនត្រឹមតែជាគ្រឿងស្តាប់កំសាន្តអារម្មណ៍ប៉ុណ្ណោះទេ វានៅមានតួនាទីសំខាន់ក្នុងការអប់រំ : រាល់ពាក្យពេចន៍ដែលសិល្បករលើកយកមកច្រៀងច្រើនបង្កប់នូវខ្លឹមសារអប់រំ និង ដំបូន្មានល្អៗ ។ ម្យ៉ាងទៀត គាត់អំពាវនាវសូមអោយក្រសួងអប់រំបញ្ចូលការសិក្សាចាប៉ីទៅក្នុងកម្មវិធីសិក្សារបស់ក្រសួង ព្រមជាមួយនឹងការថ្វាយបង្គំព្រះនិងច្បាប់រដ្ឋធម្មនុញ្ញ។ ជាមួយគ្នានេះដែរ គាត់បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ម្ចាស់អំណោយទាំងអស់ ដែលបានជួយឧបត្ថម្ភគាត់តាំងពីដើមរៀងមក និង ថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ ដែលយកចិត្តទុកដាក់នឹងសិល្បៈចាប៉ី តាមរយៈរូបគាត់ ។

លោកតា គង់ ណៃ មានវាសនាដ៏ចម្លែក ប្លែកពីធម្មតា។ ចំពោះរូបគាត់ ធម្មជាតិបានធ្វើបាបគាត់ផងនិងអាណិតគាត់ផង គឺបានធ្វើអោយគាត់ពិការភ្នែក តែបានផ្តល់ដល់រូបគាត់នូវទេពកោសល្យខ្ពស់។ ប៉ុន្តែទេពកោសល្យជាថាមពលឥតកម្រើក បើគ្មានការតស៊ូនិងសេចក្តីអង់អាច គាត់ប្រាកដជាឥតបានក្លាយខ្លួនទៅជាសិល្បករចាប៉ីដ៏ល្បីល្បាញម្នាក់នេះទេ : ជីវិតរបស់គាត់ជាគំរូដ៏កម្រមួយសម្រាប់អ្នកឯទៀត ។

x x

x